មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

Cambodian Center for Human Rights

ខែមីនា ឆ្នាំ២០១១

# របាយការណ៍ប្រចាំឆមាស
# សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា



USAID

ជំនួយពីពលរដ្ឋអាមេរិក

EAST • WEST MANAGEMENT INSTITUTE

Program on Rights and Justice (PRAJ)

កម្មវិធីសិទ្ធិ និងយុត្តិធម៌ (ប្រាជ្ញ)

# អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

របាយការណ៍ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្នុងនៅកម្ពុជា ជាលទ្ធផលនៃការអនុវត្តគម្រោងសង្កេតការណ៍សវនាការ ដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក)។ ចក្ខុវិស័យរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា គឺកម្ពុជាជាព្រះរាជាណាចក្រមួយគ្មានអំពើហិង្សា ដែលក្នុងនោះប្រជាពលរដ្ឋ ទទួលបានសិទ្ធិជាមូលដ្ឋាន មានសិទ្ធិស្មើគ្នា និងត្រូវបានផ្តល់អំណាច ដើម្បីចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ ព្រមទាំងទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍប្រទេស។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា មានគោលបំណងចង់បាននីតិរដ្ឋជាជាងនិទណ្ឌភាព - ស្ថាប័នរឹងមាំជាជាងបុគ្គលខ្លាំង និងចង់បានសង្គមសេរីពហុបក្ស ដែលក្នុងនោះភាពចម្រុះត្រូវបានគេទទួលយក និងអបអរសាទរ ជាជាងព្រងើយកន្តើយ ឬដាក់ទណ្ឌកម្ម។ ស្លាកសញ្ញារបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា មានរូបព្រាបសកំពុងហើរចេញពីរង្វង់មូលនៃផ្ទៃមេឃពណ៌ខៀវ បញ្ជាក់អំពីការទាមទារសេរីភាពនៅកម្ពុជា។ ដើម្បីសម្រេចបានចក្ខុវិស័យនេះ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ ព្រមទាំងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅទូទាំងប្រទេសកម្ពុជា។ សម្រាប់ព័ត៌មានបន្ថែមសូមទស្សនាគេហទំព័រ www.cchrcambodia.org។

## សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះត្រូវបានធ្វើឡើង ក្រោមកិច្ចឧបត្ថម្ភគាំទ្រដោយសប្បុរសអំពីសំណាក់ប្រជាពលរដ្ឋអាមេរិកាំងតាមរយៈទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍអន្តរជាតិនៃសហរដ្ឋអាមេរិក (ទ.អ.អ.ស.អ)។ ខ្លឹមសារនៃរបាយការណ៍នេះ គឺជាការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់ ទ.អ.អ.ស.អ រដ្ឋាភិបាលសហរដ្ឋអាមេរិក ឬវិទ្យាស្ថានគ្រប់គ្រងបូព៌ាបច្ចិមឡើយ។

## សំណួរ និង ការឆ្លើយតប

ប្រសិនបើអ្នកមានសំណួរ ឬចង់បានព័ត៌មានបន្ថែមអំពីរបាយការណ៍នេះ ឬប្រសិនបើអ្នកចង់ផ្តល់យោបល់តប សូមផ្ញើអ៊ីមែលមកកាន់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា តាមរយៈអាសយដ្ឋាន info@cchrcambodia.org។

©២០១០មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក)

ផ្ទះលេខ៧៩៨ ផ្លូវលេខ៩៩ សង្កាត់បឹងត្របែក
ខណ្ឌចំការមន រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

# មាតិកា


**តារាងតួលេខ** ..... i
**ករណីសិក្សា** ..... ii
**ការពន្យល់អត្ថន័យ** ..... iii
**ខ្លឹមសារសង្ខេប** ..... 1
**១. សេចក្តីផ្តើម** ..... 7
ក្របខ័ណ្ឌច្បាប់ ..... 8
បរិបទគោលនយោបាយ ..... 10
គោលបំណង គោលដៅ និងដែនកំណត់នៃរបាយការណ៍ ..... 12
**២. វិធីសាស្ត្រ** ..... 13
រយៈពេល និង ទីតាំង ..... 13
សិទ្ធិសំខាន់ៗដែលជ្រើសរើសសម្រាប់សង្កេតសវនាការ ..... 13
រចនាសម្ព័ន្ធ ..... 14
បុគ្គលិក និងការបណ្តុះបណ្តាល ..... 16
នីតិវិធីសង្កេតការណ៍សវនាការ ..... 16
ប្រព័ន្ធគ្រប់គ្រងទិន្នន័យ ..... 17
ការវិភាគ និងកិច្ចពិភាក្សា ..... 17
**៣. ទិន្នន័យ** ..... 20
សិទ្ធិទទួលបានសវនាការជាសាធារណៈ ..... 21
សិទ្ធិមានសេរីភាព និងទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល ..... 23
សិទ្ធិយល់ដឹងពីបទចោទប្រកាន់ ..... 28
ការពន្យល់ប្រាប់សិទ្ធិ ..... 30
សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីរៀបចំការពារក្តី ..... 32
សិទ្ធិមានមេធាវី និងមានវត្តមាននៅក្នុងសវនាការ ..... 33
សិទ្ធិទទួលបានការសន្មត់ទុកជាមុនថាគ្មានទោស ..... 35
សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយតុលាការមួយឯករាជ្យ មិនលំអៀង និងប្រកបដោយវិជ្ជាជីវៈ ..... 38

សិទ្ធិបង្ហាញភស្តុតាង (រួមទាំងសិទ្ធិហៅ និងសាកសួរសាក្សី)................................................ 40
សិទ្ធិទទួលដឹងពួភស្តុតាង ............................................................................................ 43
សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យសារភាព ............................................................................. 44
ការហាមឃាត់ចំពោះការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ............................... 45
សវនាការពាក់ព័ន្ធនឹងអនីតិជន ...................................................................................... 46
អនីតិជន- ភាពឯកជន ........................................................................................ 47
អនីតិជន - ការឃុំខ្លួនបណ្ដោះអាសន្ន.................................................................... 48
អនីតិជន - ការផ្ដន្ទាទោស.................................................................................... 50
**៤. ការវិភាគទិន្នន័យ** .......................................................................................52
សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ........................................................... 52
សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យសារភាព ............................................................................. 57
សិទ្ធិជនជាប់ចោទជាអនីតិជន ......................................................................................... 69
**៥.សេចក្ដីសន្និដ្ឋាន** ..............................................................................................80
**៦. គន្លងនិន្នេស** ..................................................................................................82
**៧. ឧបសម្ព័ន្ធ** ....................................................................................................87
ឧបសម្ព័ន្ធទី១៖ តារាងសង្កេតការណ៍សវនាការ.............................................................. 87
ឧបសម្ព័ន្ធទី២ បញ្ជីច្បាប់ជាមូលដ្ឋាននៃតារាងសង្កេតការណ៍សវនាការ.............................. 98
ឧបសម្ព័ន្ធទី៣៖ ក្រមសីលធម៌មន្ត្រីសង្កេតការណ៍សវនាការ ...........................................107

# តារាងតួលេខ


តួលេខទី១៖សវនាការដែលបានសង្កេត.....20
តួលេខទី២៖សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ.....22
តួលេខទី៣៖ការឃុំខ្លួនបណ្ដោះអាសន្ន.....24
តួលេខទី៤៖ ការឃុំខ្លួនបណ្ដោះអាសន្នដែលល្មើសច្បាប់ (លើសរយៈពេលកំណត់ដោយច្បាប់) 25
តួលេខទី៥៖ សិទ្ធិយល់ដឹងអំពីបទចោទប្រកាន់.....28
តួលេខទី៦៖ ការពន្យល់ប្រាប់សិទ្ធិ.....30
តួលេខទី៧៖សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការពារក្ដី.....33
តួលេខទី៨៖ សិទ្ធិមានមេធាវី និងមានវត្តមាននៅក្នុងសវនាការ.....34
តួលេខទី៩៖ ការសន្មតទុកជាមុនថាគ្មានទោស.....36
តួលេខទី១០៖ ការទាញយកពិរុទ្ធភាព.....37
តួលេខទី១១៖ ភាពឯករាជ្យ និងមិនលំអៀងរបស់ចៅក្រម.....38
តួលេខទី១២៖ ចៅក្រមប្រើទូរស័ព្ទដៃនៅក្នុងសវនាការ.....39
តួលេខទី១៣៖ ភស្តុតាង.....41
តួលេខទី១៤៖សិទ្ធិហៅ និងសាកសួរសាក្សី.....42
តួលេខទី១៥៖ សិទ្ធិទទួលដឹងឮភស្តុតាង.....43
តួលេខ១៦៖សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យសារភាព.....44
តួលេខទី ១៧៖ ការហាមឃាត់ចំពោះការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ.....46
តួលេខទី១៨៖ សវនាការដែលមានជនជាប់ចោទជាអនីតិជន.....47
តួលេខទី១៩៖ អនីតិជន និងភាពឯកជន.....47
តួលេខទី២០៖ អនីតិជន និងការឃុំខ្លួនបណ្ដោះអាសន្ន.....49
តួលេខទី២១៖អនីតិជន និងការផ្ដន្ទាទោស.....50

# ករណីសិក្សា


ករណីសិក្សាទី ១៖ ពាក្យសំដីបង្ហាញថាជនជាប់ចោទមានពិរុទ្ធភាព នៅមុនពេលប្រកាសសាលក្រម ....................................................................................................................................56
ករណីសិក្សាទី ២៖ អំណះអំណាងនៃការប្រើអំពើហឹង្សាបង្ខំជនជាប់ចោទឲ្យសារភាព ....................66
ករណីសិក្សាទី ៣៖ ការផ្តន្ទាទោសជនជាប់ចោទជាអនីតិជន .......................................................77
ករណីសិក្សាទី ៤៖ ការកាត់ជនជាប់ចោទជាអនីតិជនឲ្យរួចទោស ...............................................78

# ការពន្យល់អត្ថន័យ

| | |
|---|---|
| រដ្ឋធម្មនុញ្ញ | រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា |
| ក្រមព្រហ្មទណ្ឌ | ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា |
| ក្រមនីតិវិធីព្រហ្មទណ្ឌ | ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា |
| ច្បាប់អ៊ុនតាក់ | បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌនិងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល(១៩៩២) |
| តុលាការក្រុងភ្នំពេញ | សាលាដំបូងរាជធានីភ្នំពេញ |
| តុលាការខេត្តកណ្តាល | សាលាដំបូងខេត្តកណ្តាល |
| គម្រោង | គម្រោងសង្កេតការណ៍សវនាការនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| របាយការណ៍ទី១ | របាយការណ៍ប្រចាំឆមាសទី១ ចេញផ្សាយខែកក្កដា ឆ្នាំ២០១០ |
| របាយការណ៍ទី២ | របាយការណ៍ប្រចាំឆមាសទី២ ចេញផ្សាយខែមីនា ឆ្នាំ២០១១ |
| អំឡុងរបាយការណ៍ទី១ | អំឡុងពេលរបាយការណ៍ទី១ចាប់ពីថ្ងៃទី១០ខែសីហារ ហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ |
| អំឡុងរបាយការណ៍ទី២ | អំឡុងពេលរបាយការណ៍ទី២ ចាប់ពីថ្ងៃទី១ ខែមករា រហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០ |
| មន្ត្រីសង្កេតការណ៍សវនាការ | ក្រុមការងារសង្កេតការណ៍សវនាការនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| តារាងសង្កេតការណ៍សវនាការ | តារាងសង្កេតការណ៍ប្រើដោយមន្ត្រីសង្កេតការណ៍សវនាការដើម្បីកត់ត្រាទិន្នន័យនៅពេលសង្កេតសវនាការ |
| សេចក្តីណែនាំ | ជួយមន្ត្រីសង្កេតការណ៍សវនាការនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាឱ្យយល់ពីសំណួរនីមួយៗនៅក្នុងតារាងសង្កេតការណ៍សវនាការ |
| ក្រមសីលធម៌ | ឯកសារសង្ខេបស្តីពីកាតព្វកិច្ចមិនជ្រៀតជ្រែកមិនលំអៀងនិងរក្សាការសំងាត់ដែលតំរូវអោយមន្ត្រីសង្កេតការណ៍សវនាការគោរពតាម |
| ប្រព័ន្ធគ្រប់គ្រងទិន្នន័យ | ជាប្រព័ន្ធដែលមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាប្រើសំម្រាប់រក្សាទិន្នន័យដែលបានកត់ត្រានៅលើតារាងសង្កេតការណ៍សវនាការ។ |

| | |
|---|---|
| គម្រោងតុលាការគំរូ | គម្រោងសហប្រតិបត្តិការមួយដែលមានគោលបំណងធ្វើអោយកាន់តែប្រសើរឡើង នូវសមភាព និងប្រសិទ្ធិភាពនៃសវនាការនៅក្នុងសាលាដំបូងទាំង៤ រួមមានសាលាដំបូងរាជធានីភ្នំពេញសាលាដំបូងខេត្តកណ្តាល សាលាដំបូងខេត្តកំពង់ចាម និងសាលាដំបូងខេត្តបន្ទាយមានជ័យ ក្នុងគោលបំណងផ្តល់គំរូវិជ្ជមានមួយដល់ប្រព័ន្ធតុលាការនៅទូទាំងប្រទេសកម្ពុជា |
| បទដ្ឋានតុលាការគំរូ | បណ្តុំបទដ្ឋានគំរូដើម្បីអោយតុលាការមានសមភាពនិងប្រសិទ្ធិភាពត្រូវបានចងក្រងភ្ជាប់ជាមួយគម្រោងតុលាការគំរូនៃប្រទេសកម្ពុជា |

# ខ្លឹមសារសង្ខេប

របាយការណ៍នេះ គឺជាលទ្ធផលមួយនៃគម្រោងសង្កេតការណ៍សវនាការកម្ពុជា (គម្រោង) ដែលអនុវត្តដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា។ គម្រោងនេះមានគោលបំណង ដើរតួនាទីជាអ្នកសង្កេតការណ៍សវនាការព្រហ្មទណ្ឌនៅកម្ពុជាដោយឯករាជ្យ និងមិនលំអៀង និងប្រមូលទិន្នន័យដែលអាចធ្វើការវិភាគបាន ដើម្បីកំណត់អំពីភាពខ្លាំង និងភាពខ្សោយនៃ ប្រព័ន្ធយុត្តិធម៌។ គម្រោងបានចូលរួម និងគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា និងម្ចាស់ជំនួយអន្តរជាតិក្នុងការពង្រឹង និងកែទម្រង់ប្រព័ន្ធយុត្តិធម៌។

របាយការណ៍នេះជារបាយការណ៍ទី ២ របស់គម្រោង ដែលចេញផ្សាយបន្ទាប់ពី របាយការណ៍ទី១ (របាយការណ៍ប្រចាំឆមាសទី១) នៅខែកក្កដា ឆ្នាំ២០១០។ របាយការណ៍នេះ បង្ហាញអំពីទិន្នន័យដែលប្រមូលបានពីសវនាការព្រហ្មទណ្ឌដែលបានសង្កេតចំនួន ៥៣២ នៅ សាលាដំបូងរាជធានីភ្នំពេញ (តុលាការក្រុងភ្នំពេញ) និងសាលាដំបូងខេត្តកណ្តាល (តុលាការខេត្តកណ្តាល) ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣០ ខែមិថុនាឆ្នាំ២០១០ (អំឡុងពេលរបាយការណ៍ទី២)។ របាយការណ៍នេះក៏បានធ្វើការវិភាគផងដែរទៅលើទិន្នន័យ និងផ្តល់ជាអនុសាសន៍ ដើម្បីធ្វើការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មានលក្ខណៈកាន់ តែល្អប្រសើរឡើង។

## ប្រព័ន្ធច្បាប់

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (រដ្ឋធម្មនុញ្ញ) ធានានូវភាពឯករាជ្យរបស់ តុលាការ ព្រមទាំងសិទ្ធិសន្មតជាមុនថាគ្មានទោសរហូតដល់ពេលពិរុទ្ធភាពត្រូវបានរកឃើញ។ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ក្រមនីតិវិធីព្រហ្មទណ្ឌ) បានចែងអំពីនីតិវិធី នៃការស៊ើបសួរ និងនីតិវិធីសវនាការបទល្មើសព្រហ្មទណ្ឌ ព្រមទាំងបទប្បញ្ញត្តិមួយចំនួនទាក់ ទងនឹងសិទ្ធិរបស់ជនជាប់ចោទ។ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ក្រមព្រហ្មទណ្ឌ) ដែលត្រូវបានប្រកាសឲ្យប្រើនៅឆ្នាំ២០០៩ បានចែងអំពីប្រភេទនៃបទល្មើស គោលការណ៍ ទទួលខុសត្រូវព្រហ្មទណ្ឌ និងគោលការណ៍នៃការផ្តន្ទាទោស។ ប្រទេសកម្ពុជាក៏ត្រូវបានចង ភ្ជាប់ដោយច្បាប់អន្តរជាតិដែលខ្លួនជាភាគីផងដែរ។ ទាំងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិ មនុស្ស ទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយសុទ្ធតែធានានូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជាសាធារណៈ ដោយតុលាការមួយឯករាជ្យ និងមិនលំអៀង។

## វិធីសាស្ត្រ

មន្ត្រីសង្កេតការណ៍សវនាការនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ចូលរួមសវនាការនៅឯតុលាការក្រុងភ្នំពេញ និងតុលាការខេត្តកណ្តាលរៀងរាល់ថ្ងៃ ដោយប្រើតារាងសង្កេតការណ៍ សវនាការដែលមានសំណួរប្រមាណជា ៥០។ តារាងសំណួរនេះជាឧបករណ៍មួយសម្រាប់ វាស់វែងការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងសវនាការនីមួយៗ។ ទិន្នន័យដែលប្រមូលបាននឹងត្រូវបានប្រើជាមូលដ្ឋានគ្រឹះក្នុងកិច្ចពិភាក្សាអំពីការប្រព្រឹត្តទៅនៃតុលាការ និងកំណែទម្រង់យុត្តិធម៌។

បន្ទាប់ពីរបាយការណ៍ប្រចាំឆមាសនីមួយៗត្រូវបានបោះពុម្ពផ្សាយ បុគ្គលិកគម្រោងនឹងធ្វើការណាត់ជួបជាមួយតំណាងនៃតុលាការដែលបានសង្កេត ព្រមទាំងអង្គការ អង្គភាព ស្ថាប័នផ្នែកយុត្តិធម៌ដទៃទៀត ដើម្បីពិភាក្សាអំពីអនុសាសន៍។ កិច្ចប្រជុំនេះជាមូលដ្ឋានផ្លាស់ ប្តូរគំនិត និងផ្តល់លទ្ធភាពឲ្យយល់កាន់តែច្បាស់អំពីបញ្ហាប្រឈម ដោយស្ថាប័នដែលធ្វើការពង្រឹងប្រព័ន្ធយុត្តិធម៌។ កិច្ចប្រជុំពិភាក្សានេះមានគោលបំណងលើកកម្ពស់ការអនុវត្តអនុសាសន៍ ដែលផ្តល់ឲ្យដោយរបាយការណ៍ប្រចាំឆមាស។

ទិន្នន័យនៅក្នុងរបាយការណ៍នេះត្រូវបានប្រៀបធៀបជាមួយនឹងទិន្នន័យ ដែលប្រមូល បានពីថ្ងៃទី១០ ខែសីហា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ (អំឡុងពេលរបាយការណ៍ទី១) ក្នុង គោលបំណងកំណត់អំពីភាពប្រែប្រួលនៃការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយ យុត្តិធម៌នៅតុលាការ ដែលបានសង្កេតទាំងពីរ។ យើងមិនរំពឹងទុកថានឹងមានការប្រែប្រួល ជា វិជ្ជមានកើតចេញពីអនុសាសន៍ដែលផ្តល់ដោយរបាយការណ៍ប្រចាំឆមាសទី១នោះទេ ដោយ សារតែពេលវេលានៃការបោះពុម្ពផ្សាយរបាយការណ៍ទី១នេះ ស្ថិតនៅចុងបញ្ចប់នៃអំឡុង ពេលរបាយការណ៍ទី២ ដូច្នោះនាំឲ្យអនុសាសន៍ទាំងនោះមិនមានឥទ្ធិពលទៅលើទិន្នន័យ ដែលប្រមូលបាននៅក្នុងអំឡុងពេលនោះទេ។ កិច្ចពិភាក្សាជាមួយស្ថាប័នពាក់ព័ន្ធក្រោយ ពេលបោះពុម្ពផ្សាយរបាយការណ៍ប្រចាំឆមាសទី១ បង្ហាញនូវឥរិយាបថវិជ្ជមាន និងបែបស្ថាបនារបស់ស្ថាប័នមួយភាគធំ និងបង្ហាញអំពីឆន្ទៈទទួលយកអនុសាសន៍ដែលមាននៅក្នុងរបាយការណ៍។

## ទិន្នន័យសង្ខេប

ចៅក្រមនៅឯតុលាការក្រុងភ្នំពេញ និងតុលាការខេត្តកណ្តាល បានបំពេញការងារ បានល្អនៅក្នុងផ្នែកមួយចំនួន ដែលទាក់ទងនឹងការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយ យុត្តិធម៌។ ជាថ្មីម្តងទៀតមន្ត្រីសង្កេតការណ៍សវនាការ បានសង្កេតឃើញថាគ្មានករណីណា មួយដែលសាធារណជនត្រូវបានហាមឃាត់មិនឲ្យចូលរួមសវនាការនោះទេ។ ទោះបីជានៅក្នុង អំឡុងពេលរបាយការណ៍ទី២ គ្មានតុលាការណាមួយបិទផ្សាយជូនដំណឹងអំពីពេលវេលា និង ទីកន្លែងសវនាការ តុលាការក្រុងភ្នំពេញបានចាប់ផ្តើមបិទផ្សាយសេចក្តីជូនដំណឹងនោះហើយ នេះជាការវិវត្តមួយគួរឲ្យកោតសរសើរ។

អត្រាចំនួនមេធាវីនៃជនជាប់ចោទបទឧក្រិដ្ឋមានការកើនឡើងពី ៩៥% ទៅ ៩៧%។ ការណ៍នេះឆ្លុះបញ្ចាំងពីការគោរពមាត្រា ៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៅក្នុងសវនាការមួយ ភាគធំ នេះជាជោគជ័យរបស់តុលាការដែលបានសង្កេតទាំង២។ ចៅក្រមភាគច្រើន (៩៥%) បានប្រាប់ជនជាប់ចោទឲ្យបានដឹងអំពីបទចោទប្រកាន់ប្រឆាំងនឹងខ្លួន ទោះបីជាចំនួនភាគរយ នៃសវនាការដែលក្នុងនោះចៅក្រមប្រកាសពីច្បាប់ពាក់ព័ន្ធមានការធ្លាក់ចុះពី ៨៥% នៃចំនួន សវនាការទាំងអស់នៅក្នុងអំឡុងពេលរបាយការណ៍ទី១ មកនៅត្រឹម ៥៩% នៃចំនួនសវនាការ ទាំងអស់នៅក្នុងអំឡុងពេលរបាយការណ៍ទី២ក៏ដោយ។

ចំណាត់ការរបស់តុលាការទៅលើភស្តុតាងនិងសាក្សីនៅតែជាផ្នែកមួយវិជ្ជមាន។ ការ បង្ហាញភស្តុតាងនៅក្នុងសវនាការមានការកើនឡើងពី ៧៧% ទៅ ៩៦%។ តុលាការទាំង ២ ក៏ ត្រូវបានមើលឃើញផងដែរថា បានផ្តល់ឱកាសស្មើគ្នាដល់ភាគីទាំងពីរក្នុងការបង្ហាញភស្តុតាង និងសាកសួរសាក្សី។

នៅក្នុងចំណោមសវនាការដែលបានសង្កេត គ្មានករណីណាមួយដែលបង្ហាញថាចៅ ក្រមជំនុំជម្រះ ដើរតួនាទីជាចៅក្រមស៊ើបសួរនៅក្នុងសំណុំរឿងតែមួយនោះទេ។ ចំនួនភាគរយ នៃសវនាការដែលក្នុងនោះចៅក្រមត្រូវបានគេឃើញថា និយាយទៅកាន់បុគ្គលដទៃ ទៀតនៅ ក្នុងពេលពិភាក្សាសម្រេចរឿងក្តី (ជាតម្រុយមួយដែលអាចបង្ហាញអំពីការជះឥទ្ធិពល ពីខាង ក្រៅទៅលើសាលក្រម) មានការធ្លាក់ចុះពី ១៦% មកនៅត្រឹម ៦%។ នៅក្នុងកិច្ចពិភាក្សាដែល ផ្អែកលើអនុសាសន៍នៅក្នុងរបាយការណ៍ប្រចាំឆមាសទី១ ចៅក្រមនៅឯតុលាការក្រុងភ្នំពេញ បានធ្វើការកត់សម្គាល់ថា មានករណីចាំបាច់មួយចំនួន ក្រឡាបញ្ជីត្រូវយកឯកសារទៅកាន់បន្ទប់ ពិភាក្សា ដូច្នេះនាំឲ្យមានការសន្ទនាជាមួយចៅក្រមនៅក្នុងពេលពិភាក្សាសម្រេចរឿងក្តី។ ការសង្កេតឃើញនេះ ត្រូវបានកត់ត្រាសម្រាប់របាយការណ៍នាពេលអនាគត ហើយសំណួរដែលពាក់ព័ន្ធនៅក្នុងតារាងសង្កេតការណ៍សវនាការនឹងត្រូវបានកែប្រែដើម្បីបញ្ចូលចំណុចនេះ។

ទន្ទឹមនឹងចំណុចវិជ្ជមានទាំងនេះ របាយការណ៍ក៏បានរកឃើញនូវចំណុចគួរឲ្យព្រួយបារម្ភមួយចំនួន ដែលនៅតែកើតមានឡើង។ អត្រាសរុបនៃការឃុំខ្លួនបណ្តោះអាសន្ននៅតុលាការទាំងពីរបង្ហាញនូវការថយចុះបន្តិចបន្តួចពី ៨៨% មកនៅត្រឹម ៨៤%។ ទោះបីជាអត្រាភាគរយមានការថយចុះបែបនេះក៏ដោយ ក៏អាត្រានេះនៅតែជាចំនួនមួយដ៏ច្រើនលើសលុប បើយោងតាមសច្ចធារណ៍ច្បាប់ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ និងបើគិតទៅលើសវនាការទាក់ទងនឹងបទចោទមជ្ឈឹម ដែលមានចំនួនច្រើនជាងពាក់កណ្តាល។ ទិន្នន័យបង្ហាញសវនាការចំនួន ១៨ ដែលក្នុងនោះជនជាប់ចោទត្រូវបានឃុំខ្លួនបណ្តោះអាសន្នលើសពីរយៈពេលកំណត់ដោយច្បាប់។ ជាថ្មីម្តងទៀត ភាគច្រើននៃជនជាប់ចោទទាំងនេះ (៧២%) ត្រូវបានចោទប្រកាន់ពីបទមជ្ឈឹម។

ទន្ទឹមនឹងការមានមេធាវីជនជាប់ចោទ នៅក្នុងសវនាការទាក់ទងនឹងបទឧក្រិដ្ឋស្ទើរតែទាំងអស់ អត្រាសរុបនៃចំនួនមេធាវីការពារជនជាប់ចោទបានធ្លាក់ចុះពី ៦៨% មកនៅត្រឹម ៥៩%។ ជនជាប់ចោទចំនួនជិត ៣/៤ (៧៤%) ដែលត្រូវបានចោទប្រកាន់ពីបទមជ្ឈឹម មិនមានមេធាវីក្នុងពេលសវនាការ។

ការណ៍នេះសបញ្ជាក់ឲ្យឃើញថាការទទួលបានជំនួយផ្នែកច្បាប់នៅតែជាផ្នែកមួយដែលមានតម្រូវការខ្ពស់។

អត្រាភាគរយនៃសវនាការ ដែលក្នុងនោះចៅក្រមប្រើប្រាស់ទូរស័ព្ទដៃមានចំនួនដដែលគឺ ២៨%។ ចៅក្រមតុលាការក្រុងភ្នំពេញបានលើកឡើងថា ការនិយាយទូរស័ព្ទនៅក្នុងសវនាការជារឿយៗ គ្រាន់តែជាការសម្រួលការងារនៅក្នុងសំណុំរឿងផ្សេងទៀត ដែលគាត់ត្រូវផ្តល់ការណែនាំ និងការអនុញ្ញាតឲ្យបើកការស៊ើបសួរតែប៉ុណ្ណោះ។ នៅពេលដែលមូលហេតុនេះជាគោលបំណងនៃការទាក់ទងតាមទូរស័ព្ទភាគច្រើន ការទទួលបានភាពយុត្តិធម៌នៅក្នុងសវនាការមួយមិនអាចត្រូវបានទម្លាក់ស្តង់ដារ ដើម្បីចាត់ការការស៊ើបអង្កេតក្នុងរឿងក្តីមួយទៀតនោះឡើយ។ បុគ្គលិកតុលាការដទៃទៀតគួរតែប្រមូលការផ្តាំផ្ញើ ទុកឲ្យចៅក្រមឆ្លើយតបនៅពេលដែលសវនាការបានបញ្ចប់។

## ការវិភាគ-ការសន្មតទុកជាមុនថាគ្មានទោស

នៅក្នុងចំណោមសវនាការដែលបានសង្កេតចំនួន ៣៣៨ នៅតុលាការក្រុងភ្នំពេញ ដែលក្នុងនោះជនជាប់ចោទមានវត្តមាន (សវនាការចំនួន ៣៨ ត្រូវបានធ្វើឡើងដោយគ្មានវត្តមានជនជាប់ចោទ) មានសវនាការចំនួន ៣១៤ ឬស្មើនឹង ៩៣% ដែលក្នុងនោះជនជាប់ចោទបានបង្ហាញខ្លួននៅមុខតុលាការនៅក្នុងឯកសណ្ឋានជាអ្នកទោស។ ការណ៍នេះធ្វើឲ្យបាត់បង់នូវសិទ្ធិបង្ហាញខ្លួននៅមុខ តុលាការក្នុងនាម និងក្រោមរូបភាពជាប្រជាពលរដ្ឋដែលគ្មានទោសពៃរ៍ និងប្រកបដោយសេចក្តីថ្លៃថ្នូរ។ ជនជាប់ចោទចំនួន ៩% បង្ហាញខ្លួននៅចំពោះមុខតុលាការខេត្តកណ្តាលក្នុងឯកសណ្ឋានជាអ្នកទោស។ នៅមុនពេលបង្ហាញខ្លួននៅមុខតុលាការ ជនជាប់ចោទទាំងអស់គួរតែទទួលបានសំលៀកបំពាក់ដែលពួកគេស្លៀកពាក់នៅថ្ងៃដំបូងដែលពួកគេត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។ ប្រសិនបើមន្ត្រីពន្ធនាគារធ្វើឲ្យបាត់ ឬបោះចោលសំលៀកបំពាក់នេះ បុគ្គលដែលឃាត់ខ្លួនគួរតែមានឱកាសទទួលបានសំលៀកបំពាក់ដែលផ្ញើពីគ្រួសារ ឬមិត្តភក្តិរបស់ខ្លួន។ ចៅក្រមនៅឯតុលាការដែលបានសង្កេត កម្រនឹងពោលពាក្យទាក់ទងនឹងភាពមានទោស ឬគ្មានទោសរបស់ជនជាប់ចោទណាស់ នៅមុនពេលដែលសេចក្តីសម្រេចត្រូវបានធ្វើឡើង នេះគឺជាចំណុចមួយដ៏គួរឲ្យកោតសរសើរ។

## ការវិភាគ-សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យសារភាព

ចម្លើយសារភាព ត្រូវបានបង្ហាញជាភស្តុតាងដោយព្រះរាជអាជ្ញានៅក្នុងសវនាការចំនួន ២០៦ នៅតុលាការក្រុងភ្នំពេញ និងក្នុងសវនាការចំនួន ៨៣ នៅតុលាការខេត្តកណ្តាល។ នៅក្នុងចំណោមសវនាការដែលចម្លើយសារភាពត្រូវបានបង្ហាញជាភស្តុតាងនៅតុលាការក្រុងភ្នំពេញ មានតម្រុយ (ដូចជាការអះអាងរបស់ជនជាប់ចោទ) បង្ហាញថា ចម្លើយសារភាពអាចបានមកពីការគំរាមកំហែង ឬការគៀបសង្កត់ផ្លូវចិត្តដទៃទៀត នៅក្នុងសវនាការចំនួន ២៧ ឬស្មើនឹង ១៣% និងមានតម្រុយបង្ហាញថាចម្លើយសារភាពអាចបានមកពីការគៀបសង្កត់ក្រោមរូបភាពជាអំពើហិង្សា ឬទារុណកម្មនៅក្នុងសវនា

ការចំនួន ៣៤ ឬស្មើនឹង ១៦% នៃចំនួនសវនាការដែលបានសង្កេតទាំងអស់។ ក្នុងចំណោមសវនាការដែលចម្លើយសារភាពត្រូវបានបង្ហាញជាភស្តុតាងនៅតុលាការខេត្តកណ្តាល មានតម្រុយបង្ហាញថាចម្លើយសារភាពអាចបានមកពីការគំរាមកំហែង ឬការគៀបសង្កត់ផ្លូវចិត្តផ្សេងទៀត នៅក្នុងសវនាការចំនួនតែ ១ ប៉ុណ្ណោះ និងមានតម្រុយបង្ហាញថា ចម្លើយសារភាពអាចបានមកពីការគៀបសង្កត់ក្រោមរូបភាពអំពើហិង្សា ឬទារុណកម្មនៅក្នុងសវនាការចំនួន១ ផ្សេងទៀត។

អនុសាសន៍បន្ថែមចំនួន ៥ ត្រូវបានផ្តល់ឲ្យ ដើម្បីបង្ការមិនឲ្យកើតឡើងជាថ្មីម្តងទៀត នូវការតវ៉ាជាបន្តបន្ទាប់អំពីទង្វើមិនត្រឹមត្រូវរបស់មន្ត្រីនគរបាល និងមន្ត្រីអនុវត្តច្បាប់ដទៃទៀត។ អនុសាសន៍ទាំងនេះគឺ (១)បន្តការអប់រំ និងបណ្តុះបណ្តាលដល់អ្នកដែលពាក់ព័ន្ធនឹងការសួរចម្លើយ (២)អនុវត្តការការពារប្រឆាំងនឹងការរំលោភបំពាន និងទារុណកម្មនៅក្នុងពេលឃុំខ្លួន និងពេលសួរចម្លើយ (៣)បង្កើតនូវអង្គភាពស៊ើបអង្កេតឯករាជ្យមួយ និងយន្តការបណ្តឹង ព្រមទាំងការស៊ើបអង្កេតជាបន្ទាន់ និងមិនលំអៀងនូវរាល់បណ្តឹងអំពីការធ្វើទារុណកម្ម ឬទង្វើមិនត្រឹមត្រូវដទៃទៀត (៤) បញ្ចូលគោលការណ៍ "មិនអត់ឱនដាច់ខាត" ក្នុងការដាក់ទោសមន្ត្រីអនុវត្តច្បាប់ទាំងអស់ ដែលមានភស្តុតាងបង្ហាញថាបានប្រព្រឹត្តទង្វើមិនត្រឹមត្រូវ និង (៥) ជំរុញឲ្យមានវិធានការប្រុងប្រយ័ត្នជាងនេះ ក្នុងការទទួលយកចម្លើយសារភាពជាភស្តុតាងនៅក្នុងសវនាការ ដោយបង្កើនការប្រើប្រាស់របៀបសួរចម្លើយដែលថតសម្លេងទុក ឬមានអ្នកត្រួតពិនិត្យ។

## ការវិភាគ-យុត្តិធម៌អនីតិជន

ទោះបីមានបទប្បញ្ញត្តិដាច់ដោយឡែកសម្រាប់អនីតិជន នៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌក៏ដោយ ក៏ទិន្នន័យដែលប្រមូលបាននៅក្នុងអំឡុងពេលរបាយការណ៍ទី២ បានបង្ហាញឲ្យឃើញភាពខុសគ្នារវាងគោលការណ៍ដែលមានចែងនៅក្នុងច្បាប់ជាតិ និងអន្តរជាតិ និងការអនុវត្តច្បាប់ដោយតុលាការ។ អនីតិជនចំនួន ៩៧% ដែលត្រូវបានកាត់ទោសអំពីបទល្មើសព្រហ្មទណ្ឌនៅតុលាការក្រុងភ្នំពេញ ត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។ នេះជាសញ្ញានាំឲ្យមានការព្រួយបារម្ភអំពីចំនួនលើសលុបនៃអត្រាការឃុំខ្លួនបណ្តោះអាសន្នសរុប។ អនីតិជនចំនួន ៥ នាក់ ក្នុងចំណោម ៦ នាក់ ដែលត្រូវបានកាត់ទោសនៅឯតុលាការខេត្តកណ្តាល ត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។ នៅក្នុងសវនាការដែលជនជាប់ចោទជាអនីតិជន គ្មានតម្រុយបង្ហាញថា ចៅក្រមបានពិចារណាទៅលើទោសមិនមែនពន្ធនាគារនោះទេ ថ្វីបើជនជាប់ចោទម្នាក់ត្រូវបានដោះលែងដោយសារមូលហេតុអាយុ។

នៅក្នុងក្របខ័ណ្ឌច្បាប់ ទិន្នន័យទាំងនេះអាចនឹងបង្ហាញឲ្យឃើញអំពីភាពខ្វះចន្លោះនៃកិច្ចគាំទ្រខាងធនធាន និងរចនាសម្ព័ន្ធសង្គម ព្រមទាំងធនធាន និងរចនាសម្ព័ន្ធប្រព័ន្ធយុត្តិធម៌។ ខណៈដែលច្បាប់បង្កើតនូវការសន្មតថាអនីតិជននឹងមិនត្រូវឃុំខ្លួនមុនពេលសវនាការ និងមិនគួរទទួលទោសពន្ធនាគារ តែគួរដាក់ទោសប្រភេទផ្សេងពីនេះ ដូចជា ដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងផ្តល់សេវាសង្គម ការអនុវត្តទោសទាមទារឲ្យមាននីតិវិធីត្រឹមត្រូវ និងធនធានគ្រប់គ្រាន់ដើម្បី

ធានាថាជននោះត្រូវបានត្រួតពិនិត្យ និងវិធានការណ៍របស់តុលាការក្នុងការស្តារនីតិសម្បទាត្រូវបានគោរព។ យើងផ្តល់អនុសាសន៍ឲ្យមានយុទ្ធសាស្ត្រសហប្រតិបត្តិការនៅក្នុងវិស័យនេះ ដោយរាជរដ្ឋាភិបាលធ្វើការក្នុងភាពជាដៃគូជាមួយម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នឯកជនដទៃទៀត ដើម្បីធានាឲ្យបាននូវយុត្តិធម៌អនីតិជនដ៏មានប្រសិទ្ធិភាព ដែលផ្តោតទៅលើការធានាថាយុវជនដែលរំលោភច្បាប់ទទួលបានការលើកទឹកចិត្តឲ្យក្លាយជាសមាជិកដែលមានតួនាទីស្ថាបនាសង្គម។

## សេចក្តីសន្និដ្ឋាន

ទិន្នន័យដែលបានមកពីសវនាការចំនួន ៥៣២ ដែលបានសង្កេតក្នុងអំឡុងពេលរបាយការណ៍ទី២ បង្ហាញនូវលទ្ធផលចំរុះ។ អត្រាចំនួនមេធាវីនៅក្នុងសវនាការបទឧក្រិដ្ឋ មានការកើនឡើងជិតដល់ ១០០% ដែលជាចំនួនទាមទារដោយច្បាប់។ ចៅក្រមបានពោលពាក្យដែលបង្ហាញនូវការយល់ដឹងមិនពេញលេញអំពីគោលការណ៍សន្មតជាមុនថាគ្មានទោស នៅក្នុងសវនាការចំនួនតិចតួចប៉ុណ្ណោះ។ ចំណាត់ការភស្តុតាង និងសាក្សីនៅតែជាចំណុចវិជ្ជមាន ដោយតុលាការបានផ្តល់ឱកាសស្មើគ្នាដល់គូភាគីក្នុងការបង្ហាញភស្តុតាង និងសាកសួរសាក្សី។ ប៉ុន្តែការព្រួយបារម្ភនៅតែមានទាក់ទងនឹងអត្រាខ្ពស់នៃការឃុំខ្លួនបណ្តោះអាសន្ន និងអត្រាទាបនៃចំនួនមេធាវីនៅក្នុងរឿងក្តីបទមជ្ឈឹម។ ចៅក្រមបន្តប្រើទូរស័ព្ទដៃនៅក្នុងសវនាការ។ ការអះអាងអំពីទង្វើមិនត្រឹមត្រូវរបស់មន្ត្រីនគរបាល រួមមានការគំរាមកំហែង និងការប្រើអំពើហិង្សា ឬទារុណកម្ម បន្តកើតមានឡើងនៅក្នុងសវនាការមួយចំនួនតូច។ អនុសាសន៍នៅក្នុងរបាយការណ៍នេះ ត្រូវបានផ្តល់ទៅឲ្យអង្គភាព និងស្ថាប័នផ្សេងៗ ហើយជាថ្មីម្តងទៀតបង្ហាញនូវភាពជាប់ទាក់ទងគ្នារវាងស្ថាប័នទាំងនេះនៅក្នុងប្រព័ន្ធយុត្តិធម៌។ ថ្វីបើការសង្កេតការណ៍សវនាការស្ថិតនៅតែក្នុងបន្ទប់សវនាការក៏ដោយ ក៏ការជំរុញឲ្យមានការគោរពសិទ្ធិមួយចំនួននៅក្នុងរបាយការណ៍នេះទាមទារឲ្យមានកិច្ចសហការណ៍ ការគាំទ្រ និងការដឹកនាំនៃក្រុមផ្សេងទៀតដូចជាភ្នាក់ងារអនុវត្តច្បាប់ មន្ត្រីពន្ធនាគារ និងអង្គការមិនមែនរដ្ឋាភិបាល។ នេះគឺជាតម្លៃផ្សារភ្ជាប់នៃគម្រោងប្រមូលទិន្នន័យត្រឹមត្រូវ ដែលអាចប្រើប្រាស់ជាមូលដ្ឋានសម្រាប់បើកកិច្ចពិភាក្សា និងកិច្ចសន្ទនារវាងដៃគូពាក់ព័ន្ធផ្សេងៗ។ នៅពេលដែលធ្វើការជាមួយគ្នា ដៃគូពាក់ព័ន្ធទាំងនេះអាចជួយអភិវឌ្ឍប្រព័ន្ធតុលាការកម្ពុជា ដើម្បីធានាឲ្យមានយុត្តិធម៌ និងសមភាពសម្រាប់ប្រជាពលរដ្ឋគ្រប់រូប។

# ១. សេចក្តីផ្តើម

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ជាសិទ្ធិមួយដែលត្រូវបានគេទទួលស្គាល់ជាសកល ហើយស្ថិតនៅកម្រិតខ្ពស់បំផុតនៃច្បាប់អន្តរជាតិ ទាំងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស[1] ទាំងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។[2] សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (រដ្ឋធម្មនុញ្ញ)[3] និងបទប្បញ្ញត្តិនានានៅក្នុងច្បាប់ជាតិ។[4] សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌កើតចេញពីសិទ្ធិជាក់លាក់មួយចំនួន រួមទាំងសិទ្ធិនៅក្នុងដំណាក់កាលមុនសវនាការ ដែលត្រូវបានទទួលស្គាល់ និងផ្តល់ឲ្យនៅក្នុងពេលនោះ ដើម្បីធានាថា បុគ្គលណាម្នាក់ដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌណាមួយ ទទួលបានការយកចិត្តទុកដាក់យ៉ាងសមគួរ នៅក្នុងខណៈដែលរដ្ឋកំណត់អំពីភាពមាន ឬគ្មានទោសរបស់គេ។

សវនាការយុត្តិធម៌មានសារៈសំខាន់ក្នុងការការពារ ទាំងសិទ្ធិជនជាប់ចោទ ទាំងសិទ្ធិជនរងគ្រោះ ដើម្បីឲ្យមានការត្រួតពិនិត្យភស្តុតាងទាំងអស់ឲ្យបានហ្មត់ចត់ដោយតុលាការមួយឯករាជ្យ និងមិនលំអៀង និងដើម្បីធានាបាននូវរដ្ឋបាលកិច្ចយុត្តិធម៌ល្អ។ ការទទួលស្គាល់ និងការបង្កើតឲ្យមានបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងនីតិវិធីត្រឹមត្រូវតាមច្បាប់ បង្ការនូវការជ្រៀតជ្រែកមិនត្រឹមត្រូវ និងដោយអយុត្តិធម៌ទៅលើការរស់នៅរបស់ប្រជាពលរដ្ឋ ការប្រើអំណាចរដ្ឋ ឬនយោបាយដោយមិនត្រឹមត្រូវ ឬការអនុវត្ត "យុត្តិធម៌ សង្ខេប"។ ជាគោលការណ៍ទូទៅ ដោយមិនគិតពីប្រភេទនៃបទល្មើសដែលចោទប្រកាន់ជនជាប់ចោទទាំងអស់ ត្រូវទទួលបាននូវឱកាសពិតប្រាកដដើម្បីឆ្លើយតបទៅនឹងការចោទប្រកាន់ បង្ហាញ និងតទល់ភស្តុតាង សាកសួរ និងដេញដោលសាក្សីប្រកបដោយសេចក្តីថ្លៃថ្នូរ និងមិនលំអៀង។

---

[1] មហាសន្និបាតអង្គការសហប្រជាជាតិ - មាត្រា១០ នៃ *សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស* ចុះថ្ងៃទី១០ ខែធ្នូឆ្នាំ១៩៤៨។

[2] មហាសន្និបាតអង្គការសហប្រជាជាតិ - មាត្រា១៤ នៃ *កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ* ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦។

[3] មាត្រា៣១ នៃរដ្ឋធម្មនុញ្ញធានានូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌តាមរយៈការបញ្ចូលសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអនុសញ្ញាអន្តរជាតិផ្សេងទៀត រួមទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយទៅក្នុងអត្ថបទរបស់ខ្លួន។ មាត្រា៣៨ និង១២៨ នៃរដ្ឋធម្មនុញ្ញក៏បានធានាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ផ្សេងទៀតផងដែរ។

[4] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចែងអំពីសិទ្ធិមួយចំនួននៅក្នុងនីតិវិធី ដែលជួយធានា ឲ្យមានសវនាការយុត្តិធម៌។ ឧទាហរណ៍មាត្រា៣០០ ចែងថាជនជាប់ចោទអាចមានមេធាវីតាមការជ្រើសរើសរបស់ខ្លួន។

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ អនុវត្តចំពោះគ្រប់ជនជាប់ចោទនៃបទល្មើសព្រហ្មទណ្ឌទាំងអស់ ទោះបីជាបទល្មើសនោះមានលក្ខណៈសាហាវ ឬគួរឲ្យស្អប់ខ្ពើម និងទោះបីជាព្រះរាជអាជ្ញាមានភស្តុតាងច្បាស់លាស់យ៉ាងណាក៏ដោយ។ គោលការណ៍នេះត្រូវបានគូសបញ្ជាក់នៅកម្ពុជាសព្វថ្ងៃតាមរយៈការស៊ើបអង្កេត និងការកាត់ទោសសមាជិកជាន់ខ្ពស់នៃរបបខ្មែរក្រហម និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភច្បាប់ជាតិ និងអន្តរជាតិ នៅក្នុងអំឡុងរបបខ្មែរក្រហម។ នៅក្នុងសាលក្រមទីមួយ ដែលប្រកាសដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) អង្គជំនុំជម្រះបានទទួលស្គាល់យ៉ាងច្បាស់ នូវការរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទកាំងហ្គេកអ៊ាវ ហៅឌុច ដែលត្រូវបានឃុំខ្លួនខុសច្បាប់ដោយតុលាការយោធាកម្ពុជាពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ ដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧។[5] ការរំលោភសិទ្ធិជនជាប់ចោទនេះត្រូវបានសំអាងជាហេតុផលបន្ធូរបន្ថយការដាក់ទោសចុងក្រោយ (ត្រូវបានបន្ថយសរុប ៥ ឆ្នាំ)។ ការណ៍នេះបង្កើតបានជាយុត្តិសាស្ត្រច្បាស់លាស់មួយ ដែលបញ្ជាក់អំពីការទទួលស្គាល់ជាសកលនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងប្រព័ន្ធតុលាការកម្ពុជា។[6]

## ក្របខ័ណ្ឌច្បាប់

ប្រទេសកម្ពុជា គឺជាភាគីមួយនៃលិខិតតុបករណ៍សិទ្ធិមនុស្សជាសកលសំខាន់ៗមួយចំនួន រួមមានសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ លិខិតតុបករណ៍ទាំងនេះធានាថា ជនដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌមានសិទ្ធិទទួលបានការជំនុំជម្រះមួយយុត្តិធម៌ និងជាសាធារណៈ ដោយសាលាជម្រះក្តីមួយឯករាជ្យ និងមិនលំអៀង[7] និងមានសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសរហូតដល់ពេលដែលពិរុទ្ធភាពត្រូវបានរកឃើញតាមច្បាប់។[8] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏ត្រូវបានដាក់បញ្ចូលផងដែរទៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុក។ មាត្រា៣១ នៃរដ្ឋធម្មនុញ្ញចែងថា កម្ពុជា*"ទទួលស្គាល់និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុង...កតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស។"* ការណ៍នេះត្រូវបានបញ្ជាក់បន្ថែមដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ដែលបានលើក

---

[5] កថាខណ្ឌ ៦៣២ នៃសាលក្រមចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ព្រះរាជអាជ្ញា តទល់នឹង កាំងហ្គេកអ៊ាវ ហៅឌុច សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/ECCC/TC។

[6] សូមអាន សេចក្តីថ្លែងការណ៍នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ក្រោមចំណងជើងថា *សវនាការឌុចៈ គំរូមួយដ៏ល្អសម្រាប់តុលាការកម្ពុជា* ចេញផ្សាយថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ នៅលើវែបសាយ www.cchrcambodia.org។

[7] មាត្រា១០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។ មាត្រា១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[8] មាត្រា១១(១) នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។ មាត្រា១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។

ឡើងថា "*អនុសញ្ញាអន្តរជាតិដែលកម្ពុជាបានទទួលស្គាល់*" ជាផ្នែកមួយនៃច្បាប់ ដែលចៅក្រមជំនុំជម្រះត្រូវយកមកពិចារណា។[9]

រដ្ឋធម្មនុញ្ញបានផ្តល់នូវការធានាមួយចំនួន ដែលបង្កើតបានជាក្របខ័ណ្ឌការងារមូលដ្ឋានសម្រាប់ការជំនុំជម្រះដោយយុត្តិធម៌។ មាត្រា៣១ ធានាថា៖ "*ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់*"។ មាត្រា៣៨ ចែងអំពីសិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរ៖ "*វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ ជនជាប់ចោទត្រូវទុកជាមនុស្សឥតទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។ ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។*" មាត្រា១២៨ ធានាថា អំណាចតុលាការជា" *អំណាចឯករាជ្យ*" និងត្រូវ "*ធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។*"

នីតិវិធីព្រហ្មទណ្ឌកម្ពុជាត្រូវបានចងក្រងក្នុងឆ្នាំ ២០០៧ ជាក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ក្រមនីតិវិធីព្រហ្មទណ្ឌ) ដែលជំនួសបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ឆ្នាំ១៩៩២ (ច្បាប់អ៊ុនតាក់)។ ក្រមនីតិវិធីព្រហ្មទណ្ឌបានចែងយ៉ាងលំអិត អំពីនីតិវិធីច្បាប់សម្រាប់ការស៊ើបអង្កេត និងការកាត់ទោសបទល្មើសព្រហ្មទណ្ឌ ព្រមទាំងសិទ្ធិជនរងគ្រោះ និងជនដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។ នៅក្នុងពិធីបើកសន្និសិទស្តីពីការផ្សព្វផ្សាយក្រមនីតិវិធីព្រហ្មទណ្ឌ សម្តេចនាយករដ្ឋមន្ត្រីហ៊ុនសែន បានពន្យល់អំពីប្រភពនៃក្រមនីតិវិធីព្រហ្មទណ្ឌថា៖ "*យោងតាមវប្បធម៌ និង ទំនៀមទំលាប់ច្បាប់កម្ពុជាដែលមានប្រភពដើមពីប្រព័ន្ធច្បាប់រ៉ូម៉ាំងអាល្លឺម៉ង់ (ប្រព័ន្ធច្បាប់ស៊ីវិល) ក្រមនីតិវិធីព្រហ្មទណ្ឌនេះមានមូលដ្ឋានលើគោលការណ៍សំខាន់ៗទាំងឡាយ ដែលមាននៅក្នុងប្រព័ន្ធនីតិវិធីព្រហ្មទណ្ឌ ដើម្បីធានាបាននូវនិរន្តភាពស្ថាប័នតុលាការ និងស្ថាប័នពាក់ព័ន្ធដទៃទៀត ដែលដោះស្រាយរឿងក្តីព្រហ្មទណ្ឌសព្វថ្ងៃ។*"[10]

សម្តេចនាយករដ្ឋមន្ត្រីបានកត់សម្គាល់ថា បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ជាក់ច្បាស់អំពីអំណាចនៃអង្គភាពតុលាការនីមួយៗ និងថាតើស្ថាប័នទាំងនេះមានទំនាក់ទំនងគ្នាយ៉ាងដូចម្តេច៖ "*វាច្បាស់ណាស់បើយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌនេះ ស្ថាប័នអយ្យការនៅតែជាដើមបណ្តឹងក្នុងរឿងក្តីព្រហ្មទណ្ឌ ហើយចៅក្រមស៊ើបសួរនៅតែទទួលបន្ទុកធ្វើការស៊ើបអង្កេត និងប្រមូលភស្តុតាងមុននឹងបញ្ជូនរឿងក្តីទៅឲ្យចៅក្រមជំនុំជម្រះ ដែលនឹងកាត់ទោសជនជាប់ចោទ។*"[11]

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ក្រមព្រហ្មទណ្ឌ) ដែលត្រូវបានប្រកាសឲ្យប្រើនៅឆ្នាំ២០០៩ ជាច្បាប់កំណត់ចំណាត់ថ្នាក់នៃបទល្មើស គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌ គោលការណ៍នៃការដាក់ទោស ដែនយុត្តាធិការនៃតុលាការ និងបទល្មើសព្រហ្មទណ្ឌថ្មីជាច្រើនទៀត។

---

[9] សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ របស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០៧។

[10] សុន្ទរកថារបស់សម្តេចហ៊ុនសែនក្នុងពិធីបើកសន្និសិទស្តីពីការផ្សព្វផ្សាយក្រមនីតិវិធីព្រហ្មទណ្ឌ នៅសណ្ឋាគារឡឺរ៉ូយាល់រាជធានីភ្នំពេញ នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៧។

[11] ដូចខាងលើ។

បទប្បញ្ញត្តិទូទៅដែលមាននៅក្នុងគន្ថីទី១ នៃក្រមព្រហ្មទណ្ឌ បានចូលជាធរមាននៅក្នុងអំឡុងពេលរបាយការណ៍។[12] ក្រមព្រហ្មទណ្ឌទាំងមូល រួមមានបទប្បញ្ញត្តិដែលនិយាយអំពីបទល្មើសថ្មីៗ ចូលជាធរមាននៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១០ ក្នុងរាជធានីភ្នំពេញ និងនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០ នៅតាមបណ្តាខេត្តទូទាំងប្រទេស។[13]

## បរិបទគោលនយោបាយ

នៅក្នុងកាលៈទេសៈមួយចំនួន ដំណើរការនៃប្រព័ន្ធតុលាការ ជាការព្រួយបារម្ភមួយសំខាន់ក្នុងចំណោមការព្រួយបារម្ភដទៃទៀត ពាក់ព័ន្ធនឹងសិទ្ធិមនុស្សនៅកម្ពុជា គឺជាបញ្ហាស្នូល ដោយសារតែស្ថាប័ននេះជាអ្នកការពារ និងជំរុញឲ្យមានការគោរពសិទ្ធិផ្សេងៗ ព្រមទាំងបង្កើនវឌ្ឍនភាពផ្នែកសង្គម និងសេដ្ឋកិច្ច។ នៅឆ្នាំ២០០៨ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតឲ្យមានអភិបាលកិច្ចល្អ ដោយបូករួមទាំងកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលជាស្នូលនៃកម្មវិធីនយោបាយបឋមរបស់យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធិភាពនៅក្នុងដំណាក់ទី២។[14] អភិបាលកិច្ចល្អត្រូវបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណ ថាជា *"តម្រូវការសំខាន់ជាងគេដើម្បីធានានូវការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ប្រកបដោយនិរន្តរភាព សមធម៌ និងយុត្តិធម៌សង្គម។"*[15]

**យុទ្ធសាស្ត្រកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៣**

**គោលដៅនៃយុទ្ធសាស្ត្រ**

១. ជំរុញឲ្យមានការការពារសិទ្ធិ និងសេរីភាពបុគ្គល
២. ទំនើបភាវូបណីកម្មក្របខ័ណ្ឌការងារច្បាប់
៣. បង្កើនការទទួលបានព័ត៌មានទាក់ទងនឹងច្បាប់និងតុលាការ
៤. ពង្រឹងគុណភាពនីតិវិធីច្បាប់ និងសេវាពាក់ព័ន្ធ
៥. ពង្រឹងសេវាតុលាការ
៦. ដាក់ចេញនូវវិធីសាស្ត្រដោះស្រាយជម្លោះដទៃទៀត
៧. ពង្រឹងវិស័យច្បាប់ និងស្ថាប័នតុលាការឲ្យបំពេញការងាររបស់ខ្លួន។

---

[12] មាត្រា៦៧២ នៃក្រមព្រហ្មទណ្ឌ៖ "លើកលែងតែបទប្បញ្ញត្តិទូទៅនៃគន្ថីទី១ (បទប្បញ្ញត្តិទូទៅ) នៃក្រម នេះ ដែលត្រូវយកទៅអនុវត្តភ្លាមក្រោយការចូលជាធរមាននៃក្រមនេះ បទប្បញ្ញត្តិដទៃទៀតត្រូវយកទៅអនុវត្តក្នុងរយៈពេល ១ឆ្នាំ ក្រោយការចូលជាធរមាននៃក្រមនេះ។"

[13] ដូចខាងលើ។ សូមមើលផងដែរ មាត្រា ៩៣ នៃរដ្ឋធម្មនុញ្ញ៖ *"ច្បាប់ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ ឡាយព្រះហស្តលេខា ប្រកាសឲ្យប្រើត្រូវចូលជាធរមាននៅរាជធានី ភ្នំពេញក្នុងរយៈពេលដប់ថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឲ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេលម្ភៃថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឲ្យប្រើ។"*

[14] សុន្ទរកថារបស់សម្តេចហ៊ុនសែនស្តីពីយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធិភាពក្នុងដំណាក់កាលទី២ ថ្លែងនៅក្នុង កិច្ចប្រជុំគណៈរដ្ឋមន្ត្រីលើកដំបូង ក្នុងនីតិកាលទី៤ នៅទីស្តីការគណៈរដ្ឋមន្ត្រី រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨។

[15] ដូចខាងលើ។

កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ត្រូវបានធ្វើឡើងស្របតាមយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៣។[16] យុទ្ធសាស្ត្របានកំណត់នូវគោលការណ៍ចំនួន ៤ ដែលដកស្រង់ចេញពីបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ដើម្បីដឹកនាំកំណែទម្រង់នេះ ដូចជាសិទ្ធិបុគ្គល ប្រជាធិបតេយ្យសេរី ការបែងចែកអំណាច និងនីតិរដ្ឋ។[17] ដោយទទួលស្គាល់សិទ្ធិប្រជាពលរដ្ឋកម្ពុជា ដែលចែងក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់អន្តរជាតិ យុទ្ធសាស្ត្របានលើកឡើងថា៖ "*ការលើកកម្ពស់សិទ្ធិបុគ្គលដូចដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនិងច្បាប់អន្តរជាតិ មានសារៈសំខាន់ក្នុងការផ្តល់លទ្ធភាពដល់ប្រជាពលរដ្ឋកម្ពុជាដើរតួនាទីជាអ្នកតំណាងនៅក្នុងផលប្រយោជន៍សេដ្ឋកិច្ច សង្គម វប្បធម៌ និងសាសនារបស់ពួកគេ និងញាំងឲ្យពួកគេមានលទ្ធភាព និងមានជំនឿ ក្នុងការប្រើប្រាស់ឱកាសដែលមានសម្រាប់ពួកគេ។*"[18] យុទ្ធសាស្ត្រដាក់ចេញនូវគោលដៅចំនួន ៧ (សូមមើលប្រអប់ខាងលើ) ដែលបង្កើតបានជាមូលដ្ឋាននៃផែនការសកម្មភាពកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលអនុម័តនៅក្នុងឆ្នាំ២០០៥។[19]

គោលបំណង របស់គម្រោងសង្កេតការណ៍សវនាការ នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាគឺដើរតួនាទីជាអ្នកសង្កេតការណ៍ សវនា ការព្រហ្មទណ្ឌ ដោយឯករាជ្យ និងមិនលំអៀង ព្រមទាំងប្រមូលទិន្នន័យ ដែលអាចវិភាគបានដើម្បីកំណត់ពីចំណុចខ្លាំង និងចំណុចខ្សោយនៃប្រព័ន្ធយុត្តិធម៌។ តាមរយៈការទាញចំណាប់អារម្មណ៍ទៅលើផ្នែកផ្សេងៗ នៃដំណើរការសវនាការ ដែលទាមទារឲ្យមានការយកចិត្តទុកដាក់ខ្ពស់ និងផ្តល់ជាអនុសាសន៍ទៅឲ្យស្ថាប័ន ដែលពាក់ព័ន្ធនឹងវិស័យយុត្តិធម៌ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា គាំទ្រកិច្ចខិតខំប្រឹងប្រែងដើម្បីពង្រឹងនិងកែទម្រង់ប្រព័ន្ធយុត្តិធម៌សម្រាប់ជាប្រយោជន៍ដល់ប្រជាពលរដ្ឋគ្រប់រូប។ គម្រោងនេះ សហការ និងគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា និងម្ចាស់ជំនួយអន្តរជាតិ ក្នុងការពង្រឹងនិងកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដែលរួមមានគម្រោងតុលាការគំរូកម្ពុជា[20] និងកម្មវិធីសិទ្ធិនិងយុត្តិធម៌ដំណាក់កាលទី២ ដែលឧបត្ថម្ភគាំទ្រដោយទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍអន្តរជាតិនៃសហរដ្ឋអាមេរិក (USAID)។

---

[16] ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ - *កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌* (ភ្នំពេញ៖ ក្រុម ប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ឆ្នាំ២០០៣)។

[17] ដូចខាងលើ។

[18] ដូចខាងលើ។

[19] ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ - *ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌* ដែលអនុម័តក្នុងសម័យប្រជុំពេញអង្គនៃរាជរដ្ឋាភិបាល កម្ពុជានៅ ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥។

[20] គម្រោងតុលាការគំរូត្រូវបានគ្រប់គ្រងដោយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ក្នុងភាពជាដៃគូជាមួយវិទ្យាស្ថានសិទ្ធិមនុស្សដាណឺម៉ាក ភ្នាក់ងារអភិវឌ្ឍអន្តរជាតិ ដាណឺ ម៉ាក និងកម្មវិធីជំនួយអូស្ត្រាលី។ គម្រោងនេះមានគោលបំណងបង្កើននូវភាពយុត្តិធម៌ និងប្រសិទ្ធិភាពនៃសវនាការនៅក្នុងតុលាការចំនួន ៤ មានតុលាការក្រុងភ្នំពេញ តុលាការខេត្តកណ្តាល តុលាការខេត្ត កំពង់ចាម និងតុលាការខេត្តបន្ទាយមានជ័យ ក្នុងគោលបំណងផ្តល់គំរូវិជ្ជមានដល់តុលាការនៅទូទាំងប្រទេសកម្ពុជា។ ភាពយុត្តិធម៌ និង

## គោលបំណង គោលដៅ និងដែនកំណត់នៃរបាយការណ៍

នេះគឺជារបាយការណ៍ប្រចាំឆមាសទី២ ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា ដែលចេញផ្សាយដោយគម្រោង (របាយការណ៍ប្រចាំឆមាសទី២) ។ របាយការណ៍ប្រចាំឆមាសទី១ ត្រូវបានចេញផ្សាយកាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ (របាយការណ៍ប្រចាំឆមាសទី១)។ គោលបំណងរបស់គម្រោង គឺសង្កេតការណ៍សវនាការព្រហ្មទណ្ឌនៅកម្ពុជា ដើម្បីវាយតម្លៃភាពយុត្តិធម៌ស្របតាមបទដ្ឋានជាតិ និងអន្តរជាតិ ផ្តល់អនុសាសន៍ដើម្បីបង្កើនការគោរព និងការអនុវត្តបទប្បញ្ញត្តិទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ព្រមទាំងប្រើទិន្នន័យ និងការរកឃើញដែលមាននៅក្នុងរបាយការណ៍ប្រចាំឆមាស ជាមូលដ្ឋានក្នុងកិច្ចពិភាក្សាជាមួយតុលាការដែលបានសង្កេត និងអ្នកដែលពាក់ព័ន្ធនឹងវិស័យយុត្តិធម៌ដទៃទៀត។ ព័ត៌មានដែលបង្ហាញនៅក្នុងរបាយការណ៍នេះជាមូលដ្ឋានមួយសម្រាប់អនុវត្តការកែទម្រង់។ ទិន្នន័យ និងអនុសាសន៍ នឹងត្រូវបានចែកចាយទៅតាមគោលដៅនៃរបាយការណ៍ ដែលមានដូចជាតុលាការកម្ពុជា និងដៃគូក្នុងវិស័យយុត្តិធម៌ដទៃទៀតសម្រាប់ប្រជុំពិភាក្សា។ នៅខែកុម្ភៈ ឆ្នាំ២០១១ មុនពេលដែលរបាយការណ៍ត្រូវបានបញ្ចប់ ពង្រាងជាភាសាខ្មែរនឹងត្រូវបានផ្ញើជូនប្រធានតុលាការក្រុងភ្នំពេញ និងប្រធានតុលាការខេត្តកណ្តាលដើម្បីទទួលបានការឆ្លើយតប យោបល់ និងអនុសាសន៍បន្ថែម។

រចនាសម្ព័ន្ធរបស់របាយការណ៍មានដូចតទៅ៖ ផ្នែកទី២ នៃរបាយការណ៍និយាយអំពីវិធីសាស្ត្រដែលត្រូវបានអនុវត្តក្នុងការប្រមូលទិន្នន័យ និងរៀបចំរបាយការណ៍នេះ។ ផ្នែកទី៣គឺ ទិន្នន័យ និងលទ្ធផលដែលបានរកឃើញពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០ (អំឡុងពេលរបាយការណ៍ទី២) ត្រូវបានបង្ហាញទន្ទឹមនឹងទិន្នន័យដែលប្រមូលបានពីថ្ងៃទី១០ ខែសីហា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ (អំឡុងពេលរបាយការណ៍ទី១) ក្នុងគោលបំណងកំណត់អំពីការប្រែប្រួលនៃការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ នៅក្នុងផ្នែកទី៤ គឺការវិភាគទិន្នន័យដែលទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ចំនួន ៣ ឲ្យបានស៊ីជម្រៅ និងផ្តល់ជាអនុសាសន៍។ ដោយសារតែរបាយការណ៍ប្រចាំឆមាសទី១ត្រូវបានចេញផ្សាយនៅចុងអំឡុងពេលរបាយការណ៍ទី២ យើងមិនរំពឹងថា អនុសាសន៍ដែលមាននៅក្នុងរបាយការណ៍ទី១មានឥទ្ធិពលលើទិន្នន័យ ដែលប្រមូលបានក្នុងអំឡុងពេលរបាយការណ៍ទី២នោះទេ។ ដូច្នេះ ក្រៅពីកំណត់សម្គាល់ខ្លីៗដែលបានមកពីការឆ្លើយតបនៅក្នុងកិច្ចពិភាក្សា របាយការណ៍នេះមិនបានវិភាគស៊ីជម្រៅទៅលើផលដែលបានមកពីការផ្តល់អនុសាសន៍ទាំងនោះ និងកិច្ចពិភាក្សាដែលមានជាបន្តបន្ទាប់ (កិច្ចពិភាក្សាជាបន្តបន្ទាប់ដែលធ្វើឡើងនៅក្នុងពេលសរសេររបាយការណ៍) ឡើយ។ បញ្ហាទាំងនេះនឹងត្រូវបានវិភាគលំអិតនៅក្នុងរបាយការណ៍បន្ទាប់។

---

ប្រសិទ្ធិភាពនៃសវនាការនៅតុលាការទាំង ៤ ត្រូវបានវាយតម្លៃដោយ យោងតាមបណ្តុំបទដ្ឋានគំរូជាតិ និងអន្តរជាតិ - បទដ្ឋានតុលាការគំរូ។

# ២. វិធីសាស្ត្រ

គម្រោងនេះត្រូវបានអនុវត្តដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា នៅក្នុងក្របខ័ណ្ឌកម្មវិធីស្រាវជ្រាវ និងច្បាប់។ គម្រោងនេះត្រូវបានអនុវត្ត និងរបាយការណ៍ត្រូវបានសរសេរស្របតាមវិធីសាស្ត្រដែលត្រូវបានរៀបរាប់នៅក្នុងជំពូកនេះ។ យើងសង្ឃឹមថា វិធីសាស្ត្រនេះអាចនឹងត្រូវបានចែករំលែក និងដាក់ក្នុងកិច្ចពិភាក្សាជាមួយអង្គការដទៃទៀត ដែលធ្វើការសង្កេតសវនាការក្នុងប្រទេសកម្ពុជាដែរ ក្នុងគោលបំណងបង្កើនកិច្ចសហការនៅក្នុងវិស័យនេះ និងជួយសម្រួលដល់កិច្ចពិភាក្សាក្នុងន័យស្ថាបនារវាងអ្នកពាក់ព័ន្ធទាំងអស់ដែលមានបំណងចង់ឲ្យការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅប្រទេសកម្ពុជាមានការរីកចម្រើនកាន់តែប្រសើរឡើង។

## រយៈពេល និង ទីតាំង

របាយការណ៍នេះបង្ហាញ និងវិភាគទិន្នន័យបានមកពីសវនាការរឿងក្តីព្រហ្មទណ្ឌចំនួន ៥៣២ ដែលបានសង្កេតនៅតុលាការក្រុងភ្នំពេញ និងតុលាការខេត្តកណ្តាល នៅក្នុងអំឡុងពេលរបាយការណ៍ទី២។ ការសង្កេតការណ៍សវនាការនៅតុលាការក្រុងភ្នំពេញ និងតុលាការខេត្តកណ្តាលដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានចាប់ផ្តើមកាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩។ របាយការណ៍ប្រចាំឆមាសទី១គ្របដណ្តប់លើសវនាការសរុបចំនួន ១៩៩ ដែលត្រូវបានសង្កេតនៅក្នុងអំឡុងពេលរបាយការណ៍ទី១ ត្រូវបានចេញផ្សាយកាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០។ តុលាការក្រុងភ្នំពេញត្រូវបានជ្រើសរើសសម្រាប់គម្រោងនេះ ដោយសារតុលាការនេះជាតុលាការដែលស្ថិតនៅក្នុងរាជធានីមានវិសាលភាពធំ និងជាតំបន់ដែលមានចំនួនប្រជាជនច្រើនជាងគេនៅក្នុងប្រទេសកម្ពុជា។ តុលាការនេះមានសកម្មភាពច្រើន ហើយការប្រព្រឹត្តទៅរបស់តុលាការនេះត្រូវបានរាយការណ៍យ៉ាងទូលាយ និងមានឥទ្ធិពលខ្លាំងជាងសាលាដំបូងដទៃទៀតនៅទូទាំងប្រទេសកម្ពុជា។ តុលាការខេត្តកណ្តាលត្រូវបានជ្រើសរើសដោយសារមានទីតាំងនៅជិតរាជធានីភ្នំពេញ ហើយចៅក្រមភាគច្រើនធ្វើជាប្រធាននៅទីនោះ និងមានបន្ទប់សវនាការចំនួន៣ សម្រាប់សង្កេតសវនាការ។ សំខាន់ជាងនេះទៅទៀតតុលាការក្រុងភ្នំពេញ និងតុលាការខេត្តកណ្តាលគឺជា "តុលាការគំរូ" ពីរក្នុងចំណោមតុលាការគំរូទាំង៤ នៃគម្រោងតុលាការគំរូ។

## សិទ្ធិសំខាន់ៗដែលជ្រើសរើសសម្រាប់សង្កេតសវនាការ

ការសង្កេតសវនាការ ផ្តោតជាសំខាន់ទៅលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មួយចំនួន ដោយសារតែសិទ្ធិទាំងនេះជាប់ទាក់ទៅនឹងបរិបទកម្ពុជា។ ដើម្បីកំណត់ថាតើសិទ្ធិណាមួយគួរតែត្រូវបានយកមកថ្លឹងថ្លែង មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាពឹងផ្អែកលើធនធានខាងក្រៅដូចជារបាយ

ការណ៍ និងការសិក្សាស្រាវជ្រាវផ្សេងៗអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា និងអំពីប្រព័ន្ធតុលាការកម្ពុជា។[21] គ្មានការពិចារណាវិជ្ជមាន ឬអវិជ្ជមានណាមួយត្រូវបានទាញចេញពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ផ្សេងទៀតដែលមិនស្ថិតក្នុងរបាយការណ៍នេះឡើយ។

ខាងក្រោមនេះគឺជាសិទ្ធិដែលត្រូវបានជ្រើសរើសសម្រាប់ការសង្កេតសវនាការ៖

- សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ
- សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល
- សិទ្ធិយល់ដឹងអំពីបទចោទប្រកាន់
- សិទ្ធិទទួលបានការពន្យល់ប្រាប់សិទ្ធិ
- សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការពារក្តី
- សិទ្ធិទទួលបានមេធាវី និងមានវត្តមាននៅក្នុងសវនាការ
- សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស
- សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការឯករាជ្យ និងមិនលំអៀង
- សិទ្ធិបង្ហាញភស្តុតាង (រួមទាំងសិទ្ធិហៅ និងសាកសួរសាក្សី )
- សិទ្ធិដឹងឮភស្តុតាងរបស់ភាគីម្ខាងទៀតសម្រាប់រៀបចំការការពារក្តី
- សិទ្ធិមិនឆ្លើយដាក់បន្ទុកខ្លួនឯង (មិនសារភាពអំពីពិរុទ្ធភាពដោយសារការបង្ខិតបង្ខំ ឬការលួងលោម)
- ការហាមឃាត់ចំពោះការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ (ត្រូវបានកាត់សេចក្តីសម្រាប់បទល្មើសមួយដែលមិនមែនជាបទល្មើសនៅពេលដែលប្រព្រឹត្ត) និង
- សិទ្ធិជនជាប់ចោទជាអនីតិជន

## រចនាសម្ព័ន្ធ

ដើម្បីកត់ត្រាទិន្នន័យទាក់ទងនឹងសវនាការឲ្យបានល្អ និងមានប្រសិទ្ធិភាព មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានបង្កើតតារាងសង្កេតការណ៍សវនាការសម្រាប់មន្ត្រីសង្កេតការណ៍សវនាការរបស់

[21] ឧទាហរណ៍៖ គណៈកម្មការអ្នកច្បាប់អន្តរជាតិ - *បទអត្ថាធិប្បាយអំពីរបាយការណ៍បឋមរបស់កម្ពុជាស្តីពីការអនុវត្តកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌* (ហ្សឺណែវ៖ គណៈកម្មការអ្នក ច្បាប់អន្តរជាតិ ខែមេសា ឆ្នាំ២០០៩)។ រីឆាត ប្លូ និង រ៉ូបឺត អាន់ជីវូត ការវាយតម្លៃលើកម្មវិធីសិទ្ធិ និងយុត្តិធម៌ (ប្រាជ្ញ)៖ របាយការណ៍ចុងក្រោយ (វ៉ាស៊ីនតោន ឌីស៊ី៖ ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍអន្តរជាតិនៃ សហរដ្ឋអាមេរិក (ទ.អ.អ.ស.អ) ខែមករា ឆ្នាំ២០០៨)។ ក្រុមការងារអង្គការមិនមែនរដ្ឋាភិបាល*របាយ ការណ៍ដូចគ្នាស្តីពីកម្ពុជា* ឆ្នាំ២០០៩ (ភ្នំពេញ៖ ក្រុមការងារអង្គការមិនមែនរដ្ឋាភិបាល ខែមេសា ឆ្នាំ ២០០៩)។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ប្រើក្នុងតុលាការ (មន្ត្រីសង្កេតការណ៍សវនាការ) (ឯកសារសបន្ថែមទី១)។ តារាងនេះត្រូវបានបង្កើតឡើងស្របតាមបរិបទប្រទេសកម្ពុជា ដែលក្នុងនោះមានសំណួរប្រមាណជា ៥០ ។ ចម្លើយទៅនឹងសំណួរទាំងនេះនឹងបង្ហាញថា តើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានគោរពដែរឬទេ។ សំណួរភាគច្រើនមានចម្លើយ៣ប្រភេទ៖ មាន គ្មាន និងមិនពាក់ព័ន្ធ ឬមិនមានព័ត៌មាន។ មន្ត្រីសង្កេតការណ៍សវនាការធ្វើការសង្កេតទៅលើការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងអំឡុងពេលសវនាការទាំងមូល ជាជាងសង្កេតសិទ្ធិទទួលបានការជំនុះជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទតែម្នាក់។ ដូច្នេះឧទាហរណ៍សំណួរ៣(ក) សួរថាតើមានការឃុំខ្លួនបណ្តោះអាសន្នដែរឬទេ? នៅពេលដែលមានជនជាប់ចោទលើសពីម្នាក់បង្ហាញខ្លួននៅក្នុងសវនាការតែមួយ មន្ត្រីសង្កេតការណ៍សវនាការឆ្លើយថា "គ្មាន" ក្នុងករណីដែលគ្មានជនជាប់ចោទណាម្នាក់ជាប់ក្នុងការឃុំខ្លួនបណ្តោះអាសន្ន។

តារាងសង្កេតការណ៍សវនាការត្រូវបានកែសម្រួល នៅចុងអំឡុងរបាយការណ៍ពេលរបាយការណ៍ទី១ និងទី២ ដើម្បីបញ្ចូលបទពិសោធន៍ដែលបានជួបប្រទះនៅក្នុងពេលសង្កេតសវនាការ ពេលវិភាគទិន្នន័យ និងក្នុងកិច្ចពិភាក្សាជាមួយអ្នកពាក់ព័ន្ធនឹងវិស័យយុត្តិធម៌ដទៃទៀត។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាក៏បានបង្កើតផងដែរ នូវឯកសារបន្ថែមមួយទំព័រភ្ជាប់ទៅនឹងតារាងសង្កេតការណ៍សវនាការ សម្រាប់ប្រើនៅក្នុងសវនាការអនីតិជន (ឯកសារបន្ថែមទី២)។ ដោយសារតែតារាងសង្កេតការណ៍សវនាការត្រូវបានកែប្រែឲ្យខ្លី មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានចងក្រងសេចក្តីណែនាំមួយងាយស្រួលយល់ (សេចក្តីណែនាំស្តីពីតារាងសង្កេតការណ៍សវនាការ) ដើម្បីធានាឲ្យមានការបកស្រាយរួមមួយសម្រាប់សំណួរនីមួយៗនៅក្នុងតារាង និងពន្យល់អំពីមូលដ្ឋានច្បាប់ និងគោលបំណងនៃសំណួរនីមួយៗ។ សេចក្តីណែនាំស្តីពីតារាងសង្កេតការណ៍សវនាការមានសារៈសំខាន់ក្នុងការពន្យល់អត្ថន័យសំណួរនីមួយៗ និងធានាឲ្យមន្ត្រីសង្កេតការណ៍សវនាការទាំងបច្ចុប្បន្ន និងអនាគត យល់ដឹងស្របគ្នាអំពីសំណួរនីមួយៗ។ ឧបករណ៍មួយផ្សេងទៀតសង្ខេបអំពីច្បាប់ជាតិ និងច្បាប់អន្តរជាតិដែលជាមូលដ្ឋាននៃសំណួរនីមួយៗនៅក្នុងតារាងសង្កេតការណ៍សវនាការគឺបញ្ជីច្បាប់ (សេចក្តីបន្ថែមទី៣) ត្រូវបានផ្តល់ឲ្យមន្ត្រីសង្កេតការណ៍សវនាការ ដើម្បីបង្កការងាយស្រួលក្នុងការយោងច្បាប់ដែលពាក់ព័ន្ធនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលត្រូវបានជ្រើសរើសសម្រាប់ការសង្កេតការណ៍សវនាការ។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា មានឆន្ទៈអនុវត្តការសង្កេតការណ៍សវនាការនេះដោយគោរពតាមគោលការណ៍មូលដ្ឋានអន្តរជាតិ[22] និងបានបង្កើតក្រមសីលធម៌សម្រាប់មន្ត្រីសង្កេតការណ៍សវនា

[22] សូមមើល៖ អង្គការលើកលែងទោសអន្តរជាតិ - *សៀវភៅស្តីពីការជំនុំជម្រះដោយយុត្តិធម៌* (ក្រុងឡុង៍៖ បោះពុម្ពផ្សាយដោយអង្គការលើកលែងទោសអន្តរជាតិ ឆ្នាំ ១៩៩៨) Al Index POL 30/02/98។ ដើលែន ណា ភីជីក និង វ៉ានីសា លេសនី - *អ្វីទៅជាការជំនុំជម្រះដោយយុត្តិធម៌៖ សេចក្តីណែនាំជាមូលដ្ឋានស្តីពីបទដ្ឋាន និងការអនុវត្តច្បាប់* (ញូវយ៉ក៖ គណៈកម្មាធិការមេធាវីសម្រាប់សិទ្ធិមនុស្ស ឆ្នាំ២០០០)។ អង្គការសន្តិសុខ និងសហប្រតិបត្តិការអឺរ៉ុប (OSCE) / ការិយាល័យវិទ្យាស្ថានលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស (ODIHR)- *សង្កេតការណ៍*

ការដែលដាក់ចេញកាតព្វកិច្ចមិនជ្រៀតជ្រែក មិនលំអៀង និងរក្សាការសំងាត់ ឲ្យមន្ត្រីសង្កេតការណ៍សវនាការគោរពតាម (ក្រមសីលធម៌) (សេចក្តីបន្ថែមលេខ៤)។

## បុគ្គលិក និងការបណ្តុះបណ្តាល

បច្ចុប្បន្ននេះក្រុមការងារនៃគម្រោងមានមន្ត្រីសង្កេតការណ៍សវនាការចំនួន ៤ នាក់ដែលមានបទពិសោធន៍ និងជំនាញផ្នែកច្បាប់។ ដូចដែលបានលើកឡើងខាងលើ មន្ត្រីសង្កេតការណ៍សវនាការត្រូវគោរពក្រមសីលធម៌។ មន្ត្រីសង្កេតការណ៍សវនាការមានជំនួយពីអ្នកប្រឹក្សាផ្នែកច្បាប់ជាតិ និងអន្តរជាតិ។ មុនការសង្កេតការណ៍សវនាការចាប់ផ្តើម មន្ត្រីសង្កេតការណ៍សវនាការត្រូវបានបណ្តុះបណ្តាលយ៉ាងហ្មត់ចត់ទាំងផ្នែកទ្រឹស្តី និងផ្នែកអនុវត្ត រួមមានការបណ្តុះបណ្តាលស្តីពី៖

- ការសង្កេតការណ៍សវនាការ និងការប្រើប្រាស់តារាងសង្កេតការណ៍សវនាការ
- ក្រមសីលធម៌ និងសារៈសំខាន់នៃភាពមិនលំអៀង ភាពមិនជ្រៀតជ្រែក ការរក្សាការសំងាត់ និងជំនាញវិជ្ជាជីវៈ
- បទដ្ឋាននៃការជំនុំជម្រះដោយយុត្តិធម៌ក្នុងច្បាប់ជាតិ និងអន្តរជាតិ និង
- បទដ្ឋានតុលាការគំរូ

មន្ត្រីសង្កេតការណ៍សវនាការ សង្កេតសវនាការរឿងក្តីព្រហ្មទណ្ឌក្នុងតុលាការស្ទើរតែរាល់ថ្ងៃ ហេតុដូច្នេះទទួលបានចំណេះដឹងជាក់ច្បាស់អំពីនីតិវិធីព្រហ្មទណ្ឌ ដែលអនុវត្តនៅក្នុងប្រទេសកម្ពុជា។ មន្ត្រីសង្កេតការណ៍សវនាការបានបង្កើតទំនាក់ទំនងល្អ និងវិជ្ជមានជាមួយបុគ្គលិករបស់តុលាការដែលបានសង្កេត នេះគឺស្របតាមគោលបំណងរបស់គម្រោង ដែលបំពេញការងារក្នុងភាពដៃគូជាមួយតុលាការ និងអ្នកពាក់ព័ន្ធវិស័យយុត្តិធម៌ដទៃទៀត ដើម្បីលើកកម្ពស់ការទទួលស្គាល់ និងអនុវត្តបទប្បញ្ញត្តិនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

## នីតិវិធីសង្កេតការណ៍សវនាការ

ស្របតាមគោលបំណងនៃគម្រោង មន្ត្រីសង្កេតការណ៍សវនាការចំនួន ២នាក់ ត្រូវបានចាត់ឲ្យសង្កេតសវនាការនៅតុលាការក្រុងភ្នំពេញ និង ២នាក់ទៀតសង្កេតសវនាការនៅតុលាការខេត្តកណ្តាល។ ការធ្វើរបៀបនេះអាចឲ្យមន្ត្រីសង្កេតការណ៍ស្គាល់ច្បាស់ពីតុលាការដែលពួកគេត្រូវធ្វើការជាមួយ និងអាចឲ្យពួកគេបង្កើតទំនាក់ទំនងជាមួយចៅក្រមនិងបុគ្គលិកនៅក្នុងតុលាការនោះ។ មជ្ឈ

---

*សវនាការ៖ សៀវភៅយោងសម្រាប់អ្នកអនុវត្ត* (ប៉ូឡូញ៖ OSCE/ ODIHR ឆ្នាំ២០០៨)។ បាបារ៉ា អូលីវើរ៉ា និង លីនដា បេសារាទី ម៉ូរ៉ាអេដ - *សៀវភៅសង្កេតការណ៍សវនាការនៃគណៈកម្មការអ្នកច្បាប់អន្តរជាតិ* (ហ្សឺណែវ៖ គណៈកម្មការអ្នកច្បាប់អន្តរជាតិ ឆ្នាំ២០០២)។

មណ្ឌលសិទ្ធិមនុស្សកម្ពុជា ជ្រើសរើសសង្កេតសវនាការព្រហ្មទណ្ឌនៅឯតុលាការទាំងពីរដោយមិនបានគ្រោងទុកជាមុន មិនគិតទៅលើប្រភេទបទចោទប្រកាន់នៅក្នុងករណីជាក់លាក់ណាមួយឡើយ។

ចំពោះសវនាការនីមួយៗដែលបានសង្កេត ទិន្នន័យត្រូវបានកត់ត្រាដោយផ្ទាល់នៅលើតារាងសង្កេតការណ៍សវនាការ។ យើងកំណត់ការយកព័ត៌មានត្រឹមតែនៅក្នុងសវនាការប៉ុណ្ណោះ ដូច្នេះគ្មានការសម្ភាស ឬកិច្ចសន្ទនាបន្ថែមនោះទេ លើកលែងតែកិច្ចខិតខំប្រឹងប្រែងក្នុងការកត់ត្រាសាលក្រមដែលប្រកាសបន្ទាប់ពីសវនាការបានបញ្ចប់។

## ប្រព័ន្ធគ្រប់គ្រងទិន្នន័យ

ទិន្នន័យនៃសវនាការនីមួយៗ ត្រូវបានស្រង់ចេញពីតារាងសង្កេតការណ៍សវនាការហើយបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ប្រព័ន្ធគ្រប់គ្រងទិន្នន័យ)។[23] ប្រព័ន្ធគ្រប់គ្រងទិន្នន័យឆ្លុះបញ្ចាំងសំណួរនៅក្នុងតារាងសង្កេតការណ៍សវនាការ និងត្រូវបានបង្កើតឡើងដោយប្រើប្រព័ន្ធ Microsoft Visual Basic។ បន្ថែមទៅលើតួនាទីរក្សាទុកទិន្នន័យដែលបានមកពីតារាងសង្កេតការណ៍សវនាការ ប្រព័ន្ធគ្រប់គ្រងទិន្នន័យត្រូវបានបង្កើតឡើងដើម្បីវិភាគទិន្នន័យដែលបានរក្សាទុក ឧទាហរណ៍ ប្រព័ន្ធនេះនឹងបង្ហាញសញ្ញាពីការឃុំខ្លួនបណ្តោះអាសន្នលើសរយៈពេលដែលបញ្ញត្តិដោយច្បាប់។ ស្របពេលដែលគម្រោងដំណើរការ ប្រព័ន្ធគ្រប់គ្រងទិន្នន័យនឹងត្រូវអភិវឌ្ឍបន្ថែមទៀត។ បន្ទាប់ពីនោះប្រព័ន្ធគ្រប់គ្រងទិន្នន័យនឹងក្លាយជាបញ្ជីរាយទិន្នន័យដ៏ធំទូលាយ និងជាធនធានដ៏មានតម្លៃសម្រាប់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងអង្គការដទៃទៀតដែលធ្វើការដើម្បីលើកកម្ពស់ការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា។

## ការវិភាគ និងកិច្ចពិភាក្សា

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា វិភាគទិន្នន័យនៃសវនាការដែលត្រូវបានរក្សាទុកក្នុង ប្រព័ន្ធគ្រប់គ្រងទិន្នន័យ ព្រមទាំងកត់សម្គាល់នូវការវិវត្តវិជ្ជមាន និងបញ្ហាអវិជ្ជមាននានាដែលកើតមាននៅក្នុងសវនាការ។ ទិន្នន័យមានមូលដ្ឋានលើចម្លើយដែលមន្ត្រីសង្កេតការណ៍សវនាការឆ្លើយទៅនឹងសំណួរនៅក្នុងតារាងសង្កេតការណ៍សវនាការ។ ទិន្នន័យត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ប្រចាំឆមាស និងប្រៀបធៀបជាមួយទិន្នន័យដែលប្រមូលបាននៅក្នុងអំឡុងពេលរបាយការណ៍លើកមុនដើម្បីកំណត់នូវភាពប្រែប្រួលនៃការអនុវត្តរបស់តុលាការ។ របាយការណ៍ប្រចាំឆមាសនីមួយៗបង្ហាញនូវការវិភាគស៊ីជម្រៅនូវផ្នែកតូចៗនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ការវិភាគនេះមានគោលបំណងផ្តល់លទ្ធភាពឲ្យមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា កំណត់បាននូវភាពខ្លាំង និងភាពខ្សោយនៃការអនុវត្តរបស់តុលាការ និងផ្តល់អនុសាសន៍សមស្របដល់តុលាការ និងអ្នកពាក់ព័ន្ធនឹងវិស័យយុត្តិធម៌ដទៃទៀត ក្នុងផ្លូវមួយដែលអាចឲ្យការទទួលស្គាល់និងការអនុវត្តបទប្បញ្ញត្តិ

[23] គេនឹងអាចទស្សនាប្រព័ន្ធគ្រប់គ្រងទិន្នន័យបាននៅលើគេហទំព័ររបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា៖ www.cchrcambodia.org ។

ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងសវនាការរឿងក្តីព្រហ្មទណ្ឌ មានលក្ខណៈកាន់តែប្រសើរឡើង។

គម្រោងមានគោលបំណងផ្តល់ទិន្នន័យត្រឹមត្រូវ ដែលជាមូលដ្ឋានជំរុញឲ្យមានការផ្លាស់ប្តូរការអនុវត្តរបស់តុលាការ និងឈានទៅរកការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។ ពង្រាងចុងក្រោយនៃរបាយការណ៍ប្រចាំឆមាសត្រូវបានផ្ញើជូនប្រធាននៃតុលាការដែលបានសង្កេត ដើម្បីទទួលបានយោបល់ និងអនុសាសន៍ នៅមុនពេលចេញផ្សាយ។ នៅពេលចេញផ្សាយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាចែកចាយរបាយការណ៍នេះទៅឲ្យដៃគូពាក់ព័ន្ធ ព្រមទាំងស្នើសុំជួបប្រជុំ ឬធ្វើបទបង្ហាញ ដើម្បីពន្យល់បន្ថែមអំពីទិន្នន័យ ការវិភាគទិន្នន័យ និងអនុសាសន៍។ បុគ្គលិកគម្រោងក៏បានស្នើសុំជួបប្រជុំផងដែរ ជាមួយតំណាងតុលាការដែលបានសង្កេត ព្រមទាំងអង្គភាព អង្គការ និងស្ថាប័នពាក់ព័ន្ធវិស័យយុត្តិធម៌ដទៃទៀត ដែលជាប់ទាក់ទងនឹងអនុសាសន៍នៅក្នុងរបាយការណ៍។ កិច្ចប្រជុំនេះជាឱកាសមួយសម្រាប់ផ្លាស់ប្តូរគំនិតយោបល់ និងនាំឲ្យមានការយល់ច្បាស់អំពីការលំបាកដែលប្រឈមមុខដោយអ្នកធ្វើការ ដើម្បីពង្រឹងប្រព័ន្ធយុត្តិធម៌។ កិច្ចប្រជុំពិភាក្សាមានគោលបំណងជំរុញឲ្យមានការអនុវត្តអនុសាសន៍ ដែលមាននៅក្នុងរបាយការណ៍ ឬវិធានការណ៍ដទៃទៀត ដែលអាចដោះស្រាយនូវការព្រួយបារម្ភដែលអាចកើតចេញពីអនុសាសន៍។

បន្ទាប់ពីចេញផ្សាយរបាយការណ៍ប្រចាំឆមាសទី១ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានស្នើសុំជួបពិភាក្សាជាមួយអង្គភាពអង្គការ និងស្ថាប័នដូចខាងក្រោម៖

- ក្រសួងយុត្តិធម៌
- ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- តុលាការក្រុងភ្នំពេញ
- តុលាការខេត្តកណ្តាល
- សាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជា
- តុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជា
- គណៈមេធាវី
- អគ្គបញ្ជាការដ្ឋាននគរបាលជាតិ
- មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍
- ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា
- អង្គការជំនួយផ្នែកច្បាប់កម្ពុជា

គោលដៅនៃកិច្ចពិភាក្សា ហាក់ដូចជាខុសគ្នាបន្តិចបន្តួចនៅក្នុងអំឡុងពេលរបាយការណ៍ ទៅតាមអង្គការ អង្គភាព និងស្ថាប័នដែលអនុសាសន៍ត្រូវបានផ្តល់ឲ្យនៅក្នុងរបាយការណ៍នីមួយៗ។ បញ្ហាប្រឈមមុខមួយនៃគម្រោង គឺការទាក់ទាញការចូលរួមពីសំណាក់ដៃគូពាក់ព័ន្ធឲ្យបានជោគជ័យ។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា សូមសំដែងការកោតសរសើរចំពោះកិច្ចពិភាក្សាវិជ្ជមាន និងបែបស្ថាបនា ដែលបានធ្វើឡើងជាមួយដៃគូពាក់ព័ន្ធ ដែលមានឆន្ទៈផ្តល់កិច្ចសហការណ៍ជាមួយគម្រោង។

# ៣. ទិន្នន័យ

នៅក្នុងអំឡុងពេលរបាយការណ៍ទី២ មន្ត្រីសង្កេតការណ៍សវនាការបានសង្កេតសវនាការទាំងអស់ចំនួន ៥៣២ នៅតុលាការក្រុងភ្នំពេញ និងតុលាការខេត្តកណ្ដាល។ ផ្នែកនេះបង្ហាញពីទិន្នន័យ "ដើម" ដែលកត់ត្រាដោយមន្ត្រីសង្កេតការណ៍សវនាការនៅលើតារាងសវនាការក្នុងពេលសង្កេតការណ៍សវនាការនីមួយៗ។ ទិន្នន័យដែលប្រមូលបានក្នុងអំឡុងពេលរបាយការណ៍ទី២ ត្រូវបានបង្ហាញទន្ទឹមគ្នាជាមួយនឹងទិន្នន័យដែលប្រមូលបានក្នុងអំឡុងពេលរបាយការណ៍ទី១ ដើម្បីធ្វើការប្រៀបធៀប និងវិភាគទៅលើការប្រែប្រួលនៃការអនុវត្តរបស់តុលាការ។

**តួលេខទី១៖សវនាការដែលបានសង្កេត**

| **នៅតុលាការក្រុងភ្នំពេញ** | | | | |
|---|---|---|---|---|
| **ទិន្នន័យ** | **អំឡុងពេលរបាយការណ៍ទី១** | | **អំឡុងពេលរបាយការណ៍ទី២** | |
| | លេខ | % | លេខ | % |
| ចំនួនសវនាការ | ១៤២ | | ៣៧៦ | |
| បទឧក្រិដ្ឋ | ៨៤ | ៥៩ | ១៩០ | ៥១ |
| បទមជ្ឈឹម | ៥៨ | ៤១ | ១៨៦ | ៤៩ |
| **នៅតុលាការខេត្តកណ្ដាល** | | | | |
| **ទិន្នន័យ** | **អំឡុងពេលរបាយការណ៍ទី១** | | **អំឡុងពេលរបាយការណ៍ទី២** | |
| | លេខ | % | លេខ | % |
| ចំនួនសវនាការ | ៥៧ | | ១៥៦ | |
| បទឧក្រិដ្ឋ | ២១ | ៣៧ | ៥៥ | ៣៥ |
| បទមជ្ឈឹម | ៣៦ | ៦៣ | ១០១ | ៦៥ |

តួលេខទី១ បង្ហាញពីចំនួន និងទីតាំងនៃសវនាការព្រហ្មទណ្ឌដែលសង្កេតដោយមន្ត្រីសង្កេតការណ៍សវនាការក្នុងអំឡុងពេលរបាយការណ៍ទី២ ព្រមទាំងបទចោទប្រកាន់នៅក្នុងសវនាការនីមួយៗ។ មាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌបានឲ្យនិយមន័យបទឧក្រិដ្ឋ ថាជាបទល្មើសទាំងឡាយណាដែលអតិបរមានៃទោសដាក់ពន្ធនាគារលើសពី ៥ឆ្នាំ។ បទមជ្ឈឹមត្រូវបានឲ្យនិយមន័យនៅក្នុងមាត្រា ៤៧ ថាជាបទល្មើសទាំងឡាយណា ដែលអតិបរមានៃទោសដាក់ ពន្ធនាគារមានរយៈពេលលើសពី ៦ថ្ងៃ និងក្រោម ឬស្មើ ៥ឆ្នាំ។ បទលហុត្រូវបានឲ្យនិយមន័យថាជាបទល្មើសទាំងឡាយណាដែលអតិបរមា

នៃទោសដាក់ពន្ធនាគារមានរយៈពេលក្រោម ឬស្មើនឹង ៦ថ្ងៃ។[24]ដូចដែលបានលើកឡើងខាងលើ សវនាការត្រូវបានជ្រើសរើសសម្រាប់សង្កេត ដោយពឹងផ្អែកទៅលើកាលវិភាគរបស់តុលាការតែប៉ុណ្ណោះ ដោយមិនគិតទៅលើប្រភេទនៃបទចោទប្រកាន់នោះទេ។ ដូច្នេះសវនាការដែលបានសង្កេតតំណាងឲ្យសវនាការគំរូ ដែលត្រូវបានជ្រើសរើសដោយមិនបានគ្រោងទុកជាមុននៅក្នុងតុលាការដែលបានសង្កេត។ ទិន្នន័យដែលប្រមូលបានពីការសង្កេតសវនាការចំនួន ៥៣២ នៅក្នុងអំឡុងពេលរបាយការណ៍ទី២ តំណាងឲ្យទិន្នន័យគំរូ ដែលមានចំនួនច្រើនជាងទិន្នន័យដែលប្រមូលបានពីសវនាការដែលបានសង្កេតចំនួន ១៩៩ នៅក្នុងអំឡុងពេលរបាយការណ៍ទី១ ការណ៍នេះបង្កើននូវភាពតំណាងនៃទិន្នន័យ។

## សិទ្ធិទទួលបានសវនាការជាសាធារណៈ

ជនគ្រប់រូបមានសិទ្ធិទទួលបានការកំណត់ពីពិរុទ្ធភាព ឬភាពគ្មានទោសនៅក្នុងសវនាការជាសាធារណៈ[25] លើកលែងតែនៅក្នុងករណីពិសេស។[26] សិទ្ធិទទួលបានសវនាការជាសាធារណៈមានធាតុផ្សំមួយចំនួន៖ ជាទូទៅសវនាការគួរតែធ្វើឡើងជាសាធារណៈ និងដោយផ្ទាល់មាត់ ព័ត៌មានអំពីទីកន្លែងនិងកាលបរិច្ឆេទនៃសវនាការគួរតែត្រូវបានបិទផ្សាយជាសាធារណៈ និងគួរតែមានមធ្យោបាយផ្សេងៗសម្រួលដល់ការចូលរួមរបស់សាធារណជន។[27] លើសពីនេះ មាត្រា ៣១៧ នៃក្រមនីតិវិធីព្រហ្ម

[24] មាត្រា ៤៨ នៃក្រមព្រហ្មទណ្ឌ។

[25] មាត្រា ៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ មាត្រា ១០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។ មាត្រា ១៤(១) នៃកតិកាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[26] មាត្រា ៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា បើតុលាការយល់ឃើញថាសាធារណភាព បង្កឲ្យមានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬដល់ទំនៀមទម្លាប់នោះ តុលាការតាមសេចក្តីសម្រេចមានសំអាងហេតុអាចបង្គាប់ឲ្យមានការពិភាក្សាដេញដោលទាំងស្រុង ឬមួយផ្នែកប្រព្រឹត្តទៅជាសម្ងាត់ ប៉ុន្តែសេចក្តីសម្រេចលើបញ្ហានេះ ត្រូវដាក់ភ្ជាប់ជាមួយនឹងសាលក្រមលើអង្គសេចក្តី។ មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា សារព័ត៌មាន និងសាធារណៈជន អាចមិនឲ្យចូលរួមទាំងស្រុង ឬផ្នែកមួយនៃសវនាការ សម្រាប់ផលប្រយោជន៍នៃ *"ទំនៀមទម្លាប់ល្អ សណ្តាប់ធ្នាប់សាធារណៈ ឬសន្តិសុខជាតិក្នុងសង្គមប្រជាធិបតេយ្យ"* នៅពេលដែលការធ្វើជាសាធារណៈ នឹងនាំឲ្យខូចប្រយោជន៍យុត្តិធម៌ ឬនៅពេលដែលផលប្រយោជន៍នៃជីវិតឯកជនរបស់គូភាគីតម្រូវឲ្យធ្វើដូច្នេះ។

[27] គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ - កថាខ័ណ្ឌទី ២៨ នៃបទអត្ថាធិប្បាយទូទៅលេខ ៣២៖ មាត្រា ១៤ - សិទ្ធិស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី និងការជំនុំជម្រះដោយយុត្តិធម៌ (CCPR/C/GC/31) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧។

ទណ្ឌ បានចែងថា នៅក្នុងគ្រប់ករណីទាំងអស់ សាលក្រមត្រូវតែប្រកាសនៅពេលសវនាការជាសាធារណៈ។[28]

សវនាការជាសាធារណៈធានាថា រដ្ឋបាលយុត្តិធម៌មានតម្លាភាព ហើយតុលាការនៅតែទទួលបានទំនុកចិត្តពីសំណាក់សាធារណជនទៅលើសេចក្ដីសម្រេច និងសាលក្រម ដែលចេញដោយស្ថាប័ននេះ។ សម្រាប់ភាគីពាក់ព័ន្ធនៅក្នុងសវនាការ ការពិនិត្យពិច័យជាសាធារណៈអាចឲ្យសាធារណជនមើលឃើញពីរបៀបសម្រេចដែលរំលោភច្បាប់ និងរំលោភអំណាច មិនគោរពនីតិវិធី ដែលមានដូចជាករណីភាគីមានភាពមិនស្មើគ្នា ឬទទួលរងការជ្រៀតជ្រែក និងឥទ្ធិពលពីខាងក្រៅ។ នៅពេលដែលប្រព័ន្ធច្បាប់ត្រូវបានអនុវត្តស្របតាមច្បាប់ និងគោលការណ៍សីលធម៌ សវនាការសាធារណៈក៏នាំឲ្យមានភាពជឿជាក់ទៅលើសមត្ថភាពរដ្ឋក្នុងការផ្ដល់យុត្តិធម៌។

**តួលេខទី២៖ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ**

| ២(ក) តើមានការបិទផ្សាយជូនដំណឹងអំពីសវនាការនៅលើក្ដារខៀនក្រៅបន្ទប់សវនាការដែរឬទេ? | | | | |
|---|---|---|---|---|
| **ទិន្នន័យ** | **អំឡុងពេលរបាយការណ៍ទី១** | | **អំឡុងពេលរបាយការណ៍ទី២** | |
| | លេខ | % | លេខ | % |
| មាន | ៥ | ៣ | ០ | ០ |
| គ្មាន | ១៩៤ | ៩៧ | ៥៣២ | ១០០ |
| **២(ខ) តើសាធារណជនត្រូវបានរារាំងមិនឲ្យចូល ឬបណ្ដេញចេញពីបន្ទប់សវនាការដែរឬទេ?** | | | | |
| **ទិន្នន័យ** | **អំឡុងពេលរបាយការណ៍ទី១** | | **អំឡុងពេលរបាយការណ៍ទី២** | |
| | លេខ | % | លេខ | % |
| មាន | ០ | ០ | ០ | ០ |
| គ្មាន | ១៩៩ | ១០០ | ៥៣២ | ១០០ |

ទិន្នន័យសំណួរទី២(ក) បង្ហាញថា គ្មានតុលាការណាមួយក្នុងចំណោមតុលាការដែលបានសង្កេត បានបិទផ្សាយជូនដំណឹងលំអិតអំពីពេលវេលា និងទីកន្លែងនៃសវនាការនោះទេនៅក្នុងអំឡុងពេលរបាយការណ៍នេះ។ សិទ្ធិទទួលការជំនុំជម្រះជាសាធារណៈ គឺជាសិទ្ធិមួយដែលត្រូវបានវិភាគលំអិតនៅក្នុងរបាយការណ៍ទី១។ ដោយសារតែរបាយការណ៍ទី១ ត្រូវបានចេញផ្សាយនៅចុងអំឡុងពេលរបាយការណ៍នេះ តុលាការមិនមានឱកាសឆ្លើយតបនឹងអនុសាសន៍ ដែលផ្ដល់ដោយមជ្ឈ

[28] មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏ចែងផងដែរថា ការចេញសាលក្រមទាំងអស់ អំពីរឿងព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ត្រូវប្រកាសជាសាធារណៈ លើកលែងតែផលប្រយោជន៍អនីតិជន តម្រូវផ្សេងពីនេះ ឬរឿងក្ដីអំពីទំនាស់គ្រួសារ ឬអាណាព្យាបាលរបស់កុមារ។

មណ្ឌលសិទ្ធិមនុស្សកម្ពុជានៅក្នុងរបាយការណ៍ទី១នោះទេ។ ប៉ុន្តែនៅក្នុងពេលសរសេររបាយការណ៍នេះ តុលាការក្រុងភ្នំពេញ បានអនុវត្តគោលការណ៍បិទផ្សាយព័ត៌មានលំអិតលើក្តារខៀនជូនដំណឹងជាទៀងទាត់។ នេះជាការវិវត្តមួយគួរឲ្យអបអរសាទរ។

ទិន្នន័យសំណួរទី២(ខ) បង្ហាញថា គ្មានការផ្លាស់ប្តូរទេចាប់ពីអំឡុងពេលរបាយការណ៍ទី១។ គ្មានករណីណាមួយដែលបង្ហាញថា សាធារណជនត្រូវបានរារាំងមិនឲ្យចូល ឬបណ្តេញចេញពីបន្ទប់សវនាការនោះទេ។ ទិន្នន័យសម្រាប់សំណួរនេះត្រូវបានបកស្រាយជាមួយនឹងលក្ខខ័ណ្ឌថា នៅពេលចាប់ផ្តើមសវនាការ មន្ត្រីសង្កេតការណ៍សវនាការស្ថិតនៅក្នុងបន្ទប់សវនាការ ដូច្នេះលទ្ធភាពនៃការសង្កេតស្ថានភាពខាងក្រៅគឺមានកម្រិត។ ប៉ុន្តែ ទោះបីជាមានកម្រិតបែបនេះក៏ដោយ ក៏មន្ត្រីសង្កេតការណ៍សវនាការត្រូវធ្វើការសង្កេតជាទូទៅថា តើមានជនណាម្នាក់មិនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងសវនាការ តាមរយៈការបដិសេធមិនឲ្យចូល ឬបណ្តេញចេញពីបន្ទប់សវនាការដែរឬទេ។

## សិទ្ធិមានសេរីភាព និងទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល

ច្បាប់ជាតិនិងច្បាប់អន្តរជាតិ បានចែងអំពីសច្ចធារណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្នៈ ជាគោលការណ៍ ជនណាម្នាក់ដែលត្រូវបានចោទប្រកាន់ថាប្រព្រឹត្តបទល្មើស ត្រូវបានដោះលែងក្រៅឃុំនៅពេលរង់ចាំការជំនុំជម្រះ នេះគឺជាជម្រើសទី១ ហើយការឃុំខ្លួនបណ្តោះអាសន្នគឺជាជម្រើសចុងក្រោយបំផុត។[29] មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់លក្ខខណ្ឌមួយចំនួន ដែលអាចនាំឲ្យមានការឃុំខ្លួនបណ្តោះអាសន្ន។

ប្រសិនបើរដ្ឋឃុំខ្លួនជនដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើស រដ្ឋមានករណីយកិច្ចយករឿងក្តីទៅជំនុំជម្រះឲ្យបានរហ័សតាមដែលអាចធ្វើទៅបាន ដើម្បីបង្ហាញភស្តុតាងប្រឆាំងនឹងជនជាប់ចោទ អនុញ្ញាតឲ្យជនជាប់ចោទតទល់នឹងភស្តុតាងនៃការចោទប្រកាន់ និងបង្ហាញភស្តុតាងរបស់ខ្លួន និងកំណត់អំពីភាពមានទោស ឬគ្មានទោស។ សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានពន្យារពេលត្រូវបានធានាដោយច្បាប់អន្តរជាតិ[30] ហើយរយៈពេលអតិបរមានៃការឃុំខ្លួនបណ្តោះអាសន្នត្រូវ

[29] មាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថាៈ "ជាគោលការណ៍ ជនត្រូវចោទត្រូវមានសេរីភាព។ ក្នុងករណីពិសេស ជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្តោះអាសន្ននៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងផ្នែកនេះ"។ មាត្រា ៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថាៈ "ការឃុំខ្លួនមនុស្ស ដើម្បីរង់ចាំការជំនុំជម្រះ គឺមិនមែនជាវិធានទូទៅទេ"។

[30] មាត្រា ៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា បុគ្គលណាដែលបានចាប់ខ្លួន ឬឃុំខ្លួនពីបទព្រហ្មទណ្ឌ នឹងត្រូវបាននាំខ្លួនទៅចំពោះមុខចៅក្រម ឬអាជ្ញាធរណាមួយផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់ឲ្យបំពេញមុខងារតុលាការ ក្នុងរយៈពេលយ៉ាងខ្លីបំផុត និងត្រូវបានជំនុំជម្រះក្នុងរយៈពេលសមស្រប ឬត្រូវដោះលែង។ គោលការណ៍ទី៣៨ នៃគោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីឯករាជ្យភាពនៃប្រព័ន្ធតុលាការ ចែងថាៈ *"ជនណាម្នាក់ដែលត្រូវបានឃុំខ្លួនដោយសារការចោទប្រកាន់ព្រហ្មទណ្ឌមានសិទ្ធិទទួលបានការជំនុំជម្រះនៅក្នុងរយៈពេលមួយសមរម្យ ឬដោះលែងនៅក្នុងពេលរង់ចាំសវនាការ។"*

បានកំណត់យ៉ាងច្បាស់នៅក្នុងច្បាប់កម្ពុជា។[31] មន្ត្រីសង្កេតការណ៍សវនាការនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា សង្កេតទៅលើភាពទូទៅនៃការឃុំខ្លួនបណ្តោះអាសន្ន និងរយៈពេលដែលជនជាប់ចោទត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។

**តួលេខទី៣៖ ការឃុំខ្លួនបណ្តោះអាសន្ន**

| ៣(ក) តើមានការឃុំខ្លួនបណ្តោះអាសន្នដែរឬទេ? | | | | |
|---|---|---|---|---|
| **ទិន្នន័យ** | **អំឡុងពេលរបាយការណ៍ទី១** | | **អំឡុងពេលរបាយការណ៍ទី២** | |
| | លេខ | % | លេខ | % |
| មាន | ១៧៦ | ៨៨ | ៤៤៦ | ៨៤ |
| គ្មាន | ៧ | ៤ | ៨ | ១,៥ |
| មិនដឹង | ១៦ | ៨ | ២ | ០,៣ |
| មិនពាក់ព័ន្ធ | - | - | ៧៦ | ១៤,២ |
| សរុប | ១៩៩ | ១០០ | ៥៣២ | ១០០ |

សំណួរ ៣(ក)កត់ត្រាភាពទូទៅនៃការឃុំខ្លួនបណ្តោះអាសន្ន បន្ទាប់ពីជនជាប់ចោទត្រូវបានចាប់ខ្លួន។ តារាងសង្កេតការណ៍សវនាការដែលប្រើនៅក្នុងអំឡុងពេលរបាយការណ៍ទី២ មានបញ្ចូលជម្រើសបន្ថែមគឺ "មិនពាក់ព័ន្ធ" ដែលត្រូវបានជ្រើសរើសនៅពេលដែលគ្មានការចាប់ខ្លួន និងគ្មានការឃុំខ្លួនបណ្តោះអាសន្ន។ ជនជាប់ចោទដែលត្រូវបានកោះហៅទៅបង្ហាញខ្លួននៅមុខតុលាការ នៅមានសេរីភាពនៅគ្រប់ដំណាក់កាលទាំងអស់មុនសវនាការ។ ដោយប្រើវិធីសាស្ត្រថ្មីនេះ មន្ត្រីសង្កេតការណ៍សវនាការជ្រើសរើសចម្លើយថា "គ្មាន" នៅក្នុងករណីដែលជនជាប់ចោទត្រូវបានចាប់ខ្លួន ប៉ុន្តែត្រូវបានដោះលែងឲ្យនៅក្រៅឃុំ (ដែលកើតឡើងតែក្នុងករណីចំនួន ១,៥% តែប៉ុណ្ណោះ)។

ទិន្នន័យសម្រាប់សំណួរ ៣(ខ) បង្ហាញថាការឃុំខ្លួនបណ្តោះអាសន្ននៅតែមានលក្ខណៈទូទៅនៅក្នុងអំឡុងពេលរបាយការណ៍។ ចំនួនភាគរយនៃករណីដែលជនជាប់ចោទត្រូវបានឃុំខ្លួនបណ្តោះអាសន្នមានការធ្លាក់ចុះបន្តិចបន្តួច។ ប៉ុន្តែបើយោងតាមសច្ចធារណ៍ច្បាប់ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន ចំនួន ៨៤% នៅតែជាអត្រាមួយខ្ពស់។ មាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងពីជម្រើសផ្សេងក្រៅពីការឃុំខ្លួនបណ្តោះអាសន្ន គឺការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលជាវិធានការណ៍មួយរឹតបន្តឹងសិទ្ធិសេរីភាពកម្រិតទាបជាងការឃុំខ្លួនបណ្តោះអាសន្ន។

ទិន្នន័យបានបង្ហាញនូវសវនាការដែលបានសង្កេតមួយចំនួន ដែលក្នុងនោះជនជាប់ចោទត្រូវបានឃុំខ្លួនបណ្តោះអាសន្នលើសរយៈពេលដែលកំណត់ដោយច្បាប់។ តួលេខទី៤ ខាងក្រោមបង្ហាញ

---

[31] មាត្រា ២០៨ និង២០៩ (នីតិជន) និងមាត្រា ២១៣ និង១១៤ (អនីតិជន) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញចែងថា ការឃុំខ្លួនជនណាម្នាក់នឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។

នូវព័ត៌មានដែលបានមកពីសវនាការចំនួន ១៨ ដែលក្នុងនោះជនជាប់ចោទត្រូវបានឃុំខ្លួនលើសរយៈពេលកំណត់ដោយច្បាប់។ ទោះបីជាសវនាការចំនួន ១៨ នេះ ស្មើនឹង ៣,៣% នៃសវនាការដែលបានសង្កេតទាំងអស់ចំនួន ៥៣២ (ធ្លាក់ចុះ ០,៥% បើប្រៀបធៀបនឹងទិន្នន័យនៅក្នុងអំឡុងពេលរបាយការណ៍ទី១) ក៏ដោយ ក៏ការឃុំខ្លួនខុសច្បាប់នៅតែជាចំណុចមួយដែលគួរឲ្យព្រួយបារម្ភ។

**តួលេខទី៨៖ ការឃុំខ្លួនបណ្ដោះអាសន្នដែលល្មើសច្បាប់ (លើសរយៈពេលកំណត់ដោយច្បាប់)**

| អំឡុងពេលរបាយការណ៍ទី២ | | | | | | | |
|---|---|---|---|---|---|---|---|
| លេខ | តុលាការ | បទចោទប្រកាន់ | ចំនួនថ្ងៃអតិបរមានៃការឃុំខ្លួនបណ្ដោះអាសន្ន | ចំនួនថ្ងៃឃុំខ្លួនបណ្ដោះអាសន្ន | ចំនួនថ្ងៃឃុំខ្លួនលើស | ទោស (មុនគិតពេលវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន) | ការគិតបញ្ចូលពេលវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន |
| ១ | PP/04-01-10 | ច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ/ប្លន់ | ៦៨២ | ៧៨៤ | ១០២ | ៥ ឆ្នាំ | មាន |
| ២ | PP/05-01-10 | ច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ/ប្លន់ | ៦៨២ | ១០១៨ | ៣៣៦ | ៥ ឆ្នាំ | មាន |
| ៣ | PP/26-04-10 | ច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ/ប្លន់ | ៦៨២ | ១០១៣ | ៣៣១ | ៥ ឆ្នាំ | មាន |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤ | PP/02-02-10 | ច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ/ប្លន់ | ៦៨២ | ១០៨២ | ៤០០ | ៧ ឆ្នាំ | មាន |
| ៥ | PP/04-05-10 | ច្បាប់អ៊ុនតាក់/ឆបោក | ៣១០ | ៥៨៨ | ២៧៨ | ១ ឆ្នាំ | មាន |
| ៦ | PP/06-05-10 | ច្បាប់អ៊ុនតាក់/ក្លែងបន្លំឯកសារ | ៣១០ | ១១៥៨ | ៨៤៨ | ៧ ខែ | មាន |
| ៧ | PP/26-01-10 | ច្បាប់អ៊ុនតាក់/រំលោភលើសេចក្តីទុកចិត្ត | ៣១០ | ៣៥០ | ៤០ | ៤ ឆ្នាំ | មាន |
| ៨ | KD/28-06-10 | ច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ/ប្លន់ | ៦៨២ | ៨៧២ | ១៩០ | ៦ ឆ្នាំ | មិនដឹង |
| ៩ | KD/19-03-10 | ច្បាប់អ៊ុនតាក់/បង្ករបួសស្នាម | ៣១០ | ៣៧៤ | ៦៤ | ១៤ ខែ | មាន |
| ១០ | KD/31-03-10 | ច្បាប់អ៊ុនតាក់/បំផ្លាញទ្រព្យសម្បត្តិ | ៣១០ | ៣៦៥ | ៥៥ | ១ ឆ្នាំ | មាន |
| ១១ | KD/12-05-10 | ច្បាប់អ៊ុនតាក់/ចោរកម្ម | ៣១០ | ៥៩៥ | ២៨៥ | ១ ឆ្នាំ | មាន |
| ១២ | KD/24-06-10 | ច្បាប់អ៊ុនតាក់/បង្ករបួសស្នាម | ៣១០ | ៤២៦ | ១១៦ | ១៣ ខែ | មាន |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៣ | KD/04-06-10 | ច្បាប់អ៊ីនតាក់/បង្ក របួសស្នាម | ៣១០ | ៤៥២ | ១៤២ | ១៥ ខែ | មាន |
| ១៤ | KD/07-06-10 | ច្បាប់អ៊ីនតាក់/ចោរកម្ម | ៣១០ | ៤៦១ | ១៥១ | ១៨ ខែ | មាន |
| ១៥ | KD/17-06-10 | ច្បាប់ស្តីការត្រួតពិនិត្យគ្រឿងញៀន / ជួញដូរគ្រឿងញៀន | ៣១០ | ៣៧៧ | ៦៧ | ២ ឆ្នាំ | មិនដឹង |
| ១៦ | KD/28-05-10 | ច្បាប់អ៊ីនតាក់/ចោរកម្ម | ៣១០ | ៧១២ | ៤០២ | ២១ ខែ | មាន |
| ១៧ | KD/03-03-10 | ច្បាប់អ៊ីនតាក់/បង្ក របួសស្នាម | ៣១០ | ៣៧៩ | ៦៩ | ១៣ ខែ (អនីតិជន) | មិនដឹង |
| ១៨ | KD/22-01-10 | ច្បាប់ស្តីពីការគ្រប់គ្រងអាវុធ/ប្រើអាវុធខុសច្បាប់ | ៣១០ | ៣៧៤ | ៦៤ | ៨ ខែ | មាន |

រយៈកំណត់នៃការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងតួលេខទី៤ ត្រូវបានគណនាអនុលោមតាមមាត្រា២០៨ និង២០៩ នៃក្រមព្រហ្មនីតិវិធីព្រហ្មទណ្ឌ ដែលចែងអំពីរយៈពេលអតិបរិមានៃការឃុំខ្លួនបណ្តោះអាសន្នសម្រាប់បទឧក្រិដ្ឋ និងបទមជ្ឈឹម។ មាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក៏មានចែងផងដែរ អំពីរយៈពេលឃុំខ្លួនបន្ថែមចំនួន ៤ខែទៀត បន្ទាប់ពីការស៊ើបអង្កេតត្រូវបានបញ្ចប់ និងមុនពេលមានការជំនុំជម្រះ។ រយៈពេលបន្ថែមនេះក៏ត្រូវបានយកមកគណនាដែរ។ រយៈពេលអតិបរិមានៃការឃុំខ្លួនបណ្តោះអាសន្នសម្រាប់បទឧក្រិដ្ឋគឺ ២២ខែ (ឬ៦៨២ថ្ងៃ)។ រយៈពេលអតិបរមាសម្រាប់បទមជ្ឈឹមគឺ ១០ ខែ (ឬ៣១០ថ្ងៃ)។

យើងមានការព្រួយបារម្ភអំពីសវនាការចំនួន ១៨ ដែលក្នុងនោះការឃុំខ្លួនបណ្តោះអាសន្ននៅមុនសវនាការលើសរយៈពេលកំណត់ដោយច្បាប់ ហើយក្នុងចំណោមនោះ សវនាការចំនួន ១៣ ទាក់ទងនឹងបទមជ្ឈឹម។ ទោះបីជាតុលាការត្រូវគិតទៅលើកត្តាជាច្រើន ដើម្បីវាយតម្លៃលើលទ្ធភាពនៃ

ការឃុំខ្លួនបណ្ដោះអាសន្ននេះ ហើយសេចក្ដីសម្រេចត្រូវបានធ្វើឡើងទៅតាមករណីនីមួយៗក៏ដោយ ក៏មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្នដែលមានចែងនៅក្នុងមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កម្រនឹងត្រូវបានអនុវត្តចំពោះជន ដែលត្រូវបានចោទប្រកាន់ពីបទល្មើសដែលមិនមានលក្ខណៈហិង្សា ដូចជាបទឆបោក បទក្លែងបន្លំឯកសារ និងបទរំលោភលើសេចក្ដីទុកចិត្ត គួរតែត្រូវបានដោះលែងឲ្យនៅក្រៅឃុំនៅមុនពេលមានការជំនុំជម្រះ។ នៅក្នុងសវនាការមួយ ជនជាប់ចោទត្រូវចោទប្រកាន់ពីបទក្លែងបន្លំលិខិតឯកជន លិខិតពាណិជ្ជកម្ម ឬលិខិតធនាគារ ដែលមានចែងនៅក្នុងមាត្រា ៥០ នៃច្បាប់អ៊ុនតាក់ ដែលត្រូវទទួលទោសពន្ធនាគារអតិបរមា ៥ឆ្នាំ។ ជនជាប់ចោទត្រូវបានឃុំខ្លួនបណ្ដោះអាសន្នក្នុងរយៈពេលជាង ៣ឆ្នាំ មុននឹងមានការជំនុំជម្រះលើរឿងក្ដី។ ជននោះត្រូវបានតុលាការផ្ដន្ទាទោសដាក់ពន្ធនាគារ ៧ ខែ។ នេះគឺមានន័យថា ជនជាប់ចោទត្រូវឃុំខ្លួនក្នុងពន្ធនាគារលើសរយៈពេលនៃការផ្ដន្ទាទោស ចំនួន ២ឆ្នាំ និង ៥ខែ។

ដូចដែលបានលើកឡើងនៅក្នុងសេចក្ដីផ្ដើមនៃរបាយការណ៍នេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបង្កើតឲ្យមានយុត្តិសាស្ត្រមួយនៅក្នុងសាលក្រមលើកដំបូងរបស់ខ្លួន ដោយបានកាត់បន្ថយទោសជនជាប់ចោទកាំងហ្កេកអ៊ាវ ហៅឌុច ព្រោះតែទទួលស្គាល់ការឃុំខ្លួនបណ្ដោះអាសន្នខុសច្បាប់។

## សិទ្ធិយល់ដឹងពីបទចោទប្រកាន់

ជនជាប់ចោទមានសិទ្ធិយល់ដឹងអំពីបទចោទប្រកាន់ដែលខ្លួនប្រឈមមុខ។[32] នេះគឺរាប់បញ្ចូលទាំងបទល្មើសដែលពួកគេត្រូវបានអះអាងថាបានប្រព្រឹត្ត និងអង្គហេតុដែលនាំឲ្យមានការចោទប្រកាន់។ ជនសង្ស័យត្រូវទទួលបានព័ត៌មានទាំងនេះ នៅក្នុងភាសាមួយដែលខ្លួនយល់បាន។[33]

**តួលេខទី៥៖ សិទ្ធិយល់ដឹងអំពីបទចោទប្រកាន់**

| ៩(ក) តើចៅក្រមបានប្រកាសពីរឿងក្ដីដែលត្រូវជំនុំជម្រះដែរឬទេ ? | | | | |
|---|---|---|---|---|
| **ទិន្នន័យ** | **អំឡុងពេលរបាយការណ៍ទី១** | | **អំឡុងពេលរបាយការណ៍ទី២** | |
| | លេខ | % | លេខ | % |
| មាន | ១៩៦ | ៩៨ | ៤៩៣ | ៩៣ |
| គ្មាន | ៣ | ២ | ៣៩ | ៧ |

[32] មាត្រា ៩៧ និង៣២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។មាត្រា ១៤(៣)(ក) និង(ច) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[33] មាត្រា ៣៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ មាត្រា ១៤(៣)(ច) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

**៩(ខ) តើចៅក្រមបានប្រាប់ពីបទចោទប្រកាន់ដែរឬទេ ?**

| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | |
|---|---|---|---|---|
| | លេខ | % | លេខ | % |
| មាន | ១៩៨ | ៩៩ | ៥០៣ | ៩៥ |
| គ្មាន | ១ | ១ | ២៩ | ៥ |

**៩(គ) តើចៅក្រមបានប្រាប់ពីមាត្រាច្បាប់ពាក់ព័ន្ធដែរឬទេ ?**

| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | |
|---|---|---|---|---|
| | លេខ | % | លេខ | % |
| មាន | ១៦៩ | ៨៥ | ៣១៣ | ៥៩ |
| គ្មាន | ៣០ | ១៥ | ២១៩ | ៤១ |

**៩(ឃ) តើចៅក្រមបានរៀបរាប់ពីឈ្មោះអ្នកចូលរួមដែរឬទេ ?**

| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | |
|---|---|---|---|---|
| | លេខ | % | លេខ | % |
| មាន | ១៩៦ | ៩៨ | ៤៤៣ | ៨៣ |
| គ្មាន | ៣ | ២ | ៨៩ | ១៧ |

**៩(ង) តើចៅក្រមបានប្រាប់ពីកាលបរិច្ឆេទនិងទីកន្លែងប្រព្រឹត្តបទល្មើសដែរឬទេ ?**

| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | |
|---|---|---|---|---|
| | លេខ | % | លេខ | % |
| មាន | ១៩៧ | ៩៩ | ៣៩៨ | ៧៥ |
| គ្មាន | ២ | ១ | ១៣៤ | ២៥ |

**៩(ច) ប្រសិនបើត្រូវការតើអ្នកបកប្រែត្រូវបានផ្តល់ឲ្យដែរឬទេ ?**

| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | |
|---|---|---|---|---|
| | លេខ | % | លេខ | % |
| មាន | ០ | ០ | ១៨ | ៣ |
| គ្មាន | ០ | ០ | ១ | ១ |
| មិនពាក់ព័ន្ធ | ១៩៩ | ១០០ | ៥១៣ | ៩៦ |

**៩(ឆ) ប្រសិនបើត្រូវការតើជនពិការត្រូវបានគេផ្តល់ជំនួយដែរឬទេ ?**

| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | |
|---|---|---|---|---|
| | លេខ | % | លេខ | % |
| មាន | ០ | ០ | ០ | ០ |
| គ្មាន | ១ | ០,៥ | ១ | ១ |

| | | | | |
|---|---|---|---|---|
| មិនពាក់ព័ន្ធ | ១៩៨ | ៩៩,៥ | ៥៣១ | ៩៩ |

ចៅក្រមបានប្រកាសរឿងក្តីដែលត្រូវជំនុំជម្រះនៅក្នុងសវនាការចំនួន ៩៣% និងប្រកាសពីបទចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទនៅក្នុងសវនាការចំនួន ៩៥% នៃសវនាការទាំងអស់ដែលបានអង្កេតនៅក្នុងអំឡុងពេលរបាយការណ៍ទី២។ តួលេខនេះបង្ហាញនូវការធ្លាក់ចុះបន្តិចបន្តួច បើប្រៀបធៀបនឹងទិន្នន័យដែលទទួលបាននៅក្នុងអំឡុងពេលរបាយការណ៍ទី១។ ចំពោះករណីដែលចៅក្រមប្រកាសអំពីច្បាប់ និងភាគីពាក់ព័ន្ធ ព្រមទាំងកាលបរិច្ឆេទ និងទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្តទិន្នន័យមានការធ្លាក់ចុះគួរឲ្យកត់សម្គាល់។ នៅក្នុងសវនាការមួយ ជនជាប់ចោទមិនទទួលបានជំនួយពីអ្នកបកប្រែនោះទេ។ ជនជាប់ចោទជាជនជាតិបែលហ្សិក ដែលអាចនិយាយ និងយល់ភាសាខ្មែរបានបន្តិចបន្តួច មានការលំបាកយ៉ាងខ្លាំងនៅក្នុងការតាមដាននីតិវិធី។ នៅក្នុងសវនាការមួយ ជនជាប់ចោទមិនទទួលបានជំនួយសម្រាប់ជនពិការ។ ជនជាប់ចោទមានវ័យចាស់ជរា ហើយមិនអាចស្តាប់ដឹងច្បាស់អំពីដំណើរការនីតិវិធី។ ទោះបីជាមានការលំបាកក្នុងការស្តាប់បែបនេះក៏ដោយ ក៏តុលាការមិនបានប្រើប្រាស់មីក្រូសម្រាប់បំពងសម្លេងឡើយ។

## ការពន្យល់ប្រាប់សិទ្ធិ

ដើម្បីអនុវត្តសិទ្ធិបានជនជាប់ចោទត្រូវដឹងច្បាស់ថាខ្លួនមានសិទ្ធិនោះ។ ដោយមើលឃើញថានៅក្នុងសវនាការបទមជ្ឈិមមួយចំនួនធំ ជនជាប់ចោទបង្ហាញខ្លួននៅមុខតុលាការដោយគ្មានមេធាវីដែលអាចពន្យល់ពួកគាត់អំពីសិទ្ធិជាមូលដ្ឋាននៅក្នុងសវនាការ មន្ត្រីសង្កេតការណ៍សវនាការធ្វើការសង្កេតថា តើចៅក្រមបានប្រាប់ជនជាប់ចោទឲ្យបានដឹងអំពីសិទ្ធិជាមូលដ្ឋានមួយចំនួនដែរឬទេ។ សិទ្ធិមួយចំនួនទាមទារឲ្យមានការពន្យល់បន្ថែម ជាពិសេសនៅពេលដែលសិទ្ធិទាំងនេះមានអត្ថន័យបច្ចេកទេសច្បាប់។ ទិន្នន័យដែលបានមកពីការសង្កេតការណ៍សវនាការបានបែងចែកដាច់ពីគ្នារវាងការប្រាប់សិទ្ធិ និងការពន្យល់ប្រាប់សិទ្ធិ។ សវនាការចំនួន ៥៤ ត្រូវបានធ្វើឡើងដោយគ្មានវត្តមានជនជាប់ចោទ។ ដូច្នេះ ទិន្នន័យសម្រាប់សំណួរទី៥ នៃតារាងសង្កេតការណ៍សវនាការមិនត្រូវបានកត់ត្រាទេ នៅក្នុងសវនាការទាំងនេះ។

**តួលេខទី៦៖ ការពន្យល់ប្រាប់សិទ្ធិ**

| ៥(ក) តើចៅក្រមបានប្រាប់ (I) និងពន្យល់ (E) ជនជាប់ចោទពីសិទ្ធិមានតំណាងស្របច្បាប់ឬសិទ្ធិការពារខ្លួនដែរឬទេ ? | | | | |
|---|---|---|---|---|
| **ទិន្នន័យ** | **អំឡុងពេលរបាយការណ៍ទី១** | | **អំឡុងពេលរបាយការណ៍ទី២** | |
| | លេខ | % | លេខ | % |
| ប្រាប់ | ១០៨ | ៥៤ | ៣៥៤ | ៦៧ |
| ប្រាប់ និងពន្យល់ | ៧៥ | ៣៨ | ៥១ | ៩ |

| | | | | |
|---|---|---|---|---|
| គ្មានប្រាប់ និង គ្មានពន្យល់ | ១២ | ៦ | ៧៣ | ១៤ |
| មិនពាក់ព័ន្ធ | ៤ | ២ | ៥៤ | ១០ |
| ៥(ខ) តើចៅក្រមបានប្រាប់ (I) និងពន្យល់ (E) ជនជាប់ចោទពីសិទ្ធិនៅស្ងៀមដែរឬទេ ? | | | | |
| **ទិន្នន័យ** | **អំឡុងពេលរបាយការណ៍ទី១** | | **អំឡុងពេលរបាយការណ៍ទី២** | |
| | លេខ | % | លេខ | % |
| ប្រាប់ | ៧៤ | ៣៧ | ៨០ | ១៥ |
| ប្រាប់ និងពន្យល់ | ៣៨ | ១៩ | ១១ | ២ |
| គ្មានប្រាប់ និង គ្មានពន្យល់ | ៨៣ | ៤២ | ៣៨៧ | ៧៣ |
| មិនពាក់ព័ន្ធ | ៤ | ២ | ៥៤ | ១០ |
| ៥(គ) តើចៅក្រមបានប្រាប់ (I) និងពន្យល់ (E) ជនជាប់ចោទពីសិទ្ធិមិនឆ្លើយដាក់បន្ទុកខ្លួនឯងដែរ ឬទេ ? | | | | |
| **ទិន្នន័យ** | **អំឡុងពេលរបាយការណ៍ទី១** | | **អំឡុងពេលរបាយការណ៍ទី២** | |
| | លេខ | % | លេខ | % |
| ប្រាប់ | ១០៤ | ៥២ | ១៣៩ | ២៦ |
| ប្រាប់ និងពន្យល់ | ៥១ | ២៦ | ៩ | ២ |
| គ្មានប្រាប់ និង គ្មានពន្យល់ | ៤០ | ២០ | ៣៣០ | ៦២ |
| មិនពាក់ព័ន្ធ | ៤ | ២ | ៥៤ | ១០ |
| ៥(ឃ) តើចៅក្រមបានប្រាប់ (I) និងពន្យល់ (E) ជនជាប់ចោទពីសិទ្ធិផ្លាស់ប្តូរចៅក្រមជំនុំជម្រះដែរ ឬទេ ? | | | | |
| **ទិន្នន័យ** | **អំឡុងពេលរបាយការណ៍ទី១** | | **អំឡុងពេលរបាយការណ៍ទី២** | |
| | លេខ | % | លេខ | % |
| ប្រាប់ | ១២១ | ៦១ | ២៨១ | ៥៣ |
| ប្រាប់ និងពន្យល់ | ៦៣ | ៣២ | ៣៩ | ៧ |
| គ្មានប្រាប់ និង គ្មានពន្យល់ | ១១ | ៥ | ១៥៨ | ៣០ |
| មិនពាក់ព័ន្ធ | ៤ | ២ | ៥៤ | ១០ |

| ៥(ង) តើចៅក្រមបានប្រាប់ (I) និងពន្យល់ (E) ជនជាប់ចោទពីសិទ្ធិមានសំណូមពរចុងក្រោយដែរឬទេ ? | | | | |
|---|---|---|---|---|
| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | |
| | លេខ | % | លេខ | % |
| ប្រាប់ | ១២១ | ៦១ | ៣៣៧ | ៦៣ |
| ប្រាប់ និងពន្យល់ | ៦៧ | ៣៤ | ៤០ | ៨ |
| គ្មានប្រាប់ និង គ្មានពន្យល់ | ៧ | ៣ | ១០១ | ១៩ |
| មិនពាក់ព័ន្ធ | ៤ | ២ | ៥៤ | ១០ |

សំណួរ ៥(ច)និង ៥(គ) បានបង្ហាញនូវភាពខុសគ្នារវាងសិទ្ធិនៅស្ងៀមក្នុងសវនាការ សិទ្ធិមិនផ្តល់កសិណ ឬឆ្លើយសំណួរ និងសិទ្ធិមិនឆ្លើយដាក់ពិរុទ្ធខ្លួនឯង។ សិទ្ធិចុងក្រោយនេះ ជាសិទ្ធិដែលផ្តោតទៅលើសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យសារភាពពីពិរុទ្ធភាព ឬធ្វើពិរុទ្ធកម្មខ្លួនឯង។

ចំនួនសវនាការដែលចៅក្រមបានប្រាប់ ឬ បានប្រាប់និងពន្យល់ជនជាប់ចោទឲ្យបានដឹងអំពីសិទ្ធិជាមូលដ្ឋានរបស់ខ្លួន មានធ្លាក់ចុះយ៉ាងខ្លាំង បើប្រៀបធៀបទៅនឹងទិន្នន័យទទួលបាននៅក្នុងអំឡុងពេលរបាយការណ៍ទី១។ ទិន្នន័យនេះនឹងត្រូវបានវិភាគយ៉ាងលំអិតនៅក្នុងផ្នែកវិភាគទិន្នន័យ។

## សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីរៀបចំការពារក្តី

បុគ្គលដែលប្រឈមមុខនឹងបទចោទប្រកាន់ព្រហ្មទណ្ឌ ត្រូវទទួលបានពេលវេលានិងមធ្យោបាយគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងបទចោទប្រកាន់ប្រឆាំងខ្លួន។[34] និយមន័យនៃពាក្យថា ពេលវេលា "គ្រប់គ្រាន់" ត្រូវបានកំណត់ (ប្វូករូមនឹងកត្តាដទៃទៀត) ទៅតាមបទចោទប្រកាន់ និងភាពស្មុគស្មាញនៃរឿងក្តី។ សិទ្ធិនេះបង្កើតបានជាកាតព្វកិច្ចផ្តល់ការអនុញ្ញាតឲ្យពន្យារពេលសវនាការតាមសំណើនៅក្នុងករណីពិសេស ដូចជានៅពេលដែលជនជាប់ចោទត្រូវចោទពីបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរ ហើយចាំបាច់ឲ្យមានការបន្ថែមពេលវេលាដើម្បីរៀបចំការពារក្តី។[35] ការសម្របសម្រួលដែលជនជាប់ចោទត្រូវទទួលបាននៅក្រោមសិទ្ធិនេះ រួមមានការទទួលបានឯកសារនិងភស្តុតាងផ្សេងទៀត

[34] មាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ មាត្រា ៨ នៃគោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីតួនាទីរបស់មេធាវី។

[35] គណៈកម្មាធិការសិទ្ធិមនុស្ស - *ទស្សនៈនៃគណៈកម្មាធិការសិទ្ធិមនុស្សអំពីមាត្រា ៥ កថាខណ្ឌ ៤ នៃ ពិធីសារបន្ថែមស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ* - កថាខណ្ឌទី ៦.៣ នៃ*សេចក្តីជូនដំណឹងលេខ ៩១៣/២០០០៖ ចាន់ តទល់នឹង ហ្គូយ៉ាណា* (CCPR/C/85/D/913/2000) ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៦។ គណៈកម្មាធិការសិទ្ធិមនុស្ស - *ការអនុញ្ញាត៖* កថាខណ្ឌទី ៦.៨ នៃ*សេចក្តីជូនដំណឹងលេខ ៥៩៤/១៩៩២៖ ហ្វីលីព តទល់នឹង ទ្រីនីដាត និង តូបាហ្គោ* (CCPR/C/56/D/594/1992) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៦។

ដែលជនជាប់ចោទត្រូវការសម្រាប់ការពាររឿងក្ដីរបស់ខ្លួន ព្រមទាំងឱកាសជួប និងពិភាក្សាជាមួយមេធាវី។

**តួលេខទី៧៖ សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការពារក្ដី**

| ៦(ក) តើមានអ្វីមួយ ដែលបង្ហាញថា មេធាវីជនជាប់ចោទត្រូវបានចាត់តាំងនៅក្នុងថ្ងៃសវនាការដែរឬទេ ?[36] | | | |
|---|---|---|---|
| **ទិន្នន័យ** | | **អំឡុងពេលរបាយការណ៍ទី២** | |
| | | លេខ | % |
| មាន | | ៨ | ១,៥ |
| គ្មាន | | ៥២៤ | ៩៨,៥ |

សំណួរ ៦(ក) ចោទសួរថា តើចៅក្រម ក្រឡាបញ្ជី ឬមេធាវី មានបាននិយាយអ្វីដែលបង្ហាញថា មេធាវីជនជាប់ចោទត្រូវបានចាត់តាំងនៅក្នុងថ្ងៃសវនាការដែរឬទេ។ នៅក្នុងចំណោមសវនាការទាំងអស់ មានសវនាការចំនួន ៨ ដែលត្រូវបានមើលឃើញថាមេធាវីត្រូវបានចាត់តាំងនៅថ្ងៃសវនាការ ដូច្នេះមេធាវីទាំងនោះអាចនឹងមិនមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការការពារក្ដី។

## សិទ្ធិមានមេធាវី និងមានវត្តមាននៅក្នុងសវនាការ

គ្រប់បុគ្គលទាំងអស់ដែលត្រូវបានចោទប្រកាន់ពីបទល្មើសណាមួយ មានសិទ្ធិមានវត្តមាននៅក្នុងសវនាការ និងការពារដោយខ្លួនឯងផ្ទាល់ ឬតាមរយៈមេធាវីតាមការជ្រើសរើសរបស់ខ្លួន។[37] យោងតាមច្បាប់កម្ពុជា ជំនួយពីមេធាវីត្រូវមានជាចំខាត នៅពេលដែលរឿងក្ដីទាក់ទងនឹងបទឧក្រិដ្ឋ ឬ នៅពេលដែលជនជាប់ចោទជាអនីតិជន។[38] នីតិវិធីច្បាប់ និងរបៀបធ្វើការងារនៃតុលាការ អាចជារឿងចម្លែកមួយសម្រាប់ជនជាប់ចោទ ហើយធ្វើឲ្យពួកគេមានការភិតភ័យ។ ដើម្បីឲ្យការជំនុំជម្រះប្រព្រឹត្តទៅដោយយុត្តិធម៌ ជាការសំខាន់ណាស់ក្នុងការធានាថា ជនជាប់ចោទមានឱកាសអាចពឹងពាក់អ្នកជំនាញដែលមានលទ្ធភាពពន្យល់បទចោទប្រកាន់ប្រឆាំងនឹងខ្លួន - សិទ្ធិរបស់ពួកគេ ដឹកនាំពួកគេនៅក្នុងនីតិវិធីជំនុំជម្រះ ព្រមទាំងតំណាង និងការពារផលប្រយោជន៍ពួកគេនៅក្នុងសវនាការ។

---

[36] សំណួរ ៦(ក) មិនត្រូវបានដាក់បញ្ចូលនៅក្នុងតារាងសង្កេតការណ៍សវនាការនៅក្នុងអំឡុងពេលរបាយការណ៍ទី១ទេ។

[37] មាត្រា ១៤(៣)(ឃ) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ មាត្រា ៣០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

[38] មាត្រា ៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## តួលេខទី៨៖ សិទ្ធិមានមេធាវី និងមានវត្តមាននៅក្នុងសវនាការ

| ៧(ក) តើជនជាប់ចោទមានមេធាវីដែរឬទេ ? | | | | |
|---|---|---|---|---|
| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | |
| | លេខ | % | លេខ | % |
| មាន | ១៣៥ | ៦៨ | ៣១២ | ៥៩ |
| គ្មាន | ៦៤ | ៣២ | ២២០ | ៤១ |
| សវនាការបទឧក្រិដ្ឋ៖៧(ក)តើជនជាប់ចោទត្រូវបានតំណាងដោយមេធាវីដែរឬទេ ? | | | | |
| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | |
| | លេខ | % | លេខ | % |
| មាន | ១០០ | ៩៥ | ២៣៨ | ៩៧ |
| គ្មាន | ៥ | ៥ | ៧ | ៣ |
| សវនាការបទមជ្ឈឹម៖ ៧(ក)តើជនជាប់ចោទត្រូវបានតំណាងដោយមេធាវីដែរឬទេ ? | | | | |
| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | |
| | លេខ | % | លេខ | % |
| មាន | ៣៥ | ៣៧ | ៧៤ | ២៦ |
| គ្មាន | ៥៩ | ៦៣ | ២១៣ | ៧៤ |
| ៧(គ) តើជនជាប់ចោទត្រូវបានបណ្តេញចេញនៅក្នុងដំណាក់កាលណាមួយនៃនីតិវិធីសវនាការដែរឬទេ ? | | | | |
| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | |
| | លេខ | % | លេខ | % |
| មាន | ៣ | ២ | ១ | ០,២ |
| គ្មាន | ១៩២ | ៩៦ | ៤៧៧ | ៨៩,៦ |
| មិនពាក់ព័ន្ធ | ៤ | ២ | ៥៤ | ១០,២ |

ដូចដែលបានលើកឡើងខាងលើ សវនាការដែលក្នុងនោះជនជាប់ចោទត្រូវបានកាត់ទោសកំបាំងមុខ មានចំនួន ៥៤ ឬស្មើនឹង១០% នៃចំនួនសវនាការទាំងអស់ដែលបានសង្កេត។ ទិន្នន័យនេះបង្ហាញនូវការកើនឡើង ២% បើប្រៀបធៀបទៅនឹងទិន្នន័យនៃសវនាការដែលជនជាប់ចោទត្រូវបានកាត់ទោសកំបាំងមុខនៅក្នុងអំឡុងពេលរបាយការណ៍ទី១។ លើសពីនេះទៅទៀត នៅក្នុងសវនាការចំនួន៣១ ជនជាប់ចោទត្រូវបានកាត់ទោសកំបាំងមុខ ដោយគ្មានវត្តមានមេធាវី ដើម្បីតំណាងពួកគេនៅក្នុងសវនាការ និងការពារក្តី។

ចំនួនភាគរយនៃសវនាការដែលក្នុងនោះជនជាប់ចោទមានមេធាវី ធ្លាក់ចុះពី ៦៨% នៅក្នុងអំឡុងពេលរបាយការណ៍ទី១ មកនៅត្រឹម ៥៩% នៅក្នុងអំឡុងពេលរបាយការណ៍ទី២។ ប៉ុន្តែចំនួនភាគរយនៃសវនាការបទឧក្រិដ្ឋដែលក្នុងនោះជនជាប់ចោទមានមេធាវី នៅតែមានអាត្រាខ្ពស់ និងកើនឡើងពី ៩៥% ទៅ ៩៧%។ ការកើនឡើងនេះឆ្លុះបញ្ចាំងអំពីការគោរពមាត្រា ៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៅក្នុងករណីមួយចំនួនធំ នេះគឺជាភាពជោគជ័យនៃតុលាការដែលបានសង្កេតទាំងពីរ។ នៅក្នុងកិច្ចពិភាក្សាជាមួយចៅក្រម និងព្រះរាជអាជ្ញានៅឯតុលាការក្រុងភ្នំពេញ លោកព្រះរាជអាជ្ញា ហ៊ីង ប៊ុនជា បានលើកឡើងថា សវនាការមួយចំនួនដែលក្នុងនោះជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ហើយគ្មានមេធាវី អាចបណ្តាលមកពីជនជាប់ចោទបដិសេធមិនចង់បានមេធាវី មេធាវីអវត្តមានដោយមិនបានជូនដំណឹងជាមុន និងសំពាធដាច់ខាតត្រូវជំនុំជម្រះដោយសារតែជនជាប់ចោទត្រូវបានឃុំខ្លួនបណ្តោះអាសន្នក្នុងរយៈពេលយូរ។[39] ប៉ុន្តែ ចំនួនភាគរយសវនាការដែលក្នុងនោះជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទមជ្ឈឹម ហើយមានមេធាវី បានធ្លាក់ចុះពី ៣៧% មកនៅត្រឹម ២៦%។

## សិទ្ធិទទួលបានការសន្មត់ទុកជាមុនថាគ្មានទោស

បុគ្គលគ្រប់រូបដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ មានសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស រហូតដល់ពេលដែលពិរុទ្ធភាពត្រូវបានបង្ហាញតាមច្បាប់។[40] នេះគឺជាសិទ្ធិមូលដ្ឋានមួយក្នុងចំណោមសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលត្រូវបានទទួលស្គាល់ជាសកល ដូច្នេះទាមទារឲ្យមានការយកចិត្តទុកដាក់ដោយបុគ្គលទាំងអស់ ដែលចូលរួមនៅគ្រប់ដំណាក់នៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ ទិន្នន័យនៃតួលេខ ទី៩ បង្ហាញថា តើជនជាប់ចោទអាចត្រូវបានចាត់ទុកថាមានពិរុទ្ធភាពនៅមុនពេលប្រកាសសាលក្រមដែរឬទេ និង/ឬ តើកត្តាណាខ្លះដែលអាចជះឥទ្ធិពលលើការសន្មតទុកជាមុនរបស់ចៅក្រមអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។

---

[39] កិច្ចប្រជុំពិភាក្សាជាមួយអ្នកស្រីចៅក្រម ចាំង ស៊ីណាត លោកចៅក្រមសេង នាង និងលោកព្រះរាជអាជ្ញាហ៊ីង ប៊ុនជា នៅតុលាការក្រុងភ្នំពេញ កាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១០។

[40] មាត្រា ១១(១) នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។ មាត្រា ១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ។ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ៖ *"វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។"*

## តួលេខទី៩៖ ការសន្មតទុកជាមុនថាគ្មានទោស

**៨(ក) តើជនជាប់ចោទស្លៀកពាក់ឯកសណ្ឋានអ្នកទោសដែរឬទេ?**[41]

| **ទិន្នន័យ** | | **អំឡុងពេលរបាយការណ៍ទី២** | |
|---|---|---|---|
| | | លេខ | % |
| មាន | | ៣១៨ | ៦០ |
| គ្មាន | | ១៦០ | ៣០ |
| មិនពាក់ព័ន្ធ | | ៥៤ | ១០ |

**៨(ខ) តើជនជាប់ចោទត្រូវបានដាក់ខ្នោះនៅក្នុងពេលសវនាការដែរឬទេ ?**

| **ទិន្នន័យ** | **អំឡុងពេលរបាយការណ៍ទី១** | | **អំឡុងពេលរបាយការណ៍ទី២** | |
|---|---|---|---|---|
| | លេខ | % | លេខ | % |
| មាន | ០ | ០ | ០ | ០ |
| គ្មាន | ១៩៥ | ៩៨ | ៤៧៨ | ៩០ |
| មិនពាក់ព័ន្ធ | ៤ | ២ | ៥៤ | ១០ |

**៨(គ) តើចៅក្រមបាននិយាយពីភាពមានទោស/គ្មានទោសរបស់ជនជាប់ចោទមុនពេលប្រកាសសាលក្រមដែរឬទេ ?**

| **ទិន្នន័យ** | **អំឡុងពេលរបាយការណ៍ទី១** | | **អំឡុងពេលរបាយការណ៍ទី២** | |
|---|---|---|---|---|
| | លេខ | % | លេខ | % |
| មាន | ២០ | ១០ | ៥ | ១ |
| គ្មាន | ១៧៩ | ៩០ | ៥២៧ | ៩៩ |

**៨(ឃ) តើមានអ្វីមួយដែលបង្ហាញថាចៅក្រមរើសអើងជនជាប់ចោទ ដោយសារបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទដែរឬទេ ?**

| **ទិន្នន័យ** | **អំឡុងពេលរបាយការណ៍ទី១** | | **អំឡុងពេលរបាយការណ៍ទី២** | |
|---|---|---|---|---|
| | លេខ | % | លេខ | % |
| មាន | ១១ | ៦ | ១ | ០,១៨ |
| គ្មាន | ១៨៨ | ៩៤ | ៥៣១ | ៩៩,៨២ |

ទិន្នន័យនៃសំណួរ ៨(ក) បង្ហាញថា មានសវនាការចំនួនជាងពាក់កណ្តាល ដែលក្នុងនោះជនជាប់ចោទស្លៀកពាក់ឯកសណ្ឋានជាអ្នកទោស។ ការណ៍នេះបណ្តាលឲ្យខូចប្រយោជជនជាប់ចោទ

[41] សំណួរ ៨(ក) មិនត្រូវបានដាក់បញ្ចូលនៅក្នុងតារាងសង្កេតការណ៍សវនាការដែលប្រើនៅក្នុងអំឡុងពេលរបាយការណ៍ទី១ នោះទេ។

យ៉ាងខ្លាំង ព្រោះឯកសណ្ឋាននេះបង្ហាញថាជនជាប់ចោទមានពិរុទ្ធភាពរួចទៅហើយ។ ទិន្នន័យនៃសំណួរ៨(ខ) បង្ហាញថាទាំងនៅក្នុងអំឡុងពេលរបាយការណ៍ទី១ ទាំងនៅក្នុងអំឡុងពេលរបាយការណ៍ទី២ គ្មានករណីណាមួយដែលជនជាប់ចោទត្រូវបានដាក់ខ្នោះដៃឡើយ នៅក្នុងសវនាការនៃតុលាការដែលបានសង្កេត។ ជាទូទៅ ជនជាប់ចោទមិនគួរជាប់ខ្នោះឡើយនៅក្នុងសវនាការ លើកលែងតែក្នុងករណី ដែលទាមទារឲ្យមានការរក្សាសន្តិសុខ ព្រោះការធ្វើរបៀបនេះបណ្តាលឲ្យមានការយល់ឃើញថាបុគ្គលនោះមានពិរុទ្ធភាព និងជាឧក្រិដ្ឋជនម្នាក់ដ៏មានគ្រោះថ្នាក់។ ទិន្នន័យនៅក្នុងផ្នែកនេះមានលក្ខណៈល្អប្រសើរនៅក្នុងអំឡុងពេលរបាយការណ៍ទាំងពីរ ហើយបង្ហាញថាតុលាការដែលបានសង្កេតមិនបានអនុវត្តការដាក់ខ្នោះជនជាប់ចោទនោះទេ។

ចំពោះសំណួរ ៨(គ) ទិន្នន័យបង្ហាញថា មានសវនាការចំនួន ៥ ដែលក្នុងនោះចៅក្រមត្រូវបានគេមើលឃើញថា បាននិយាយអំពីភាពមាន ឬគ្មានទោសរបស់ជនជាប់ចោទនៅមុនពេលប្រកាសសាលក្រម។ ទិន្នន័យនេះមានចំនួនតិចជាង ១% នៃចំនួនសវនាការទាំងអស់ដែលបានសង្កេតនៅក្នុងអំឡុងពេលរបាយការណ៍ទី២ និងបង្ហាញពីការធ្លាក់ចុះពីចំនួន ១០% នៅក្នុងអំឡុងពេលរបាយការណ៍ទី១ នេះគឺជាលទ្ធផលវិជ្ជមានមួយទៀត។ នៅក្នុងករណីទី១ ចៅក្រមបានសួរទៅជនជាប់ចោទថា "*នៅអាយុប៉ុន្នេះ អ្នកឯងលួចទ្រព្យសម្បត្តិអ្នកដទៃ?*"។ នៅក្នុងករណីទី២ ចៅក្រមបានប្រាប់ជនជាប់ចោទថា "*ទោះបីជាអ្នកឯងខំនិយាយយ៉ាងណាក៏ដោយ ក៏អ្នកឯងជាប់គុកដែរ*"។ នៅក្នុងករណីទី៣ ចៅក្រមបានចោទជនជាប់ចោទថាកុហក ដោយនិយាយថា "*ចោរតែងតែនិយាយកុហក*"។ នៅក្នុងករណីទី៤ ចៅក្រមបានលើកឡើងអំពីប្រវត្តិប្រព្រឹត្តបទល្មើសរបស់ជនជាប់ចោទ ដោយនិយាយថា "*អាជីពរបស់អ្នកឯងគឺចោរ*"។ នៅក្នុងករណីទី៥ ចៅក្រមបានបង្គាប់ឲ្យជនជាប់ចោទរៀបរាប់ដោយសង្ខេបអំពីការប្រព្រឹត្ត "*បទល្មើស*" ដោយសន្មតជាមុនថាជនជាប់ចោទបានប្រព្រឹត្តបទល្មើស។

ចំពោះសំណួរ ៨(ឃ) ចៅក្រមត្រូវបានគេឮនិយាយថា "*ជនជាប់មានទោសដោយសារតែជននេះមានបញ្ហាផ្លូវចិត្ត*"។

**តួលេខទី១០៖ ការទាញយកពិរុទ្ធភាព**

| ៩(ង) តើមានអ្វីមួយដែលបង្ហាញថាចៅក្រមទាញពិរុទ្ធភាពអំពីការនៅស្ងៀមរបស់ជនជាប់ចោទដែរឬទេ? | | | | |
|---|---|---|---|---|
| **ទិន្នន័យ** | **អំឡុងពេលរបាយការណ៍ទី១** | | **អំឡុងពេលរបាយការណ៍ទី២** | |
| | លេខ | % | លេខ | % |
| មាន | ៣ | ២ | ០ | ០ |
| គ្មាន | ១៩៦ | ៩៨ | ៩១ | ១៧ |
| មិនពាក់ព័ន្ធ | ០ | ០ | ៤៤១ | ៨៣ |

ការកែប្រែតារាងសង្កេតការណ៍សវនាការនៅក្នុងអំឡុងពេលរបាយការណ៍ នាំឲ្យទិន្នន័យនៃសំណួរ ៩(ង) មានភាពខុសគ្នាគួរឲ្យកត់សម្គាល់។ តារាងសង្កេតការណ៍សវនាការដែលបានប្រើប្រាស់នៅក្នុងអំឡុងពេលរបាយការណ៍ទី២ បានបញ្ចូលទិន្នន័យ "មិនពាក់ព័ន្ធ" ។ ទិន្នន័យនេះត្រូវបានប្រើប្រាស់នៅក្នុងករណីដែលចៅក្រមមិនបានប្រាប់ជនជាប់ចោទអំពីសិទ្ធិនៅស្ងៀមនៅក្នុងសវនាការ ឬនៅពេលដែលជនជាប់ចោទត្រូវបានជំនុំជម្រះកំបាំងមុខ។ នៅក្នុងចំណោមសវនាការដែលបានសង្កេត គ្មានករណីណាមួយដែលបង្ហាញថាចៅក្រមទាញយកពិរុទ្ធភាពពីភាពនៅស្ងៀមរបស់ជនជាប់ចោទនោះទេ។

## សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយតុលាការមួយឯករាជ្យ មិនលំអៀង និងប្រកបដោយវិជ្ជាជីវៈ

សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការមួយឯករាជ្យ និងមិនលំអៀង គឺជាសិទ្ធិជាមូលដ្ឋាន ដែលគណៈកម្មាធិការសិទ្ធិមនុស្សបានលើកឡើងថា "ជាសិទ្ធិមួយដាច់ខាត គ្មានករណីលើកលែង។"[42] ភាពយុត្តិធម៌នៃប្រព័ន្ធតុលាការ ពឹងផ្អែកលើភាពឯករាជ្យ និងមិនលំអៀងរបស់ស្ថាប័ននេះ។ ភាពឯករាជ្យនៃតុលាការទាមទារឲ្យដំណើរការចេញសេចក្តីសម្រេចមានតម្លាភាព មានមូលដ្ឋានច្បាស់លាស់ និងផ្អែកលើអត្ថបទច្បាប់ យុត្តិសាស្ត្រ សេចក្តីណែនាំ និងក្រមសីលធម៌។ ដើម្បីធានាភាពឯករាជ្យនេះ និន្នាការនយោបាយ ផលប្រយោជន៍ផ្ទាល់ខ្លួន និងទំនាក់ទំនងផ្សេងៗ មិនត្រូវមានឥទ្ធិពលលើការចេញសេចក្តីសម្រេចរបស់តុលាការឡើយ។

**តួលេខទី១១៖ ភាពឯករាជ្យ និងមិនលំអៀងរបស់ចៅក្រម**

| ៩(ក) តើចៅក្រមដើរតួនាទីជាភាគីផ្សេងទៀតដែរឬទេ នៅក្នុងនីតិវិធីសវនាការ? | | | | |
|---|---|---|---|---|
| **ទិន្នន័យ** | **អំឡុងពេលរបាយការណ៍ទី១** | | **អំឡុងពេលរបាយការណ៍ទី២** | |
| | លេខ | % | លេខ | % |
| មាន | 0 | 0 | 0 | 0 |
| គ្មាន | ១៩៩ | ១០០ | ៥៣២ | ១០០ |
| **៩(គ) តើមានអ្វីមួយដែលបង្ហាញថា ភាគីណាមួយបាននិយាយជាមួយចៅក្រមនៅក្នុងអំឡុងពេលពិភាក្សាចេញសេចក្តីសម្រេច ដែរឬទេ?** | | | | |
| **ទិន្នន័យ** | **អំឡុងពេលរបាយការណ៍ទី១** | | **អំឡុងពេលរបាយការណ៍ទី២** | |

[42] គណៈកម្មាធិការសិទ្ធិមនុស្ស - *ទស្សនៈនៃគណៈកម្មាធិការសិទ្ធិមនុស្សចំពោះមាត្រា៥ កថាខណ្ឌ៤ នៃពិធីសារបន្ថែមរបស់កតិកាសញ្ញាអន្តរជាតិនៃសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ* កថាខណ្ឌ ៥.២ នៃ *សេចក្តីជូនដំណឹងលេខ ២៦៣/១៩៨៧៖ លោក ហ្គនហ្សាឡេស ដេល រីយ៉ូ ជាមួយនឹង ប៉េរូ* (CCPR/C/46/D/263/1987) ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩២ ។

| | | | | |
|---|---|---|---|---|
| មាន | ៣២ | ១៦ | ៣៤ | ៦ |
| គ្មាន | ១៦៧ | ៨៤ | ៤៩៨ | ៩៤ |

មាត្រា៥៥ និង ២៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានហាមឃាត់មិនឲ្យចៅក្រមជំនុំជម្រះរឿងក្ដីដែលខ្លួនដើរតួនាទីជាចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង។ គ្មានសវនាការណាមួយដែលចៅក្រមជំនុំជម្រះដើរតួនាទីមួយផ្សេងទៀតនៅក្នុងរឿងក្ដីតែមួយឡើយ។ ការរកឃើញនេះមានលក្ខណៈដូចទៅនឹងទិន្នន័យនៅក្នុងអំឡុងពេលរបាយការណ៍ទី១ដែរ។

ទិន្នន័យនៃសំណួរទី៩(គ) បង្ហាញអំពីការថយចុះនៃចំនួនភាគរយសវនាការ ដែលក្នុងនោះភាគីនៃនីតិវិធី ឬក្រឡាបញ្ជី ត្រូវបានគេមើលឃើញថា បាននិយាយជាមួយចៅក្រមនៅក្នុងអំឡុងពេលពិភាក្សាសម្រេចរបស់តុលាការ។ តំណាងគម្រោងបានជួបជាមួយចៅក្រមតុលាការក្រុងភ្នំពេញនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១០ ដើម្បីពិភាក្សាអំពីលទ្ធផលដែលបានរកឃើញ និងអនុសាសន៍នានាដែលមាននៅក្នុងរបាយការណ៍ប្រចាំឆមាសទី១។ ឆ្លើយតបទៅនឹងទិន្នន័យ និងអនុសាសន៍ដែលបានផ្ដល់ឲ្យទាក់ទងនឹងសំណួរ៩(គ) ចៅក្រមបានកត់សម្គាល់ថា តុលាការក្រុងភ្នំពេញមានបន្ទប់ដាច់ដោយឡែក សម្រាប់ចៅក្រមពិភាក្សាសម្រេចសេចក្ដី ។ ចៅក្រមបានលើកឡើងថា ក្រៅពីក្រឡាបញ្ជីដែលពេលខ្លះចូលក្នុងបន្ទប់នេះ ក្នុងគោលបំណងយកឯកសារជូនចៅក្រម ដើម្បីពិចារណាសម្រេចសេចក្ដី គ្មានភាគីណាមួយត្រូវបានអនុញ្ញាតឲ្យចូលក្នុងបន្ទប់ពិភាក្សាសម្រេចសេចក្ដី នៅមុនពេលចៅក្រមប្រកាសសាលក្រមឡើយ។ នៅក្នុងការសង្កេតសវនាការលើកក្រោយ សំណួរ៩(គ) នឹងត្រូវកែប្រែដើម្បីបែងចែករវាងករណីដែលមនុស្សចូលក្នុងបន្ទប់ពិភាក្សា ឬនិយាយទៅកាន់ចៅក្រមជាក្រឡាបញ្ជី ឬអ្នកជំនួយការដទៃទៀត និងករណីដែលបុគ្គលនោះជាភាគីនៃនីតិវិធី ដូចជាព្រះរាជអាជ្ញា។

ការសង្កេតចៅក្រមប្រើប្រាស់ទូរស័ព្ទដៃនៅក្នុងពេលសវនាការ នៅក្នុងអំឡុងពេលរបាយការណ៍ទី១ បានចាប់ផ្ដើមពាក់កណ្ដាលផ្លូវ គឺនៅក្រោយពេលដែលមន្ត្រីសង្កេតការណ៍សវនាការមើលឃើញថាការប្រើប្រាស់ទូរស័ព្ទនៅក្នុងសវនាការនេះជាទម្លាប់ទូទៅ។ ដូច្នេះ យើងប្រមូលបានទិន្នន័យពីសវនាការចំនួនត្រឹមតែ ៦០ ប៉ុណ្ណោះ នៅក្នុងចំណោមសវនាការដែលបានសង្កេតចំនួន ១៩៩។

**តួលេខទី១២៖ ចៅក្រមប្រើទូរស័ព្ទដៃនៅក្នុងសវនាការ**

| ១៨ តើចៅក្រមនិយាយទូរស័ព្ទដៃរឬទេ ក្នុងអំឡុងពេលសវនាការ? | | | | |
|---|---|---|---|---|
| **ទិន្នន័យ** | **អំឡុងពេលរបាយការណ៍ទី១** | | **អំឡុងពេលរបាយការណ៍ទី២** | |
| | លេខ | % | លេខ | % |
| មាន | ១៧ | ២៨ | ១៥១ | ២៨ |
| គ្មាន | ៤៣ | ៧២ | ៣៨១ | ៧២ |

ទិន្នន័យនៃសំណួរ១៨ បានបង្ហាញថា ការប្រើប្រាស់ទូរស័ព្ទ នៅតែជាទម្លាប់ទូទៅនៅក្នុងអំឡុងពេលរបាយការណ៍ទី២ ភាគរយនៃសវនាការដែលក្នុងនោះចៅក្រមឆ្លើយទូរស័ព្ទមានចំនួនដូចគ្នា។ ការណ៍នេះធ្វើឲ្យមានការព្រួយបារម្ភថា តើចៅក្រមម្នាក់ដែលឆ្លើយ ឬនិយាយទូរស័ព្ទ អាចផ្តោតការយកចិត្តទុកដាក់គ្រប់គ្រាន់ទៅលើអំណះអំណាងរបស់ភាគី និងភស្តុតាងដែលត្រូវបានបង្ហាញដែរឬទេ។ ដូចដែលបានលើកឡើងនៅក្នុងរបាយការណ៍ប្រចាំឆមាសទី១ ការប្រើប្រាស់ទូរស័ព្ទដៃនៅក្នុងសវនាការ ក៏អាចជះឥទ្ធិពលទៅលើភាពជឿជាក់របស់សាធារណជនទៅលើតុលាការ ដោយបង្កជាកង្វល់ថា ចៅក្រមទទួលឥទ្ធិពលពីភាគីខាងក្រៅ នៅក្នុងពេលដំណើរការនីតិវិធី។

ឆ្លើយតបទៅនឹងទិន្នន័យ និងអនុសាសន៍ ដែលទាក់ទងទៅនឹងការប្រើប្រាស់ទូរស័ព្ទដៃក្នុងពេលសវនាការ ចៅក្រមតុលាការក្រុងភ្នំពេញបានបញ្ជាក់ថា ចៅក្រមត្រូវតែអាចទាក់ទងបាននៅក្នុងពេលសវនាការ ពីព្រោះពួកគេដើរតួនាទីជាចៅក្រមស៊ើបសួរនៅក្នុងសំណុំរឿងមួយផ្សេងទៀត ហើយត្រូវទាក់ទងដោយនគរបាលយុត្តិធម៌ ដើម្បីសម្រេចលើការស៊ើបអង្កេត។ នៅពេលដែលករណីនេះជាគោលបំណងនៃការទាក់ទងតាមទូរស័ព្ទភាគច្រើន ការទទួលបានភាពយុត្តិធម៌នៅក្នុងសវនាការមួយមិនអាចត្រូវបានទម្លាក់ស្តង់ដារ ដើម្បីចាត់ការការស៊ើបអង្កេតក្នុងរឿងក្តីមួយទៀតនោះឡើយ។ បុគ្គលិកតុលាការដទៃទៀតគួរតែប្រមូលការផ្តាំផ្ញើនានា ទុកឲ្យចៅក្រមឆ្លើយតបនៅពេលដែលសវនាការបានបញ្ចប់។

## សិទ្ធិបង្ហាញភស្តុតាង (រួមទាំងសិទ្ធិហៅ និងសាកសួរសាក្សី)

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ក៏ផ្សារភ្ជាប់ផងដែរទៅនឹងគោលការណ៍ស្មើភាពគ្នា ដែលក្នុងនោះជនណាក៏ដោយដែលជាភាគីក្នុងរឿងក្តី ត្រូវមានឱកាសគ្រប់គ្រាន់ដើម្បីបង្ហាញរឿងក្តីរបស់ខ្លួនទៅតុលាការស្របតាមលក្ខខណ្ឌដែលថា ជននោះមិនត្រូវបានដាក់នៅក្នុងស្ថានភាពមិនស្មើគ្នាបើប្រៀបធៀបទៅនឹងភាគីម្ខាងទៀត។[43] ខណៈដែលតុលាការត្រូវចេញសេចក្តីសម្រេចដោយពឹងផ្អែកលើភស្តុតាងតែមួយមុខនោះ គ្រប់ភាគីពាក់ព័ន្ធទាំងអស់ត្រូវមានឱកាសស្មើគ្នាក្នុងការបង្ហាញភស្តុតាង ដើម្បីគាំទ្ររឿងក្តីរបស់ខ្លួន។[44] ជាទូទៅភស្តុតាងមាន ៣ ប្រភេទ (១) សក្ខីភាពសាក្សី (ដូចជាកំណត់ហេតុពីបុគ្គលដែលបានឃើញហេតុការណ៍) (២) ការបង្ហាញឯកសារ (ដូចជាប័ណ្ណកម្មសិទ្ធិដីធ្លី) និង/ឬ (៣) វត្ថុតាង (ដូចជាអាវុធប្រឡាក់ឈាម)។

[43] មាត្រា១៤ (៣)(ង) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។

[44] មាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**តួលេខទី១៣៖ ភស្តុតាង**

| ១០(ក) តើភស្តុតាងត្រូវបានបង្ហាញដែរឬទេ ? | | | | |
|---|---|---|---|---|
| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | |
| | លេខ | % | លេខ | % |
| មាន | ១៥៣ | ៧៧ | ៥១២ | ៩៦ |
| គ្មាន | ៤៦ | ១៣ | ២០ | ៤ |
| **១០(ខ) តើមានអ្វីមួយដែលបង្ហាញថាភាគីណាមួយមិនបានទទួលឱកាសបង្ហាញភស្តុតាងដែរឬទេ ?** | | | | |
| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | |
| | លេខ | % | លេខ | % |
| មាន | ៣ | ២ | ៣ | ១ |
| គ្មាន | ១៩៦ | ៩៨ | ៥២៩ | ៩៩ |

ទិន្នន័យនៃសំណួរ១០(ក) បង្ហាញថា ភស្តុតាងដែលត្រូវបានបង្ហាញនៅក្នុងអំឡុងពេលរបាយការណ៍ទី២ មានអត្រាខ្ពស់ជាងទិន្នន័យនៅក្នុងអំឡុងពេលរបាយការណ៍ទី១។ នេះគឺជាការផ្លាស់ប្តូរវិជ្ជមានមួយ។ ប៉ុន្តែក្នុងចំណោមសវនាការដែលបានសង្កេតទាំងអស់ នៅមានសវនាការមួយចំនួន (១%) ដែលក្នុងនោះភាគីមួយត្រូវបានបដិសេធមិនផ្តល់ឱកាសឲ្យបង្ហាញភស្តុតាង។ ទិន្នន័យទាក់ទងនឹងប្រភេទនៃភស្តុតាងដែលត្រូវបានបង្ហាញនៅក្នុងតុលាការដែលបានសង្កេតនីមួយៗ នឹងត្រូវបានវិភាគលំអិតនៅក្នុងផ្នែកវិភាគទិន្នន័យ។

ទាក់ទងទៅនឹងគោលការណ៍ស្មើភាពគ្នា ភាគីនីមួយៗមានសិទ្ធិហៅសាក្សី ដើម្បីផ្តល់សក្ខីភាពគាំទ្ររឿងក្តីរបស់ខ្លួន និងសាកសួរសាក្សីដែលហៅដោយភាគីដទៃទៀតនៃរឿងក្តី។[45]ជនជាប់ចោទមានសិទ្ធិហៅ និងសាកសួរសាក្សីរបស់ខ្លួនក្នុងលក្ខខណ្ឌដូចគ្នាទៅនឹងសាក្សីដាក់បន្ទុកខ្លួន។[46] សិទ្ធិនេះមិនគួរត្រូវបានបកស្រាយថាជាសិទ្ធិដែលគ្មានព្រំដែន អាចបង្ខំសាក្សីឲ្យចូលរួមសវនាការ ឬជាសិទ្ធិដែលអាចហៅសាក្សីដោយមិនកំណត់ចំនួននោះទេ។ មាត្រា ៣២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបញ្ជាក់ថាសាក្សីគួរតែនៅក្នុងបន្ទប់រង់ចាំរហូតដល់ពេលត្រូវបានហៅទៅសាកសួរ ហើយសាក្សីមិនគួរមើលឃើញ ឬស្តាប់ឮអ្វីដែលកើតឡើងនៅក្នុងបន្ទប់សវនាការ នៅមុនពេលផ្តល់សក្ខីភាពនោះទេ។ នៅក្នុងបន្ទប់រង់ចាំ សាក្សីមិនអនុញ្ញាតឲ្យទាក់ទងជាមួយសាក្សីដទៃទៀតនោះទេ។[47] បទប្បញ្ញត្តិទាំង

---

[45] មាត្រា១៤(៣)(ង) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។ មាត្រា២៩៨ ៣២៤ និង៣២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

[46] មាត្រា ១៤(៣)(ង) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។

[47] មាត្រា ៣២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

នេះ មានគោលដៅជៀសវាងនូវករណី ដែលសាក្សីយកលំនាំតាម ឬក្លែងសក្ខីភាពឲ្យស្របតាមដំណើរនៃរឿងក្តី។

**តួលេខទី១៤៖ សិទ្ធិហៅ និងសាកសួរសាក្សី**

| ១១(ក) តើមានអ្វីមួយដែលបង្ហាញថាភាគីណាមួយមិនបានទទួលឱកាសហៅសាក្សីដែរឬទេ ? | | | | |
|---|---|---|---|---|
| **ទិន្នន័យ** | **អំឡុងពេលរបាយការណ៍ទី១** | | **អំឡុងពេលរបាយការណ៍ទី២** | |
| | លេខ | % | លេខ | % |
| មាន | ៤ | ២ | ១ | ០,១៨ |
| គ្មាន | ១៩៥ | ៩៨ | ៥៣១ | ៩៩,៨២ |
| **១១(ខ) តើមានអ្វីមួយដែលបង្ហាញថាភាគីណាមួយមិនបានទទួលឱកាសសាកសួរសាក្សីដែរឬទេ ?** | | | | |
| **ទិន្នន័យ** | **អំឡុងពេលរបាយការណ៍ទី១** | | **អំឡុងពេលរបាយការណ៍ទី២** | |
| | លេខ | % | លេខ | % |
| មាន | ០ | ០ | ៣ | ០,៦ |
| គ្មាន | ៥៨ | ២៩ | ៧៩ | ១៤,៤ |
| មិនពាក់ព័ន្ធ | ១៤១ | ៧១ | ៤៥០ | ៨៥ |
| **១១(គ) តើសាក្សីស្ថិតនៅក្នុងបន្ទប់សវនាការដែរឬទេ នៅមុនពេលសាកសួរ ?** | | | | |
| **ទិន្នន័យ** | **អំឡុងពេលរបាយការណ៍ទី១** | | **អំឡុងពេលរបាយការណ៍ទី២** | |
| | លេខ | % | លេខ | % |
| មាន | ១០ | ៥ | ២៨ | ៥ |
| គ្មាន | ៤៨ | ២៤ | ៥៤ | ១០ |
| មិនពាក់ព័ន្ធ | ១៤១ | ៧១ | ៤៥០ | ៨៥ |

នៅក្នុងចំណោមសវនាការដែលបានសង្កេតក្នុងអំឡុងពេលរបាយការណ៍ទី២ មានសវនាការមួយចំនួន (តិចជាង ១%) បង្ហាញថាភាគីម្ខាងមិនបានទទួលឱកាសហៅសាក្សី។ សាក្សីមានវត្តមាននៅក្នុងសវនាការចំនួន ៨២ (ស្មើនឹង១៥%) នៃចំនួនសវនាការដែលបានសង្កេតទាំងអស់ចំនួន ៥៣២។ នៅក្នុងចំណោមសវនាការចំនួន ៨២ នេះ មានសវនាការចំនួន ៤ ដែលក្នុងនោះមានការបង្ហាញថាភាគីម្ខាងមិនបានទទួលឱកាសសាកសួរសាក្សី។ ការធ្វើរបៀបនេះគឺរំលោភលើមាត្រា ១៤(៣)(ង) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ នៅក្នុងចំណោមសវនាការចំនួន ៨២នេះផងដែរ មានសវនាការចំនួន ២៨ ដែលក្នុងនោះសាក្សីត្រូវផ្តល់សក្ខីភាពមានវត្តមាននៅក្នុងបន្ទប់សវនាការនៅមុនពេលសាកសួរ។

ចំពោះសំណួរ ១១(ក) ជនជាប់ចោទមានបំណងចង់ឲ្យភាគីរដ្ឋប្បវេណីដែលបានដាក់ពាក្យបណ្តឹង បង្ហាញខ្លួននៅចំពោះមុខតុលាការ ដើម្បីឲ្យខ្លួនអាចតទល់នឹងភស្តុតាងដែលភាគីដាក់ចូលនៅក្នុងពាក្យបណ្តឹង។ ចៅក្រមបានបដិសេធមិនទទួលស្គាល់ថាជនជាប់ចោទត្រូវការហៅភាគីរដ្ឋប្បវេណីឲ្យមកធ្វើជាសាក្សី។

ចំពោះសំណួរ ១១(ខ) នៅក្នុងករណីទី១ ជនជាប់ចោទមិនត្រូវបានអនុញ្ញាតឲ្យសាកសួរសាក្សី។ ចៅក្រមបានបដិសេធសំណើរបស់មេធាវីជនជាប់ចោទសុំសាកសួរសាក្សី។ ករណីទី២ នៅពេលដែលមេធាវីជនជាប់ចោទស្នើសុំសាកសួរសាក្សីខាងជនជាប់ចោទ ចៅក្រមបានបដិសេធ ហើយបង្គាប់ឲ្យសាក្សីចាកចេញពីបន្ទប់សវនាការ។ ករណីទី៣ ចៅក្រមបានហៅសាក្សីឲ្យផ្តល់សក្ខីភាព និងធ្វើការសាកសួរ ហើយបានអនុញ្ញាតឲ្យសាក្សីនោះចាកចេញ ដោយមិនបានផ្តល់ឱកាសឲ្យភាគីជនជាប់ចោទ ឬព្រះរាជអាជ្ញាសាកសួរសាក្សីឡើយ។

## សិទ្ធិទទួលដឹងពូភស្តុតាង

សិទ្ធិទទួលដឹងពូភស្តុតាង គឺជាសិទ្ធិរបស់ភាគីទាំងអស់ទទួលបានឯកសារទាំងអស់ និងដឹងពូភស្តុតាងទាំងអស់ដែលទាក់ទងនឹងរឿងក្តី។ ឯកសារសំខាន់ៗ គឺជាសំណុំរឿងដែលរៀបចំដោយចៅក្រមស៊ើបសួរ និងដីកាចោទប្រកាន់ដែលត្រូវបានបញ្ជូនទៅឲ្យប្រធានតុលាការដើម្បីកំណត់កាលបរិច្ឆេទសវនាការជំនុំជម្រះ។ សំណុំរឿងនេះមានភស្តុតាងទាំងអស់ដែលប្រមូលបាន និងសេចក្តីសន្និដ្ឋានរបស់ចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរមានករណីយកិច្ចប្រមូលទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក នៅក្នុងពេលបំពេញកិច្ចស៊ើបសួរ។[48]សិទ្ធិទទួលដឹងពូភស្តុតាង ដើម្បីការពារក្តីរួមបញ្ចូលទាំងសិទ្ធិមេធាវីជនជាប់ចោទម្នាក់ពិនិត្យភស្តុតាងដែលដាក់បន្ទុកកូនក្តីរបស់ខ្លួន (នៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី)។[49]

**តួលេខទី១៥៖ សិទ្ធិទទួលដឹងពូភស្តុតាង**

| **១២(ក) តើមានអ្វីមួយដែលបង្ហាញថាភាគីណាមួយមិនបានដឹងពូអំពីភស្តុតាងរបស់ភាគីម្ខាងទៀតដែរឬទេ ?** | | | | |
|---|---|---|---|---|
| **ទិន្នន័យ** | **អំឡុងពេលរបាយការណ៍ទី១** | | **អំឡុងពេលរបាយការណ៍ទី២** | |
| | លេខ | % | លេខ | % |
| មាន | ៣ | ២ | ៤ | ១ |
| គ្មាន | ១៩៦ | ៩៨ | ៥២៨ | ៩៩ |

[48] មាត្រា ១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

[49] មាត្រា៣១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ មាត្រា ១៤(៣)(ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

នៅក្នុងចំណោមសវនាការដែលបានសង្កេត មានសវនាការចំនួន ៩ ដែលបង្ហាញថា ភាគីម្ខាងមិនបានដឹងពួភស្តុតាងរបស់ភាគីម្ខាងទៀត។ ទិន្នន័យនេះស្មើនឹង ១% នៃចំនួនសវនាការដែលបានសង្កេតទាំងអស់ នៅក្នុងអំឡុងពេលរបាយការណ៍ទី២ និងមានចំនួនប្រហាក់ប្រហែលទៅនឹងទិន្នន័យនៅក្នុងអំឡុងពេលរបាយការណ៍ទី១។ នៅក្នុងសវនាការចំនួន ៣ ដែលក្នុងនោះរឿងក្តីពឹងផ្អែកទាំងស្រុងទៅលើភស្តុតាងជាឯកសារ ដែលតុលាការមិនមាននៅក្នុងដៃ គឺៈ កិច្ចសន្យាពាក់ព័ន្ធនឹងរឿងក្តីចោរកម្ម កិច្ចសន្យាពាក់ព័ន្ធនឹងរឿងក្តីជម្លោះដីធ្លី និងឯកសារក្លែងក្លាយដែលជាមូលដ្ឋានគ្រឹះនៃបទចោទប្រកាន់ក្លែងបន្លំលិខិត។ ករណីទី៤ ពាក់ព័ន្ធនឹងការរំលោភច្បាប់ព្រៃឈើ ដែលក្នុងនោះកូនសោរសំខាន់សម្រាប់ការពារក្តី គឺលិខិតមួយច្បាប់ដែលផ្ញើទៅកាន់ការិយាល័យរដ្ឋបាលព្រៃឈើ ដែល ភាគីរដ្ឋប្បវេណី ព្រះរាជអាជ្ញា ឬចៅក្រមមិនមាននៅក្នុងដៃ។

## សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យសារភាព

សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យសារភាពពីពិរុទ្ធភាពនេះ ទាក់ទងនឹងការហាមឃាត់ដាច់ខាតនូវការធ្វើទារុណកម្ម ឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ឬដាក់ទណ្ឌកម្ម។ នេះគឺមានន័យថា គ្មានការគៀបសង្កត់ផ្លូវចិត្ត ឬផ្លូវកាយ ដោយផ្ទាល់ ឬមិនផ្ទាល់ ដែលបង្កជាស្លាកស្នាមលើជនជាប់ចោទដោយមន្ត្រីស៊ើបអង្កេត ឬមន្ត្រីតុលាការ ដើម្បីទទួលបានចម្លើយសារភាពអំពីពិរុទ្ធភាពឡើយ។

**តួលេខទី១៦៖ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យសារភាព**

| ១៣(ក) តើមានអ្វីមួយដែលបង្ហាញថា ជនជាប់ចោទត្រូវបានគំរាមកំហែងបង្ខំឲ្យសារភាពដែរឬទេ? | | | | |
|---|---|---|---|---|
| **ទិន្នន័យ** | **អំឡុងពេលរបាយការណ៍ទី១** | | **អំឡុងពេលរបាយការណ៍ទី២** | |
| | លេខ | % | លេខ | % |
| មាន | ៦ | ៣ | ២៨ | ៥ |
| គ្មាន | ១១២ | ៥៦ | ២៦១ | ៥០ |
| មិនពាក់ព័ន្ធ | ៨១ | ៤១ | ២៤៣ | ៤៥ |
| **១៣(ខ) តើមានអ្វីមួយដែលបង្ហាញថាជនជាប់ចោទត្រូវបានគេធ្វើទារុណកម្មបង្ខំឲ្យឆ្លើយសារភាពដែរឬទេ?** | | | | |
| **ទិន្នន័យ** | **អំឡុងពេលរបាយការណ៍ទី១** | | **អំឡុងពេលរបាយការណ៍ទី២** | |
| | លេខ | % | លេខ | % |
| មាន | ១០ | ៥ | ៣៥ | ៧ |
| គ្មាន | ១០៨ | ៥៤ | ២៥៤ | ៤៨ |
| មិនពាក់ព័ន្ធ | ៨១ | ៤១ | ២៤៣ | ៤៥ |

ស្របតាមគោលបំណងនៃសំណួរ ១៣(ក) និង ១៣(ខ) ការបង្ខិតបង្ខំត្រូវបានឲ្យនិយមន័យថាជាការគៀបសង្កត់ផ្លូវចិត្តមិនត្រឹមត្រូវ ដូចជាការគំរាមកំហែង។ សំណួរ ១៣(ខ) ត្រូវបានប្រើដើម្បីសង្កេតថា តើមានអ្វីមួយដែលបង្ហាញថា ជនជាប់ចោទត្រូវបានគៀបសង្កត់ឲ្យសារភាព តាមរយៈការប្រើអំពើហិង្សា ឬទារុណកម្ម។ សំណួរនេះត្រូវបានបកស្រាយដូចគ្នា នៅក្នុងអំឡុងពេលរបាយការណ៍ទាំង ២។ ហេតុផលដែលនាំទៅរកការឆ្លើយសំណួរទាំងនេះ ត្រូវបានកត់ត្រាដោយមន្ត្រីសង្កេតការណ៍សវនាការ ដែលមានដូចជា អំណះអំណាងជាក់លាក់របស់ជនជាប់ចោទអំពីការប្រព្រឹត្តមិនត្រឹមត្រូវ និងការសង្កេតមើលស្លាកស្នាមដែលបណ្តាលមកពីការរំលោភបំពានលើរាងកាយ។ យើងគួរកត់សម្គាល់ផងដែរថា ទិន្នន័យនៃសំណួរនេះហាក់ដូចជាការប៉ាន់ស្មាន ឧទាហរណ៍ដូចជាមន្ត្រីសង្កេតការណ៍សវនាការមិនអាចកំណត់ឲ្យប្រាកដប្រជាថា អំណះអំណាងរបស់ជនជាប់ចោទនៅក្នុងតុលាការជាការពិតដែរឬទេ។

នៅក្នុងចំណោមសវនាការដែលបានសង្កេត មានសវនាការចំនួន ២៨៩ ដែលក្នុងនោះចម្លើយសារភាពត្រូវបានគេលើកយកមកបង្ហាញជាភស្តុតាងប្រឆាំងជនជាប់ចោទ។ ចំនួននេះ ស្មើនឹង ៥៩% នៃចំនួនសវនាការដែលបានសង្កេតនៅក្នុងអំឡុងពេលរបាយការណ៍ទី២។ ចំនួននេះមានការធ្លាក់ចុះបន្តិចបន្តួច បើប្រៀបធៀបទៅនឹងទិន្នន័យនៅក្នុងអំឡុងពេលរបាយការណ៍ទី១ ដែលក្នុងនោះចម្លើយសារភាពត្រូវបានបង្ហាញជាភស្តុតាងនៅក្នុងសវនាការចំនួន ៥៩%។ ប៉ុន្តែទិន្នន័យនៃការពឹងផ្អែកទៅលើចម្លើយសារភាព ដើម្បីដាក់ទោសនៅតែមានអត្រាខ្ពស់។

នៅក្នុងចំណោមសវនាការ ដែលចម្លើយសារភាពត្រូវបានបង្ហាញជាភស្តុតាងចំនួន ២៨៩ មានសវនាការចំនួន ២៨ ឬស្មើនឹង ១០% ដែលក្នុងនោះមានតម្រុយបង្ហាញថាចម្លើយសារភាពអាចទទួលបានមកពីការគំរាមកំហែង ឬការគៀបសង្កត់ផ្លូវចិត្តផ្សេងទៀត។ ក្នុងចំណោមសវនាការដែលបានសង្កេតទាំងនោះ ក៏មានសវនាការចំនួន ៣៥ ឬស្មើនឹង ១២% ដែលក្នុងនោះមានតម្រុយបង្ហាញថាចម្លើយសារភាពអាចទទួលបានមកពីការគៀបសង្កត់ក្រោមទម្រង់ជាអំពើហិង្សា ឬទារុណកម្ម។ ទិន្នន័យទាំង ២ នេះ បង្ហាញឲ្យឃើញនូវការកើនឡើង បើប្រៀបធៀបទៅនឹងអំឡុងពេលរបាយការណ៍ទី១ ដែលក្នុងនោះទិន្នន័យដូចគ្នានេះមានចំនួន ៥% និង ៨%។ ទិន្នន័យនេះ នឹងត្រូវបានវិភាគលំអិតនៅក្នុងផ្នែកវិភាគទិន្នន័យ។

## ការហាមឃាត់ចំពោះការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ

នេះគឺជាគោលការណ៍មូលដ្ឋានមួយនៃច្បាប់ព្រហ្មទណ្ឌ ដែលក្នុងនោះគ្មានបុគ្គលណាម្នាក់អាចត្រូវបានគេរកឃើញថាជាប់ពិរុទ្ធនៃបទល្មើសព្រហ្មទណ្ឌណាមួយ ប្រសិនបើអំពើ ឬការខកខាន ដែលបុគ្គលនោះប្រព្រឹត្ត មិនត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ នៅពេលដែលអំពើ ឬការខកខាននោះកើតឡើង។ ស្រដៀងគ្នានេះដែរ ទោសដែលមានលក្ខណៈធ្ងន់ជាងទោសដែលមានចែងក្នុងច្បាប់នៅពេលដែលបទល្មើសព្រហ្មទណ្ឌត្រូវបានប្រព្រឹត្ត មិនត្រូវបានយកមកអនុវត្តនោះទេ។ ប្រសិនបើ បន្ទាប់

ពីពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត មានបទប្បញ្ញត្តិច្បាប់ដែលដាក់ទោសស្រាលជាង ទោសស្រាលនោះនឹងត្រូវបានអនុវត្ត។ ការហាមឃាត់ចំពោះការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ មានចែងនៅក្នុងច្បាប់អន្តរជាតិ មាត្រា ១១(២) នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងក្នុងច្បាប់ជាតិមាត្រា ៣ នៃក្រមព្រហ្មទណ្ឌ។

**តួលេខទី១៧៖ ការហាមឃាត់ចំពោះការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ**

| **១៥(ក) តើមានអ្វីមួយបង្ហាញថាបទល្មើសមិនមែនជាបទល្មើសនៅពេលដែលអំពើត្រូវបានប្រព្រឹត្ត?** | | | | |
|---|---|---|---|---|
| **ទិន្នន័យ** | **អំឡុងពេលរបាយការណ៍ទី១** | | **អំឡុងពេលរបាយការណ៍ទី២** | |
| | លេខ | % | លេខ | % |
| មាន | 0 | 0 | 0 | 0 |
| គ្មាន | ១៩៩ | ១០០ | ៥៣២ | ១០០ |

ក្នុងចំណោមសវនាការដែលបានសង្កេត គ្មានករណីណាមួយដែលបង្ហាញថាមានការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ ឬទោស នោះទេ។ ការចាប់ផ្តើមអនុវត្តក្រមព្រហ្មទណ្ឌ អាចនឹងនាំឲ្យមានការភ័ន្តច្រឡំចំពោះករណីនេះ ដោយសារតែក្រមនេះមានបទល្មើស និងទោសថ្មីជាច្រើន។ មាត្រា ១០ នៃក្រមព្រហ្មទណ្ឌចែងថា បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសដែលស្រាលជាងត្រូវអនុវត្តភ្លាម។ ប៉ុន្តែបទប្បញ្ញត្តិថ្មីដែលចែងអំពីទោសធ្ងន់ជាង នឹងត្រូវអនុវត្តតែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបទប្បញ្ញត្តិនេះ។[50]

## សវនាការពាក់ព័ន្ធនឹងអនីតិជន

អនីតិជនដែលត្រូវបានចោទប្រកាន់បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ មានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដូចគ្នាទៅនឹងនីតិជនដែរ ព្រមទាំងទទួលបាននូវការការពារបន្ថែមទៅតាមអាយុ ការដឹងខុសត្រូវ និងការវិវត្តនៃសតិបញ្ញា។

---

[50] មាត្រា ៦៧២ នៃក្រមព្រហ្មទណ្ឌចែងថា "*លើកលែងតែបទប្បញ្ញត្តិទូទៅនៃគន្ថីទី១ (បទប្បញ្ញត្តិទូទៅ) នៃក្រមនេះ ដែលត្រូវយកទៅអនុវត្តភ្លាមក្រោយការចូលជាធរមាននៃក្រមនេះ បទប្បញ្ញត្តិដទៃទៀតត្រូវយកទៅអនុវត្តក្នុងរយៈពេល ១ ឆ្នាំ ក្រោយការចូលជាធរមាននៃក្រមនេះ*"។ ដូច្នេះ បទល្មើសថ្មី និងបទល្មើសដដែលដែលមានទោសធ្ងន់ជាង ត្រូវបានអនុវត្តលុះត្រាតែផ្នែកផ្សេងទៀតនៃក្រមព្រហ្មទណ្ឌចូលជាធរមាននៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១០ នៅរាជធានីភ្នំពេញ និងនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០ នៅទូទាំងប្រទេស។

**តួលេខទី១៨៖ សវនាការដែលមានជនជាប់ចោទជាអនីតិជន**

| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | |
|---|---|---|---|---|
| ចំនួនសវនាការ | ២៦ | | ៤៦ | |
| | លេខ | % | លេខ | % |
| បទឧក្រិដ្ឋ | ១៦ | ៦២ | ៣៣ | ៧២ |
| បទមជ្ឈិម | ១០ | ៣៨ | ១៣ | ២៨ |

នៅក្នុងអំឡុងពេលរបាយការណ៍ទី២ នៅក្នុងចំណោមសវនាការដែលបានសង្កេតចំនួន ៥៣២ មានសវនាការចំនួន ៤៦ ដែលក្នុងនោះជនជាប់ចោទជាអនីតិជន។ ទិន្នន័យនេះស្មើនឹង ៩% នៃចំនួនសវនាការដែលបានសង្កេតទាំងអស់។ ជនជាប់ចោទជាអនីតិជនទាំងនោះ មានមេធាវីនៅក្នុងសវនាការចំនួន ៤៥ និងគ្មានមេធាវីនៅក្នុងសវនាការមួយ។

## អនីតិជន- ភាពឯកជន

ជាទូទៅសវនាការព្រហ្មទណ្ឌដែលមានជនជាប់ចោទជានីតិជន គួរតែធ្វើឡើងជាសាធារណៈ ដើម្បីគោរពតាមសិទ្ធិទទួលបានសវនាការជាសាធារណៈ។ ប៉ុន្តែ នៅក្នុងសវនាការដែលក្នុងនោះជនជាប់ចោទជាអនីតិជន ជាការស្របច្បាប់ដែលថាអ្នកចូលរួមនៅក្នុងសវនាការត្រូវបានរឹតត្បិត ដើម្បីការពារភាពឯកជនរបស់អនីតិជន និងជៀសវាងជះឥទ្ធិពលអាក្រក់ទៅថ្ងៃក្រោយ។[51]

**តួលេខទី១៩៖ អនីតិជន និងភាពឯកជន**

| ២(ក) តើមានការបិទផ្សាយជូនដំណឹងអំពីសវនាការនៅលើក្តារខៀនក្រៅបន្ទប់សវនាការដែរឬទេ? | | | | |
|---|---|---|---|---|
| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | |
| | លេខ | % | លេខ | % |
| មាន | 0 | 0 | 0 | 0 |
| គ្មាន | ២៦ | ១០០ | ៤៦ | ១០០ |

[51] មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា សារព័ត៌មាន និងសាធារណជន អាចមិនឲ្យចូលរួមទាំងស្រុង ឬផ្នែកមួយនៃសវនាការ នៅពេលផលប្រយោជន៍នៃជីវិតឯកជនរបស់គូភាគីតម្រូវឲ្យធ្វើដូច្នេះ។ សូមមើលផងដែរ គណៈកម្មាធិការសិទ្ធិកុមារ - ទំព័រទី៦៥-៦៦ នៃ*បទអត្ថាធិប្បាយទូទៅលេខ ១០៖ សិទ្ធិកុមារនៅក្នុងវិស័យយុត្តិធម៌អនីតិជន* (CRC/C/GC/10) ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៧។

| ២(ខ) តើសាធារណជនត្រូវបានរារាំងមិនឲ្យចូល ឬ បណ្តេញចេញពីបន្ទប់សវនាការដែរឬទេ? | | | | |
|---|---|---|---|---|
| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | |
| | លេខ | % | លេខ | % |
| មាន | 0 | 0 | 0 | 0 |
| គ្មាន | ២៦ | ១០០ | ៤៦ | ១០០ |
| ៤(គ) តើមានវបាំងការពារអនីតិជន នៅក្នុងការផ្តល់ចម្លើយជាសាធារណៈដែរឬទេ? | | | | |
| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | |
| | លេខ | % | លេខ | % |
| មាន | 0 | 0 | 0 | 0 |
| គ្មាន | ២៦ | ១០០ | ៤៦ | ១០០ |

ទិន្នន័យសំណួរ ២(ក) និង ២(ខ) នៃតារាងសង្កេតការណ៍សវនាការអនីតិជន បានបង្ហាញថា តុលាការដែលបានសង្កេត មិនបានរឹតត្បិតទៅលើការចូលរួមសវនាការដែលមានជនជាប់ចោទជាអនីតិជននោះទេ។ ការធ្វើរបៀបនេះហាក់ដូចជាបង្ហាញថា តុលាការមិនបានយកចិត្តទុកដាក់ទៅលើភាពឯកជនរបស់អនីតិជនដែលត្រូវបានជំនុំជម្រះនោះទេ។ នៅក្នុងសវនាការដែលមានជនជាប់ចោទជានីតិជនផង និងជាអនីតិជនផង មានផលប្រយោជន៍ស្របច្បាប់ដែលធានាថាជនល្មើសជានីតិជនមានសិទ្ធិទទួលបានសវនាការជាសាធារណៈ។ នៅក្នុងករណីបែបនេះ ភាពឯកជនរបស់ជនជាប់ចោទជាអនីតិជនអាចត្រូវបានគោរពតាមរយៈការប្រើប្រាស់វបាំងការពារ នៅពេលដែលអនីតិជនត្រូវបានសាកសួរ និងផ្តល់សក្ខីភាព។ គ្មានសវនាការណាមួយដែលតុលាការប្រើប្រាស់វបាំងការពារភាពឯកជនរបស់ជនជាប់ចោទអំពីការផ្តល់សក្ខីភាពជាសាធារណៈឡើយ។

## អនីតិជន - ការឃុំខ្លួនបណ្តោះអាសន្ន

លើសពីករណីនីតិជន បទដ្ឋានអន្តរជាតិក៏មិនជំរុញឲ្យមានការឃុំខ្លួនបណ្តោះអាសន្នអនីតិជនដែរ។ នៅក្នុងករណីភាគច្រើន ផលប្រយោជន៍របស់កុមារត្រូវបានការពារ ដោយការមិនបំបែកពួកគេពីឪពុកម្តាយរបស់ពួកគេ។[52] គេគួរតែជៀសវាងឃុំខ្លួនកុមារតាមដែលអាចធ្វើទៅបាន និងប្រើវិធីនេះជាមធ្យោបាយចុងក្រោយបំផុត ហើយឃុំខ្លួនកុមារក្នុងរយៈពេលមួយខ្លីសមរម្យ។[53] មាត្រា ១០(២)(ខ) និង ១០(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា ជនជាប់ចោទជាអនីតិជនត្រូវដាក់ផ្សេងពីនីតិជន ហើយត្រូវទទួលការជំនុំជម្រះឲ្យបានឆាប់តាមដែលអាចធ្វើបាន

[52] មាត្រា ៩ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។
[53] មាត្រា ៣៧(ខ) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

ហើយត្រូវស្ថិតនៅក្នុងការប្រព្រឹត្តទៅលើពួកគេ សមស្របតាមអាយុ និងស្ថានភាពនីត្យានុកូលភាពរបស់គេ។

**តួលេខទី២០៖ អនីតិជន និងការឃុំខ្លួនបណ្តោះអាសន្ន**

| ២(ខ) តើមានការឃុំខ្លួនបណ្តោះអាសន្នដែរឬទេ? | | | | |
|---|---|---|---|---|
| **ទិន្នន័យ** | **អំឡុងពេលរបាយការណ៍ទី១** | | **អំឡុងពេលរបាយការណ៍ទី២** | |
| | លេខ | % | លេខ | % |
| មាន | ១៧ | ៦៥ | ៤៥ | ៩៦ |
| គ្មាន | ៧ | ២៧ | ១ | ២ |
| មិនដឹង | ០ | ០ | ០ | ០ |
| មិនពាក់ព័ន្ធ (គ្មានការចាប់ខ្លួន) | ២ | ៨ | ១ | ២ |
| **៣(ក)ប្រសិនបើមានការឃុំខ្លួនបណ្តោះអាសន្ន តើមានអ្វីមួយដែលបង្ហាញថា ជនជាប់ចោទមិនត្រូវបានដាក់ដោយឡែកពីនីតិជនដែរឬទេ?** | | | | |
| **ទិន្នន័យ** | **អំឡុងពេលរបាយការណ៍ទី១** | | **អំឡុងពេលរបាយការណ៍ទី២** | |
| | លេខ | % | លេខ | % |
| មាន | ០ | ០ | ០ | ០ |
| គ្មាន | ១៨ | ៦៩ | ៤៥ | ៩៦ |
| មិនពាក់ព័ន្ធ | ៨ | ៣១ | ២ | ៤ |

នៅក្នុងចំណោមសវនាការចំនួន ៤៦ ដែលមានជនជាប់ចោទជាអនីតិជន ហើយដែលបានសង្កេតនៅក្នុងអំឡុងពេលរបាយការណ៍ទី២ មានសវនាការចំនួន ៩៦% ដែលអនីតិជនត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។ ទិន្នន័យនេះមានការកើនឡើងបើប្រៀបធៀបទៅនឹងទិន្នន័យនៅក្នុងអំឡុងពេលរបាយការណ៍ទី១ ដែលមានសវនាការចំនួន ៦៥% ដែលក្នុងនោះជនជាប់ចោទជាអនីតិជនត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។ តួលេខនេះបង្ហាញសញ្ញាគួរឲ្យព្រួយបារម្ភ ដោយសារមូលហេតុ ២។ មូលហេតុទី១ នៅក្នុងសវនាការចំនួន ១៣ អនីតិជនត្រូវបានចោទប្រកាន់ពីបទមជ្ឈឹម។ មូលហេតុទី២ អត្រានៃការឃុំខ្លួនបណ្តោះអាសន្នជនជាប់ចោទជាអនីតិជន មានកម្រិត*ខ្ពស់* ជាងធម្មតា។

ច្បាប់ និងបទដ្ឋានជាតិ អន្តរជាតិ បានចែងយ៉ាងច្បាស់ថា ក្នុងករណីពិសេស ដែលក្នុងនោះអនីតិជនត្រូវបានឃុំខ្លួនបណ្តោះអាសន្ន អនីតិជនគួរតែត្រូវបានបំបែកពីនីតិជន។[54] ការធ្វើរបៀបនេះគឺ

---

[54] មាត្រា ១៦៦ នៃក្រមព្រហ្មទណ្ឌចែងអំពីលក្ខខណ្ឌនៃការឃុំខ្លួនអនីតិជនក្នុងពន្ធនាគារថា *"អនីតិជនដែលជាប់ពន្ធនាគារ ត្រូវឃុំខ្លួននៅទីកន្លែងពិសេស ខណ្ឌដាច់ពីនីតិជន"*។ សូមមើលផងដែរ មាត្រា៣៧(គ) នៃអនុសញ្ញាស្តី

ដោយសារតែអនីតិជនងាយនឹងរងគ្រោះដោយសារអំពើហឹង្សា និងអាជីវកម្មផ្លូវភេទ ហើយត្រូវបានទប់ស្កាត់មិនឲ្យមានទំនាក់ទំនងជាមួយឧក្រិដ្ឋជនដែលជានីតិជន ដោយសារតែទំនាក់ទំនងនេះអាចជះឥទ្ធិពលមិនល្អលើការស្តារនីតិសម្បទាអនីតិជនឡើងវិញ។[55] នៅក្នុងចំណោមសវនាការដែលបានសង្កេត គ្មានករណីមួយណាដែលបង្ហាញ (ការតវ៉ារបស់មេធាវីជនជាប់ចោទ) ថាអនីតិជនមិនត្រូវបានបំបែកពីនីតិជន ក្នុងពេលឃុំខ្លួនបណ្តោះអាសន្នឡើយ។

## អនីតិជន - ការផ្តន្ទាទោស

នៅពេលសម្រេចការដាក់ទោសលើអនីតិជនដែលបានប្រព្រឹត្តល្មើសច្បាប់ព្រហ្មទណ្ឌ ចៅក្រមត្រូវគិតទៅលើផលប្រយោជន៍របស់កុមារជាអាទិភាព។[56] ការដាក់ទោសត្រូវតែស្របនឹងភាពធ្ងន់ធ្ងរ និងកាលៈទេសៈនៃបទល្មើស ព្រមទាំងអាយុជនល្មើស ដើម្បីកាត់បន្ថយកំហុស ស្របតាមកាលៈទេសៈ និងសេចក្តីត្រូវការរបស់មនុស្សដែលមានវ័យក្មេង រួមទាំងគោលបំណងជំរុញឲ្យមាននីតិសម្បទា និងចូលរួមក្នុងសង្គមជាតិឡើងវិញ នេះជាផលប្រយោជន៍វែងឆ្ងាយរបស់សង្គម។[57] ការដាក់ពន្ធនាគារអនីតិជនដែលរកឃើញថាល្មើសនឹងច្បាប់ព្រហ្មទណ្ឌ ត្រូវតែជាវិធានការណ៍ចុងក្រោយបង្អស់ ដែលត្រូវបានប្រើតែក្នុងករណីពិសេសប៉ុណ្ណោះ។[58]

### តួលេខទី២១៖ អនីតិជន និងការផ្តន្ទាទោស

| ៩(ឃ) តើមានអ្វីមួយដែលបង្ហាញថា ចៅក្រមពិចារណាទៅលើទោសមិនមែនពន្ធនាគារ មុននឹងគិតពីទោសពន្ធនាគារដែរឬទេ? | | | | |
|---|---|---|---|---|
| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | |
| | លេខ | % | លេខ | % |
| មាន | 0 | 0 | 0 | 0 |

---

ពីសិទ្ធិកុមារ និងវិធានទី១៣.៤ នៃវិធានបទដ្ឋានអប្បបរមាអង្គការសហប្រជាជាតិសម្រាប់រដ្ឋបាលយុត្តិធម៌អនីតិជន (វិធានប៉េកាំង) ដែលអនុម័តដោយសេចក្តីសម្រេចរបស់អង្គមហាសន្និបាតលេខ ៤០/៣៣ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥។

[55] គណៈកម្មាធិការសិទ្ធិកុមារ - កថាខណ្ឌ ៨៥ នៃ *បទអត្ថាធិប្បាយទូទៅ លេខ១០៖ សិទ្ធិកុមារនៅក្នុងវិស័យយុត្តិធម៌អនីតិជន*។

[56] មាត្រា ៣(១) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។ សូមមើលផងដែរ គណៈកម្មាធិការសិទ្ធិកុមារ - កថាខណ្ឌ ១០ និង ៧១ នៃ *បទអត្ថាធិប្បាយទូទៅ លេខ១០៖ សិទ្ធិកុមារនៅក្នុងវិស័យយុត្តិធម៌អនីតិជន*។

[57] មាត្រា ៤០(១) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។ សូមមើលផងដែរ គណៈកម្មាធិការសិទ្ធិកុមារ - កថាខណ្ឌ ៧១ នៃ *បទអត្ថាធិប្បាយទូទៅ លេខ១០៖ សិទ្ធិកុមារនៅក្នុងវិស័យយុត្តិធម៌អនីតិជន*។

[58] មាត្រា ៣៧(ខ) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

| | | | | |
|---|---|---|---|---|
| គ្មាន | ២០ | ៧៧ | ៤៥ | ៩៨ |
| មិនពាក់ព័ន្ធ | ៦ | ២៣ | ១ | ២ |

នៅក្នុងសវនាការមួយ ចៅក្រមបានកាត់ឲ្យជនជាប់ចោទជាអនីតិជនរួចទោស ដោយយោងទៅលើអាយុរបស់ជននោះ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ ទង្វើនេះគួរឲ្យកោតសរសើរ។ នៅក្នុងចំណោមសវនាការចំនួន ៤៥ ដែលក្នុងនោះជនជាប់ចោទជាអនីតិជន ក្នុងអំឡុងពេលរបាយការណ៍ទី២ គ្មានតម្រុយណាមួយដែលបង្ហាញថាចៅក្រមពិចារណាលើទោសមិនមែនពន្ធនាគារឡើយ។ បញ្ហានេះនឹងត្រូវបានពិភាក្សាលំអិតនៅក្នុងផ្នែកវិភាគទិន្នន័យ។

# ៤. ការវិភាគទិន្នន័យ

ផ្នែកនេះបង្ហាញអំពីការវិភាគដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា នូវទិន្នន័យដែលប្រមូលបានពាក់ព័ន្ធនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ចំនួន ៣៖ ការសន្មតទុកជាមុនថាគ្មានទោស សិទ្ធិទទួលបានការពារពីការឆ្លើយដាក់បន្ទុកខ្លួនឯង និងការប្រព្រឹត្តទៅលើជនជាប់ចោទជាអនីតិជន។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានឹងផ្តល់ការវិភាគស៊ីជម្រៅ និងអនុសាសន៍ចំពោះសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មួយចំនួន ដែលយើងប្រមូលបានទិន្នន័យនៅក្នុងអំឡុងពេលរបាយការណ៍នីមួយៗ។ យើងធ្វើរបៀបនេះដើម្បីធានាថា ការវិភាគនេះមានលក្ខណៈលំអិតស៊ីជម្រៅ និងត្រូវបានបង្ហាញក្រោមទម្រង់ដែលអាចគ្រប់គ្រង និងប្រើប្រាស់បាននៅក្នុងកិច្ចពិភាក្សាជាមួយតុលាការ និងដៃគូពាក់ព័ន្ធដទៃទៀត។

ការវិភាគនេះត្រូវបានធ្វើឡើងដូចទៅនឹងរបាយការណ៍ទី១ ដែលវិភាគទៅលើសិទ្ធិចំនួន ៤ គឺ សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការមួយឯករាជ្យ និងមិនលំអៀង សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ សិទ្ធិមានមេធាវី និងមានវត្តមាននៅក្នុងសវនាការ ការឃុំខ្លួនបណ្តោះអាសន្ន និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល។

## សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស

បុគ្គលគ្រប់រូបដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ មានសិទ្ធិទទួលបាននូវការសន្មតទុកជាមុនថាគ្មានទោស រហូតដល់ពេលដែលពិរុទ្ធភាពត្រូវបានរកឃើញតាមច្បាប់។[59] នេះគឺជាសិទ្ធិមូលដ្ឋានរបស់បុគ្គលម្នាក់ៗ ដែលត្រូវបានទទួលស្គាល់ជាសកល។ សិទ្ធិនេះទាមទារឲ្យមានការយកចិត្តទុកដាក់ជាពិសេសពីសំណាក់បុគ្គលគ្រប់រូប ដែលបានចូលរួមក្នុងគ្រប់ដំណាក់កាលនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។

អាជ្ញាធរសាធារណៈ និងមន្ត្រីទាំងអស់ រួមទាំងចៅក្រម គួរតែជៀសវាងការវិនិច្ឆ័យទុកជាមុននូវលទ្ធផលនៃរឿងក្តី។ ការឃុំខ្លួនបណ្តោះអាសន្នមិនគួរត្រូវបានអនុវត្តជាទណ្ឌកម្មចំពោះបុគ្គលដែល ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសឡើយ ហើយក៏មិនគួរត្រូវបានប្រើជាមធ្យោបាយក្រៅប្រព័ន្ធតុលាការវាយតម្លៃទៅលើភាពមានពិរុទ្ធភាពឡើយ។[60] ការបដិសេធសំណើសុំនៅក្រៅឃុំ មិនប៉ះ

[59] មាត្រា ១១(១) នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។ មាត្រា ១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ។

[60] ហេតុផលស្របច្បាប់នៃការឃុំខ្លួនបណ្តោះអាសន្នមានចែងនៅក្នុងមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ពាល់ដល់ការសន្មតទុកជាមុនថាគ្មានទោសនោះឡើយ។[61] ការប្រព្រឹត្តទៅនៃការជំនុំជម្រះ គួរតែឆ្លុះបញ្ចាំងនូវការសន្មតទុកជាមុនថាគ្មានទោស ចៅក្រមអនុញ្ញាតឲ្យជនជាប់ចោទមានឱកាសពិតប្រាកដក្នុងការបញ្ចេញមតិ ហើយគួរតែមានការយកចិត្តទុកដាក់ ដើម្បីធានាថាការសន្មតជាមុនអំពីពិរុទ្ធភាពដូចជា តាមរយៈឯកសណ្ឋានអ្នកទោស ឬខ្នោះ មិនអនុវត្តទៅលើជនជាប់ចោទនៅក្នុងសវនាការ ព្រោះថាការធ្វើរបៀបនេះអាចជះឥទ្ធិពលដោយចេតនា ឬអចេតនាទៅលើជំនឿរបស់តុលាការពាក់ព័ន្ធនឹងភាពមានទោស ឬគ្មានទោសរបស់ជនជាប់ចោទ។[62]

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាសង្កេត ការទទួលស្គាល់គោលការណ៍សន្មតទុកជាមុនថាគ្មានទោសដោយអាជ្ញាធរ តាមរយៈវិធី ២។ វិធីទី១ មន្ត្រីសង្កេតការណ៍សវនាការសង្កេតថាតើជនជាប់ចោទបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងឯកសណ្ឋានជាអ្នកទោស ឬជាប់ខ្នោះដៃរឬទេ ព្រោះស្ថានភាពទាំង ២ នេះបញ្ជាក់ថាជនជាប់ចោទជាប់ពិរុទ្ធ នៅមុនពេលដែលភស្តុតាងត្រូវបានបង្ហាញដោយភាគីទាំង ២ និងមុនការកំណត់អំពីភាពមាន ឬគ្មានទោសដោយតុលាការមួយដែលមិនលំអៀង។ វិធីទី២ មន្ត្រីសង្កេតការណ៍សវនាការសង្កេតមើលថាតើនៅមុនពេលចេញសាលក្រម ចៅក្រមមានបាននិយាយអ្វីដែលបង្ហាញថា ចៅក្រមអាចវិនិច្ឆ័យទុកជាមុននូវលទ្ធផលនៃរឿងក្តី ហើយមិនបានធ្វើការពិចារណាទៅលើភស្តុតាង និងសក្ខីភាពនៃភាគីទាំងអស់នៃរឿងក្តីដែរឬទេ។

## មូលដ្ឋានច្បាប់

សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស រហូតដល់ពេលដែលពិរុទ្ធភាពត្រូវបានរកឃើញតាមច្បាប់ គឺជាសិទ្ធិមួយដាច់ខាត ដែលមិនអាចមានការចែងផ្ទុយពីនេះ ការដាក់កម្រិត ឬការដាក់ព្រំដែនឡើយ។[63] សិទ្ធិនេះស្ថិតនៅលើកម្រិតខ្ពស់បំផុតនៃច្បាប់អន្តរជាតិ គឺនៅក្នុងមាត្រា១១(១) នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងមាត្រា១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

ការសន្មតទុកជាមុនថាគ្មានទោសក៏មានចែងផងដែរ នៅក្នុងមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ "*វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ*"។ មាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[61] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ - កថាខណ្ឌ៣០ នៃ*បទអត្ថាធិប្បាយទូទៅលេខ៣២ ស្តីពីមាត្រា១៤៖ សិទ្ធិស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី ព្រមទាំងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌*។

[62] ដូចខាងលើ។

[63] គណៈកម្មាធិការសិទ្ធិមនុស្ស - កថាខណ្ឌទី១១ នៃ*បទអត្ថាធិប្បាយទូទៅលេខ ២៩៖ ប្រទេសក្នុងភាពអាសន្ន* (CCPR/C/21/Rev.1/add.11) ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០១។ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ - កថាខណ្ឌទី៦ នៃបទអត្ថាធិប្បាយទូទៅលេខ៣២៖ មាត្រា១៤-*សិទ្ធិស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី ព្រមទាំងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌*។

ចែងថា "*វិមតិសង្ស័យត្រូវតែបានជាអត្ថប្រយោជន៍ដល់ជនជាប់ចោទជា និច្ច*"។ មាត្រា៣៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា "*ទោះបីជាជនជាប់ចោទអវត្តមានក៏ដោយ តុលាការត្រូវតែស្វែងរកឲ្យឃើញការពិត ស្តាប់ចម្លើយភាគីដទៃទៀត សាក្សី និងពិនិត្យវត្ថុតាង*"។

ប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារឆ្នាំ១៩៩៨ ចែងថា "*អ្នកទោសដែលតម្រូវឲ្យបង្ហាញខ្លួននៅចំពោះមុខតុលាការ ត្រូវអនុញ្ញាតឲ្យស្លៀកសំលៀកបំពាក់ ស្អាតបាត និងសមរម្យ ផ្ទាល់ខ្លួនរបស់គេ*"។[64] គណៈកម្មាធិការសិទ្ធិមនុស្សក៏បានលើកឡើងផងដែរថា ជនជាប់ចោទមិនគួរ "*មានវត្តមាននៅចំពោះមុខតុលាការនៅក្នុងរូបភាពមួយ ដែលបង្ហាញថាពួកគេជាពិរុទ្ធជនដ៏មានគ្រោះថ្នាក់នោះឡើយ*"។[65]

## ទិន្នន័យ

នៅក្នុងចំណោមសវនាការដែលបានសង្កេតចំនួន ៥៣២ គ្មានករណីណាមួយដែលបង្ហាញថាជនជាប់ចោទមានវត្តមាននៅក្នុងសវនាការទាំងជាប់ខ្នោះនោះទេ។ ការណ៍នេះគួរឲ្យកោតសរសើរ។ នៅក្នុងករណីខ្លះ សិទ្ធិជនជាប់ចោទចាំបាច់ត្រូវដាក់កម្រិត ដើម្បីដោះស្រាយបញ្ហាសន្តិសុខ ប៉ុន្តែករណីនេះមិនដែលកើតមានឡើងនោះឡើយ។ ទិន្នន័យនៃសំណួរ ៨(ក) បង្ហាញថា នៅក្នុងចំណោមសវនាការដែលបានសង្កេតចំនួន ៣៣៨ នៅតុលាការក្រុងភ្នំពេញ (នៅក្នុងសវនាការចំនួន ៣៨ ទៀត ជនជាប់ចោទត្រូវបានកាត់ទោសកំបាំងមុខ) ជនជាប់ចោទមានវត្តមានក្នុងឯកសណ្ឋានជាអ្នកទោសនៅសវនាការចំនួន ៣១៤ ឬស្មើនឹង ៩៣% នៃចំនួនសវនាការដែលបានសង្កេតទាំងអស់។ ផ្ទុយទៅវិញ ក្នុងចំណោមសវនាការដែលបានសង្កេតចំនួន ១៤០ នៅតុលាការខេត្តកណ្តាល (នៅក្នុងសវនាការចំនួន ១៦ ទៀត ជនជាប់ចោទត្រូវបានកាត់ទោសកំបាំងមុខ) ជនជាប់ចោទមានវត្តមានក្នុងឯកសណ្ឋានជាអ្នកទោសតែនៅក្នុងសវនាការចំនួន ៤ ឬស្មើនឹង ៣% តែប៉ុណ្ណោះ។

ការសន្មតជាមុនថាគ្មានទោស ទាមទារឲ្យជនជាប់ចោទមានវត្តមាននៅក្នុងតុលាការក្នុងឯកសណ្ឋានជាពលរដ្ឋធម្មតា។ គ្រប់ជនជាប់ចោទទាំងអស់ត្រូវនាំទៅកាន់តុលាការក្នុងរូបភាព និងកត្តិយសជាជនម្នាក់ដែលគ្មានទោស។ ការណ៍ដែលជនជាប់ចោទត្រូវបានបង្ខំឲ្យចូលរួមក្នុងសវនាការដោយស្លៀកពាក់ជាអ្នកទោស បង្ហាញថាជនជាប់ចោទជាឧក្រិដ្ឋជនដែលមានពិរុទ្ធភាពរួចទៅហើយ ការណ៍នេះអាចនឹងជះឥទ្ធិពល ដោយចេតនា ឬអចេតនា ទៅលើការវិនិច្ឆ័យរបស់ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬចៅក្រម របៀបនៃចំណាត់ការនីតិវិធី និងចុងក្រោយបង្អស់លទ្ធផលនៃរឿងក្តី។

---

[64] ក្រសួងមហាផ្ទៃ-ប្រការ ៨(៥)ច និងប្រការ ៨(៨)ង នៃប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ លេខ២១៧ ចុះថ្ងៃទី៣១ ខែមិនា ឆ្នាំ១៩៩៨។ សូមមើលផងដែរ ប្រការ ៤.១.១ នៃប្រកាសលេខ២៣ ស្តីពីនីតិវិធីពន្ធនាគារ។

[65] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ - កថាខណ្ឌ៣០ នៃ*បទអត្ថាធិប្បាយទូទៅលេខ៣២ ស្តីពីមាត្រា១៤៖ សិទ្ធិស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី ព្រមទាំងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌*។

ការណ៍ដែលជនជាប់ចោទបង្ហាញខ្លួននៅចំពោះមុខតុលាការក្រុងភ្នំពេញជារឿយៗនៅក្នុងឯកសណ្ឋានជាអ្នកទោស អាចនឹងបន្ទាបស្តង់ដារនៃការសន្មតទុកជាមុនថាគ្មានទោសនៅក្នុងសវនាការភាគច្រើន។ បញ្ហានេះជាប់ទាក់ទងទៅនឹងកម្រិតខ្ពស់នៃការឃុំខ្លួនបណ្តោះអាសន្ន។ វិធាន៩៣(១) នៃបទដ្ឋានអប្បបរមាអង្គការសហប្រជាជាតិស្តីពីការប្រព្រឹត្តទៅលើអ្នកទោសបានស្នើថា *"សំលៀកបំពាក់ និងរបស់របរផ្សេងទៀតដែលជាកម្មសិទ្ធិរបស់អ្នកទោសស្ថិតនៅក្រោមវិធានរបស់ស្ថាប័នអ្នកទោសមិនត្រូវបានអនុញ្ញាតឲ្យរក្សាទុករបស់របរ លើកលែងតែមានការអនុញ្ញាតរបស់ស្ថាប័នឃុំឃាំងនោះ។"*[66] ដូច្នេះជនទាំងឡាយណាដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្ន គួរតែអាចស្លៀកសំលៀកបំពាក់របស់ខ្លួនទៅកាន់តុលាការ ឬមានឱកាសទទួលបានសំលៀកបំពាក់ពីមិត្តភក្តិ ឬក្រុមគ្រួសារនៅមុនពេលបង្ហាញខ្លួននៅមុខតុលាការប្រសិនបើមន្ត្រីពន្ធនាគារធ្វើបាត់ ឬបោះចោលសំលៀកបំពាក់របស់ពួកគេនៅមុនពេលឃុំខ្លួន។[67]

ទិន្នន័យនៃសំណួរ ៨(គ) បង្ហាញថាចៅក្រមនៅតុលាការដែលបានសង្កេតកម្រនឹងនិយាយអំពីភាពមាន ឬគ្មានទោសនៃជនជាប់ចោទនៅមុនពេលប្រកាសសាលក្រមណាស់។ នេះជាការរកឃើញមួយដ៏គួរឲ្យកោតសរសើរ។ សវនាការដែលក្នុងនោះចៅក្រមបាននិយាយពាក្យសំដីទាំងនោះមានចំនួន ១% នៃចំនួនសវនាការដែលបានសង្កេតនៅតុលាការនីមួយៗ។ ផ្នែកទិន្នន័យនៃរបាយការណ៍នេះក៏បានបង្ហាញផងដែរថា ទិន្នន័យនៃការប្រើពាក្យសំដីនេះនៅក្នុងតុលាការទាំង២ មានការធ្លាក់ចុះពី១០% នៅក្នុងអំឡុងពេលរបាយការណ៍ទី១ មកនៅត្រឹម១% នៅក្នុងអំឡុងពេលរបាយការណ៍ទី២។ ទោះបីជាករណីសិក្សាទី១ មិនតំណាងឲ្យការប្រែប្រួលទិន្នន័យជាទូទៅក៏ដោយ ក៏ករណីនេះជាឧទាហរណ៍មួយនៃសវនាការមួយចំនួនដែលក្នុងនោះពាក្យសំដីចៅក្រម បានបង្ហាញពីការខកខានមិនបានទទួលស្គាល់គោលការណ៍សន្មតទុកជាមុនថាគ្មានទោស។

---

[66] អង្គការសហប្រជាជាតិ - បទដ្ឋានអប្បបរមាស្តីពីការប្រព្រឹត្តទៅលើអ្នកទោស ដែលអនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី១ស្តីពីការបង្ការបទឧក្រិដ្ឋ និងការប្រព្រឹត្តទៅលើជនល្មើស ដែលប្រព្រឹត្តទៅនៅទីក្រុងហ្សឺណែវ នៅឆ្នាំ១៩៥៥ និងអនុម័តដោយក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម តាមរយៈវិធាន ៩៣(១) នៃសេចក្តីសម្រេចលេខ ៦៦៣គ (XXIV) ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៥៧ និងលេខ ២០៧៦ (LXII) ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៧៧។

[67] អង្គការសហប្រជាជាតិ - វិធាន ១៧(៣) និង ៩៣(១) នៃបទដ្ឋានអប្បបរមាស្តីពីការប្រព្រឹត្តទៅលើអ្នកទោស។ សូមមើលផងដែរ អង្គការលើកលែងទោសអន្តរជាតិ - *សៀវភៅស្តីពីការជំនុំជម្រះដោយយុត្តិធម៌* (ក្រុងឡុងដ៏៖ ការបោះពុម្ពផ្សាយរបស់អង្គការលើកលែងទោសអន្តរជាតិ ឆ្នាំ១៩៩៨) AI Index POL 30/02/98 ទំព័រទី១០៩។

**ករណីសិក្សាទី១៖ ពាក្យសំដីបង្ហាញថាជនជាប់ចោទមានពិរុទ្ធភាព នៅមុនពេលប្រកាសសាលក្រម**

**តុលាការ** ៖តុលាការក្រុងភ្នំពេញ
**កាលបរិច្ឆេទសង្កេត** ៖ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១០

ជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទក្រុមជនប្រដាប់អាវុធ យោងតាមមាត្រា៣៦ នៃច្បាប់អ៊ុនតាក់។ អង្គហេតុមានដូចតទៅ៖ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៨ ជនជាប់ចោទបានជិៈម៉ូតូជាមួយបុរស ២នាក់ទៀត ដែលមិនស្គាល់អត្តសញ្ញាណ ចាកចេញពីសណ្ឋាគារនៅសង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ ឆ្ពោះទៅកាន់ពោធិចិនតុង។ ប៉ូលីសបានបញ្ឈប់បុរសទាំង ៣ ដែលព្យាយាមរត់គេច។ បុរសម្នាក់ក្នុងចំណោមបុរសដែលមិនស្គាល់អត្តសញ្ញាណនោះ បានប្រើកាំភ្លើងបាញ់ទៅលើប៉ូលីស ហើយបុរស ២នាក់ទៀតបានរត់គេចខ្លួន ចោលជនជាប់ចោទនៅកន្លែងកើតហេតុ ដែលក្រោយមកត្រូវបានប៉ូលីសចាប់ខ្លួន។

នៅក្នុងសវនាការចៅក្រមបានព្រមានជនជាប់ចោទថា ទោះបីជាជនជាប់ចោទព្យាយាមឆ្លើយការពារខ្លួនយ៉ាងណាក៏ដោយ ក៏ជនជាប់ចោទនៅតែជាប់ពន្ធនាគារដែរ។ ចៅក្រមបាននិយាយថា "ទោះបីជាអ្នកឯងព្យាយាមនិយាយអ្វីក៏ដោយ ក៏អ្នកឯងជាប់គុកដែរ"។ បានឮពាក្យសំដីនេះ ជនជាប់ចោទដែលព្យាយាមឆ្លើយការពារខ្លួនប្រឆាំងនឹងការចោទប្រកាន់ ហាក់ដូចជាមានការខកចិត្ត និងខ្លបខ្លាច ហើយភ្លាមនោះឈប់ឆ្លើយការពារខ្លួននៅក្នុងការសួរឆ្លើយឆ្លងនៅក្នុងសវនាការ។ ពាក្យសំដីរបស់ចៅក្រមនៅក្នុងសវនាការ បានបង្ហាញថាចៅក្រមបានសម្រេចថា ជនជាប់ចោទមិនអាចជៀសផុតពីជាប់ពន្ធនាគារឡើយ ហើយការផ្តល់សក្ខីភាពរបស់ជនជាប់ចោទមិនត្រូវបានយកមកពិចារណាឡើយ។

# អនុសាសន៍

**មន្ទីរឃុំខ្លួនបណ្តោះអាសន្ននៅតុលាការក្រុងភ្នំពេញ និងតុលាការខេត្តកណ្តាល** គួរតែធានាថាអ្នកជាប់ពន្ធនាគារ ដែលត្រូវបង្ហាញខ្លួននៅចំពោះមុខតុលាការទទួលបានឱកាសស្លៀកសំលៀកបំពាក់ផ្ទាល់ខ្លួនរបស់ពួកគេ អនុលោមតាមមាត្រា ៩(៥)(ច) នៃប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ។ នៅមុនពេលបង្ហាញខ្លួននៅមុខតុលាការ ជនជាប់ចោទទាំងអស់គួរតែទទួលបានសំលៀកបំពាក់ដែលស្លៀកពាក់នៅមុនពេលឃុំខ្លួនបណ្តោះអាសន្ន ឬទទួលបានឱកាសស្វែងរកសំលៀកបំពាក់ផ្សេងទៀតពីមិត្តភ័ក្ត ឬក្រុមគ្រួសារ ប្រសិនបើមន្ត្រីពន្ធនាគារបានធ្វើឲ្យបាត់ ឬបោះចោលសំលៀកបំពាក់ទាំងនោះ។

# សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យសារភាព

សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យសារភាព ពាក់ព័ន្ធនឹងការហាមឃាត់ដាច់ខាតការធ្វើទារុណកម្ម ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ឬដាក់ទណ្ឌកម្ម។ សិទ្ធិនេះមានន័យថា គ្មានការគៀបសង្កត់ដោយផ្ទាល់ ឬដោយប្រយោលទៅលើរាងកាយ ឬស្មារតីរបស់ជនជាប់ចោទ ធ្វើឡើងដោយមន្ត្រីយុត្តិធម៌ ឬអាជ្ញាធរស៊ើបអង្កេត ដើម្បីទទួលបានចម្លើយសារភាពឡើយ។ សិទ្ធិនេះផ្សាភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងសិទ្ធិនៅស្ងៀម។ ការរំលោភបំពានលើរូបរាងកាយ ទារុណកម្ម និងអំពើឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបដទៃទៀត ដែលប្រព្រឹត្តទៅលើជនជាប់ចោទ មិនអាចទទួលយកបានឡើយទោះជាស្ថិតនៅក្នុងករណីណាក៏ដោយ។ ជាងនេះទៅទៀត នៅពេលដែលប្រព្រឹត្តអំពើបែបនេះក្នុងគោលបំណងទទួលបានចម្លើយសារភាព ភស្តុតាងដែលទទួលបានតាមរយៈការប្រើអំពើបែបនោះ មិនគួរឲ្យជឿទុកចិត្តបាននោះទេ។

## មូលដ្ឋានច្បាប់

ការធ្វើទារុណកម្មជាក់ស្តែង គឺខុសច្បាប់ នៅក្នុងខ្លឹមសារនៃលិខិតគុបករណ៍សិទ្ធិមនុស្សទាំង ៣ គឺសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប។ មាត្រា៥ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងមាត្រា៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយចែងថា គ្មានជនណាម្នាក់ត្រូវទទួលទារុណកម្ម ឬការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាបបានឡើយ។ អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបចែងថា *"រដ្ឋភាគីត្រូវចាត់វិធានការខាងផ្លូវច្បាប់រដ្ឋបាលតុលាការ និងវិធានការផ្សេងទៀត ដើម្បីបង្ការកុំឲ្យមានទារុណកម្មនៅលើដែនដីក្រោមសមត្ថកិច្ចរបស់ខ្លួន"*[68] និង *"ត្រូវធានាថាទារុណកម្មជាបទល្មើសក្រោមច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន។"*[69] អនុសញ្ញាប្រឆាំងទារុណកម្ម និងការ ប្រព្រឹត្តមកលើខ្លួនឬទណ្ឌកម្មឯទៀតដែលឃោរឃៅអមនុស្សធម៌ឬបន្ថោកបន្ទាបក៏បានដាក់កាតព្វកិច្ច ឲ្យរដ្ឋភាគីស៊ើបអង្កេត *"ជាបន្ទាន់ និងមិនលំអៀង"* នៅពេលដែលមានមូលហេតុសមស្របគួរឲ្យជឿបានថា អំពើទារុណកម្មត្រូវបានប្រព្រឹត្តក្នុងដែនដីក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។[70] មាត្រា១៥ ចែងថារដ្ឋ

---

[68] មាត្រា ២(១) នៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប។

[69] មាត្រា ៤(១)នៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប។

[70] មាត្រា ១២ នៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប។

ភាគីត្រូវធានាថា សេចក្តីថ្លែងការណ៍ទាំងឡាយដែលបានមកពីអំពើទារុណកម្មមិនត្រូវយកមកសំអាងជាភស្តុតាងក្នុងនីតិវិធីណាមួយឡើយ។

មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញចែងអំពីការការពារនិងការធានាថា៖ *"ច្បាប់ការពារមិនឲ្យមានការរំលោភបំពានលើរូបកាយបុគ្គលណាមួយឡើយ...ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើតលុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។ ការបង្ខិតបង្ខំការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនឃុំឃាំងឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឲ្យធ្វើឡើយ។ អ្នកដៃដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិតត្រូវទទួលទោសតាមច្បាប់។ ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តីមិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ។"*

មាត្រា៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា៖ *"ចម្លើយដែលទទួលបានក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬខាងផ្លូវចិត្ត គ្មានតម្លៃជាភស្តុតាងទេ។"* ទារុណកម្មត្រូវបានចាត់ទុកយ៉ាងច្បាស់ដោយក្រមព្រហ្មទណ្ឌថាជាអំពើខុសច្បាប់។ បទឃាតកម្មដោយទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។[71] មាត្រា២១០ ក៏មានចែងផងដែរអំពីបទទារុណកម្ម និងអំពើឃោរឃៅ ថាជាអំពើខុសច្បាប់។ នៅក្នុងខណៈដែលគ្មានការកំណត់អត្ថន័យច្បាស់អំពី"ទារុណកម្ម" ឬ "អំពើឃោរឃៅ" ដោយក្រមព្រហ្មទណ្ឌ របាយការណ៍ ដែលប្រទេសកម្ពុជាដាក់ជូនគណៈកម្មាធិការប្រឆាំងទារុណកម្មនៅឆ្នាំ២០១០ បានលើកឡើងថា មាត្រា៣១នៃរដ្ឋធម្មនុញ្ញនិងមាត្រា៩នៃក្រមព្រហ្មទណ្ឌ បានទទួលស្គាល់យ៉ាងច្បាស់ថា គ្រប់អនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន គឺត្រូវបានអនុវត្តក្នុងប្រទេសកម្ពុជា រួមទាំងអនុសញ្ញាប្រឆាំងទារុណកម្ម ដែលត្រូវបានចូលរួមនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ ។[72] ដូច្នេះនិយមន័យនៃទារុណកម្មនៅក្នុងមាត្រា១(១) នៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាបត្រូវបានទទួលស្គាល់ដោយច្បាប់កម្ពុជា។

ទារុណកម្ម ឬអំពើឃោរឃៅត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារក្នុងរយៈពេលពី៧ឆ្នាំ ទៅ១៥ឆ្នាំ ឬពី១០ឆ្នាំ ទៅ២០ឆ្នាំ នៅពេលដែលអនុវត្តដោយអ្នករាជការសាធារណៈនៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន។[73]

---

[71]មាត្រា ២០៥ នៃក្រមព្រហ្មទណ្ឌ។

[72] គណៈកម្មាធិការប្រឆាំងទារុណកម្ម កថាខណ្ឌ១ នៃ*ការពិចារណាទៅលើរបាយការណ៍ដាក់ជូនដោយរដ្ឋភាគីក្រោមមាត្រា ១៩ នៃអនុសញ្ញា៖ កម្ពុជា* (CAT/C/KHM/2) ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១០។

[73] មាត្រា ២១០ និង ២១៣ នៃក្រមព្រហ្មទណ្ឌ។

ទិន្នន័យ

សម្រាប់គោលបំណងនៃសំណួរ ១៣ (ក) និង១៣ (ខ) ការគំរាមកំហែងត្រូវបានឲ្យនិយមន័យថាជាការគៀបសង្កត់ផ្លូវចិត្តមិនត្រឹមត្រូវ ដូចជាការគំរាមកំហែង នៅខណៈដែលសំណួរ ១៣ (ខ) ត្រូវបានប្រើសម្រាប់សង្កេតថា តើមានអ្វីមួយបង្ហាញថាជនជាប់ចោទត្រូវបានគៀបសង្កត់ដោយអំពើហឹង្សា ឬទារុណកម្ម។ តម្រុយដែលសង្កេតឃើញត្រូវបានកត់ត្រាដោយមន្ត្រីសង្កេតការណ៍សវនាការ ឧទាហរណ៍ដូចជា ជនជាប់ចោទបានអះអាងជាក់លាក់អំពីការប្រព្រឹត្តមិនត្រឹមត្រូវមកលើខ្លួន ឬស្លាកស្នាមដែលមើលឃើញបញ្ជាក់ពីការរំលោភលើរូបរាងកាយ។ យើងគួរកត់សម្គាល់ផងដែរថា ទិន្នន័យនៅក្នុងសំណួរនេះមិនបានផ្តល់ភស្តុតាងប្រាកដប្រជាថា ការប្រព្រឹត្តមិនត្រឹមត្រូវនោះពិតជាកើតមានមែន ព្រោះថា មន្ត្រីសង្កេតការណ៍សវនាការមិនអាចកំណត់ច្បាស់ថា ការអះអាងរបស់ជនជាប់ចោទនៅក្នុងតុលាការពិតជាមានលក្ខណៈត្រឹមត្រូវពិតប្រាកដនោះទេ។

ចម្លើយសារភាពត្រូវបានបង្ហាញដោយព្រះរាជអាជ្ញាជាភស្តុតាង ក្នុងសវនាការចំនួន២០៦ នៅតុលាការក្រុងភ្នំពេញ និងក្នុងសវនាការចំនួន ៨៣ នៅតុលាការខេត្តកណ្តាល។ នៅក្នុងចំណោមសវនាការដែលចម្លើយសារភាពត្រូវបានបង្ហាញជាភស្តុតាងនៅក្នុងតុលាការក្រុងភ្នំពេញ មានតម្រុយបង្ហាញថាចម្លើយសារភាពអាចបានពីការគំរាមកំហែង ឬការគៀបសង្កត់ផ្លូវចិត្តផ្សេងទៀតនៅក្នុងសវនាការចំនួន ២៧ ឬស្មើនឹង១៣% និងមានតម្រុយបង្ហាញថាចម្លើយសារភាពអាចបានពីការគៀបសង្កត់ក្រោមទម្រង់នៃអំពើហឹង្សា ឬទារុណកម្ម នៅក្នុងសវនាការចំនួន ៣៤ ឬស្មើនឹង ១៦% ។ នៅក្នុងចំណោមសវនាការ ដែលក្នុងនោះចម្លើយសារភាពត្រូវបានបង្ហាញជាភស្តុតាងនៅក្នុងតុលាការខេត្តកណ្តាល មានតម្រុយបង្ហាញថាចម្លើយសារភាពអាចបានពីការគំរាមកំហែង ឬការគៀបសង្កត់ផ្លូវចិត្តផ្សេងទៀត នៅក្នុងសវនាការតែចំនួន ១ ប៉ុណ្ណោះ និងមានតម្រុយបង្ហាញថាចម្លើយសារភាពអាចបានពីការគៀបសង្កត់ក្រោមទម្រង់ជាអំពើហឹង្សា ឬទារុណកម្ម នៅក្នុងសវនាការ ១ ផ្សេងទៀត។

វិធីសាស្ត្រ ៥ បន្ថែមទៀត ដែលអាចអនុវត្តជំណាលគ្នា ដើម្បីកាត់បន្ថយករណីប្រើការ គំរាមកំហែង អំពើហឹង្សា ឬទារុណកម្មក្នុងការសួរចម្លើយ និងកាត់បន្ថយចំនួននៃការតវ៉ាអំពីការប្រព្រឹត្តបែបនេះ ដែលនាំឲ្យបាត់បង់ជំនឿលើមន្ត្រីនគរបាល ហើយលើសពីនេះគឺប្រព័ន្ធយុត្តិធម៌ទាំងមូល។ វិធីសាស្ត្រទី១ គឺការបន្តផ្តល់ការអប់រំ និងបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់អំពីបច្ចេកទេសសួរចម្លើយដោយគ្មានការបង្ខិតបង្ខំ និងអំពីភាពមិនស្របច្បាប់ និងផលវិបាកនៃការប្រើបច្ចេកទេសមិនត្រឹមត្រូវ។ វិធីសាស្ត្រទី២ គឺការធានាឲ្យបានតឹងរឹងនូវការអនុវត្តស្របតាមនីតិវិធីឃុំខ្លួន និងសួរចម្លើយដែលមានស្រាប់ និងពង្រឹងការការពារតាមរយៈការកែប្រែបទប្បញ្ញត្តិដែលជាប់ពាក់ព័ន្ធនៅក្នុងក្រមនីតិវិធីព្រហ្ម

ទណ្ឌ។ វិធីសាស្ត្រទី៣ គឺការបង្កើតអង្គភាពស៊ើបអង្កេតឯករាជ្យ និងយន្តការបណ្តឹង ព្រមទាំងការស៊ើបអង្កេតជាបន្ទាន់ និងមិនលំអៀងនូវរាល់បណ្តឹងទាក់ទងនឹងការធ្វើទារុណកម្ម ឬការប្រព្រឹត្តមិនត្រឹមត្រូវដទៃទៀត។ វិធីសាស្ត្រទី៤ គឺការទប់ស្កាត់និទណ្ឌភាពនៃជនដែលបានប្រព្រឹត្តទង្វើមិនត្រឹមត្រូវទៅលើជនជាប់ឃុំ ដោយ ធានាថា ជនដែលត្រូវបានដាក់ទោសតាមច្បាប់។ វិធីសាស្ត្រទី៥ គឺតុលាការមិនត្រូវទទួលយកចម្លើយសារភាព ដែលមានតម្រុយពិតប្រាកដបង្ហាញថាចម្លើយសារភាពនេះបានមកពីទង្វើមិនត្រឹមត្រូវនៅក្នុងដំណើរការសួរចម្លើយឡើយ។

## ការអប់រំ និងបណ្តុះបណ្តាល

យោងតាមរបាយការណ៍ដំបូង ដែលប្រទេសកម្ពុជាដាក់ជូនគណៈកម្មាធិការប្រឆាំងទារុណកម្មនៅឆ្នាំ២០០២ នគរបាលជាតិប្រមាណលើសពី ៩៥ ០០០ នាក់ត្រូវបានបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្សនៅចន្លោះឆ្នាំ ១៩៩៥ និង ២០០១ តាមរយៈកិច្ចសហប្រតិបត្តិការរវាងក្រសួងមហាផ្ទៃ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា និងអង្គការមិនមែនរដ្ឋាភិបាលធ្វើការទាក់ទងនឹងសិទ្ធិមនុស្សមានដូចជា សមាគមអាដហុក អង្គការលីកាដូ និងអង្គការរក្សារការពារសិទ្ធិមនុស្សនៅកម្ពុជា វីជីលែន។ គម្រោងមេរៀនត្រូវបានអះអាងថារៀបចំក្រោមកិច្ចសហការជាមួយ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា និងត្រូវបានបង្រៀននៅក្នុងវគ្គបណ្តុះបណ្តាលដែលមានរយៈពេល ៥ថ្ងៃ។[74]

ជាការសំខាន់ណាស់ ដែលការបណ្តុះបណ្តាលនេះត្រូវបានធ្វើបន្តសម្រាប់នគរបាលជាតិ មន្ត្រីយោធា មន្ត្រីពន្ធនាគារ ព្រមទាំងអាជ្ញាធរដទៃទៀតដែលមានអំណាចមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីធានាថាមន្ត្រីដែលត្រូវបានជ្រើសរើសថ្មីបន្តទទួលបានការអប់រំ និងបណ្តុះបណ្តាល។ ការបណ្តុះបណ្តាលគួរតែបញ្ចូលនូវសេចក្តីណែនាំអំពីនីតិវិធីស្របច្បាប់ត្រឹមត្រូវទាក់ទងនឹងការឃុំខ្លួន និងសួរចម្លើយ ព្រមទាំងវិធីសាស្ត្រនៃការសួរចម្លើយដោយគ្មានការបង្ខិតបង្ខំ។ ជាការចាំបាច់ផងដែរដែលនៅក្នុងវគ្គបណ្តុះបណ្តាលនោះមានការលើកយកមកនិយាយនូវបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ ដែលចែងយ៉ាងច្បាស់ថាទារុណកម្មជាអំពើខុសច្បាប់ និងផលវិបាកនៃការដាក់ទោសជនប្រព្រឹត្ត។

---

[74] គណៈកម្មាធិការប្រឆាំងនឹងទារុណកម្ម- កថាខណ្ឌ ១០១ នៃ*ការពិចារណាទៅលើរបាយការណ៍ដែលដាក់ជូនដោយរដ្ឋភាគីស្តីពីមាត្រា ១៩ នៃអនុសញ្ញា៖ របាយការណ៍ដំបូងនៃរដ្ឋភាគីនៅឆ្នាំ១៩៩៣៖ សារបន្ថែម៖ កម្ពុជា* (CAT/C/21/Add.5) ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៣។

## ការការពារនៅក្នុងអំឡុងពេលឃុំខ្លួន និងសួរចម្លើយ

ក្រមនីតិវិធីព្រហ្មទណ្ឌបានចែងអំពីនីតិវិធីនៃការចាប់ និងឃុំខ្លួនជនសង្ស័យ។ ដើម្បីទទួលបានប្រសិទ្ធិភាព ការអប់រំ និងការបណ្តុះបណ្តាលស្តីពីនីតិវិធីត្រឹមត្រូវ គួរតែភ្ជាប់ជាមួយនូវការឃ្លាំមើល និងការជំរុញឲ្យមានការអនុវត្តនីតិវិធីនោះ។ ការជំរុញឲ្យអនុវត្តមាត្រា ៩៦-១០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌអាចជួយកាត់បន្ថយការរំលោភ និងទារុណកម្ម ដោយធានាថាការឃាត់ខ្លួនក្រោយការចាប់ខ្លួនមិនលើសពីរយៈពេល ៤៨ ម៉ោង បន្ទាប់ពីពេលចាប់ខ្លួន[75] និងអនុញ្ញាតឲ្យជនជាប់ឃុំមានទំនាក់ទំនងជាមួយមេធាវី។[76]

មាត្រា ៩៨ ចែងថា ក្នុងរយៈពេល ២៤ ម៉ោងកន្លងផុតទៅ បុគ្គលដែលឃាត់ខ្លួនអាចសុំសន្ទនាជាមួយមេធាវី។ ជនណាម្នាក់ដែលបានជ្រើសរើសអាចនិយាយជាមួយជនដែលឃាត់ខ្លួនក្នុងរយៈពេល ៣០នាទី។ ដូចដែលបានចែង មាត្រា ៩៨ បង្កើតនូវភាពគ្រោះថ្នាក់ដែលអាចកើតមានឡើងនៅក្នុងអំឡុងពេល ២៤ ម៉ោង ដែលក្នុងនោះជនជាប់ចោទអាចនឹងមិនបានដឹងអំពីសិទ្ធិទទួលបានមេធាវី និងអាចត្រូវបានគំរាមកំហែង ធ្វើទុកបុកម្នេញ ឬមិនយកចិត្តទុកដាក់។ បទប្បញ្ញត្តិនេះគួរតែត្រូវបានកែប្រែដើម្បីអនុញ្ញាតឲ្យជនដែលត្រូវបានចាប់ខ្លួន ឬឃុំខ្លួន អាចសុំជួបជាមួយមេធាវីនៅគ្រប់ដំណាក់កាលនៃការឃុំខ្លួន និងអាចទាក់ទងជាមួយមេធាវីយ៉ាងឆាប់រហ័សតាមដែលអាចធ្វើទៅបាន។ រយៈពេលកំណត់ ៣០ នាទី ក៏ត្រូវបានមើលឃើញថាមានលក្ខណៈខ្លីពេក និងគួរតែបន្លាយពេល ឬលុបចោលទាំងស្រុងតាមរយៈការធ្វើវិសោធនកម្ម។

មាត្រា ១៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា *"ជនជាប់ចោទអាចត្រូវសួរចម្លើយបានតែនៅចំពោះមុខមេធាវីរបស់ខ្លួនប៉ុណ្ណោះ"*។ ប៉ុន្តែបទប្បញ្ញត្តិនេះពាក់ព័ន្ធតែទៅនឹងការសួរចម្លើយដោយចៅក្រមស៊ើបសួរក្រោយពេលដែលជនជាប់ចោទត្រូវបានចោទប្រកាន់។ ចំពោះការឃាត់ខ្លួននៅក្នុងដំណាក់កាលនគរបាលយុត្តិធម៌ គ្មានការការពារបែបនេះឡើយ។ ការធ្វើវិសោធនកម្មមាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលបានស្នើខាងលើ នឹងអនុញ្ញាតឲ្យជនដែលឃាត់ខ្លួនអាចស្នើសុំឲ្យមេធាវី

---

[75] មាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា៖ "ការឃាត់ខ្លួនមានចិរវេលា៤៨ (សែសិបប្រាំបី) ម៉ោង"។ ប៉ុន្តែតាមរយៈការអនុញ្ញាតរបស់ព្រះរាជអាជ្ញា នគរបាលយុត្តិធម៌អាចពន្យារពេល ២៤ ម៉ោងបន្ថែមទៀត នៅក្នុង "ករណីពិសេស" ដូចជាករណីដែលជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ និងមានភស្តុតាងចង្អុលអំពីពិរុទ្ធភាពរបស់បុគ្គលនោះ។

[76] មាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថាក្នុងរយៈពេល ២៤ ម៉ោងកន្លងផុតទៅ បុគ្គលដែលឃាត់ខ្លួនអាចសុំសន្ទនាជាមួយមេធាវី ឬជាមួយជនណាម្នាក់ដែលខ្លួនបានជ្រើសរើស កុំឲ្យតែជននេះមានការទាក់ទិននៅក្នុងរឿងជាមួយ។"

មានវត្តមាននៅពេលដែលនគរបាលយុត្តិធម៌ ឬមន្ត្រីផ្សេងទៀតសួរចម្លើយពួកគេនៅក្នុងពេលឃាត់ខ្លួនដំបូងបន្ទាប់ពីពេលចាប់ខ្លួន។

ការថតការសួរចម្លើយជាសម្លេង ឬវីដេអូ ក៏អាចជួយការបន្ថយការគំរាមកំហែង ការប្រើអំពើហិង្សា និងទារុណកម្ម ដើម្បីទទួលបានចម្លើយសារភាព ទោះបីជាវិធីនេះហាក់ដូចជាមិនសមស្របទៅនឹងធនធានសមត្ថភាពនៃការិយាល័យនគរបាល និងតុលាការភាគច្រើននៅកម្ពុជាក៏ដោយ។ វិធីសាស្ត្រនេះ ក៏អាចជួយផងដែរក្នុងការប្រយុទ្ធប្រឆាំងនឹងអំណះអំណាងក្លែងក្លាយអំពីចម្លើយសារភាពដែលបានមកពីការបង្ខិតបង្ខំមិនត្រឹមត្រូវ។

## ការស៊ើបសួរជាបន្ទាន់ និងមិនលំអៀងរាល់គ្រប់បណ្តឹងទាំងអស់

គណៈកម្មាធិការប្រឆាំងនឹងទារុណកម្ម បានផ្តល់អនុសាសន៍ឲ្យកម្ពុជាបង្កើតស្ថាប័នមួយឯករាជ្យ មានសមត្ថកិច្ចដោះស្រាយបណ្តឹងប្រឆាំងនឹងមន្ត្រីនគរបាល និងមន្ត្រីអនុវត្តច្បាប់ដទៃទៀត។[77] យោងតាមរបាយការណ៍ដែលប្រទេសកម្ពុជា ដាក់ជូនគណៈកម្មាធិការប្រឆាំងនឹងទារុណកម្មនៅឆ្នាំ ២០០៩ នីតិវិធីបច្ចុប្បន្នដែលប្រើសម្រាប់បំពេញពាក្យបណ្តឹងប្រឆាំងនឹងមន្ត្រីនគរបាល ឬមន្ត្រីពន្ធនាគារ តម្រូវឲ្យដាក់បណ្តឹងទៅក្រសួងមហាផ្ទៃ ប្រសិនបើបណ្តឹងទាក់ទងនឹងការបំពេញការងារពេលមានតួនាទី ឬដាក់បណ្តឹងទៅតុលាការក្នុងករណីដែលបណ្តឹងនោះទាក់ទងនឹងការប្រព្រឹត្តបទល្មើស។[78]

កាលពីថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០០៧ កម្ពុជាបានផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម (“OPCAT”)។ ពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងទារុណកម្ម ដាក់កាតព្វកិច្ចឲ្យរដ្ឋភាគីបង្កើតយន្តការបង្ការថ្នាក់ជាតិឯករាជ្យមួយ (“NPM”) សម្រាប់បង្ការការធ្វើទារុណកម្មនៅថ្នាក់ជាតិនៅក្នុងអំឡុងពេល១ឆ្នាំ បន្ទាប់ពីពិធីសារនេះចូលជាធរមាន ឬផ្តល់សច្ចាប័ន ឬថ្ងៃចូលរួមក្នុងពិធីសារនេះ។[79] ភារកិច្ចជាក់លាក់នៃយន្តការបង្ការថ្នាក់ជាតិដូចដែលបានលើកឡើងនៅក្នុងពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងទារុណកម្ម មានដូចជា៖

ក. ត្រួតពិនិត្យជាទៀងទាត់នូវរាល់ការប្រព្រឹត្តទៅលើជនដែលឃុំដោយរដ្ឋ ដើម្បីពង្រឹងការការពារពួកគេប្រឆាំងនឹងទារុណកម្ម។

---

[77] គណៈកម្មាធិការប្រឆាំងនឹងទារុណកម្ម- កថាខណ្ឌ ៧ នៃ*សេចក្តីសន្និដ្ឋាន និងអនុសាសន៍របស់គណៈកម្មាធិការប្រឆាំងនឹងទារុណកម្ម៖ កម្ពុជា* (CAT/C/CR/31/7) ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០០៤។

[78] គណៈកម្មាធិការប្រឆាំងនឹងទារុណកម្ម- កថាខណ្ឌ ៧៥ នៃ*ការពិចារណាទៅលើរបាយការណ៍ដាក់ជូនដោយរដ្ឋភាគី ស្តីពីមាត្រា១៩ នៃអនុសញ្ញា៖ កម្ពុជា* (CAT/C/KHM/2) ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១០។

[79] មាត្រា ១៧ នៃពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងនឹងទារុណកម្ម។

ខ. ផ្តល់ជាអនុសាសន៍ទៅឲ្យអាជ្ញាធរពាក់ព័ន្ធ ក្នុងគោលបំណងធ្វើឲ្យលក្ខខ័ណ្ឌ និងការប្រព្រឹត្តទៅលើបុគ្គលដែលសេរីភាពត្រូវបានដកហូត មានលក្ខណៈកាន់តែប្រសើរឡើង ព្រមទាំងទប់ស្កាត់ទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប និង

គ. ដាក់សំណើ និងការសង្កេតពាក់ព័ន្ធនឹងច្បាប់ដែលមានស្រាប់ និងពង្រាងច្បាប់។[80]

របាយការណ៍ដែលកម្ពុជាដាក់ជូនគណៈកម្មាធិការប្រឆាំងទារុណកម្ម នៅឆ្នាំ ២០០៩បានរាយការណ៍ថា យន្តការបែបនោះត្រូវបានបង្កើតឡើងដោយនាយករដ្ឋមន្ត្រី តាមរយៈអនុក្រឹត្យចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ២០០៩។[81] ប៉ុន្តែ យន្តការដែលត្រូវបានរាយការណ៍ថាមានគណៈកម្មាធិការមួយ ដែលក្នុងនោះមានសមាជិកចំនួន១៣ នាក់មកពីក្រសួងនានា ហើយស្ថិតនៅក្រោមការដឹកនាំរបស់ក្រសួងមហាផ្ទៃ មិនឆ្លើយតបទៅនឹងការទាមទាររបស់មាត្រា ១៧ និង ១៨ នៃពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងទារុណកម្មនោះទេ។

មាត្រា ១៨ នៃពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងទារុណកម្ម ចែងថាយន្តការបង្ការថ្នាក់ជាតិត្រូវតែដំណើរការដោយឯករាជ្យ ហើយអ្នកបម្រើការក៏ត្រូវតែជាបុគ្គលឯករាជ្យ រួមមានអ្នកជំនាញដែលមានសមត្ថភាព និងចំណេះដឹងវិជ្ជាជីវៈ។ យោងតាមសេចក្តីណែនាំដែលចេញផ្សាយដោយការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សប្រចាំនៅកម្ពុជា តម្រូវការមូលដ្ឋាននៃយន្តការបង្ការថ្នាក់ជាតិគឺឯករាជ្យភាពពីរដ្ឋាភិបាល មានន័យថាយន្តការនេះមិនត្រូវស្ថិតនៅក្រោមអាជ្ញាធរក្រសួងមន្ទីរណាមួយ ឬស្ថាប័នដទៃទៀតរបស់រដ្ឋាភិបាល និងមិនគួរទទួលធ្វើការមន្ត្រីដែលកំពុងបំពេញការងារឲ្យក្រសួង ឬស្ថាប័ននានារបស់រដ្ឋ ឲ្យបម្រើការនៅក្នុងយន្តការនេះឡើយ។[82] ដើម្បីធានាថាយន្តការមានភាពឯករាជ្យគួរឲ្យជឿទុកចិត្តបានក្នុងការទទួល និងស៊ើបអង្កេតបណ្តឹងទាក់ទងនឹងទារុណកម្ម និងទង្វើមិនត្រឹមត្រូវដទៃទៀត កម្ពុជាគួរតែបង្កើតយន្តការបង្ការថ្នាក់ជាតិមួយដែលឆ្លើយតបទៅនឹងការទាមទាររបស់ពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងនឹងទារុណកម្ម ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

---

[80] មាត្រា ១៩ នៃពិធីសារបន្ថែមទៅលើអនុសញ្ញាប្រឆាំងទារុណកម្ម។

[81] គណៈកម្មាធិការប្រឆាំងនឹងទារុណកម្ម កថាខណ្ឌ ៩៧ *ការពិចារណាទៅលើរបាយការណ៍ដាក់ជូនដោយរដ្ឋភាគីស្តីពីមាត្រា ១៩ នៃអនុសញ្ញា៖ កម្ពុជា* (CAT/C/KHM/2) ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១០។

[82] ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា ទំព័រទី១ ប័ណ្ណព័ត៌មានលេខ៥៖ OPCAT យន្តការបង្ការថ្នាក់ជាតិ ខែមេសា ឆ្នាំ២០០៨ ដែលអាចរកបាន៖ http://cambodia.ohchr.org/WebDOCs/DocInfoNote/004 InfoNoteE.pdf។

អនុសញ្ញាប្រឆាំងនឹងទារុណកម្ម ក៏មានចែងផងដែរអំពីយន្តការបណ្តឹងថ្នាក់បុគ្គល។ មាត្រា ២២ ចែងថា រដ្ឋភាគីនៃអនុសញ្ញាប្រឆាំងនឹងទារុណកម្មអាចប្រកាសទទួលស្គាល់គ្រប់ពេលវេលានូវសមត្ថកិច្ចរបស់គណៈកម្មាធិការប្រឆាំងនឹងទារុណកម្មក្នុងការទទួល និងពិចារណាលើសេចក្តីជូន ដំណឹងដែលបានមកពី ឬក្នុងនាមបុគ្គលដែលជាកម្មវត្ថុនៃយុត្តាធិការរបស់គណៈកម្មាធិការនេះ ដែលទាមទារក្នុងនាមជនរងគ្រោះនៃអំពើទារុណកម្ម ឬការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។ ប្រទេសកម្ពុជាមិនទាន់បានធ្វើសេចក្តីថ្លែងការណ៍ ដើម្បីទទួលស្គាល់យុត្តាធិការនៃគណៈកម្មាធិការប្រឆាំងនឹងទារុណកម្មទទួលពាក្យបណ្តឹងពីបុគ្គល។ ដើម្បីបង្ហាញនូវឆន្ទៈពិតប្រាកដក្នុងការបំបាត់ការប្រើទារុណកម្មនៅកម្ពុជា រាជរដ្ឋាភិបាលកម្ពុជាគួរតែដាក់ជូននូវសេចក្តីថ្លែងការណ៍នោះជាបន្ទាន់។

## ការកាត់ទោសចារី

ដូចដែលបានលើកឡើងខាងលើ មាត្រា២១០ នៃក្រមព្រហ្មទណ្ឌកំណត់បទល្មើសជាក់លាក់ទាក់ទងនឹងបទទារុណកម្ម និងអំពើឃោរឃៅ។ មាត្រា ២១៣ ចែងពីទណ្ឌកម្មដែលមានលក្ខណៈធ្ងន់ធ្ងរសម្រាប់ផ្តន្ទាទោសមន្ត្រីរដ្ឋាភិបាលដែលប្រព្រឹត្តបទល្មើសនេះនៅក្នុងក្របខ័ណ្ឌនៃការបំពេញការងាររបស់ខ្លួន។ បទប្បញ្ញត្តិទាំងនេះនឹងចូលជាធរមាននៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ ២០១០ នៅរាជធានីភ្នំពេញ និងនៅថ្ងៃទី២០ ខែធ្នូ នៅទូទាំងប្រទេស ព្រមទាំងផ្តល់ជាមូលដ្ឋានច្បាប់សម្រាប់កាត់ទោសមន្ត្រីអនុវត្តច្បាប់ដែលបានប្រព្រឹត្តទង្វើមិនត្រឹមត្រូវ។ ការកាត់ទោសអាចត្រូវបានធ្វើឡើង នៅពេលដែលមានភស្តុតាងគ្រប់គ្រាន់គួរឲ្យជឿបានទាក់ទងនឹងទង្វើរបស់បុគ្គល ឬក្រុមនោះ។ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងអន្តរជាតិ មិន អាចត្រូវបានដោះស្រាយដោយអះអាងថា ចារីត្រូវបានដាក់ពិន័យនៅក្នុងស្ថាប័ននោះទេ។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញផានាថា ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់។

## ការវាយតម្លៃភស្តុតាង

ចៅក្រមគួរតែត្រួតពិនិត្យឲ្យបានម៉ត់ចត់ នៅពេលធ្វើការពិចារណាទៅលើចម្លើយសារភាពដែលអះអាងថាទទួលបានពីការគៀបសង្កត់បង្ខិតបង្ខំ។ រដ្ឋធម្មនុញ្ញ និងក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងយ៉ាងច្បាស់ថា ចម្លើយសារភាពដែលបានមកពីការបង្ខិតបង្ខំមិនអាចមានតម្លៃជាភស្តុតាងនោះទេ។[83]

[83] មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ដូចដែលបានលើកឡើង ជាមួយនឹងការព្រួយបារម្ភដោយតំណាងសិទ្ធិមនុស្សពិសេសប្រចាំនៅកម្ពុជានៅក្នុងរបាយការណ៍នៅឆ្នាំ២០០៨[84] នៅមុនពេលអនុម័តក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២៤(៣) នៃច្បាប់អ៊ុនតាក់ ចែងថាចម្លើយសារភាពតែមួយមុខ មិនអាចទុកជាមូលដ្ឋានសម្រាប់ផ្តន្ទាទោសឡើយ។ ពិរុទ្ធភាពរបស់ជនជាប់ចោទ ត្រូវស៊ីសង្វាក់ជាមួយភស្តុតាងដទៃទៀត។ បទប្បញ្ញត្តិនេះមានគោលបំណងបញ្ចៀសនូវការពឹងផ្អែកទាំងស្រុងទៅលើចម្លើយសារភាព និងភាពប្រថុយប្រថាននៃចម្លើយសារភាពក្លែងក្លាយដែលបានមកពីការគៀបសង្កត់ដែលធ្វើឡើងដោយនគរបាល ឬអាជ្ញាធរដទៃទៀត។ នៅក្នុងចំណោមសវនាការចំនួន ៣៧៦ ដែលសង្កេតនៅតុលាការក្រុងភ្នំពេញ មានសវនាការចំនួន ៣៧ និងក្នុងចំណោមសវនាការចំនួន ១៥៦ ដែលសង្កេតនៅតុលាការខេត្តកណ្តាល មានសវនាការចំនួន ២០ ដែលក្នុងនោះភស្តុតាងដាក់បន្ទុកត្រូវបានបង្ហាញតែមួយគត់ គឺចម្លើយសារភាពរបស់ជនជាប់ចោទ។

នៅពេលដែលមានភស្តុតាងដទៃទៀត ចៅក្រមជំនុំជម្រះគួរតែពិចារណាច្រានចោលចម្លើយសារភាពដែលជាប់ពាក់ព័ន្ធនឹងការតវ៉ាជំទាស់ ហើយពិចារណាតែទៅលើភស្តុតាងផ្សេងទៀត។ នៅពេលដែលគ្មានភស្តុតាងបន្ថែមទៅលើចម្លើយសារភាពដែលត្រូវបានបដិសេធ និងលើកឡើងថាចម្លើយសារភាពនេះបានមកពីការបង្ខិតបង្ខំមិនត្រឹមត្រូវ ចៅក្រមជំនុំជម្រះគួរតែកាត់ឲ្យជនជាប់ចោទរួចទោស។ ការយកចិត្តជាពិសេសទៅលើការទទួលយកចម្លើយសារភាពដែលពាក់ព័ន្ធនឹងការតវ៉ាជំទាស់ ជំរុញឲ្យមានការប្រើប្រាស់បច្ចេកទេសសួរចម្លើយត្រឹមត្រូវ និងមិនលើកទឹកចិត្តឲ្យមានការប្រើអំពើហិង្សា ទារុណកម្ម និងទង្វើមិនត្រឹមត្រូវដទៃទៀត។ ជនដែលប្រព្រឹត្តអំពើទាំងអស់នេះមិនត្រឹមតែប្រឈមមុខនឹងការកាត់ទោស ការផ្តន្ទាទោស និងការដាក់ពន្ធនាគារប៉ុណ្ណោះទេ ចម្លើយសារភាពនឹងច្រានចោល មិនចាត់ទុកជាភស្តុតាងប្រើក្នុងតុលាការឡើយ។

[84] តំណាងសិទ្ធិមនុស្សពិសេសប្រចាំនៅកម្ពុជា - ទំព័រទី៧ នៃ*ជំនួយបច្ចេកទេស និងកសាងសមត្ថភាព៖ របាយការណ៍របស់ យ៉ាសហ្គាយ អ្នកតំណាងនៃអគ្គលេខាធិការសិទ្ធិមនុស្សប្រចាំនៅកម្ពុជា*(A/HRC/7/42) ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០៨។

**ករណីសិក្សាទី២៖ អំណះអំណាងនៃការប្រើអំពើហឹង្សាបង្ខំជនជាប់ចោទឲ្យសារភាព**

**តុលាការ** ៖តុលាការក្រុងភ្នំពេញ

**កាលបរិច្ឆេទសង្កេតការណ៍** ៖ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១០

ជនជាប់ចោទត្រូវចោទប្រកាន់ពីបទចែកចាយគ្រឿងញៀនខុសច្បាប់។ ជនជាប់ចោទត្រូវចាប់ខ្លួននៅពេលកំពុងទិញគ្រឿងញៀន (ម៉ាទឹកកក) ២៩ កញ្ចប់នៅផ្ទះអ្នកលក់គ្រឿងញៀនកាលពីថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៩ នៅរាជធានីភ្នំពេញ។ នៅក្នុងសវនាការ ជនជាប់ចោទបានអះអាងជាច្រើនលើកច្រើនសារថា ខ្លួនត្រូវបានវាយនៅខណៈពេលដែលខ្លួនត្រូវបានឃាត់ខ្លួននៅប៉ុស្តិ៍នគរបាល ក្នុងគោលបំណងទាញយកចម្លើយសារភាព។ ចៅក្រមយកមិនបានយកចិត្តទុកដាក់ទៅលើការអះអាងរបស់ជនជាប់ចោទនោះទេ និងស្តីបន្ទោសខ្លាំងៗថាជនជាប់ចោទកុហក ហើយប្រើអំណះអំណាងនេះជា "ឧបាយកល" ដើម្បីបិទបាំងទោសកំហុសរបស់ខ្លួន។ ចៅក្រមបានធ្វើការកត់សម្គាល់ថា ជនជាប់ចោទពុំមានភស្តុតាងគាំទ្រអំណះអំណាងរបស់ខ្លួននោះទេ។ បន្ទាប់ពីត្រូវបានស្តីបន្ទោសដោយចៅក្រម ជនជាប់ចោទភ្លាមនោះបានឈប់និយាយ និងឱនក្បាល។

នៅក្នុងកាលៈទេសៈបែបនេះ ជនជាប់ចោទបានអះអាងថាអាជ្ញាធរបានវាយរាយកាយបង្ខិតបង្ខំឲ្យសារភាព ចៅក្រមគួរតែផ្តល់យោបល់ឲ្យជនជាប់ចោទអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការដាក់ពាក្យបណ្តឹងជាផ្លូវការ។ ប្រសិនបើជនជាប់ចោទបានសារភាពថាបានប្រព្រឹត្តល្មើស ហើយអះអាងថាចម្លើយសារភាពនោះបានមកពីការបង្ខិតបង្ខំលើរូបកាយ ចៅក្រមគួរតែពិចារណាដោយប្រុងប្រយ័ត្នថាតើចម្លើយសារភាពនោះអាចទទួលយកបាន អនុលោមតាមមាត្រា៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញដែរឬទេ។

# អនុសាសន៍

- ក្រសួងមហាផ្ទៃគួរបន្តផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីនគរបាលជាតិ (រួមទាំងមន្ត្រីនគរបាលយុត្តិធម៌) និងមន្ត្រីពន្ធនាគារអំពីបច្ចេកទេសសួរចម្លើយដែលគ្មានការបង្ខិតបង្ខំ និងហាមឃាត់ដាច់ខាតនូវការធ្វើទារុណកម្ម ដែលឃោរឃៅ អមនុស្សធម៌ បន្ថោកបន្ទាប ឬទណ្ឌកម្ម។ ការបណ្តុះបណ្តាលគួរតែត្រូវបានធ្វើឡើង ដោយសហការជាមួយអង្គការខាងក្រៅដូចជា ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងអង្គការក្រៅរដ្ឋាភិបាល

សិទ្ធិមនុស្ស និងប្រើប្រាស់គម្រោងមេរៀនដែលបានបង្កើតរួចជាស្រេច ក្នុងកិច្ចសហប្រតិបត្តិជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស។

- រាជរដ្ឋាភិបាលគួរស្នើធ្វើវិសោធនកម្មមាត្រា៩៦ និង៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីអនុញ្ញាតឲ្យជនត្រូវចាប់ខ្លួន និងឃុំខ្លួនអាចសុំជួបមេធាវីនៅក្នុងគ្រប់ដំណាក់កាលនៃការឃុំខ្លួន និងអាចទាក់ទងជាមួយមេធាវីយ៉ាងឆាប់រហ័សតាមដែលអាចធ្វើទៅបាន។ រយៈពេលកំណត់ ៣០ នាទីសម្រាប់ការទាក់ទងនោះគួរតែត្រូវបានបន្លាយ ឬដកចេញទាំងស្រុងពីមាត្រា ៩៨។
- រាជរដ្ឋាភិបាលកម្ពុជាគួរស្នើវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីបញ្ចូលការទាមទារឲ្យការសួរចម្លើយទាំងអស់ និងការទទួលយកចម្លើយសារភាពដែលបានមកពីការសួរចម្លើយនោះត្រូវបានថតជាវីដេអូ និងផ្តល់ធនធានបន្ថែមដើម្បីឲ្យដំណើរការនេះអាចប្រព្រឹត្តទៅបាន។
- ក្នុងរយៈពេលដែលរង់ចាំការកែប្រែច្បាប់ខាងលើ មន្ត្រីនគរបាលយុត្តិធម៌ និងចៅក្រមស៊ើបសួរគួរតែធានាថារាល់ការសួរចម្លើយ និងចម្លើយសារភាពដែលបានមកពីការសួរចម្លើយនោះ ត្រូវបានថតជាវីដេអូ ឬត្រូវបានធ្វើឡើងដោយមានវត្តមានមេធាវីរបស់ជនជាប់ចោទ។ រាជរដ្ឋាភិបាលកម្ពុជាគួរចាត់ការឲ្យរហ័ស បង្កើតយន្តការបង្ការថ្នាក់ជាតិដើម្បីស៊ើបអង្កេតបណ្តឹងរួមទាំងអំណះអំណាងអំពីការធ្វើទារុណកម្ម ប្រឆាំងនឹងនគរបាល មន្ត្រីពន្ធនាគារ និងមន្ត្រីអនុវត្តច្បាប់ដទៃទៀត ដើម្បីសង្កេតការឃុំខ្លួន និងផ្តល់ជាអនុសាសន៍ដល់រាជរដ្ឋាភិបាល។ យន្តការបង្ការថ្នាក់ជាតិគួរតែត្រូវបង្កើតឡើងស្របតាមមាត្រា ១៧ និង ១៨ នៃពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងទារុណកម្ម ដែលទាមទារឲ្យស្ថាប័ន ឬយន្តការនេះមានឯករាជ្យពីរដ្ឋាភិបាល។
- រាជរដ្ឋាភិបាលកម្ពុជាគួរចេញនូវសេចក្តីថ្លែងការណ៍ ទទួលយកយុត្តាធិការរបស់គណៈកម្មាធិការប្រឆាំងនឹងទារុណកម្ម អនុលោមតាមមាត្រា ២២ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម ក្នុងការទទួល និងពិចារណាលើបណ្តឹងដែលមកពី និងក្នុងនាមបុគ្គលជនរងគ្រោះនៃអំពើទារុណកម្ម ឬការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។
- រាជរដ្ឋាភិបាលកម្ពុជា និងព្រះរាជអាជ្ញា គួរតែអនុវត្តគោលការណ៍មិនអត់ឱនចំពោះការធ្វើទារុណកម្ម និងទង្វើមិនត្រឹមត្រូវ ដែលប្រព្រឹត្តដោយមន្ត្រីអនុវត្តច្បាប់។ គេត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់ និងមិនលំអៀងលើរាល់ការអះអាងអំពីទង្វើមិនត្រឹមត្រូវទាំង នោះ។ ការធ្វើទារុណកម្មគួរតែនាំឲ្យមានការកាត់ទោសជនដែលទទួលខុសត្រូវ និងផ្អាកការងារនៅពេលដែលរង់ចាំលទ្ធផលនៃការកាត់ទោស។

- ប្រសិនបើចម្លើយសារភាពមិនត្រូវបានថតជាវីដេអូ ឬធ្វើឡើងដោយមានវត្តមានមេធាវី ហើយក្រោយមកជនជាប់ចោទប្រកែកមិនទទួលស្គាល់ចម្លើយសារភាពនោះ ដោយអះអាងថាមានការប្រព្រឹត្តទង្វើមិនត្រឹមត្រូវ ចៅក្រមជំនុំជម្រះគួរតែបដិសេធមិនទទួលយកចម្លើយសារភាពនោះជាភស្តុតាង។

# សិទ្ធិជនជាប់ចោទជាអនីតិជន

នៅក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ជាទូទៅ"អនីតិជន"ជាជនទាំងឡាយណា ដែលមានអាយុនៅក្រោម ១៨ឆ្នាំ។[85] អនីតិជនដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសមានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដូចទៅនឹងនីតិជនដែរ ព្រមទាំងទទួលបានការការពារបន្ថែមសមស្របទៅតាមអាយុ ការដឹងខុសត្រូវ និងការវិវត្តសតិបញ្ញារបស់ក្មេង។ គោលបំណងបឋមនៃយុត្តិធម៌អនីតិជនគួរតែជាការស្តារនីតិសម្បទារឡើងវិញ និងបញ្ចូលជនល្មើសទៅក្នុងសង្គម ដើម្បីឲ្យក្លាយជាសមាជិកម្នាក់មានប្រយោជន៍នៅក្នុងសង្គម។ គណៈកម្មាធិការសិទ្ធិកុមារបានសង្ខេបថា៖

*"កុមារខុសពីមនុស្សពេញវ័យ នៅក្នុងការវិវត្តផ្នែកចិត្តសាស្ត្រ និងរាងកាយ ព្រមទាំងតម្រូវការផ្នែកសតិអារម្មណ៍ និងការផ្នែកអប់រំ។ ភាពខុសគ្នានេះជាមូលដ្ឋានសម្រាលពិរុទ្ធភាពនៃកុមារដែលទំនាស់ជាមួយច្បាប់។ ភាពខុសគ្នាទាំងនេះ និងភាពខុសគ្នាដទៃទៀត គឺជាមូលហេតុដែលនាំឲ្យមានប្រព័ន្ធយុត្តិធម៌អនីតិជនដាច់ដោយឡែក និងតម្រូវឲ្យមានការអនុវត្តខុសគ្នាចំពោះកុមារ។ ការការពារផលប្រយោជន៍សំខាន់បំផុតរបស់កុមារ គោលបំណងនៃយុត្តិធម៌ព្រហ្មទណ្ឌដែលមានពីមុន ដូចជា ការបង្ក្រាប/ ការដាក់ទោស បានប្រែក្លាយទៅជាគោលបំណងស្តារនីតិសម្បទា និងស្តាបនាឡើងវិញ នៅពេលដែលដោះស្រាយជាមួយជនល្មើសជាកុមារ។ គោលបំណងនេះអាចធ្វើទៅបានរួមជាមួយនឹងការយកចិត្តទុកដាក់ទៅលើសន្តិសុខសាធារណៈ។"*[86]

## មូលដ្ឋានច្បាប់

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ បានចែងបទប្បញ្ញត្តិជាក់លាក់សម្រាប់អនុវត្តលើអនីតិជននៅក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ ដែលគាំទ្រដោយវិធានច្បាប់ និងគោលការណ៍អន្តរជាតិមួយចំនួន។[87] នៅប្រទេសកម្ពុជា មាត្រា ៣១ និង ៤៨ នៃ

---

[85] មាត្រា ១ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។ គណៈកម្មាធិការសិទ្ធិកុមារ កថាខ័ណ្ឌទី៣៦ នៃ*បទអត្ថាធិប្បាយទូទៅលេខ១០៖ សិទ្ធិកុមារនៅក្នុងវិស័យយុត្តិធម៌អនីតិជន*។

[86] គណៈកម្មាធិការសិទ្ធិកុមារ កថាខ័ណ្ឌ១០ នៃ*បទអត្ថាធិប្បាយទូទៅលេខ១០៖ សិទ្ធិកុមារនៅក្នុងវិស័យយុត្តិធម៌អនីតិជន*។

[87] មហាសន្និបាតអង្គការសហប្រជាជាតិ - សេចក្តីប្រកាសស្តីពីសិទ្ធិកុមារ អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៥៩។ មហាសន្និបាតអង្គការសហប្រជាជាតិ - សេចក្តីណែនាំរបស់អង្គការសហប្រជាជាតិស្តីពីការបង្ការអនីតិជនប្រព្រឹត្តបទល្មើស (គោលការណ៍ រីយាត អនុម័តដោយសេចក្តី

រដ្ឋធម្មនុញ្ញ បានទទួលស្គាល់យ៉ាងច្បាស់លាស់នូវអនុសញ្ញាស្តីពីសិទ្ធិកុមារ និងធានាថា រដ្ឋគួរតែការពារសិទ្ធិកុមារ ហើយនៅក្នុងក្របខ័ណ្ឌច្បាប់ក៏គួរតែមានបទប្បញ្ញត្តិ ដែលបែងចែកដាច់ដោយឡែកនូវការអនុវត្តទៅលើអនីតិជននៅក្នុងផ្នែកសំខាន់ៗមួយចំនួន។

## យុទ្ធសាស្ត្រទូទៅ

អនុសញ្ញាស្តីពីសិទ្ធិកុមារចែងថា រដ្ឋត្រូវអនុម័តច្បាប់ និងនីតិវិធីដែលចែងអំពីអាយុអប្បបរមា កុមារដែលមានអាយុក្រោមអាយុអប្បបរមានេះ កុមារនឹងត្រូវបានសន្មតថាគ្មានសមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។[88] មាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌចែងថានីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់អាយុចាប់ពី១៨ ឆ្នាំឡើងទៅ។ ដូច្នេះច្បាប់កម្ពុជាទទួលស្គាល់អនីតិជនថាជាជនទាំងឡាយណាដែលមានអាយុក្រោម ១៨ឆ្នាំ។

នៅពេលដែលមានបទល្មើសកើតឡើង ជនដែលមានអាយុក្រោម ១៤ឆ្នាំ មិនអាចត្រូវបានកាត់ទោស ឬជំនុំជម្រះនៅចំពោះមុខតុលាការឡើយ។ អនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ ១៨ឆ្នាំ នៅតែជាកម្មវត្ថុនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ប៉ុន្តែមិនទទួលខុសត្រូវពេញលេញនោះទេ លើកលែងតែករណីពិសេស។ មាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌ បានបង្កើតសច្ចធារណ៍ប្រឆាំងនឹងការផ្តន្ទាទោសអនីតិជន ដោយចែងថា "*អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ។ ប៉ុន្តែតុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។*"

មាត្រា ៣(១) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារចែងថា ផលប្រយោជន៍សំខាន់របស់កុមារត្រូវតែស្ថិតនៅក្នុងការពិចារណាដំបូងបង្អស់នៅក្នុងគ្រប់សកម្មភាពទាក់ទងនឹងកុមារ រួមមានសកម្មភាពដែលអនុវត្តដោយតុលាការ ស្ថាប័នរដ្ឋបាល ឬនីតិបញ្ញត្តិ។ បទដ្ឋានអន្តរជាតិភាគច្រើនជំរុញឲ្យរដ្ឋបង្កើតនីតិវិធី និងស្ថាប័នពិសេស ឬដាច់ដោយឡែក សម្រាប់ដោះស្រាយករណីដែលកុមារត្រូវបានចោទ

---

សម្រេចរបស់អង្គមហាសន្និបាតលេខ ៤៥ /១១២ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩០។ មហាសន្និបាតអង្គការសហប្រជាជាតិ - វិធានអប្បបរមានៃបទដ្ឋានអង្គការសហប្រជាជាតិសម្រាប់រដ្ឋបាលយុត្តិធម៌អនីតិជន (វិធានក្រុងប៉េកាំង) អនុម័តដោយសេចក្តីសម្រេចរបស់អង្គមហាសន្និបាតលេខ៤០/៣៣ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥។

[88] មាត្រា ៤០(៣)(ក) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

ប្រកាន់ ឬត្រូវបានរកឃើញថាមានពិរុទ្ធភាពដោយបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។[89] មាត្រា ៤០(១) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារចែងថា រដ្ឋភាគីទទួលស្គាល់សិទ្ធិកុមារគ្រប់រូបជាប់ចោទថាបានប្រព្រឹត្តល្មើសនឹងច្បាប់ព្រហ្មទណ្ឌ " *មានសិទ្ធិទទួលបានការគិតគូរឲ្យបានសមស្របទៅនឹងការលើកស្ទួយ ការយល់របស់កុមារអំពីសេចក្តីថ្លៃថ្នូរនឹងតម្លៃរបស់ខ្លួន ដើម្បីពង្រឹងកុមារឲ្យចេះគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានរបស់អ្នកដទៃ និងយកមកគិតនូវអាយុរបស់កុមារ ព្រមទាំងសេចក្តីប្រាថ្នាចង់បញ្ចូលកុមារមកក្នុងសង្គមវិញ និងចង់ឲ្យកុមារមានតួនាទីស្ថាបនានៅក្នុងសង្គម។"*

## ការឃុំខ្លួន

នៅពេលដែលអនីតិជនត្រូវបានឃុំខ្លួន សំណុំរឿងរបស់ពួកគេគួរតែត្រូវបានផ្តល់អាទិភាព និងលើកយកមកជំនុំជម្រះឲ្យបានលឿនតាមដែលអាចធ្វើទៅបាន ដើម្បីធានាថា ការឃុំខ្លួនបណ្តោះអាសន្នមានរយៈពេលខ្លីតាមតែអាចធ្វើទៅបាន។ រដ្ឋភាគីក៏ត្រូវបង្កើតឲ្យមានអាយុអប្បបរមាដែលនៅក្រោមនោះ សិទ្ធិសេរីភាពរបស់កុមារមិនត្រូវបានដកហូត។[90] មាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា អនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ ពុំអាចត្រូវបានគេឃាត់ខ្លួនឡើយ។ មាត្រានេះក៏បានចែងអំពីរយៈពេលឃុំខ្លួនអតិបរមាសម្រាប់អនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ ១៨ឆ្នាំ ដែលមានរយៈពេលតិចជាងនីតិជន នឹងមិនអាចពន្យាពេលបានដូចករណីនីតិជននោះឡើយ។ មាត្រា ១០០ ចែងថា កាលណាបុគ្គលដែលត្រូវបានឃាត់ខ្លួនជាអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ឪពុកម្តាយ ដល់អ្នកតំណាងស្របច្បាប់ ឬដល់អ្នកទទួលភារកិច្ចលើអនីតិជននេះ។

មាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានបង្កើតសច្ចធារណ៍ច្បាប់ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្នសម្រាប់គ្រប់ជនត្រូវចោទ ដោយមិនគិតពីអាយុរបស់ពួកគេ ដោយចែងថា៖ "*ជាគោលការណ៍ ជនត្រូវចោទត្រូវនៅមានសេរីភាព។ ក្នុងករណីពិសេសជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្តោះអាសន្ន នៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងផ្នែកនេះ*"។ មាត្រា ២១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា អនីតិជនអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ មិនអាចត្រូវឃុំខ្លួនបណ្តោះអាសន្នទេ។ ចៅក្រមស៊ើបសួរ

[89] ឧទាហរណ៍មាត្រា ៤០(៣)(ខ) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ចែងថារដ្ឋភាគីត្រូវខិតខំលើកស្ទួយការបង្កើតច្បាប់ នីតិវិធី អាជ្ញាធរ និងស្ថាប័ន ជាពិសេសសម្រាប់អនុវត្តទៅលើកុមារដែលត្រូវបានចោទប្រកាន់ថាបានរំលោភច្បាប់ព្រហ្មទណ្ឌ។

[90] មហាសន្និបាតអង្គការសហប្រជាជាតិ - វិធាន ១១(ក) នៃវិធានអង្គការសហប្រជាជាតិស្តីពីការការពារអនីតិជនដែលត្រូវបានដកហូតសេរីភាព (A/RES/45/113) ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩០។

អាចសម្រេចប្រគល់អនីតិជននេះឲ្យអ្នកអាណាព្យាបាល ឬក្នុងករណីគ្មានអ្នកអាណាព្យាបាល ត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្តោះអាសន្ន រង់ចាំសេចក្តីសម្រេចរបស់តុលាការ។ មាត្រា ១៦៦ នៃក្រមព្រហ្មទណ្ឌចែងអំពីលក្ខខណ្ឌនៃការឃុំខ្លួនអនីតិជននៅក្នុងពន្ធនាគារថា "*អនីតិជនដែលជាប់ពន្ធនាគារ ត្រូវឃុំខ្លួននៅកន្លែងពិសេស ខណ្ឌដាច់ពីនីតិជន។ អនីតិជនស្ថិតនៅក្រោមរបបដោយឡែកជាឯកត្តបុគ្គល ដែលជាកន្លែងសម្រាប់អប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។*" គណៈកម្មាធិការសិទ្ធិកុមារបានកត់សម្គាល់ថា "*មានភស្តុតាងជាច្រើនបង្ហាញថា ការឃុំខ្លួនកុមារជាមួយនឹងមនុស្សពេញវ័យនៅក្នុងពន្ធនាគារ ឬមន្ទីរឃុំឃាំង ធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ ការរីកលូតលាស់ និងលទ្ធភាពអនាគតរបស់ពួកគេរួចផុតពីការប្រព្រឹត្តបទល្មើស និងចូលរួមក្នុងសង្គមវិញ។*"[91]

## ការជំនុំជម្រះ

នៅក្នុងករណីដែលសមស្រប គេគួរតែដោះស្រាយជាមួយជនល្មើសអនីតិជន ដោយមិនប្រើការជំនុំជម្រះជាផ្លូវការ ដោយគោរពយ៉ាងពេញលេញនូវសិទ្ធិមនុស្ស និងការធានាផ្លូវច្បាប់នានា ដូចជាការសន្មតជាមុនថាគ្មានទោស។ វិធានផ្សេងទៀតក្រៅពីនីតិវិធីព្រហ្មទណ្ឌ ដូចជាសន្ទានកម្មរវាងចារី និងជនរងគ្រោះ ការប្រជុំជាមួយគ្រួសាររបស់ចារី ការផ្តល់ការប្រឹក្សា បំពេញកិច្ចការសហគមន៍ ឬកម្មវិធីអប់រំ គួរតែត្រូវបានពិចារណា។[92] ក្រមព្រហ្មទណ្ឌបានបង្កើតនូវសច្ចធារណ៍ច្បាប់អនុញ្ញាតឲ្យមានជម្រើសផ្សេងពីការឃុំខ្លួនសម្រាប់អនីតិជននៅក្នុងមាត្រា ៣៩។

នីតិវិធីព្រហ្មទណ្ឌដែលទាក់ទងនឹងការយកចិត្តទុកជាពិសេសចំពោះអនីតិជន គួរតែធានាថាអនីតិជនត្រូវបានប្រាប់ដោយផ្ទាល់ឲ្យដឹងអំពីបទចោទប្រកាន់ប្រឆាំងនឹងខ្លួន។ នៅក្នុងដំណើរការនីតិវិធីតុលាការទាំងមូល អនីតិជនមានសិទ្ធិមានមេធាវី និងទទួលបានជំនួយសមស្របពីសំណាក់ឪពុកម្តាយ ឬអាណាព្យាបាលរបស់ខ្លួន ក្នុងការរៀបចំ និងបង្ហាញការការពារក្តី។ កុមារដែលមានសមត្ថភាពអាចបញ្ចេញទស្សនៈយល់ឃើញរបស់ខ្លួន គួរតែទទួលបានឱកាសបញ្ចេញទស្សនៈរបស់ខ្លួននៅក្នុងនីតិវិធីតុលាការដែលទាក់ទងនឹងខ្លួន ដោយផ្ទាល់ ឬតាមរយៈតំណាង។[93] ដើម្បីការពារភាពឯកជន

[91] គណៈកម្មាធិការសិទ្ធិកុមារ - កថាខណ្ឌទី៨៥ នៃ*បទអត្ថាធិប្បាយទូទៅលេខ១០៖ សិទ្ធិកុមារនៅក្នុងវិស័យយុត្តិធម៌អនីតិជន។*

[92] មាត្រា៤០(៣)(ខ) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ - កថាខណ្ឌ ៨៤ នៃ*បទអត្ថាធិប្បាយទូទៅលេខ៣២៖ មាត្រា១៤ - សិទ្ធិស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។*

[93] មាត្រា ១២ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

របស់កុមារ សវនាការ ឬការជំនុំជម្រះដែលមានអនីតិជនចូលរួម ជាទូទៅគួរតែត្រូវបានធ្វើឡើងជាអសាធារណៈ។[94]

## សេចក្ដីសម្រេច

មាត្រា ១៤ (១) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានចែងយ៉ាងច្បាស់ថា ការចេញសាលក្រមអាចត្រូវបានប្រកាសជាអសាធារណៈ *"នៅពេលដែលផលប្រយោជន៍អនីតិជនតម្រូវឲ្យធ្វើដូច្នេះ។"* ការយកចិត្តទុកដាក់ការពារភាពឯកជនរបស់ជនជាប់ចោទជាអនីតិជនបូករួមទាំងការជៀសវាងមិនធ្វើឲ្យកុមារក្លាយជាមនុស្សគ្មានតម្លៃក្នុងសង្គម និងបង្កើនលទ្ធភាពស្ដារនីតិសម្បទាឡើងវិញ។។

## ការដាក់ទោស

គណៈកម្មាធិការសិទ្ធិកុមារបានកត់សម្គាល់ថា *"សេចក្ដីសម្រេចផ្ដួចផ្ដើមបង្កើតនីតិវិធីព្រហ្មទណ្ឌផ្លូវការមួយ មិនមែនមានន័យថា នីតិវិធីនេះត្រូវតែធ្វើឡើងនៅក្នុងតុលាការ ដើម្បីដាក់ទោសកុមារនោះឡើយ។"*[95] គណៈកម្មាធិការបានសង្កត់ធ្ងន់ថា អាជ្ញាធរមានសមត្ថកិច្ច ដែលនៅក្នុងប្រទេសភាគច្រើនជាស្ថាប័នអយ្យការ គួរតែបន្តស្វែងរកជម្រើសផ្សេងក្រៅពីការដាក់ទោសដោយតុលាការ។ ជម្រើសទាំងនេះមានដូចជា ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ឬចូលរួមក្នុងស្ថាប័នអប់រំ គួរតែត្រូវបានអនុវត្តចំពោះកុមារ ដើម្បីផ្អាកនូវនីតិវិធីព្រហ្មទណ្ឌ/អនីតិជនផ្លូវការ ដែលនឹងត្រូវបញ្ចប់ ប្រសិនបើការអនុវត្តវិធានការណ៍ទាំងនេះទទួលបាននូវលទ្ធផលគួរជាពេញចិត្ត។[96] វិធានការណ៍ទាំងនេះមានចែងនៅក្នុងមាត្រា ៣៩-៤១ នៃក្រមព្រហ្មទណ្ឌ។

ការដាក់ពិន័យត្រូវសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរ និងកាលៈទេសៈនៃការប្រព្រឹត្តបទល្មើស ព្រមទាំងអាយុ ការកាត់បន្ថយការទទួលខុសត្រូវ កាលៈទេសៈ សេចក្ដីត្រូវការរបស់ក្មេង ព្រមទាំងគោលបំណងលើកកម្ពស់ការស្ដារនីតិសម្បទា និងការចូលរួមក្នុងសង្គម ដើម្បីជាប្រយោជន៍វែងឆ្ងាយនៃ

---

[94] មាត្រា ១៤(១) នៃកតិការសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថាសារព័ត៌មាន និងសាធារណៈជនអាចមិនឲ្យចូលរួមទាំងស្រុង ឬផ្នែកមួយនៃសវនាការ នៅពេលដែលផលប្រយោជន៍នៃជីវិតឯកជនរបស់គូភាគីតម្រូវឲ្យធ្វើដូច្នេះ។ សូមមើលផងដែរ គណៈកម្មាធិការសិទ្ធិកុមារ - កថាខណ្ឌ ៦៥-៦៦ នៃ*បទអត្ថាធិប្បាយទូទៅលេខ១០៖ សិទ្ធិកុមារនៅក្នុងវិស័យយុត្តិធម៌អនីតិជន*។

[95] គណៈកម្មាធិការសិទ្ធិកុមារ - កថាខណ្ឌ ៦៨ នៃ*បទអត្ថាធិប្បាយទូទៅលេខ១០៖ សិទ្ធិកុមារនៅក្នុងវិស័យយុត្តិធម៌អនីតិជន*។

[96] ដូចខាងលើ។

សង្គម។[97] ដូចដែលបានលើកឡើងខាងលើ មាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌបានបង្កើតសច្ចធារណ៍ច្បាប់ប្រឆាំងនឹងការផ្តន្ទាទោស និងដាក់ពន្ធនាគារអនីតិជន លើកលែងតែ "*កាលៈទេសៈនៃការប្រព្រឹត្តបទល្មើស ឬបុគ្គលិកលក្ខណៈអនីតិជនតម្រូវឲ្យ*" មានការផ្តន្ទាទោសព្រហ្មទណ្ឌ។ មាត្រា ១៦០-១៦៥ នៃក្រមព្រហ្មទណ្ឌបានចែងយ៉ាងច្បាស់អំពីការដាក់ពិន័យទៅលើអនីតិជន។ ការផាកពិន័យជាអតិបរមា និងរយៈពេលនៃការដាក់ពន្ធនាគារ ត្រូវកាត់បន្ថយពាក់កណ្តាលសម្រាប់អនីតិជន[98] និងបទប្បញ្ញត្តិទាក់ទងទៅនឹងការមិនរាងចាលដែលអនុវត្តចំពោះនីតិជន មិនត្រូវបានអនុវត្តចំពោះអនីតិជនឡើយ។[99] មាត្រា ១៦៥ បានចែងអំពីកាតព្វកិច្ចដោយឡែកមួយចំនួន ដែលតុលាការអាចដាក់ឲ្យអនីតិជនអនុវត្តនៅក្នុងអំឡុងពេលព្យួរទោសសាកល្បង។

## ទិន្នន័យ និងការវិភាគ

### អាយុដែលទទួលខុសត្រូវព្រហ្មទណ្ឌ

នៅក្នុងចំណោមសវនាការចំនួន ៣៧៦ ដែលបានសង្កេតនៅឯតុលាការក្រុងភ្នំពេញ មានសវនាការចំនួន ៤០ ដែលជាប់ទាក់ទងនឹងអនីតិជន (ប្រមាណ ១១%)។ ភាគច្រើននៃសវនាការទាំងនេះ (៨០%) ទាក់ទងនឹងបទល្មើសឧក្រិដ្ឋ។ នៅក្នុងសវនាការចំនួន ២ ជនជាប់ចោទមានអាយុក្រោមអាយុអប្បបរមានៃការទទួលខុសត្រូវព្រហ្មទណ្ឌ នៅពេលប្រព្រឹត្តបទល្មើស។ ការប្រកាសសាលក្រមត្រូវបានពន្យារពេលនៅក្នុងសវនាការមួយក្នុងចំណោមសវនាការទាំងនេះ មន្រ្តីសង្កេតការណ៍សវនាការមិនអាចទទួលបានព័ត៌មានអំពីការដាក់ទោស។ នៅក្នុងសវនាការមួយទៀត ជនជាប់ចោទអនីតិជនត្រូវបានសម្រេចឲ្យរួចខ្លួន ដោយសារតែការទទួលស្គាល់អាយុរបស់គេនៅពេលប្រព្រឹត្តបទល្មើស ប៉ុន្តែមិនត្រូវបានដោះលែងនៅមុនពេលឃុំខ្លួនបណ្តោះអាសន្នរយៈពេល ៥ខែ នោះទេ។ នៅក្នុងចំណោមសវនាការចំនួន ១៥៦ ដែលបានសង្កេតនៅតុលាការខេត្តកណ្តាល មានសវនាការចំនួន ៦ (ស្មើនឹង ៤%) ជាប់ទាក់ទងនឹងអនីតិជន។ សវនាការទាំងនេះភាគច្រើន (៨០%) ទាក់ទងនឹងបទល្មើសមជ្ឈិម។ អនីតិជនទាំងអស់ដែលត្រូវបានជំនុំជម្រះទោសនៅតុលាការខេត្តកណ្តាល មានអាយុចាប់ពី ១៤ ឆ្នាំ ដល់ ១៨ ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស។

---

[97] គណៈកម្មាធិការសិទ្ធិកុមារ - កថាខណ្ឌ ៧១ នៃ*បទអត្ថាធិប្បាយទូទៅលេខ១០៖ សិទ្ធិកុមារនៅក្នុងវិស័យយុត្តិធម៌អនីតិជន*។

[98] មាត្រា១៦០នៃក្រមព្រហ្មទណ្ឌ។

[99] មាត្រា១៦៣នៃក្រមព្រហ្មទណ្ឌ។

## ការឃុំខ្លួនបណ្ដោះអាសន្ននៃអនីតិជន

នៅក្នុងចំណោមសវនាការចំនួន ៤០ ដែលពាក់ព័ន្ធនឹងអនីតិជន នៅតុលាការក្រុងភ្នំពេញ ជនជាប់ចោទជាអនីតិជនទាំងអស់ត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន លើកលែងតែសវនាការមួយប៉ុណ្ណោះដែលអនីតិជនមិនត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន។ ការឃុំខ្លួនបណ្ដោះអាសន្ននេះមានចំនួនលើសពីអត្រាទូទៅនៃការឃុំខ្លួនបណ្ដោះអាសន្ន ដែលបានសង្កេតនៅតុលាការទាំងពីរនៅក្នុងអំឡុងពេលរបាយការណ៍ទី២។ ការព្រួយបារម្ភនេះទាក់ទងជាពិសេសទៅនឹងសច្ចធារណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងមាត្រា ២០៣ នៃក្រមព្រហ្មទណ្ឌ និងការទាមទាររបស់ច្បាប់ និងបទដ្ឋានអន្តរជាតិ ដែលចែងថា ការឃុំខ្លួនអនីតិជននៅមុនពេលសវនាការ *"ត្រូវប្រើសម្រាប់តែវិធានការចុងក្រោយប៉ុណ្ណោះ"*[100] ហើយថា *"ត្រូវខិតខំប្រឹងប្រែងអនុវត្តនូវវិធានការណ៍ដទៃទៀត"*។[101] ក្នុងចំណោមសវនាការដែលបានសង្កេតមានតែសវនាការចំនួន ១ ប៉ុណ្ណោះដែលក្នុងនោះជនជាប់ចោទត្រូវបានចាប់ខ្លួន ប៉ុន្តែក្រោយមកត្រូវបានដោះលែងរង់ចាំសវនាការ។

នៅក្នុងចំណោមសវនាការចំនួន៦ ទាក់ទងនឹងអនីតិជន ដែលបានសង្កេតនៅតុលាការខេត្តកណ្ដាល មានសវនាការចំនួន ៥ ដែលក្នុងនោះអនីតិជនត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន ។ នៅក្នុងសវនាការផ្សេងទៀត ជនជាប់ចោទមិនត្រូវបានចាប់ខ្លួន និងត្រូវបានកោះហៅឲ្យបង្ហាញខ្លួននៅក្នុងសវនាការ។ យើងគួរកត់សម្គាល់ផងដែរថា នៅក្នុងសវនាការដែលបានសង្កេតនៅក្នុងតុលាការក្រុងភ្នំពេញ អនីតិជនភាគច្រើនត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ខណៈដែលនៅក្នុងសវនាការដែលបានសង្កេតនៅខេត្តកណ្ដាល អនីតិជនភាគច្រើនត្រូវបានចោទប្រកាន់ពីបទមជ្ឈឹម។

នៅក្នុងចំណោមសវនាការចំនួន ៤៦ ដែលទាក់ទងនឹងអនីតិជន គ្មានករណីណាមួយដែលបង្ហាញថាជនជាប់ចោទ ឬភាគីជនជាប់ចោទបានលើកឡើងថា ជនជាប់ចោទមិនត្រូវបានឃុំខ្លួនបណ្ដោះអាសន្នដាច់ដោយឡែកនីតិជននោះឡើយ។

## ទោសមិនមែនពន្ធនាគារសម្រាប់អនីតិជន

មន្ត្រីសង្កេតការណ៍សវនាការអាចទទួលបានព័ត៌មានអំពីសាលក្រម និងការផ្ដន្ទាទោសនៅក្នុងសវនាការចំនួន ៣០ នៅក្នុងចំណោមសវនាការដែលបានសង្កេតចំនួន ៤៦ ពាក់ព័ន្ធនឹងអនីតិជន។ នៅក្នុងចំណោមសវនាការទាំងនេះ មានសវនាការចំនួន ១ ដែលក្នុងនោះអនីតិជនត្រូវបានកាត់ឲ្យរួចទោស។ នៅក្នុងសវនាការចំនួន ២៩ ផ្សេងទៀត គ្មានតម្រុយណាមួយបង្ហាញថាចៅក្រមពិចារណាទៅលើទោសមិនមែនពន្ធនាគារឡើយ អនីតិជនត្រូវបានរកឃើញថាមានពិរុទ្ធភាព និងផ្ដន្ទាទោសដាក់

[100] មាត្រា ៣៧(ខ) នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ។

[101] អង្គមហាសន្និបាតអង្គការសហប្រជាជាតិ - វិធានទី១៧ នៃ*វិធានអង្គការសហប្រជាជាតិសម្រាប់ការពារអនីតិជនដែលត្រូវបានដកហូតសេរីភាព*។ អង្គមហាសន្និបាតអង្គការសហប្រជាជាតិ - វិធានទី១៣ នៃ*វិធានបទដ្ឋានអប្បបរមាអង្គការសហប្រជាជាតិសម្រាប់គ្រប់គ្រងវិស័យយុត្តិធម៌អនីតិជន* (វិធានក្រុងប៉េកាំង)។

ពន្ធនាគារ។ សំណុំរឿងចំនួន ២ ផ្សេងទៀត ត្រូវបានបញ្ជូនឲ្យស៊ើបសួរម្តងទៀត នៅខណៈដែលសវនាការចំនួន ១៤ ផ្សេងទៀត គ្មានព័ត៌មានទាក់ទងនឹងសាលក្រម និងការផ្តន្ទាទោស ។

មាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌ បានបង្កើតនូវសច្ចធារណ៍ច្បាប់ប្រឆាំងនឹងទណ្ឌកម្ម និងការដាក់ទោសពន្ធនាគារលើអនីតិជន ដោយបានចែងថា អនីតិជនដែលប្រព្រឹត្តបទល្មើស *"ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ"* តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជន *"ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ"*។ ប៉ុន្តែ ជម្រើសស្វ័យប្រវត្តិគឺថាការកាត់ទោសព្រហ្មទណ្ឌនឹងមិនត្រូវបានយកមកអនុវត្ត ហើយការពិចារណាទៅលើទោសមិនមែនពន្ធនាគារនឹងត្រូវបានអនុវត្ត។

ការឆ្លើយតបដោយទោសមិនមែនពន្ធនាគារ ដែលចែងនៅក្នុងមាត្រា ៤០ និង ៤១ មានដូចខាងក្រោម៖

- ប្រគល់អនីតិជនទៅឲ្យឪពុកម្តាយ អាណាព្យាបាល អ្នកដែលមានទូនាទីជាអាណាព្យាបាល ឬជនដទៃទៀតដែលគួរឲ្យទុកចិត្តបាន។
- ប្រគល់អនីតិជនឲ្យទៅទីភ្នាក់ងារសេវាសង្គមដែលទទួលថែទាំអនីតិជន។
- ប្រគល់អនីតិជនឲ្យទៅអង្គការឯកជនដែលមានសមត្ថភាពទទួលថែទាំពួកគេ។
- ប្រគល់អនីតិជនឲ្យទៅមន្ទីរពេទ្យជំនាញ ឬ ស្ថាប័នឯកទេសណាមួយ។
- ដាក់អនីតិជនឲ្យនៅស្ថិតនៅក្រោមការការពារដោយតុលាការ។

មាត្រា ១៦៥ បានចែងអំពីកាតព្វកិច្ចដោយឡែកអនុវត្តទៅលើអនីតិជន ក្នុងករណីនៃការព្យួរទោសសាកល្បង រួមបញ្ចូលទាំងកាតព្វកិច្ចនានាក្នុងការទទួលការបង្ហាត់បង្រៀន ឬការបណ្តុះបណ្តាលវិជ្ជាជីវៈ ។ មាត្រា ៩៨ ចែងអំពីទោសជាការងារសហគមន៍ជំនួសឲ្យមូលទោស។ ការឆ្លើយតបផ្លូវច្បាប់ទាំងនេះចំពោះបទល្មើសព្រហ្មទណ្ឌដែលប្រព្រឹត្តដោយអនីតិជន គួរតែត្រូវបានអនុវត្តចំពោះគ្រប់ករណីទាំងអស់ដែលជាករណីពិសេសតម្រូវដោយមាត្រា ៣៩។ ការពិចារណាដែលអាចយកជាការបាន រួមមានឱកាសប្រព្រឹត្តបទល្មើសជាថ្មីម្តងទៀត លទ្ធភាពក្នុងការស្តារនីតិសម្បទា និងភាពគ្រោះថ្នាក់កើតឡើងក្នុងសហគមន៍។ ការឆ្លើយតបចំពោះបទល្មើសត្រូវតែសមាមាត្រ ចំពោះបទល្មើសមជ្ឈិមភាគច្រើនដែលប្រព្រឹត្តដោយជនជាប់ចោទជាអនីតិជន ការឆ្លើយតបគួរតែជាទោសមិនមែនពន្ធនាគារ ក្នុងគោលបំណងបង្ការមិនឲ្យបទល្មើសកើតឡើងជាថ្មីម្តងទៀត។ ប៉ុន្តែការឆ្លើយតបរបៀបនេះ គឺអាស្រ័យទៅលើការពង្រឹងសេវាសង្គម ដែលផ្តល់ដោយរដ្ឋ និងអង្គការឯកជន ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលនានា ។

ស្ថិតនៅក្រោមក្របខណ្ឌច្បាប់ដែលចែងអំពីការអនុវត្តខុសគ្នាទៅលើអនីតិជន ទិន្នន័យនៅក្នុងផ្នែកនេះអាចនឹងបង្ហាញភាពខ្វះចន្លោះនៃធនធាន រចនាសម្ព័ន្ធសង្គម និងយុត្តិធម៌ ដែលគាំទ្រតុលាការក្នុងការអនុវត្តច្បាប់។ ឧទាហរណ៍ នៅក្នុងខណៈដែលច្បាប់បង្កើតសច្ចធារណ៍ថាអនីតិជននឹងមិនត្រូវ

បានឃុំខ្លួននៅពេលរង់ចាំសវនាការ និងមិនគួរទទួលទោសពន្ធនាគារឡើយ ប៉ុន្តែទោសផ្សេងពីនេះ ដូចជាការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ និងបំពេញការងារសហគមន៍ ដែលទាមទារឲ្យមាននីតិវិធីត្រឹមត្រូវ និងធនធានគ្រប់គ្រាន់ ដើម្បីធានាថាជនត្រូវបានសង្កេត និងសេចក្តីបង្គាប់របស់តុលាការស្តារនីតិសម្បទាត្រូវបានគោរព។ វិធីសាស្ត្រសហការណ៍នៅក្នុងផ្នែកនេះ ជាមួយរដ្ឋាភិបាល និងដៃគូ ដូចជាម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការឯកជន ត្រូវបានផ្តល់ជាអនុសាសន៍ ដើម្បីធានានូវការអភិវឌ្ឍដំណើរការយុត្តិធម៌អនីតិជនដ៏មានប្រសិទ្ធិភាព ដែលសង្កត់ធ្ងន់ទៅលើការធានាថាកុមារដែលរំលោភច្បាប់ទទួលបានការគាំទ្រគ្រប់គ្រាន់ ដើម្បីក្លាយជាសមាជិកមានប្រយោជន៍នៅក្នុងសង្គម។

## ករណីសិក្សាទី ៣ ៖ ការផ្តន្ទាទោសជនជាប់ចោទជាអនីតិជន

**តុលាការ** ៖ តុលាការរាជធានីភ្នំពេញ
**កាលបរិច្ឆេទសង្កេតការណ៍** ៖ថ្ងៃទី២៩ ខែមិនា ឆ្នាំ២០១០

សវនាការពាក់ព័ន្ធចំពោះជនត្រូវចោទចំនួន ៣នាក់ ដែលក្នុងនោះម្នាក់ជាអនីតិជន។ ជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទប្លន់ ។ ពួកគេត្រូវបានការអះអាងថា បានលួចលុយចំនួន ៥០០០ រៀល និងទូរស័ព្ទដៃមួយពីជនរងគ្រោះដែលកំពុងជិះម៉ូតូនៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៩ នៅវេលាម៉ោង ១២ និង៣០នាទី។ ជនរងគ្រោះបានដាក់ពាក្យបណ្តឹងទៅប៉ូលីស។ ជនជាប់ចោទត្រូវបានចាប់ខ្លួននៅថ្ងៃទី២៤ ខែ តុលា ឆ្នាំ២០០៩។ ជនត្រូវចោទជានីតិជន ២ នាក់ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ៦ ឆ្នាំ រីឯជនជាប់ចោទជាអនីតិជនត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ៣ ឆ្នាំ។

ការផ្តន្ទាទោសអនីតិជននៅក្នុងសវនាការនេះ ឆ្លុះបញ្ចាំងបទប្បញ្ញត្តិនៃមាត្រា ៦៨ នៃច្បាប់អ៊ុនតាក់ ដែលចែងថាយុវភាពនៃអ្នកជាប់ទោសស្ថិតក្នុងស្ថានសម្រាលទោស។ មាត្រា ៦៨(២) ចែងថាទណ្ឌកម្មដែលចែងនៅក្នុងច្បាប់អ៊ុនតាក់ ត្រូវកាត់បន្ថយពាក់កណ្តាល នៅពេលអនុវត្តទៅលើជនជាប់ចោទដែលមានអាយុតិចជាង ១៨ ឆ្នាំ។ ដូច្នេះសេចក្តីសម្រេចនេះគឺត្រឹមត្រូវឈរលើមូលដ្ឋានគោលការណ៍ច្បាប់ទាំងនេះ។

ប៉ុន្តែគោលការណ៍ផ្តន្ទាទោសដែលចែងនៅក្នុងច្បាប់អ៊ុនតាក់ ស្ថិតនៅក្នុងការជជែកវែកញែកអំពីការជំនួសដោយគោលការណ៍ដែលមានចែងនៅក្នុងគន្ថីទី១ នៃក្រមព្រហ្មទណ្ឌ។ មាត្រា ១០ ចែងថាបទប្បញ្ញត្តិថ្មីដែលចែងអំពីទោសដែលស្រាលជាងត្រូវអនុវត្តភ្លាម។ មាត្រានេះនឹងនាំឲ្យមានការអនុវត្តសច្ចធារណ៍ច្បាប់ប្រឆាំងនឹងទណ្ឌកម្មព្រហ្មទណ្ឌ ចំពោះអនីតិជននៅក្នុងមាត្រា ៣៩។ ការដាក់ទោសអនីតិជន ៣ ឆ្នាំក្នុងពន្ធនាគារពីបទចោរកម្មទូរស័ព្ទដៃមួយ និងលុយចំនួន ៥០០០ រៀល មិនមានលក្ខណៈសមាមាត្រទៅនឹងកម្រិតនៃបទល្មើស និងយុវភាពនៃជនជាប់ចោទ និងមិនស្របតាម គោលបំណងលើកកម្ពស់ការស្តារនីតិសម្បទាអនីតិជនដែលជនល្មើសឡើយ។

## ករណីសិក្សាទី ៤ ៖ ការកាត់ជនជាប់ចោទជាអនីតិជនឲ្យរួចទោស

**តុលាការ** ៖តុលាការរាជធានីភ្នំពេញ
**កាលបរិច្ឆេទសង្កេតការណ៍** ៖ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០

កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៩ មនុស្ស ៣ នាក់ត្រូវបានចោទពីបទប្លន់ អនុលោម តាម មាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។ ជនជាប់ចោទម្នាក់ក្នុងចំណោមនោះគឺជាកុមារ (អាយុ ១៤ ឆ្នាំ)។ ប៉ុន្តែ នៅពេលដែលប៉ូលីសចាប់ខ្លួនគាត់ គាត់បាននិយាយថាគាត់មានអាយុ ១៨ឆ្នាំ។ ជនជាប់ចោទទាំង ៣នាក់ បានបដិសេធថាមិនបានប្រព្រឹត្តបទល្មើសប្លន់នេះទេ ហើយបាននិយាយថា ពួកគេមិនដឹងថាបទល្មើសនេះបានកើតឡើងនៅទីណាផងទេ។ ចៅក្រមបានបញ្ជាឲ្យអានកំណត់ហេតុរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានបញ្ជាក់ថា ជនជាប់ចោទទាំង ៣នាក់ បានលបចូលផ្ទះរបស់គាត់ ហើយបានលួចទ្រព្យសម្បត្តិរបស់ គាត់។ ចៅក្រមបានសួរថា “តើអ្នកឯងបានប្រព្រឹត្តបទល្មើសនេះនៅសង្កាត់ទឹកថ្លា ខណ្ឌសែនសុខ មែនដែរឬទេ?” ជនជាប់ចោទបានឆ្លើយថា ពួកគេមិនបានប្រព្រឹត្តបទល្មើសនោះទេ ហើយមិនបានដឹងរឿងអ្វីទាល់តែសោះ។ នៅពេលប្រកាសសាលក្រម ជនជាប់ចោទជាអនីតិជនដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្នក្នុងរយៈពេល ៥ ខែ រួចមកហើយនោះ ត្រូវបានលើកលែងការចោទប្រកាន់។ ចៅក្រមបានលើកយកអនុសញ្ញាស្តីពីសិទ្ធិកុមារ និងសំបុត្រកំណើតមកសំអាងជាភស្តុតាង។ ជនត្រូវចោទជានីតិជន ២នាក់ ទៀតត្រូវបានកាត់ទោស និងផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ៥ ឆ្នាំ ។

នេះគឺជាឧទាហរណ៍គំរូមួយដែលចៅក្រមទទួលស្គាល់អាយុជនជាប់ចោទ ដែលមិនស្ថិតនៅក្រោមការទទួលខុសត្រូវព្រហ្មទណ្ឌ និងបានឆ្លើយតបតាមនោះ។

# អនុសាសន៍

- **ក្រសួងយុត្តិធម៌**គួរតែជាដៃគូជាមួយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គណៈមេធាវីកម្ពុជា និងអង្គការខាងក្រៅ ដូចជាឧត្តមស្នងការអង្គការសហប្រជាជាតិផ្នែក សិទ្ធិមនុស្សប្រចាំនៅកម្ពុជា និង/ឬ អង្គការមិនមែនរដ្ឋាភិបាលដទៃទៀត ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលដល់មេធាវី និងចៅក្រម អំពីការអនុវត្តបទប្បញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌថ្មី ដែលប៉ះពាល់ដល់អនីតិជន ជាពិសេសសច្ចធារណ៍ទណ្ឌកម្មព្រហ្មទណ្ឌ និងការដាក់ពន្ធនាគារ នៅក្នុងមាត្រា ៣៩ និងជម្រើសផ្សេងក្រៅពីការដាក់ទោសពន្ធនាគារ។
- **ក្រសួងយុត្តិធម៌ និងក្រសួងអប់រំ យុវជន និងកីឡា** គួរតែបង្កើតវិធីសាស្ត្រ និងកម្មវិធីនានាដែលផ្តល់ជម្រើសសម្រាប់ការឆ្លើយតបទៅនឹងយុវជនដែលប្រព្រឹត្តល្មើស និងអនុញ្ញាតឲ្យព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរ អាចបង្វែរជនល្មើសជាអនីតិជនពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌផ្លូវការ ។

- **អង្គការមិនមែនរដ្ឋាភិបាល និងអង្គការឯកជននានា**គួរស្វែងរកកិច្ចសហការណ៍ជាដៃគូជាមួយ **តុលាការ ក្រសួងយុត្តធម៌ ក្រសួងអប់រំ យុវជន និងកីឡា** ដើម្បីផ្តល់ការគាំទ្រ និងសេវាស្តារនីតិសម្បទាសម្រាប់យុវជនដែលប្រព្រឹត្តិល្មើសច្បាប់ព្រហ្មទណ្ឌ ផ្តល់មធ្យោបាយផ្សេងទៀតដែលប្រាកដប្រជា និងអាចសម្រេចបាន ពាក់ព័ន្ធនឹងការកាត់ទោសព្រហ្មទណ្ឌ និងទោសពន្ធនាគារ។
- **ចៅក្រមស៊ើបសួរ**គួរតែធានាថាបទប្បញ្ញត្តិច្បាប់ជាតិ និងអន្តរជាតិដែលបង្កើតសច្ចធាណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្នអនីតិជន ត្រូវបានគោរព។ ការឃុំខ្លួនបណ្តោះអាសន្នអនីតិជនត្រូវបានយកមកអនុវត្ត តែក្នុងករណីពិសេសប៉ុណ្ណោះ ព្រមទាំងប្រើជាមធ្យោបាយចុងក្រោយបំផុត និងក្នុងរយៈពេលមួយខ្លីបំផុត។
- **ចៅក្រម** គួរតែធានាថា ការដាក់ពន្ធនាគារអនីតិជនជាមធ្យោបាយចុងក្រោយ និងត្រូវបានជំនួសដោយបទប្បញ្ញត្តិផ្តន្ទាទោសថ្មីនៅក្នុងក្រមព្រហ្មទណ្ឌ ដោយដាក់ទោសមិនមែនពន្ធនាគារ ដែលមានដូចជាការបំពេញការងារសហគមន៍ នៅក្នុងពេលព្យួរទោស ដាក់ក្រោមវិធានការតាមដាន អប់រំ ការពារ និងឧបត្ថម្ភ ដែលចែងនៅក្នុងមាត្រា ៣៩ និង៤០ នៃក្រមព្រហ្មទណ្ឌ។
- **ចៅក្រម** គួរតែយកចិត្តទុកដាក់រក្សាភាពឯកជនរបស់ជនជាប់ចោទអនីតិជននៅក្នុងសេចក្តីសម្រេច។
- ដើម្បីការពារភាពឯកជនរបស់ជនជាប់ចោទអនីតិជន ស្របតាមមាត្រា ៤០(២)(vii) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ **ព្រះរាជអាជ្ញា** គួរតែស្នើសុំ **ចៅក្រម** គួរតែបង្គាប់ឲ្យបើកសវនាការជាអសាធារណៈចំពោះគ្រប់ករណីដែលពាក់ព័ន្ធនឹងជនជាប់ចោទអនីតិជន លើកលែងតែក្នុងករណីពិសេសណាមួយ ដែលនាំឲ្យសេចក្តីសម្រេចនោះមិនត្រឹមត្រូវសមហេតុផល។
- **ក្រសួងមហាផ្ទៃ**គួរកសាងមន្ទីរឃុំឃាំងថ្មី ដើម្បីធានាថាជនជាប់ឃុំជាអនីតិជនទាំងអស់ត្រូវបានឃុំខ្លួនក្នុងកន្លែងពិសេស ដាច់ដោយឡែកពីជនជាប់ឃុំជានីតិជន ស្របតាមមាត្រា ១៦៦ នៃក្រមព្រហ្មទណ្ឌ មាត្រា ១០(២)(ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមាត្រា ៣៧(គ) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។
- **ក្រសួងមហាផ្ទៃ** គួរតែធានាថាមន្ទីរឃុំឃាំងទាំងនោះផ្តល់នូវកម្មវិធីស្តារនីតិសម្បទា រួមមានការអប់រំ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដូចដែលបានរៀបរាប់នៅក្នុងរបាយការណ៍របស់ប្រទេសកម្ពុជាឆ្នាំ ២០០៩ ដាក់ជូនគណៈកម្មាធិការប្រឆាំងនឹងទារុណកម្ម ។

# ៥.សេចក្តីសន្និដ្ឋាន

ទិន្នន័យដែលប្រមូលបានមកពីសវនាការចំនួន ៥៣២ សង្កេតនៅក្នុងអំឡុងពេលរបាយការណ៍ទី ២ បង្ហាញនូវលទ្ធផលចំរុះ ។ ទិន្នន័យបានបង្ហាញថា មានការថយចុះនូវចំនួនសវនាការដែលក្នុងនោះភាគីជនជាប់ចោទ បានលើកឡើងអំពីបញ្ហាពេលវេលានិងមធ្យោបាយមិនគ្រប់គ្រាន់។ អត្រានៃមេធាវីនៅក្នុងសវនាការបទឧក្រិដ្ឋឈានជិតដល់ចំនួន ១០០% ដែលជាចំនួនមួយទាមទារដោយច្បាប់។ ទិន្នន័យបង្ហាញនូវចំនួនករណីតិចតួច ដែលក្នុងនោះចៅក្រមបាននិយាយនូវពាក្យសំដីដែលបង្ហាញការយល់ដឹងមិនពេញលេញអំពីការសន្មតទុកជា មុនថាគ្មានទោស។ ចំណាត់ការលើភស្តុតាង និងសាក្សីដោយតុលាការនៅតែជាចំណុចវិជ្ជមាន ដែលក្នុងនោះភាគីមានឱកាសស្មើគ្នាក្នុងការបង្ហាញភស្តុតាង និងសាកសួរសាក្សី។ ប៉ុន្តែការព្រួយបារម្ភធ្ងន់ធ្ងរនៅតែកើតមានឡើង ពាក់ព័ន្ធនឹងអត្រាខ្ពស់នៃការឃុំខ្លួនបណ្តោះអាសន្ន និងអត្រាទាបនៃមេធាវីសម្រាប់ជនជាប់ចោទដែលត្រូវបានចោទប្រកាន់ពីបទមជ្ឈឹម។ ចៅក្រមបន្តប្រើទូរស័ព្ទដៃនៅក្នុងបន្ទប់សវនាការ ទង្វើនេះអាចនឹងផ្សាភ្ជាប់ទៅនឹងចំនួនសំណុំរឿងច្រើន និងកិច្ចខិតខំប្រឹងប្រែងពិតប្រាកដក្នុងការចាត់ការស៊ើបអង្កេត និងជំនុំជម្រះរឿងក្តីពីរផ្សេងគ្នា។ អំណះអំណាងអំពីទង្វើមិនត្រឹមត្រូវ ដែលរួមមានការគំរាមកំហែង និងការប្រើអំពើហិង្សា និងទារុណកម្ម បន្តជះឥទ្ធិពលទៅលើសវនាការចំនួនបន្តិចបន្តួចប៉ុន្តែជាចំនួនមួយដ៏សំខាន់។

ក្រមព្រហ្មទណ្ឌនឹងចូលជាធរមាននៅក្នុងអំឡុងពេលរបាយការណ៍លើកក្រោយ និងហាក់ដូចជាជះឥទ្ធិពលយ៉ាងសំខាន់ទៅលើប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ ក្រមនេះមានចែងអំពីបទល្មើសព្រហ្មទណ្ឌថ្មីៗមួយចំនួនធំ សម្រាប់ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរ។ ដូចដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះ បទប្បញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌថ្មីបានដាក់ការធ្វើទារុណកម្ម និង "អំពើឃោរឃៅ" ផ្សេងទៀត ដែលប្រព្រឹត្តដោយអាជ្ញាធររដ្ឋាភិបាល ឲ្យនៅក្រៅច្បាប់ និងបង្កើតនូវសច្ចធារណ៍ប្រឆាំងនឹងទណ្ឌកម្មព្រហ្មទណ្ឌលើជនល្មើសអនីតិជន។ ជាការសំខាន់ណាស់ដែលចៅក្រម និងមេធាវីទាំងអស់ផ្សាំខ្លួនឲ្យបានឆាប់រហ័សជាមួយនឹងភាពលំអិតនៃច្បាប់ថ្មី និងចាប់ផ្តើមអនុវត្តបទប្បញ្ញត្តិនៃក្រមនេះចាប់ពីថ្ងៃទី១០ ខែធ្នូ នៅរាជធានីភ្នំពេញ និងថ្ងៃទី២០ ខែធ្នូ នៅទូទាំងប្រទេស នៅពេលដែលបទប្បញ្ញត្តិដែលនៅសេសសល់ចូលជាធរមាន។

អនុសាសន៍នៅក្នុងរបាយការណ៍នេះ ត្រូវបានដាក់ជូនទៅអង្គភាព និងស្ថាប័នមួយចំនួន និងជាថ្មីម្តងទៀត លើកឡើងអំពីភាពជាប់ទាក់ទងគ្នានៅក្នុងប្រព័ន្ធយុត្តិធម៌។ ទោះបីជាការសង្កេតការណ៍សវនាការកើតឡើងតែនៅក្នុងបន្ទប់សវនាការក៏ដោយ ក៏ភាពរីកចម្រើននៃការគោរពសិទ្ធិទាំងឡាយដែលត្រូវបានវិភាគនៅក្នុងរបាយការណ៍នេះទាមទារឲ្យមានកិច្ចសហការណ៍ ការគាំទ្រ និងការដឹកនាំរបស់ក្រុមដទៃទៀត ដូចជាភ្នាក់ងារអនុវត្តច្បាប់ អាជ្ញាធរពន្ធនាគារ និងអង្គការមិនមែនរដ្ឋាភិបាល។ នេះគឺតម្លៃផ្សាភ្ជាប់នៃគម្រោង ប្រមូលទិន្នន័យត្រឹមត្រូវមិនលំអៀងដែលអាចជាមូលដ្ឋានសម្រាប់

បើកកិច្ចពិភាក្សាជាមួយដៃគូពាក់ព័ន្ធ។ កិច្ចសហការរវាងអង្គការទាំងនេះអាចជួយអភិវឌ្ឍប្រព័ន្ធយុត្តិធម៌កម្ពុជា ដើម្បីធានាថាប្រព័ន្ធនេះយុត្តិធម៌ និងផ្តល់យុត្តិធម៌ស្មើគ្នាសម្រាប់ជនគ្រប់រូប។

រាជធានីភ្នំពេញ ខែមីនា ឆ្នាំ២០១១

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

# ៦. គន្លងនិទ្ទេស

## នីតិអន្តរជាតិ

### សន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ

អង្គមហាសន្និបាតអង្គការសហប្រជាជាតិ *សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស* ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ១៩៤៨។

អង្គមហាសន្និបាតអង្គការសហប្រជាជាតិ *កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ* ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦។

អង្គមហាសន្និបាតអង្គការសហប្រជាជាតិ *អនុសញ្ញាប្រឆាំងនឹងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប* ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤។

អង្គមហាសន្និបាតអង្គការសហប្រជាជាតិ *អនុសញ្ញាស្តីពីសិទ្ធិកុមារ* ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩។

អង្គមហាសន្និបាតអង្គការសហប្រជាជាតិ ពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងនឹងទារុណកម្ម (OPCAT) អនុគណៈកម្មាធិការបង្ការទារុណកម្ម ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២។

### ឧបករណ៍ច្បាប់អន្តរជាតិដទៃទៀត

អង្គការសហប្រជាជាតិ *គោលការណ៍មូលដ្ឋានស្តីពីឯករាជ្យភាពនៃប្រព័ន្ធតុលាការ* អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី៧ ស្តីពីការបង្ការបទល្មើស និងការប្រព្រឹត្តទៅលើជនល្មើស រៀបចំឡើងនៅទីក្រុងមីឡាន ពីថ្ងៃទី២៦ ខែសីហា ដល់ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ ១៩៨៥ គាំទ្រដោយសេចក្តីសម្រេចនៃអង្គមហាសន្និបាតលេខ ៤០/៣២ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ និងលេខ ៤០/១៤៦ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៨៥។

អង្គការសហប្រជាជាតិ *គោលការណ៍មូលដ្ឋានស្តីពីតួនាទីមេធាវី* អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី៨ ស្តីពីការបង្ការបទល្មើស និងការប្រព្រឹត្តទៅលើជនល្មើស រៀបចំឡើងនៅទីក្រុងហាវ៉ាណា ប្រទេសគុយបា នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩០។

ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិ *វិធានបទដ្ឋានអប្បបរមានៃការប្រព្រឹត្តទៅលើទណ្ឌិត* ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩០។

ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិ *វិធានបទដ្ឋានអប្បបរមានៃការប្រព្រឹត្តទៅលើទណ្ឌិត* ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៥៥។

អង្គមហាសន្និបាតអង្គការសហប្រជាជាតិ *សេចក្តីប្រកាសស្តីពីសិទ្ធិកុមារ* អនុម័តដោយ សេចក្តីសម្រេចនៃអង្គមហាសន្និបាត លេខ១៣៨៦ (XIV) ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៥៩។

អង្គមហាសន្និបាតអង្គការសហប្រជាជាតិ *សេចក្តីណែនាំរបស់អង្គការសហប្រជាជាតិស្តីពីការបង្ការអនីតិជនប្រព្រឹត្តបទល្មើស (សេចក្តីណែនាំ រីយ៉ាត)* អនុម័តដោយសេចក្តីសម្រេច នៃអង្គមហាសន្និបាតលេខ ៤៥/១១២ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩០។

អង្គមហាសន្និបាតអង្គការសហប្រជាជាតិ *វិធានអង្គការសហប្រជាជាតិស្តីពីការការពារអនីតិជនដែលត្រូវបានដកហូតសេរីភាព* ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩០។

អង្គមហាសន្និបាតអង្គការសហប្រជាជាតិ *វិធានអប្បបរមានៃបទដ្ឋានអង្គការសហប្រជាជាតិសម្រាប់រដ្ឋបាលយុត្តិធម៌អនីតិជន* ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥។

# នីតិជាតិ

## ច្បាប់

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣ ដូចដែលបានធ្វើវិសោធនកម្ម)

ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (២០០៧)

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (២០០៩)

## ឧបករណ៍ដទៃទៀត

គម្រោងតុលាការគំរូកម្ពុជា *បទដ្ឋាន និងលក្ខណៈជាតុលាការគំរូ* អាចរកបាននៅលើគេហទំព័រ៖ http://www.phnompenh.um.dk/NR/rdonlyres/C3FF25E2-1E56-4333-B9D9-82869FF97653/0/ModelCourtcriteria.pdf

ក្រសួងមហាផ្ទៃ ប្រកាសលេខ ២១៧ ស្តីពីការគ្រប់គ្រងពន្ធនាគារ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៩៨។

# ករណីសិក្សា

## អន្តរជាតិ

គណៈកម្មាធិការសិទ្ធិមនុស្ស *ទស្សនៈនៃគណៈកម្មាធិការសិទ្ធិមនុស្សលើមាត្រា ៥ កថាខណ្ឌ ៤ នៃពិធីសារបន្ថែមលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សេចក្តីជូនដំណឹងលេខ ២៦៣/១៩៨៧៖ លោក ហ្គន់ហ្សាឡេស ដេល រីយ៉ូ តទល់នឹង ប៉េរូ*។ សេចក្តីសម្រេចចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩២ (ICCPR/C/46/D/263/1987) អាចរកបាននៅលើគេហទំព័រ៖ http://www.unhchr.ch/tbs/doc.nsf/0/3977b6d1e738710c80256730004f6aaf?Open document

គណៈកម្មាធិការសិទ្ធិមនុស្ស ការទទួលយក៖ សេចក្តីជូនដំណឹង លេខ ៥៩៤/១៩៩២៖ ហ្វីលីព តទល់នឹង ទ្រីនីដាត និងតូបាហ្គោ។ សេចក្តីសម្រេចចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៦ (CCPR/C/56/D/594/1992) អាចរកបាននៅលើគេហទំព័រ៖ http://www.bayefsky.com/pdf/124_trinidad594.pdf

គណៈកម្មាធិការសិទ្ធិមនុស្ស *ទស្សនៈរបស់គណៈកម្មាធិការសិទ្ធិមនុស្សលើមាត្រា ៥ កថាខណ្ឌ ៤ នៃពិធីសារបន្ថែមលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ* សេចក្តីជូនដំណឹងលេខ ៩១៣/២០០០៖ ចាន់ តទល់នឹង ហ្គូយ៉ាណា។ សេចក្តីសម្រេចចុះថ្ងៃទី ២៣ ខែមករា ឆ្នាំ២០០៦ (CCPR/C/85/D/913/2000) អាចរកបាននៅលើគេហទំព័រ៖ http://www.unhchr.ch/tbs/doc.nsf/0/b69fa1d51ad367c6c12571060050284e?Opendocument

## ជាតិ

ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧។

អង្គជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា *ព្រះរាជអាជ្ញា តទល់នឹង កាំងហ្គេកអ៊ាវ ហៅឌុច*។ សាលក្រម សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អជ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០។

## របាយការណ៍

គណៈកម្មការសិទ្ធិមនុស្សអាស៊ាន *កម្ពុជាត្រូវការយន្តការថ្នាក់ជាតិឯករាជ្យដើម្បីបង្ការទារុណកម្ម ផ្សេងពីអង្គភាពស៊ើបអង្កេតរបស់រដ្ឋាភិបាល*។ ក្រុងហុងកុង៖ គណៈកម្មការសិទ្ធិមនុស្សអាស៊ាន ឆ្នាំ២០០៨ អាចរកបាននៅលើគេហទំព័រ៖ http://www.ahrchk.net/statements/mainfile.php/2008statements/1590/

ប្លូ រីឆាត និងរ៉ូបើត អានជីវូត *ការវាយតម្លៃទៅលើកម្មវិធីសិទ្ធិ និងយុត្តិធម៌ (ប្រាជ្ញ)៖ របាយការណ៍ចុងក្រោយ*។ ក្រុងវ៉ាស៊ីនតោន៖ ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍអន្តរជាតិនៃសហរដ្ឋអាមេរិក (USAID) ខែមករា ឆ្នាំ២០០៨ អាចរកបាននៅលើគេហទំព័រ៖ http://www.usaid.gov/kh/democracy and_governance/documents/Cambodia_HR-ROL_Evaluation_Final_Report.pdf

គណៈកម្មាធិការសិទ្ធិកុមារ *បទអត្ថាធិប្បាយទូទៅលេខ ១០៖ សិទ្ធិកុមារនៅក្នុងវិស័យយុត្តិធម៌អនីតិជន* (CRC/C/GC/10) ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៧ អាចរកបាននៅលើគេហទំព័រ៖ http://www.unhchr.ch/tbs/doc.nsf/0/b0ebdbcd1e49d11dc1257306004f1864?Opendocument

គណៈកម្មាធិការប្រឆាំងទារុណកម្ម *ការពិចារណាទៅលើរបាយការណ៍ដាក់ជូនដោយរដ្ឋភាគីស្តីពីមាត្រា ១៩ នៃអនុសញ្ញា៖ របាយការណ៍បឋមនៃរដ្ឋភាគីឆ្នាំ ១៩៩៣៖ បន្ថែម៖ ប្រទេសកម្ពុជា* (CAT/C/21/Add.5) ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៣ អាចរកបាននៅលើគេហទំព័រ៖http://www.unhchr.ch/tbs/doc.nsf/0/5b8731365463a467c1256d5c005174ab/$FILE/G0340136.pdf

គណៈកម្មាធិការប្រឆាំងទារុណកម្ម *ការពិចារណាទៅលើរបាយការណ៍ដាក់ជូនដោយរដ្ឋភាគីស្តីពីមាត្រា ១៩ នៃអនុសញ្ញា៖ ប្រទេសកម្ពុជា* (CAT/C/KHM/Q/2) ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១០ អាចរកបាននៅលើគេហទំព័រ៖ http://www2.ohchr.org/english/bodies/cat/docs/AdvanceVersions/CAT-C-KHM-2.pdf

គណៈកម្មាធិការប្រឆាំងទារុណកម្ម *សេចក្តីសន្និដ្ឋាន និងអនុសាសន៍ របស់គណៈកម្មាធិការប្រឆាំងទារុណកម្ម៖ ប្រទេសកម្ពុជា* (CAT/C/CR/31/7) ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០០៤ អាចរកបាននៅលើគេហទំព័រ៖http://www.unhchr.ch/tbs/doc.nsf/(Symbol)/CAT.C.CR.31.7.En?OpenDocument

ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ *កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌* ក្រុងភ្នំពេញ៖ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ឆ្នាំ២០០៣។

ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ *ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌* អនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានៅឯកិច្ចប្រជុំពេញអង្គនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥។

គណៈកម្មាធិការសិទ្ធិមនុស្ស *CCPR សេចក្តីអត្ថាធិប្បាយទូទៅលេខ ២៩៖ មាត្រា ៤៖ បដិប្បញ្ញត្តិនៅក្នុងអំឡុងពេលរដ្ឋមានអាសន្ន* (CCPR/C/21/Rev.1/Add.11) ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០១ អាចរកបាននៅលើគេហទំព័រ៖http://www.unhcr.org/refworld/docid/453883fd1f.html

គណៈកម្មាធិការសិទ្ធិមនុស្ស *សេចក្តីអត្ថាធិប្បាយទូទៅលេខ ៣២ មាត្រា ១៤៖ សិទ្ធិស្មើភាពគ្នាចំពោះតុលាការ និងសាលាជម្រះក្តី និងសវនាការយុត្តិធម៌* (CCPR/C/GC/32) ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០០៧ អាចរកបាននៅលើគេហទំព័រ៖ http://www.unhcr.org/refworld/type,GENERAL,,,478b2b2f2,0.html

គណៈកម្មការអ្នកច្បាប់អន្តរជាតិ *បទអត្ថាធិប្បាយរបស់គណៈកម្មការអ្នកច្បាប់អន្តរជាតិ លើរបាយការណ៍បឋមរបស់ប្រទេសកម្ពុជា ស្តីពីការអនុវត្តកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។* ក្រុងហ្សឺណែវ៖ គណៈកម្មការអ្នកច្បាប់អន្តរជាតិ ខែមេសា ឆ្នាំ២០០៩ អាចរកបាននៅលើគេហទំព័រ៖http://www.icj.org/IMG/Cambodia_CESCR_Oral_SubmissionFINAL-30-04-09.pdf

ក្រុមការងារអង្គការមិនមែនរដ្ឋាភិបាល *របាយការណ៍ដូចគ្នាស្តីប្រទេសកម្ពុជា ឆ្នាំ២០០៩។* ក្រុងភ្នំពេញ៖ ក្រុមការងារអង្គការមិនមែនរដ្ឋាភិបាល ខែមេសា ឆ្នាំ២០០៩ អាចរកបាននៅលើគេហទំព័រ៖ http://www2.ohchr.org/english/bodies/cescr/docs/ngos/NGO_WG_Cambodia_CESCR42.pdf

ការិយាល័យឧត្តមក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ *OPCAT យន្តការបង្ការថ្នាក់ជាតិ* ខែមេសា ឆ្នាំ២០០៨ អាចរកបាននៅលើគេហទំព័រ៖ http://cambodia.ohchr.org/WebDOCs/DocInfoNotes/004_InfoNoteE.pdf

តំណាងពិសេសសិទ្ធិមនុស្សប្រចាំនៅកម្ពុជា *ជំនួយបច្ចេកទេស និងការកសាងសមត្ថភាព៖ របាយការណ៍របស់តំណាងពិសេសនៃអគ្គលេខាធិការដ្ឋានសិទ្ធិមនុស្សប្រចាំនៅកម្ពុជា យ៉ាស ហ្គាយ* (A/HRC/7/42) ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០៨ អាចរកបាននៅលើគេហទំព័រ៖

http://daccess-dds-ny.un.org/doc/UNDOC/GEN/G08/115/04/PDF/G0811504.pdf?OpenElement

## សៀវភៅស្ដីពីការជំនុំជម្រះដោយយុត្តិធម៌

អង្គការលើកលែងទោសអន្តរជាតិ *សៀវភៅស្ដីពីការជំនុំជម្រះដោយយុត្តិធម៌របស់ អង្គការលើកលែងទោសអន្តរជាតិ*។ទីក្រុងឡុងដ៍៖ ការបោះពុម្ពផ្សាយរបស់អង្គការលើកលែងទោសអន្តរជាតិ ឆ្នាំ១៩៩៨ AI Index POL 30/02/98 អាចរកបាននៅលើគេហទំព័រ៖ http://www.amnesty.org/en/library/asset/POL30/002/1998/en/81bf7626-d9b1-11dd-af2b-b1f6023af0c5/pol300021998en.pdf

អូលីវើរ៉ា បាបារ៉ា និងលីនដា បេសារាទី ម៉ូរ៉ាអេដ *សៀវភៅស្ដីពីការសង្កេតសវនាការរបស់ក្រុមប្រឹក្សាអ្នកច្បាប់អន្តរជាតិ* ឆ្នាំ២០០២ អាចរកបាននៅលើគេហទំព័រ៖ http://www.jsmp.minihub.org/Reports/otherresources/Trial_Observation_Manual.pdf

អង្គការសន្តិសុខ និងសហប្រតិបត្តិការនៅអឺរ៉ុប/ ការិយាល័យវិទ្យាស្ថានប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស (ODIHR)។ *ការសង្កេតការណ៍សវនាការ៖ សៀវភៅយោងសម្រាប់អ្នកអនុវត្ត*។ ប្រទេសប៉ូឡូញ៖ OSCE/ODIHR ឆ្នាំ២០០៨ អាចរកបាននៅលើគេហទំព័រ៖ http://www.osce.org/publications/odihr/2008/04/30849_1119_en.pdf

ភីជីក ដេលេណា និងវ៉ាណេសា លេសនី *អ្វីទៅជាការជំនុំជម្រះដោយយុត្តិធម៌? សេចក្ដីណែនាំមូលដ្ឋានស្ដីពីបទដ្ឋានច្បាប់ និងការអនុវត្ត*។ ក្រុងញូវយ៉ក៖ គណៈកម្មាធិការមេធាវីសម្រាប់សិទ្ធិមនុស្ស ឆ្នាំ២០០០ អាចរកបាននៅលើគេហទំព័រ៖http://www.humanrightsfirst.org/pubs/descriptions/fair_trial.pdf

## សុន្ទរកថា

សុន្ទរកថាសម្ដេចហ៊ុន សែនថ្លែងនៅពិធីបើកសន្និសិទស្ដីពីការផ្សព្វផ្សាយក្រមនីតិវិធីព្រហ្មទណ្ឌ នៅសណ្ឋាគារឡឺរ៉ូយ៉ាល់ ក្រុងភ្នំពេញ នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៧។

សុន្ទរកថាសម្ដេចហ៊ុន សែនស្ដីពីយុទ្ធសាស្ត្រចតុកោណសម្រាប់ការរីកលូតលាស់ ការងារ សមភាព និងប្រសិទ្ធិភាព ដំណាក់កាលទី២ ក្នុងកិច្ចប្រជុំលើកទី១ នីតិកាលទី៤ នៃរដ្ឋសភាជាតិ នៅទីស្ដីការគណៈរដ្ឋមន្ត្រី ក្រុងភ្នំពេញ នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨។

## សេចក្ដីថ្លែងការណ៍

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា *សវនាការខុច ៖ ឧទាហរណ៍ដ៏ល្អមួយសម្រាប់តុលាការកម្ពុជា* ចេញផ្សាយនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០។

# ៧. ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១៖ តារាងសង្កេតការណ៍សវនាការ

| **១. ព័ត៌មានទូទៅ** | | | |
|---|---|---|---|
| ១(ក) កាលបរិច្ឆេទសវនាការ | | | |
| ១(ខ) អ្នកសង្កេតការណ៍ | | | |
| ១(គ) តុលាការ | ភ្នំពេញ☐ | កណ្តាល☐ | ផ្សេងៗ☐ |
| ១(ឃ) ចៅក្រម | ទី១ | ទី២ | ទី៣ |
| ១(ង) ក្រឡាបញ្ជី | | | |
| ១(ច) បទចោទប្រកាន់ | ឧក្រិដ្ឋ☐<br>ព័ត៌មានលំអិត[104]៖<br>មាត្រាច្បាប់ដែលទាក់ទង៖ | មជ្ឈិម☐ | |
| ១(ឆ) តើមានជនជាប់ចោទជាអនីតិជនដែរឬទេ? | មាន☐<br>ប្រសិនបើមានសូមបំពេញឯកសារភ្ជាប់ | គ្មាន☐ | |

| **២.សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ** | | |
|---|---|---|
| ២(ក) តើមានការបិទផ្សាយជូនដំណឹងអំពីសវនាការនៅលើក្តារខៀនក្រៅបន្ទប់សវនាការដែរឬទេ? | មាន☐ | គ្មាន☐ |
| ២(ខ) តើសាធារណៈជនត្រូវបានរាំងមិនអោយចូល ឬបណ្តេញចេញពីបន្ទប់សវនាការដែរឬទេ? | មាន☐<br>ប្រសិនបើមាន តើមានមូលហេតុត្រឹមត្រូវ ដែរឬទេ?<br>មាន☐<br>ពន្យល់៖ | គ្មាន☐<br><br>គ្មាន☐ |

| **៣. សិទ្ធិទទួលបានការជំនុំជម្រះក្នុងរយៈពេលសមរម្យ** មិនពាក់ព័ន្ធ ☐ (គ្មានការចាប់ ខ្លួនគ្មានការឃុំខ្លួនបណ្តោះអាសន្ន) | | |
|---|---|---|
| ៣.១. កាលបរិច្ឆេទនៃការចាប់ខ្លួន ____________________ | មិនដឹង ☐ | ចំនួនថ្ងៃគិតពីថ្ងៃចាប់ខ្លួនដល់ថ្ងៃសវនាការ៖ |

[104] ប្រសិនបើជាករណីជួញដូរមនុស្ស សូមមើលឯកសារភ្ជាប់ទី២ : សវនាការករណីជួញដូរមនុស្ស។

| | |
|---|---|
| ៣.២.តើមានការឃុំខ្លួនបណ្តោះអាសន្នដែរឬទេ? | មាន☐ គ្មាន☐ មិនដឹង☐<br>ប្រសិនបើមាន តើការឃុំខ្លួននោះបន្តដល់ពេលសវនាការដែរឬទេ?<br>មាន☐ គ្មាន☐<br>ប្រសិនបើទេ តើការឃុំខ្លួនបណ្តោះអាសន្នបញ្ចប់នៅពេលណា?<br>______________________ មិនដឹង ☐ |

| ៤. សិទ្ធិយល់អំពីប្រភេទនៃបទចោទប្រកាន់ | | | |
|---|---|---|---|
| ៤(ក)តើចៅក្រមបានប្រកាសពីរឿងក្តីដែលត្រូវជំនុំជម្រះដែរឬទេ? | មាន☐ | គ្មាន☐ | |
| ៤(ខ) តើចៅក្រមបានប្រាប់ពីបទចោទដែរឬទេ? | មាន☐ | គ្មាន☐ | |
| ៤(គ) តើចៅក្រមបានប្រាប់ពីមាត្រាច្បាប់ពាក់ព័ន្ធដែរឬទេ? | មាន☐ | គ្មាន☐ | |
| ៤(ឃ) តើចៅក្រមបានរៀបរាប់ពីឈ្មោះអ្នកចូលរួមដែរឬទេ? | មាន☐ | គ្មាន☐ | |
| ៤(ង) តើចៅក្រមបានប្រាប់ពីកាលបរិច្ឆេទ និងទីកន្លែងប្រព្រឹត្តបទល្មើសដែរឬទេ? | មាន☐ | គ្មាន☐ | |
| ៤(ច) ប្រសិនបើត្រូវការ តើអ្នកបកប្រែត្រូវបានផ្តល់អោយដែរឬទេ? | មាន☐ | គ្មាន☐ | មិនពាក់ព័ន្ធ☐ |
| ៤(ឆ) ប្រសិនបើត្រូវការ តើជនពិការត្រូវបានគេផ្តល់ជំនួយដែរឬទេ? | មាន☐<br>ប្រសិនបើមាន តើជាជំនួយផ្នែកអ្វី?<br>ស្តាប់☐<br>ពន្យល់៖ | គ្មាន☐<br><br>មើល☐ | មិនពាក់ព័ន្ធ☐<br><br>ផ្សេងៗ☐ |

| ៥. ការពន្យល់ប្រាប់សិទ្ធិ មិនពាក់ព័ន្ធ ☐ (ករណីសវនាការកំបាំងមុខ) | | | |
|---|---|---|---|
| ៥(ក) តើចៅក្រមបានប្រាប់ (I) និងពន្យល់ (E) ជនជាប់ចោទពីសិទ្ធិមានតំណាងស្របច្បាប់ ឬសិទ្ធិការពារខ្លួន ដែរឬទេ? | មានតែ I ☐ | I និង E ☐ | គ្មានទាំង I និង E ☐ |
| ៥(ខ) តើចៅក្រមបានប្រាប់ (I) និងពន្យល់ (E) ជនជាប់ចោទពីសិទ្ធិនៅស្ងៀម ដែរឬទេ? | មានតែ I ☐ | I និង E ☐ | គ្មានទាំង I និង E ☐ |
| ៥(គ) តើចៅក្រមបានប្រាប់ (I) និងពន្យល់ (E) ជនជាប់ចោទពីសិទ្ធិមិនឆ្លើយដាក់កំហុសខ្លួនឯង ដែរឬទេ? | មានតែ I ☐ | I និង E ☐ | គ្មានទាំង I និង E ☐ |
| ៥(ឃ) តើចៅក្រមបានប្រាប់ (I) និងពន្យល់ (E) ជនជាប់ចោទពីសិទ្ធិផ្លាស់ប្តូរចៅក្រមជំនុំជម្រះ ដែរឬទេ? | មានតែ I ☐ | I និង E ☐ | គ្មានទាំង I និង E ☐ |
| ៥(ង) តើចៅក្រមបានប្រាប់ (I) និងពន្យល់ (E) ជនជាប់ចោទពីសិទ្ធិមានសំណូមពរចុងក្រោយ ដែរឬទេ? | មានតែ I ☐ | I និង E ☐ | គ្មានទាំង I និង E ☐ |

| ៦. សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការការពារក្តី | | |
|---|---|---|
| ៦(ក) តើបញ្ហាពេលវេលា និងមធ្យោបាយគ្រប់ | មាន☐ | គ្មាន☐ |

| | |
|---|---|
| គ្រាន់ត្រូវបានលើកឡើងដោយមេធាវីជនជាប់ចោទដែរឬទេ? | ពន្យល់: |

| ៧. សិទ្ធិទទួលបានតំណាងស្របច្បាប់ និងមានវត្តមាននៅក្នុងសវនាការ | |
|---|---|
| ៧(ក) តើជនជាប់ចោទត្រូវបានតំណាងដោយមេធាវី ដែរឬទេ? | មាន☐ គ្មាន☐ |
| ៧(ខ) តើមានជនជាប់ចោទ លើសពីម្នាក់ដែរឬទេ? | មាន☐ គ្មាន☐ មិនពាក់ព័ន្ធ☐<br>ប្រសិនបើមាន តើចម្លើយរបស់ជនជាប់ចោទ មានទំនាស់ផលប្រយោជន៍ជាមួយគ្នា ដែរឬទេ?<br>មាន☐ គ្មាន☐<br>តើជនជាប់ចោទត្រូវបានតំណាងដោយមេធាវីខុសគ្នាដែរឬទេ?<br>មាន☐ គ្មាន☐ |
| ៧(គ) តើជនជាប់ចោទត្រូវបានបណ្តេញចេញនៅក្នុងដំណាក់កាលណាមួយនៃនីតិវិធីសវនាការដែរឬទេ? | មាន☐ គ្មាន☐ |

| ៨. ការសន្មត់ទុកជាមុនថា គ្មានទោស | |
|---|---|
| ៨(ក) តើជនជាប់ចោទស្លៀកឯកសណ្ឋានអ្នកទោសដែរឬទេ? | មាន☐ គ្មាន☐ មិនពាក់ព័ន្ធ☐ |
| ៨(ខ)តើជនជាប់ចោទត្រូវបានដាក់ខ្នោះនៅក្នុងពេលសវនាការ ដែរឬទេ? | មាន☐ គ្មាន☐<br>ប្រសិនបើមាន តើមានហេតុផលសមស្រប ដែរឬទេ?<br>មាន☐ គ្មាន☐<br>មូលហេតុ: |
| ៨(គ)តើចៅក្រមបាននិយាយពីភាពមានទោស ឬគ្មានទោសរបស់ជនជាប់ចោទដែរឬទេ នៅមុនពេលដែលសេចក្តីសម្រេចត្រូវបានធ្វើឡើង? | មាន☐ គ្មាន☐<br>ពន្យល់: |
| ៨(ឃ)តើមានអ្វីមួយ ដែលបង្ហាញថា ចៅក្រមរើសអើង ជនជាប់ចោទ ដោយសារបុគ្គលិកលក្ខណ:ផ្ទាល់ខ្លួន របស់ជនជាប់ចោទ ដែរឬទេ? | មាន☐ គ្មាន☐<br>ប្រសិនបើមាន តើបុគ្គលិកលក្ខណ:ណាមួយ?<br>អាយុ☐ ភេទ☐ ស្ថានភាពគ្រួសារ☐<br>មុខរបរ☐ ជាតិពន្ធុ☐ សញ្ជាតិ ☐<br>សាសនា☐ វង្សត្រកូល☐ ប្រវត្តិប្រព្រឹត្តបទល្មើស<br>ពន្យល់៖ |

| ៩. ឯករាជ្យភាពនៃចៅក្រម | |
|---|---|
| ៩(ក) តើចៅក្រមដើរតួនាទីជាភាគីផ្សេងទៀត ដែរឬទេ នៅក្នុងនីតិវិធីសវនាការ? | មាន☐ គ្មាន☐<br>ប្រសិនបើមាន តើភាគីណាមួយ?<br>ព្រះរាជអាជ្ញា☐ភាគីជនជាប់ចោទ☐ដើមបណ្ដឹងរដ្ឋប្បវេណី☐<br>ចៅក្រមស៊ើបសួរ ☐ |
| ៩(ខ) តើមានអ្វីមួយ ដែលបង្ហាញថា ចៅក្រមមានផលប្រយោជន៍នៅក្នុងរឿងក្ដី ដោយសារតួនាទីនៅក្នុងវិស័យតុលាការ ដែរឬទេ? | មាន☐ គ្មាន☐<br>ពន្យល់៖ |
| ៩(គ)តើមានអ្វីមួយ ដែលបង្ហាញថា ភាគីណាមួយបាននិយាយជាមួយចៅក្រម នៅក្នុងកំឡុងពេលពិភាក្សាចេញសេចក្ដីសម្រេច ដែរឬទេ? | មាន☐ គ្មាន☐<br>ប្រសិនបើមាន តើភាគីណាមួយ?<br>ព្រះរាជអាជ្ញា ☐ ភាគីជនជាប់ចោទ ☐ ដើមបណ្ដឹងរដ្ឋប្បវេណី ☐<br>ពន្យល់៖ |
| ៩(ឃ)តើមានអ្វីមួយ ដែលបង្ហាញថា ចៅក្រមធ្វើទុក្ខបុកម្នេញទៅលើភាគីណាមួយ ដែរឬទេ? | មាន☐ គ្មាន☐<br>ប្រសិនបើមាន តើភាគីណាមួយ?<br>ព្រះរាជអាជ្ញា☐ភាគីជនជាប់ចោទ☐ដើមបណ្ដឹងរដ្ឋប្បវេណី☐<br>ពន្យល់៖ |
| ៩(ង) តើមានអ្វីមួយ ដែលបង្ហាញថា ចៅក្រមទាញពិរុទ្ធភាព អំពីការនៅស្ងៀមរបស់ជនជាប់ចោទ ដែរឬទេ? | មាន☐ ទេ☐<br>ពន្យល់៖ |

| ១០. ភស្តុតាង | |
|---|---|
| ១០(ក) តើភស្តុតាងត្រូវបានបង្ហាញ ដែរឬទេ? | មាន☐ គ្មាន☐<br>ប្រសិនបើមានតើបង្ហាញដោយភាគីណាមួយ?<br>ព្រះរាជអាជ្ញា☐ ភាគីជនជាប់ចោទ ☐ ដើមបណ្ដឹងរដ្ឋប្បវេណី ☐<br>ប្រសិនបើមាន តើភស្តុតាងណាមួយដែលត្រូវបានបង្ហាញ?<br>វត្ថុតាង☐ ឯកសារ☐ កំណត់ហេតុសាក្សី ☐ ចម្លើយសារភាព☐<br>ផ្សេងៗ☐<br>ពន្យល់៖ |
| ១០(ខ) តើមានអ្វីមួយ ដែលបង្ហាញថា ភាគីណាមួយមិនត្រូវបានផ្ដល់ឱកាស អោយបង្ហាញភស្តុតាង ដែរឬទេ? | មាន☐ គ្មាន☐<br>ប្រសិនបើមាន តើភាគីណាមួយ?<br>ព្រះរាជអាជ្ញា☐ ភាគីជនជាប់ចោទ ☐ ដើមបណ្ដឹងរដ្ឋប្បវេណី☐ |

| | |
|---|---|
| | មូលហេតុ៖ |

| ១១. សិទ្ធិហៅ និងសាកសួរសាក្សី | |
|---|---|
| ១១(ក) តើមានអ្វីមួយ ដែលបង្ហាញថា ភាគីណាមួយមិនត្រូវបានផ្តល់ឱកាសអោយហៅសាក្សី ដែរឬទេ? | មាន☐ គ្មាន☐<br>ប្រសិនបើមាន<br>តើភាគីណាមួយ?<br>ព្រះរាជអាជ្ញា☐ ភាគីជនជាប់ចោទ ☐ ដើមបណ្តឹងរដ្ឋប្បវេណី☐<br>មូលហេតុ៖ |
| ១១(ខ) តើមានអ្វីមួយ ដែលបង្ហាញថា ភាគីណាមួយមិនត្រូវបានផ្តល់ឱកាសអោយសាកសួរសាក្សី ដែរឬទេ? | មាន☐ គ្មាន☐ មិនពាក់ព័ន្ធ☐<br>ប្រសិនបើមាន តើភាគីណាមួយ?<br>ព្រះរាជអាជ្ញា☐ ភាគីជនជាប់ចោទ ☐ ដើមបណ្តឹងរដ្ឋប្បវេណី☐<br>មូលហេតុ៖ |
| ១១(គ) តើសាក្សីស្ថិតនៅក្នុងបន្ទប់សវនាការដែរឬទេ នៅមុនពេលសាកសួរ? | មាន☐ គ្មាន☐ មិនពាក់ព័ន្ធ☐ |

| ១២. សិទ្ធិទទួលដឹងពួកស្តុតាងរបស់ភាគីម្ខាងទៀត | |
|---|---|
| ១២(ក) តើមានអ្វីមួយ ដែលបង្ហាញថា ភាគីណាមួយមិនបានដឹងឮអំពីភស្តុតាងរបស់ភាគីម្ខាងទៀតដែរឬទេ? | មាន☐ គ្មាន☐<br>ប្រសិនបើមាន តើភាគីណាមួយដែលមិនមាន ភស្តុតាងនោះ?<br>ព្រះរាជអាជ្ញា☐ ភាគីជនជាប់ចោទ☐ ដើមបណ្តឹងរដ្ឋប្បវេណី☐<br>ពន្យល់៖ |

| ១៣. សិទ្ធិមិនឆ្លើយដាក់បន្ទុកខ្លួនឯង | |
|---|---|
| ១៣(ក) តើមានអ្វីមួយ ដែលបង្ហាញថា ជនជាប់ចោទត្រូវបានគំរាមកំហែងបង្ខំអោយសារភាព ដែរឬទេ? | មាន☐ គ្មាន☐ មិនពាក់ព័ន្ធ☐<br>ពន្យល់៖ |
| ១៣(ខ) តើមានអ្វីមួយ ដែលបង្ហាញថា ជនជាប់ចោទត្រូវបានគេធ្វើទារុណកម្មបង្ខំអោយសារភាព ដែរឬទេ? | មាន☐ គ្មាន☐ មិនពាក់ព័ន្ធ☐<br>ពន្យល់៖ |

| ១៤. ហាមឃាត់ការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសតែមួយ | |
|---|---|
| ១៤(ក) តើមានអ្វីមួយ ដែលបង្ហាញថា ជនជាប់ចោទត្រូវបានតុលាការវិនិច្ឆ័យម្តងរួចមកហើយចំពោះបទល្មើសនេះ ដែរឬទេ? | មាន☐ គ្មាន☐<br>ពន្យល់៖ |

| ១៥. ហាមឃាត់ចំពោះការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ | |
|---|---|
| ១៥(ក) តើមានអ្វីមួយ ដែលបង្ហាញថា បទល្មើសនេះមិនមែនជាបទល្មើសនៅក្រោមច្បាប់ជាតិ ឬអន្តរជាតិ នៅពេលដែលបទល្មើសនេះត្រូវបានប្រព្រឹត្ត ដែរឬទេ? | មាន☐ គ្មាន☐<br>ពន្យល់៖ |

| ១៦. សាលក្រម មិនដឹង☐ | |
|---|---|
| ១៦(ក) កាលបរិច្ឆេទ | ____________________ |
| ១៦(ខ) តើជនជាប់ចោទស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន ដែរឬទេ នៅក្នុងចន្លោះពេលសវនាការ និងពេលចេញសាលក្រម? | មាន☐ គ្មាន☐ មិនដឹង☐ ពុំទាក់ព័ន្ធ☐ |
| ១៦(គ) ប្រភេទ | មានពិរុទ្ធភាព☐គ្មានពិរុទ្ធភាព☐ ស៊ើបបន្ថែម ☐ សវនាការមុនអង្គសេចក្តី ☐ |
| ១៦(ឃ) អំណះអំណាងផ្លូវច្បាប់ | មាន☐គ្មាន ☐សូមបញ្ជាក់៖ មិនដឹង☐ |
| ១៦(ង) ភស្តុតាង | មាន☐គ្មាន☐ មិនដឹង☐<br>សូមបញ្ជាក់៖ |

| ១៧. ទោស មិនពាក់ព័ន្ធ☐ មិនដឹង☐ | | |
|---|---|---|
| ១៧(ក) ប្រភេទ: | ពន្ធនាគារ☐ | រយៈពេល៖<br>តើរាប់បញ្ចូលរយៈពេលឃុំខ្លួនបណ្តោះអាសន្ន ដែរឬទេ? មាន☐ គ្មាន☐ មិនដឹង☐ មិនពាក់ព័ន្ធ☐ |
| | ប្រាក់ផាកពិន័យ☐ | លំអិត៖ |
| | ប្រាក់សងជំងឺចិត្ត☐ | លំអិត៖ |

| ១៨. ផ្សេងៗ | | |
|---|---|---|
| ១៨(ក) តើចៅក្រមនិយាយទូរស័ព្ទ | មាន☐ | គ្មាន☐ |

| | |
|---|---|
| ដែរឬទេ ក្នុងកំឡុងពេលសវនាការ? | ប្រសិនបើមាន តើ:<br>និយាយថារវល់ ហើយដាក់ទូរស័ព្ទចុះ? ☐ បន្តការនិយាយទូរស័ព្ទ? ☐<br>ប្រសិនបើមាន តើជា:<br>សម្លេងរោទិ៍ឮខ្លាំង? ☐ សម្លេងញ័រ? ☐ |
| ១៨(ខ)៖ | |

## ឯកសារភ្ជាប់ ទី១ ៖ជនជាប់ចោទជាអនីតិជន

| ១. អាយុ | | | |
|---|---|---|---|
| ១(ក) អាយុ | ០-១៤ ឆ្នាំ☐ | | ១៥-១៧ ឆ្នាំ☐ |
| ១(ខ) នៅក្នុងករណីដែលជនជាប់ចោទត្រូវបានគេរកឃើញថាមានអាយុតិចជាង ១៨ ឆ្នាំ តើចៅក្រមចេញសេចក្តីសម្រេចអោយរួចទោសភ្លាមៗ ដែរឬទេ? | មាន☐<br>ពន្យល់៖ | គ្មាន☐ | មិនពាក់ព័ន្ធ☐ |

| ២. សិទ្ធិទទួលបានការជំនុំជម្រះក្នុងរយៈពេលសមរម្យ | |
|---|---|
| ២(ក) កាលបរិច្ឆេទនៃការចាប់ខ្លួន | |
| ២(ខ) តើមានការឃុំខ្លួនបណ្តោះអាសន្ន ដែរឬទេ? | មាន☐ គ្មាន☐ មិនដឹង☐<br>ប្រសិនបើមាន តើការឃុំខ្លួនបណ្តោះអាសន្ននោះមានរហូត ដល់ពេល សវនាការ ដែរឬទេ?<br>មាន☐ គ្មាន☐ |

| | |
|---|---|
| | ប្រសិនបើគ្មាន តើការឃុំខ្លួនបណ្តោះអាសន្នបញ្ចប់នៅពេលណា? |

| ៣. ដំណាក់កាលមុនសវនាការ | |
|---|---|
| ៣(ក) ប្រសិនបើមានការឃុំខ្លួនបណ្តោះអាសន្ន តើមានអ្វីមួយ ដែលបង្ហាញថា ជនជាប់ចោទ មិនត្រូវបានដាក់ដោយឡែកពីនីតិជន ដែរឬទេ? | មាន☐ គ្មាន☐ មិនពាក់ព័ន្ធ☐<br>ពន្យល់៖ |

| ៤. ដំណាក់កាលសវនាការ | |
|---|---|
| ៤(ក) តើចៅក្រមស្លៀកសំលៀកបំពាក់ធម្មតា ដែរឬទេ? | មាន☐ គ្មាន☐<br>ពន្យល់៖ |
| ៤(ខ) តើមានអ្វីមួយ ដែលបង្ហាញថា អនីតិជនចង់អោយឪពុកម្តាយ ឬអ្នកថែរក្សា មានវត្តមាននៅក្នុងពេលសវនាការ ដែរឬទេ? | មាន☐ គ្មាន☐<br>ប្រសិនបើមាន តើឪពុកម្តាយរបស់គេមានវត្តមាននៅក្នុងសវនាការ ដែរឬទេ?<br>មាន☐ គ្មាន☐ |
| ៤(គ) តើមានរបាំងការពារអនីតិជន នៅក្នុងការផ្តល់ចម្លើយជាសាធារណៈ ដែរឬទេ? | មាន☐ គ្មាន☐<br>ពន្យល់: |
| ៤(ឃ) តើមានអ្វីមួយ ដែលបង្ហាញថា ចៅក្រមពិចារណាទៅលើទោសមិនមែនពន្ធនាគារ មុននឹងគិតពី ទោសពន្ធនាគារ ដែរឬទេ? | មាន☐ គ្មាន☐ មិនពាក់ព័ន្ធ☐<br>ពន្យល់: |

## ឯកសារភ្ជាប់ ទី២ : ករណីជួញដូរមនុស្ស

| ១. ព័ត៌មានទូទៅ | |
|---|---|
| ១(ក) តើសវនាការធ្លាប់ត្រូវបានពន្យារពេលដែរឬទេ? | មាន☐ គ្មាន☐<br>ប្រសិនបើមាន សូមបញ្ជាក់អោយលំអិត: |
| ១(ខ) តើករណីនេះទាក់ទងនឹងមាត្រាច្បាប់អ្វី? | |
| ១(គ) សូមសង្ខេបអង្គហេតុនៃរឿងក្តី | |

| ២. ជនជាប់ចោទ | |
|---|---|
| ២(ក) អាយុ | ០-១៤[113]☐ ១៥-១៧☐ ១៨-២៥☐ ២៦-៣៥☐ ២៦-៤៥☐ ៤៦+☐ |
| ២(ខ) ភេទ | ប្រុស☐ ស្រី☐ |
| ២(គ) ស្ថានភាពគ្រួសារ | រៀបការ☐ នៅលីវ☐ |
| ២(ឃ) មុខរបរ | មេបន☐ អ្នកទេសចរណ៍/ជនបរទេស☐ អ្នករកស៊ីផ្លូវភេទ☐<br>ផ្សេងៗ ☐ សូមបញ្ជាក់៖ |
| ២(ង) សញ្ជាតិ | កម្ពុជា☐ វៀតណាម☐ ថៃ☐ ឡាវ☐ ផ្សេងៗ☐ មិនដឹង☐ |
| ២(ច) ជាតិពិន្ទុ | មាន☐ គ្មាន☐ មិនដឹង☐<br>ប្រសិនបើមាន សូមបញ្ជាក់:<br>ទំពូន☐ ស្នៀង☐ ចាម☐<br>ព្នង☐ សំរ៉ែ☐ ចារ៉ាយ☐<br>គួយ☐ ផ្សេងៗ☐ |
| ២(ឆ) សាសនា | ព្រះពុទ្ធ☐ មូស្លីម☐ គ្រឹស្ត☐ ជឿលើព្រលឹង☐ ផ្សេងៗ☐ មិនដឹង☐ |
| ២(ជ) ពិការភាព | ភ្នែក☐ ត្រចៀក☐ ផ្លូវចិត្ត☐ ផ្សេងៗ☐ មិនពាក់ព័ន្ធ☐ |

| ៣. ជនរងគ្រោះ | |
|---|---|
| ៣(ក) អាយុ | ០-១៤☐ ១៥-១៧☐ ១៨-២៥☐ ២៦-៣៥☐ ២៦-៤៥☐ ៤៦+☐ |
| ៣(ខ) ភេទ | ប្រុស☐ ស្រី☐ |
| ៣(គ) ស្ថានភាពគ្រួសារ | រៀបការ☐ នៅលីវ☐ |
| ៣(ឃ) មុខរបរ | អ្នកចាប់សរសៃ☐ អ្នករកស៊ីផ្លូវភេទ☐ អ្នករត់តុក្នុងភោជនីយដ្ឋាន☐<br>អ្នកធ្វើការក្នុងផ្ទះ☐ កម្មករសំណង់☐ អ្នកលីសែងឥវ៉ាន់☐<br>ផ្សេងៗ☐ សូមបញ្ជាក់៖ |
| ៣(ង) សញ្ជាតិ | កម្ពុជា☐ វៀតណាម☐ ថៃ☐ ឡាវ☐ ផ្សេងៗ☐ មិនដឹង☐ |
| ៣(ច) ជាតិពិន្ទុ | មាន☐ គ្មាន☐ មិនដឹង☐<br>ប្រសិនបើមាន សូមបញ្ជាក់៖<br>ទំពូន☐ ស្នៀង☐ ចាម☐<br>ព្នង☐ សំរ៉ែ☐ ចារ៉ាយ☐ |

[113] ចន្លោះអាយុនេះត្រូវបានជ្រើសរើស ព្រោះប្រសិនបើជនជាប់ចោទមានអាយុលើសពី ១៤ ឆ្នាំ ប៉ុន្តែក្រោម ១៨ ឆ្នាំ ពួកគេត្រូវបានចាត់ទុកថាជាអនីតិជន ករណីនេះមិនតម្រូវអោយថៅក្រមដោះលែងជនជាប់ចោទអោយរួចទោសនោះទេ។ ប្រសិនបើ ជនជាប់ចោទមានអាយុចន្លោះពី ១៤ ឆ្នាំ ទៅ ១៨ ឆ្នាំ សូមមើលឯកសារភ្ជាប់ទី១ ។

| | |
|---|---|
| | គួយ☐ ផ្សេងៗ☐ |
| ៣(ឆ) សាសនា | ព្រះពុទ្ធ☐ មូស្លីម☐ គ្រីស្ត☐ អ្នកជឿលើព្រលឹង☐ ផ្សេងៗ ☐ មិនដឹង☐ |
| ៣(ជ) ពិការភាព | ភ្នែក☐ ត្រចៀក☐ ផ្លូវចិត្ត☐ ផ្សេងៗ☐ មិនពាក់ព័ន្ធ☐ |
| ៣(ឈ)ការអប់រំ | បឋមសិក្សា ☐ អនុវិទ្យាល័យ☐ វិទ្យាល័យ☐ ឧត្តមសិក្សា☐ មិនដឹង☐ |

| **៤. សិទ្ធិរបស់ជនរងគ្រោះ** | |
|---|---|
| ៤(ក) តើមានអ្វីមួយ ដែលបង្ហាញថា ជនរងគ្រោះកុហកអំពីអាយុរបស់ខ្លួន ដែរឬទេ? | មាន☐ គ្មាន☐<br>ពន្យល់៖ |
| ៤(ខ) តើមានអ្វីមួយ ដែលបង្ហាញថា ជនរងគ្រោះមានទំនាក់ទំនងជាមួយ ជនជាប់ចោទនៅចន្លោះពេលចាប់ ខ្លួន និងសវនាការ ដែរឬទេ? | មាន☐ គ្មាន☐<br>ពន្យល់៖ |
| ៤(គ) តើមេធាវីជនរងគ្រោះបាន ស្នើសុំអោយរក្សាអត្តសញ្ញាណជន រងគ្រោះជាការសំងាត់ ដែរឬទេ (ឧ. មេធាវីស្នើអោយធ្វើសវនាការជា អសាធារណ: ឬប្រើរបាំងការពារ)? | មាន☐ គ្មាន☐<br>ប្រសិនបើមាន តើចៅក្រមអនុញ្ញាតតាមសំណូមពរ ដែរឬទេ?<br>យល់ព្រម☐ មិនយល់ព្រម☐ |
| ៤(ឃ) តើចៅក្រមប្រើអាកប្បកិរិយា សមរម្យ ដែរឬទេ ចំពោះការសាកសួរ ទាក់ទងនឹងករណីរសើប?(ឧ. ករណីទាក់ទងនឹងផ្លូវភេទ) | មាន☐គ្មាន ☐ មិនពាក់ព័ន្ធ☐<br>ពន្យល់៖ |

| **៥. ច្បាប់** | |
|---|---|
| ៥(ក) តើមានអ្វីមួយ ដែលបង្ហាញថា ចៅក្រមភ័ន្តច្រឡំច្បាប់ទាក់ទងនឹងការជួញដូរ មនុស្ស ដែរឬទេ? | មាន☐ គ្មាន☐<br>ពន្យល់៖ |
| ៥(ខ)តើមានអ្វីមួយ ដែលបង្ហាញថា ចៅក្រម ភ័ន្តច្រឡំនិយមន័យនៃការជួញដូរមនុស្ស និងការនាំចេញដោយមិនស្របច្បាប់ ដែរឬទេ? | មាន☐ គ្មាន☐<br>ពន្យល់៖ |

| **៦. ជនរងគ្រោះជាស្ត្រី**មិនពាក់ព័ន្ធ☐ | |
|---|---|
| ៦(ក) តើមានមន្ត្រីតុលាការជាស្ត្រី | មាន☐ គ្មាន ☐ |

| | |
|---|---|
| ដែរឬទេ? | ពន្យល់៖ |
| ៦(ខ) តើជនរងគ្រោះត្រូវបានតំណាងដោយមេធាវីជាស្ត្រី ដែរឬទេ? | មាន☐ គ្មាន☐<br>ពន្យល់៖ |

| ៧. សាក្សី | |
|---|---|
| ៧(ក) តើមានអ្វីមួយ ដែលបង្ហាញថាសាក្សីត្រូវបានធ្វើទុក្ខបុកម្នេញដោយជនជាប់ចោទ ដែរឬទេ? | មាន☐ គ្មាន☐<br>ពន្យល់៖ |

## ឧបសម្ព័ន្ធទី២ បញ្ជីច្បាប់ជាមូលដ្ឋាននៃតារាងសង្ខេបការណ៍សវនាការ

| | | ក្រមនីតិវិធីព្រហ្មទណ្ឌ | ច្បាប់អ៊ិនតាក់ | រដ្ឋធម្មនុញ្ញ | ក្រមសីលធម៌ចៅក្រម និងព្រះរាជអាជ្ញា | កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោ | គោលការណ៍មូលដ្ឋាន ស្តីពីឯករាជ្យភាពរបស់ | គោលការណ៍មូលដ្ឋាន ស្តីពីតួនាទីរបស់មេធាវី | អនុសញ្ញាប្រឆាំងនឹងទារុណកម្ម | គោលការណ៍បែនហ្គាឡរ | សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស | បទដ្ឋានតុលាការគំរូ | អត្ថាធិប្បាយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ | ២(ក) តើមានការបិទផ្សាយជូនដំណឹងអំពីសវនាការនៅលើក្តារខៀន ក្រៅបន្ទប់សវនាការដែរឬទេ? | មាត្រា ៣១៦ | x | x | x | មាត្រា ១៤ (១) | x | x | x | x | មាត្រា ១០ | x | ជាពិសេសសំដៅទៅរកធាតុនាំឲ្យមានសវនាការជាសាធារណៈក្នុងបទអត្ថាធិប្បាយទូទៅលេខ ៣២ នៃគណៈកម្មាធិការសិទ្ធិមនុស្ស |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២(ខ) តើសាធារណៈជនត្រូវបានរារាំងមិនអោយចូល ឬបណ្តេញចេញពីបន្ទប់សវនាការដែរឬទេ? | មាត្រា ៣១៦ | មាត្រា ២៣ | x | x | មាត្រា ១៩(១) | x | x | x | x | មាត្រា ១០ | បទដ្ឋាន ១១ | |
| សិទ្ធិទទួលបានការជំនុំជម្រះ ដោយគ្មានការពន្យារពេល | ៣(ក)ថ្ងៃចាប់ខ្លួន? | ការឃាត់ខ្លួន និងគន្លីទី៤ ជំពូកទី៣ ផ្នែកទី៥៖ | មាត្រា ១៣ ១៩ ២១ | មាត្រា ៣៨ | x | មាត្រា ១៩ (៣)(គ) | x | x | x | x | មាត្រា ៩ | បទដ្ឋាន ៩ បទដ្ឋាន ១០ | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ៣(ខ) តើមានការឃុំខ្លួនបណ្ដោះអាសន្ន ដែរឬទេ? | | | មាត្រា ៣៨ | x | មាត្រា ៩ (៣) | x | x | x | x | មាត្រា ៩ | បទដ្ឋាន ៤ បទដ្ឋាន ១០ | មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ សំដៅតែទៅលើភាពស្របច្បាប់នៃការឃុំខ្លួន សេចក្ដីប្រកាសជាសកល ស្ដីពីសិទ្ធិមនុស្ស សំដៅតែទៅលើភាពខុសច្បាប់នៃការឃុំខ្លួន |
| សិទ្ធិយល់ពីបទចោទប្រកាន់ | ៤(ក) តើចៅក្រមបានប្រកាសពីរឿងក្ដីដែលត្រូវជំនុំជំម្រះដែរឬទេ? | x | x | x | x | មាត្រា ១៤ (៣)(ក) | x | x | x | x | x | បទដ្ឋាន៥ (សមត្ថភាព) | |
| | ៤(ខ) តើចៅក្រមបានប្រាប់ពីបទចោទ ដែរឬទេ? | មាត្រា ៣២៥ | x | x | x | x | x | x | x | x | x | បទដ្ឋាន ២ | |
| | ៤(គ) តើចៅក្រមបានប្រាប់ពីមាត្រា ច្បាប់ពាក់ព័ន្ធដែរឬទេ? | x | x | x | x | x | x | x | x | x | x | បទដ្ឋាន ៥ (សមត្ថភាព) | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ៤(ឃ) តើចៅក្រមបានរៀបរាប់ពីឈ្មោះអ្នកចូលរួម ដែរឬទេ? | មាត្រា ៣២២ | x | x | x | x | x | x | x | x | x | បទដ្ឋាន ៥ (សមត្ថភា ៣) | |
| | ៤(ង) តើចៅក្រមបានប្រាប់ពីកាលបរិច្ឆេទ និងទីកន្លែងប្រព្រឹត្តបទល្មើសដែរឬទេ? | មាត្រា ៣២៥ | x | x | x | មាត្រា ១៤ (៣) (ក) | x | x | x | x | x | បទដ្ឋាន ២ | |
| | ៤(ច) ប្រសិនបើត្រូវការ តើអ្នកបកប្រែត្រូវបានផ្តល់អោយដែរឬទេ? | មាត្រា ៣៣០ | x | x | x | មាត្រា ១៤ (៣) (ច) | x | x | x | គោលការណ៍ ទី៥ | | បទដ្ឋានទី ២ | មាត្រា ៣៣០ ពាក្យថា "អាច" ត្រូវបានប្រើ |
| | ៤(ឆ) ប្រសិនបើត្រូវការ តើជនពិការត្រូវបានគេផ្តល់ជំនួយ ដែរឬទេ? | មាត្រា ៣៣១ | x | x | មាត្រា ៧ | x | x | x | x | | x | បទដ្ឋានទី ៧ & ៩ | |
| | ៥(ក) តើចៅក្រមបានប្រាប់ (I) និងពន្យល់ (E) ជនជាប់ចោទពីសិទ្ធិមានតំណាងស្របច្បាប់ ឬសិទ្ធិការពារខ្លួន ដែរឬទេ? | មាត្រា ៣០១ (សិទ្ធិមានមេធាវី) | មាត្រា ១០ (១) | មាត្រា ១២៨ (ចៅក្រមគួរតែការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ) | | មាត្រា ១៤ (៣) | x | មាត្រា ១ និង មាត្រា ៥ | x | x | x | បទដ្ឋាន៥ (សមត្ថភាព) | |
| | ៥(ខ) តើចៅក្រមបានប្រាប់ (I) និងពន្យល់ (E) ជនជាប់ចោទពីសិទ្ធិនៅស្ងៀម ដែរឬទេ? | x | x | | | x | x | x | x | x | x | | |
| | ៥(គ) តើចៅក្រមបានប្រាប់ (I) និងពន្យល់ (E) ជនជាប់ចោទពីសិទ្ធិមិនឆ្លើយដាក់កំហុសខ្លួនឯង ដែរឬទេ? | x | x | | | មាត្រា ១៤ (៣) (ឆ) | | x | x | x | x | បទដ្ឋាន ៥ (សមត្ថភាព ) | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ៥(ឃ) តើចៅក្រមបានប្រាប់ (I) និងពន្យល់ (E) ជនជាប់ចោទពីសិទ្ធិផ្លាស់ប្តូរចៅក្រមជំនុំជម្រះ ដែរឬទេ? | មាត្រា ៥៥៦ និង ៥៥៧ | x | | | x | x | x | x | x | x | បទដ្ឋាន ៥ (សមត្ថភាព ) | |
| | ៥(ង) តើចៅក្រមបានប្រាប់ (I) និងពន្យល់ (E) ជនជាប់ចោទពីសិទ្ធិមានសំណូមពរចុងក្រោយ ដែរឬទេ? | មាត្រា ៣៣៥ (សិទ្ធិមានសំណូមពរចុងក្រោយ ) | x | | | x | x | x | x | x | x | បទដ្ឋាន ២ និង ៥ | |
| និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការ | ៦(ក) តើបញ្ហាពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ត្រូវបានលើកឡើងដោយមេធាវីជនជាប់ចោទ ដែរឬទេ? | មាត្រា ១៥៩ ៣០៤ ៣១៩ | មាត្រា ១៧ (២) មាត្រា ២១ (២) | x | x | មាត្រា ១៤ (៣) (ខ) | x | មាត្រា ៨ | x | x | x | បទដ្ឋាន ២ | |
| សិទ្ធិទទួលបានតំណាងស្របច្បាប់ | ៧(ក) តើជនជាប់ចោទត្រូវបានតំណាងដោយមេធាវី ដែរឬទេ? | មាត្រា ៣០១ | មាត្រា ១០ | មាត្រា ៣៨ | x | មាត្រា ១៤ (២) | x | មាត្រា ១, ៥, ៧ | x | x | x | បទដ្ឋាន ២ | |
| | ៧(គ) តើជនជាប់ចោទត្រូវបានបណ្តេញចេញនៅក្នុងដំណាក់កាលណាមួយនៃនីតិវិធី សវនាការដែរឬទេ? | មាត្រា ៣០០ | x | x | x | មាត្រា ១៤ (៣) (ឃ) | x | x | x | x | x | បទដ្ឋាន ២ | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ការសន្មតទុកជាមុនថាគ្មានទោស | ៨(ក) តើជនជាប់ចោទស្លៀកឯកសណ្ឋានអ្នកទោស ដែរឬទេ? | x | មាត្រា ២៥ | មាត្រា ៣៨ | x | មាត្រា ១៤(២) | x | x | x | x | មាត្រា ១១ (១) | បទដ្ឋាន ២, ៩ | ប្រសិនបើជនជាប់ត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅមុនសវនាការ ពួកគេមិនគួរស្លៀកឯកសណ្ឋានអ្នកទោសនោះទេ |
| | ៨(ខ) តើជនជាប់ចោទត្រូវបានដាក់ខ្នោះនៅក្នុងពេលសវនាការដែរឬទេ? | x | | | x | | x | x | x | x | | បទដ្ឋាន ២, ៩ | ប្រសិនបើមិនមានករណីចាំបាច់ទាក់ទងនឹងសន្តិសុខទេ ជនជាប់ចោទមិនគួរត្រូវបានដាក់ខ្នោះឡើយ |
| | ៨(គ) តើចៅក្រមបាននិយាយពីភាពមានទោស ឬគ្មានទោស របស់ជនជាប់ចោទដែរឬទេ នៅមុនពេលដែលសេចក្តីសម្រេចត្រូវបានធ្វើឡើង? | មាត្រា ៣៥១ | | | x | | x | x | x | x | | បទដ្ឋាន ២, ៧, ៩ | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ៨(ឃ) តើមានអ្វីមួយ ដែលបង្ហាញថា ចៅក្រមរើសអើង ជនជាប់ចោទ ដោយសារបុគ្គលិកលក្ខណៈផ្ទាល់ខ្លួន របស់ជនជាប់ចោទដែរឬទេ? | x | មាត្រា ២៨ | មាត្រា ៣១ | មាត្រា ៧ | | x | x | x | x | x | បទដ្ឋាន ៧, ៨, ៩ | |
| ឯករាជ្យភាព/ ភាពមិនលំអៀងរបស់ចៅក្រម | ៩(ក) តើចៅក្រមដើរតួនាទីជាភាគីផ្សេងទៀតដែរឬទេ នៅក្នុងនីតិវិធីសវនាការ? | មាត្រា ៥៥ និង ២៨៨ | មាត្រា ១ | មាត្រា ១២៨, ១៣០, ១៣២ | មាត្រា ២, ១៣, ១៧ | មាត្រា ១៤ (១) | មាត្រា ១ - ៧ | x | x | គោលការណ៍ ១ និង ២.៥.២ | មាត្រា ១០ | បទដ្ឋាន ៧ | |
| | ៩(ខ) តើមានអ្វីមួយ ដែលបង្ហាញថា ចៅក្រមមានផលប្រយោជន៍នៅក្នុងរឿងក្តី ដោយសារតួនាទីនៅក្នុងវិស័យតុលាការ ដែរឬទេ? | x | | | មាត្រា ២, ៣, ៨, ១១, ១២, ១៤, ១៧, ២០ | | | សូមមើលទាំងអស់ | x | គោលការណ៍ ១ និង ២.៥.៣ | | បទដ្ឋាន ៣, ៦, ៧, ៩ | |
| | ៩(គ) តើមានអ្វីមួយ ដែលបង្ហាញថា ភាគីណាមួយបាននិយាយជាមួយចៅក្រមនៅក្នុងកំឡុងពេលពិភាក្សាចេញសេចក្តីសម្រេចដែរឬទេ? | មាត្រា ៣៣៧ | | | មាត្រា ៩ | | | x | x | គោលការណ៍ ១ និង ២.៤ | | បទដ្ឋាន ៣, ៧ | |
| | ៩(ឃ) តើមានអ្វីមួយ ដែលបង្ហាញថា ចៅក្រមធ្វើទុក្ខបុកម្នេញទៅលើភាគីណាមួយ ដែរឬទេ? | x | | | មាត្រា ៨ | | | x | x | គោលការណ៍ ៣.១ និង ៥ | | បទដ្ឋាន ៧ | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ៩(ង) តើមានអ្វីមួយ ដែលបង្ហាញថា ចៅក្រមទាញពិរុទ្ធភាព អំពីការនៅស្ងៀមរបស់ជនជាប់ចោទ ដែរឬទេ? | x | | | x | | | x | x | x | | បទដ្ឋាន ៧ | |
| ភស្តុតាង | ១០(ក) តើភស្តុតាងត្រូវបានបង្ហាញ ដែរឬទេ? | មាត្រា ៣២១, ៣៣៤ | មាត្រា ២៤ | x | x | x | x | x | x | x | x | x | |
| | ១០(ខ) តើមានអ្វីមួយ ដែលបង្ហាញថា ភាគីណាមួយមិនត្រូវបានផ្តល់ឱកាស អោយបង្ហាញភស្តុតាង ដែរឬទេ? | មាត្រា ៣២៦ និង ៣៣៤ | មាត្រា ២៤ (៤) | x | x | x | មាត្រា ១៤ (៣) (ង) | x | x | x | x | បទដ្ឋាន ៨ | |
| សិទ្ធិហៅ និងសាកសួរសាក្សី | ១១(ក) តើមានអ្វីមួយ ដែលបង្ហាញថា ភាគីណាមួយមិនត្រូវបានផ្តល់ឱកាសអោយហៅសាក្សី ដែរឬទេ? | មាត្រា ២៩៨ | មាត្រា ២៤ (៤), ២៤ (៥) | x | x | មាត្រា ១៤ (៣) (ង) | x | x | x | x | x | បទដ្ឋាន ៨ | |
| | ១១(ខ) តើមានអ្វីមួយ ដែលបង្ហាញថា ភាគីណាមួយមិនត្រូវបានផ្តល់ឱកាសអោយសាកសួរសាក្សី ដែរឬទេ? | មាត្រា ៣២៦ | មាត្រា ២៤ (១) | x | x | មាត្រា ១៤ (៣) (ង) | x | x | x | x | x | បទដ្ឋាន ៨ | |
| | ១១(គ) តើសាក្សីស្ថិតនៅក្នុងបន្ទប់សវនាការ ដែរឬទេ នៅមុនពេលសាកសួរ? | មាត្រា ៣២២ | x | x | x | x | x | x | x | x | x | x | |
| សិទ្ធិទទួលដឹងឮ | ១២(ក) តើមានអ្វីមួយ ដែលបង្ហាញថា ភាគីណាមួយមិនបានដឹងឮអំពីភស្តុតាងរបស់ភាគីម្ខាងទៀតដែរឬទេ? | មាត្រា ៣១៩ | x | x | x | x | x | x | x | x | x | x | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| សិទ្ធិមិនឆ្លើយដាក់បន្ទុកខ្លួនឯង | ១៣(ក) តើមានអ្វីមួយ ដែលបង្ហាញថា ជនជាប់ចោទត្រូវបានគំរាមកំហែងបង្ខំ អោយសារភាព ដែរឬទេ? | មាត្រា ៣២១ | មាត្រា ១២ (១), មាត្រា ២៤ (៣) | មាត្រា ៣៨ | x | មាត្រា ៧ និង ១៤ (៣) (ឆ) | x | x | x | x | x | x | |
| | ១៣(ខ) តើមានអ្វីមួយ ដែលបង្ហាញថា ជនជាប់ចោទត្រូវបានគេធ្វើទារុណកម្ម បង្ខំអោយសារភាព ដែរឬទេ? | | | | x | | x | x | ទាំងអស់ | x | មាត្រា ៥ | x | |
| ការហាមឃាត់ការវិនិច្ឆ័យ | ១៤(ក) តើមានអ្វីមួយ ដែលបង្ហាញថា ជនជាប់ចោទត្រូវបានតុលាការវិនិច្ឆ័យម្តង រួចមកហើយចំពោះបទល្មើសនេះ ដែរឬទេ? | មាត្រា ១២ | x | x | x | មាត្រា ១៤ (៧) | x | x | x | x | x | បទដ្ឋាន ៩ | |
| ការហាមឃាត់ចំពោះការអនុវត្តអនុភាពប្រតិសកម្ម | ១៥(ក) តើមានអ្វីមួយ ដែលបង្ហាញថា បទល្មើសនេះមិនមែនជាបទល្មើសនៅក្រោមច្បាប់ជាតិ ឬអន្តរជាតិ នៅពេលដែល បទល្មើសនេះត្រូវបានប្រព្រឹត្ត ដែរឬទេ? | x | x | x | x | មាត្រា ១៥ | x | x | x | x | មាត្រា ១១ (២) | បទដ្ឋាន ៩ | |

## ឧបសម្ព័ន្ធទី៣៖ ក្រមសីលធម៌មន្ត្រីសង្កេតការណ៍សវនាការ

### ការរៀបចំ និងត្រៀមទុកជាមុន

### ករណីយកិច្ចទូទៅ

*ការរក្សាការសម្ងាត់*

- កម្មវិធីសង្កេតការណ៍សវនាការគោរពយ៉ាងពេញលេញនូវគោលការណ៍រក្សាការសម្ងាត់ ដោយមិនផ្សព្វផ្សាយព័ត៌មានសម្ងាត់។
- មន្ត្រីសង្កេតការណ៍សវនាការទាំងអស់ត្រូវមានការយល់ដឹងឲ្យបានទូលំទូលាយ នូវគោលការណ៍រក្សាការសម្ងាត់ទាក់ទងនឹងការសង្កេតការណ៍សវនាការ ចំពោះព័ត៌មាន ទាំងឡាយដែលយកបានពីតុលាការ ក៏ដូចជាព័ត៌មានទាក់ទងទៅនឹងដំណើរការ និងការគ្រប់គ្រងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ។

### មុនពេលអនុវត្តកម្មវិធីសង្កេតការណ៍សវនាការ

*ការវាយតម្លៃបឋម*

នៅមុនពេលដំណើរការការសង្កេតការណ៍សវនាការ មន្ត្រីសង្កេតការណ៍សវនាការត្រូវមានការយល់ដឹងឲ្យបានច្បាស់លាស់អំពី៖

- យន្តការតុលាការនៅក្នុងប្រទេសកម្ពុជា
- ឋានានុក្រម និងយុត្តាធិការតុលាការ
- កម្រិតនៃការសហការ និង/ឬ ការចូលរួម ដែលសង្ឃឹមថានឹងទទួលបានពី ក) ចៅក្រម ខ) ព្រះរាជអាជ្ញា គ) មេធាវីជនជាប់ចោទ និង ឃ) រដ្ឋាភិបាល។

*សេចក្តីជូនដំណឹង*

- សេចក្តីសម្រេចអំពីអ្នកដែលនឹងទទួលសេចក្តីជូនដំណឹងអំពីការសង្កេតការណ៍សវនាការជាផ្លូវការ និង/ឬ មិនផ្លូវការ ត្រូវធ្វើឡើងមុនការសង្កេតការណ៍សវនាការចាប់ផ្តើម និងត្រូវសម្រេចដោយប្រធានគម្រោង ស្របតាមគោលបំណងរបស់គម្រោង។
- ប្រសិនបើ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាជូនដំណឹងទៅតុលាការ អំពីការសង្កេតការណ៍សវនាការ សេចក្តីជូនដំណឹងនោះត្រូវតែអនុលោមទៅតាមការអនុវត្តជាទូទៅ។
- អ្នកសង្កេតការណ៍សវនាការត្រូវតែកត់ត្រាទុកនូវបុគ្គលទាំងឡាយណាដែលខ្លួនបានផ្តល់ព័ត៌មាន និង/ឬ ពិគ្រោះយោបល់ជាមួយ មុន និង/ឬ ក្នុងអំឡុងពេលសវនាការ ។ ការកត់ត្រាទាំងនេះមានរួមទាំងសេចក្តីលំអិត និងទម្រង់នៃសេចក្តីជូនដំណឹង។
- ថាតើអនុស្សរណៈយោគយល់គ្នាមួយ ("MOU") ត្រូវបានចុះហត្ថលេខារវាងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងក្រសួងយុត្តិធម៌។

## នៅមុនពេលសង្កេតការការណ៍សវនាការនីមួយៗ

### *ការវាយតម្លៃបឋម*

ព័ត៌មានខាងក្រោមត្រូវប្រមូលមុនពេលសវនាការនីមួយៗ ឬ នៅពេលដែលមិនអាចធ្វើដូច្នេះបាន គឺត្រូវមានការកត់ចំណាំ និងស្រាវជ្រាវ ធ្វើឡើងបន្ទាប់ ឬក្នុងអំឡុងពេលសវនាការ៖

- ថាតើមានរបាយការណ៍ពាក់ព័ន្ធនឹងសវនាការស្រដៀងគ្នាកម្ពុជាដែរឬទេ។
- ថាតើមានកម្រងច្បាប់ និងសន្ធិសញ្ញាអន្តរជាតិណា ដែលទាក់ទងនឹងសវនាការកំពុងសង្កេតការណ៍នេះ។
- ថាតើច្បាប់ជាតិ និងច្បាប់នីតិវិធីណាខ្លះទាក់ទងនឹងករណីដែលកំពុងសង្កេតការណ៍នេះ។
- បទប្បញ្ញត្តិរដ្ឋធម្មនុញ្ញ ដែលពាក់ព័ន្ធ។

### *សេចក្តីជូនដំណឹង*

- អ្នកសង្កេតការណ៍សវនាការទាំងអស់ត្រូវចងក្រងឯកសារលំអិតអំពីការប្រឹក្សាយោបល់ជាមួយ ក) រដ្ឋាភិបាល ខ) ស្នាក្តីភាគីខាងចុងចោទ គ) ព្រះរាជអាជ្ញា ឃ) ចៅក្រម ង) ក្រឡាបញ្ជី ឬ ច)ភាគីពាក់ព័ន្ធដទៃទៀត ។

## *ការចូលទៅកាន់តុលាការ*

- អ្នកសង្កេតការណ៍សវនាការទាំងអស់ត្រូវចុះឈ្មោះនៅតុលាការមុនធ្វើការសង្កេតការណ៍ ប្រសិនបើចង់ស្នើសុំឯកសារ ឬចូលក្នុងតុលាការ ។ អ្នកសង្កេតការណ៍សវនាការទាំងអស់ត្រូវរក្សាទុកឯកសារផ្លូវការទាំងអស់ ។

# នៅក្នុងអំឡុងពេលសវនាការ

## *គោលការណ៍ទូទៅ*

- ទៅដល់តុលាការឲ្យបានមុនម៉ោង ដើម្បីមានពេលវេលាគ្រប់គ្រាន់នឹងចូលទៅកាន់តុលាការ ស្វែងរកក្នុងបន្ទប់សវនាការ និងរកកន្លែងអង្គុយសមរម្យ ។ ចំណុចនេះត្រូវពិពណ៌នានៅក្នុងទម្រង់របាយការណ៍ ។
- មន្ត្រីសង្កេតការណ៍សវនាការត្រូវរៀបចំខ្លួន និងពន្យល់ឲ្យបានច្បាស់អំពីមូលដ្ឋានច្បាប់ គោលបំណង និងទិសដៅនៃគម្រោង ដល់បុគ្គលិកតុលាការ និងមន្ត្រីច្បាប់នានា។

## *អត្តសញ្ញាណ*

- ពាក់អត្តសញ្ញាណប័ណ្ណសម្គាល់ជាមន្ត្រីសង្កេតការណ៍សវនាការនៅគ្រប់ពេលវេលា និងបង្ហាញអត្តសញ្ញាណប័ណ្ណនេះទៅមន្ត្រីតុលាការប្រសិនបើមានការស្នើសុំឲ្យបង្ហាញ ។
- ប្រសិនបើមានការបញ្ហាណាមួយកើតឡើង ក្នុងការចូលតុលាការ អត្តសញ្ញាណប័ណ្ណនេះនឹងធ្វើឲ្យមន្ត្រីមូលដ្ឋានស្គាល់គម្រោងសង្កេតការណ៍សវនាការ។

## *ការប្រព្រឹត្តក្នុងតុលាការ*

- មន្ត្រីសង្កេតការណ៍សវនាការ ត្រូវប្រកាន់ខ្ជាប់នូវអត្តចរិតជាមន្ត្រីសង្កេតការណ៍សវនាការអាជីពគ្រប់ពេលវេលា។
- ត្រូវមានចំណេះដឹងច្បាប់ខ្ពស់ រួមទាំងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។
- មន្ត្រីសង្កេតការណ៍សវនាការត្រូវសម្រេចថាអង្គុយកន្លែងណា ដើម្បីធានាបាននូវភាពមិនលំអៀង និងងាយស្រួលក្នុងការសង្កេតការណ៍សវនាការ។ មន្ត្រីសង្កេតការណ៍គួរជ្រើសរើសកន្លែងអង្គុយដែលគេអាចមើលឃើញ ជាកន្លែងអព្យាក្រឹត នៅក្នុងបន្ទប់សវនាការ ។ មន្ត្រីសង្កេតការណ៍សវនាការត្រូវបង្ហាញអាកប្បកិរិយាគួរសម និងសុភាពចំពោះមន្ត្រីតុលាការ និងភាគីទាំងអស់ពាក់ព័ន្ធរឿងក្តី។
- ស្លៀកសម្លៀកបំពាក់សមរម្យ ។
- ទៅដល់តុលាការទាន់ពេលវេលា ។

- រក្សានូវការគោរពក្នុងគ្រប់ទំនាក់ទំនងជាមួយមន្ត្រីតុលាការ និងអ្នកដទៃទៀត ។
- ធ្វើការតក់ត្រាដោយចំហរក្នុងអំឡុងពេលសវនាការ នៅលើតារាងសង្កេតការណ៍សវនាការរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ដោយមិនធ្វេសប្រហែសក្នុងពេលសវនាការ។
- មន្ត្រីសង្កេតការណ៍សវនាការត្រូវមានភាពច្នៃក និងយល់ច្បាស់អំពីតារាងសង្កេតការណ៍សវនាការ និងសេចក្តីណែនាំអំពីការសង្កេតការណ៍សវនាការ ។
- ធានាសុវត្ថិភាព និងរក្សាការសម្ងាត់នូវរាល់កំណត់ត្រាទាំងអស់ ។
- ធ្វើការណែនាំខ្លួនទៅតុលាការតាមរយៈភាគីមួយដែលអព្យាក្រឹត (ប្រសិនបើយើងនៅបន្តសង្កេតការណ៍ក្នុងបន្ទប់សវនាការរហូតដល់ពេលបញ្ចប់សវនាការទាំងអស់) ដើម្បីបង្កើននូវតម្លាភាព ។

## *ភាពមិនលំអៀង និងភាពមិនជ្រៀតជ្រែក*

- អង្គុយលើកៅអីសមរម្យមួយនៅក្នុងបន្ទប់សវនាការ ដែលអាចឲ្យអ្នកអាចសង្កេតបាន ឮបាន និងអាចតាមមើលបាននូវគ្រប់ចំណុចទាំងអស់នៃសវនាការ ។
- មិនត្រូវអង្គុយជាប់ជាមួយភាគីជនជាប់ចោទ ឬព្រះរាជអាជ្ញា ។
- មិនត្រូវសួរអ្នកច្បាប់អំពីគំនិតរបស់ពួកគេ ឬឲ្យគេផ្តល់ការណែនាំអំពីរឿងក្តីណាមួយ។
- ជៀសវាងជ្រៀតជ្រែកចូលដំណើរការសវនាការ ។
- មិនត្រូវបង្អាក់ដំណើរការសវនាការណាមួយ ឬនិយាយទៅកាន់មន្ត្រីច្បាប់ ឬអ្នកចូលរួមសវនាការ។
- មិនត្រូវធ្វើអន្តរាគមន៍នៅក្នុងសវនាការ ឬប៉ុនប៉ងជះឥទ្ធិពលទៅលើលទ្ធផលនៃរឿងក្តីក្នុងគ្រប់រូបភាព។
- មិនត្រូវបង្ហាញភាពលំអៀង ឬការគាំទ្រណាមួយដល់ភាគីនៃរឿងក្តី។
- មិនត្រូវសំដែងនូវយោបល់ណាមួយអំពីដំណើរការសវនាការណាមួយ ទោះជានៅក្នុង ឬនៅក្រៅបន្ទប់សវនាការ ។ នៅពេលមានអ្នកណាម្នាក់សួរសំណួរជាក់លាក់ ត្រូវឆ្លើយតបដោយពន្យល់អំពីតួនាទីជាមន្ត្រីសង្កេតការណ៍សវនាការ និងអំពីក្រមសីលធម៌នៃភាពមិនលំអៀង ។
- មន្ត្រីសង្កេតការណ៍សវនាការ មិនគួរធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈណាមួយឡើយ ។
- ប្រសិនបើអាច មន្ត្រីសង្កេតការណ៍សវនាការគួរកត់ត្រាទុកនូវរាល់អត្ថបទសារព័ត៌មានណា ដែលពាក់ព័ន្ធទៅនឹងសវនាការ និង ត្រូវដឹងអំពីការឃ្លាំមើលជាក់ស្តែង ដើម្បីទុកជាប្រយោជន៍ដល់មន្ត្រីសង្កេតការណ៍សវនាការនាពេលអនាគត។